Ver1.0

農業技能測定試験

ហៅថា ការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញនៅក្នុងវិស័យកសិកម្ម

テキスト 畜産農業全般

《សៀវភៅសិក្សា ខ្លឹមសារទូទៅស្តីអំពីកសិកម្មចិញ្ចឹមសត្វ》

カンボジア(クメール)語版
ភាសាខ្មែរ

一般社団法人 全国農業会議所

នីតិបុគ្គលសមាគមរួមបញ្ចូលទូទៅ សភាកសិកម្មជាតិ(NCA)

ប្រវត្តិនៃការកែសម្រួល

ចំនួនដងនៃការកែសម្រួល	ថ្ងៃកែសម្រួល	ខ្លឹមសារសង្ខេបនៃការកែសម្រួល	ចំណុចកែសម្រួល
1.0	ថ្ងៃទី2ខែ12ឆ្នាំ2019	ការបោះពុម្ពលើកទីមួយត្រូវបានចេញផ្សាយ។	ការបោះពុម្ពលើកទីមួយត្រូវបានចេញផ្សាយ។

សេចក្តីផ្តើម

វិស័យកសិកម្មនៅប្រទេសជប៉ុន កំពុងជួបបញ្ហាធ្ងន់ធ្ងរដោយសារការខ្វះកម្លាំងពលកម្ម។ ដូច្នេះ យើងបានរៀបចំគម្រោងថ្មីមួយដោយទទួលយកកម្លាំងពលកម្មពីធនធានមនុស្សជាជនបរទេស ដែលសុទ្ធសឹងជាអ្នកមានសមត្ថភាពនិងបទពិសោធន៍គ្រប់គ្រាន់អាចធ្វើការងារនៅក្នុង វិស័យកសិកម្មនៅប្រទេសជប៉ុនបាន(ធនធានមនុស្សជាជនបរទេសសម្រាប់ការជួយគាំទ្រវិស័យកសិកម្ម) ដោយក្នុងនោះ ប្រព័ន្ធហ្វឹកហ្វឺន ពលករជំនាញត្រូវបានបង្កើតឡើង។គម្រោងនេះត្រូវបានរំពឹងទុកជាខ្លាំងថានឹងអាចជួយទ្រទ្រង់នូវការថែរក្សានិងអភិវឌ្ឍន៍វិស័យកសិកម្មនៅប្រទេសជប៉ុន ដោយបន្ថែមលើប្រព័ន្ធហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស។

ជនបរទេសដែលនឹងចូលបម្រើការងារនៅក្នុងវិស័យកសិកម្មតាមរយៈគម្រោងនេះ ចាំបាច់ត្រូវបំពេញលក្ខខ័ណ្ឌផ្នែកចំណេះដឹងនិងសមត្ថភាពជំនាញជាដើមដែលទាក់ទងនឹងវិស័យកសិកម្មដែលប្រទេសជប៉ុនបានកំណត់។

ដោយហេតុនេះ នីតិបុគ្គលសមាគមរួមបញ្ចូលទូទៅ សភាកសិកម្មជាតិបានទទួលជំនួយពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាប់ផ្តើមអនុវត្តការប្រឡង វាយតម្លៃនិងត្រួតពិនិត្យលើចំណេះដឹងនិងសមត្ថភាពជំនាញរបស់ជនបរទេសស្តីអំពីវិស័យកសិកម្មនៅមុនពេលពួកគេមកដល់ប្រទេសជប៉ុន (ហៅថា ការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញនៅក្នុងវិស័យកសិកម្ម) ចាប់ពីឆ្នាំ2019នេះតទៅ។ នៅក្នុងនោះរួមមានការប្រឡងពីរប្រភេទ គឺ [1]ខ្លឹមសារទូទៅស្តីអំពីកសិកម្មដាំដំណាំ និង [2]ខ្លឹមសារទូទៅស្តីអំពីកសិកម្មចិញ្ចឹមសត្វ។

សៀវភៅសិក្សានេះ ត្រូវបានចងក្រងឡើងដោយរួមមានចំណេះដឹងនិងបច្ចេកទេសចាំបាច់នានាសម្រាប់អ្នកដែលនឹងចូលរួមនៅក្នុងការប្រឡងលើខ្លឹមសារទូទៅស្តីអំពីកសិកម្មចិញ្ចឹមសត្វ ដោយប្រើប្រាស់រូបភាពនិងរូបគំនូសផ្សេងៗដើម្បីសម្រួលដល់អ្នកសិក្សាអោយងាយស្រួលក្នុងការស្វែងយល់។ យើងសង្ឃឹមថាសៀវភៅសិក្សានេះនឹងក្លាយជាជំនួយមួយផ្នែកនៅក្នុងការសិក្សាសម្រាប់ត្រៀមប្រឡងរបស់អ្នកចូលរួមប្រឡងទាំងអស់។

នៅក្នុងការប្រឡងលើខ្លឹមសារទូទៅស្តីអំពីកសិកម្មចិញ្ចឹមសត្វនឹងរួមមានសំណួរដែលវាយតម្លៃថាតើបេក្ខជនមានសមត្ថភាពភាសាជប៉ុនចាំបាច់គ្រប់គ្រាន់សម្រាប់ការចូលបម្រើការងារនៅក្នុងវិស័យកសិកម្មនៅប្រទេសជប៉ុនដែរឬទេ។ ដូច្នេះសូមប្រើប្រាស់សៀវភៅសិក្សាភាសាជប៉ុនផ្សេងមួយទៀតដែលសភាកសិកម្មជាតិបានបង្កើតឡើងផងដែរ ដើម្បីត្រៀមលក្ខណៈនៅក្នុងការប្រឡង។

ជាចុងក្រោយ នៅក្នុងការបង្កើតសៀវភៅសិក្សានេះ យើងបានទទួលកិច្ចសហការយ៉ាងខ្ពង់ខ្ពស់ពីសមាជិកគ្រប់រូបនៃគណៈកម្មាធិការរៀបចំការប្រឡងវាយតម្លៃសមត្ថភាពជំនាញជនបរទេសសម្រាប់ការគាំទ្រវិស័យកសិកម្មផ្នែកកសិកម្មចិញ្ចឹមសត្វ រួមមាន លោកយ៉ូស៊ីដាមីយ៉ាអុ(ខ្លឹមសារទាក់ទងនឹងគោចិញ្ចឹមយកទឹកដោះ) លោកមីស៊ុមីខូជិ(ខ្លឹមសារទាក់ទងនឹងការចិញ្ចឹមជ្រូក) លោកគីណាស៊ីតាអាគីហ៊ីរ៉ុ(ខ្លឹមសារទាក់ទងនឹង គោចិញ្ចឹមយកសាច់) លោកសាតូខាំង(ខ្លឹមសារទាក់ទងនឹងការចិញ្ចឹមមាន់) ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ។

ខែតុលា ឆ្នាំ2019

នីតិបុគ្គលសមាគមរួមបញ្ចូលទូទៅ សភាកសិកម្មជាតិ

មាតិកា

I លក្ខណៈពិសេសនៃការចិញ្ចឹមសត្វ

1 កសិកម្មផលិតទឹកដោះ (គោចិញ្ចឹមយកទឹកដោះ) 1

2 ការផលិតសាច់គោ (គោចិញ្ចឹមយកសាច់) 6

3 ការចិញ្ចឹមជ្រូក (សត្វជ្រូក) 10

4 ការចិញ្ចឹមមាន់ 19

① មាន់ ចិញ្ចឹម យកស៊ុត 19

② មាន់ ចិញ្ចឹម យកសាច់ 22

5 ផ្សេងៗ 25

① សេះទម្ងន់ស្រាល 25

② ការចិញ្ចឹមឃ្មុំ 28

6 សំណួរសាកល្បង 31

II ចំណេះដឹងមូលដ្ឋានទាក់ទងនឹងការចិញ្ចឹមសត្វនិងចំណីសត្វ

1 គោចិញ្ចឹមយកទឹកដោះ 34

2 គោចិញ្ចឹមយកសាច់ 49

3 សត្វជ្រូក 58

4 ការចិញ្ចឹមមាន់ 64
① មាន់ចិញ្ចឹមយកស៊ុត 64
② មាន់ ចិញ្ចឹម យកសាច់ 86
5 ក្រៅពីនេះ 95
① សេះទម្ងន់ស្រាល 95
② ការចិញ្ចឹមឃ្មុំ 98
6 សំណួរសាកល្បង 101

Ⅲ ការងារគ្រប់គ្រងសត្វចិញ្ចឹមជាប្រចាំថ្ងៃ

1 ការគ្រប់គ្រងអនាម័យនិងការគ្រប់គ្រងសុវត្ថិភាពរបស់កសិដ្ឋាន 105
2 គោចិញ្ចឹមយកទឹកដោះ 109
3 គោចិញ្ចឹមយកសាច់ 117
4 សត្វជ្រូក 120
5 ការចិញ្ចឹមមាន់ (មានចិញ្ចឹមយកស៊ុតនិងមាន់ចិញ្ចឹមយកសាច់)..... 124
6 ការគ្រប់គ្រងអនាម័យនៅកសិដ្ឋាន 131
① សេះទម្ងន់ស្រាល 131
② ការចិញ្ចឹមឃ្មុំ 133

7 ចំណុចសំខាន់ៗនៅក្នុងការងារគ្រប់គ្រងនិងការសង្កេតមើលសត្វចិញ្ចឹម (សម្រាប់ការប្រឡងជំនាញអនុវត្តន៍) ... 137

8 សំណួរសាកល្បង 140

<ឯកសារយោង> វាក្យសព្ទទាក់ទងនឹងការចិញ្ចឹមសត្វដែលអ្នកនឹងជួបប្រទះញឹកញាប់នៅក្នុងការងារប្រចាំថ្ងៃ 142

សេចក្តីផ្តើម

ចំណុចដែលត្រូវប្រុងប្រយ័ត្ននៅពេលចូលក្នុងប្រទេសជប៉ុន

នៅពេលទៅបំពេញការងារខាងវិស័យកសិកម្មនៅក្នុងប្រទេសជប៉ុន សូមអនុវត្តទៅតាមវិធានដូចខាងក្រោម ដើម្បីទប់ស្កាត់ការរាតត្បាតនៃជម្ងឺឆ្លងពីបសុសត្វ និងសត្វល្អិតចង្រៃទាំងឡាយ។

- សូមកុំប៉ះពាល់បសុសត្វទាំងឡាយរយៈពេល1សប្តាហ៍ មុនពេលមកប្រទេសជប៉ុន។
- ជាគោលការណ៍ សូមកុំចូលទៅក្នុងពោងចិញ្ចឹមសត្វរយៈពេល1សប្តាហ៍បន្ទាប់ពីចូលដល់ប្រទេសជប៉ុន (រួមទាំងការចូលប្រទេសជប៉ុនសារជាថ្មីផងដែរ)។
- សូមកុំយកមកជាមួយនូវស្បែកជើងកវែង ស្បែកជើងនិងសម្លៀកបំពាក់ធ្វើការដែលប្រឡាក់ និងដែលបានប្រើប្រាស់នៅបរទេស។
- ហាមយកចូលក្នុងប្រទេសជប៉ុននូវផលិតផលសាច់ ដូចជាសាច់ជ្រូក សាច់ក្រក សាច់បន្ទះ និងសាច់ដែលគ្មានលិខិតត្រួតពិនិត្យជាដើម។
- សូមផ្តាំគ្រួសារ ឬមិត្តភ័ក្ត កុំឲ្យផ្ញើផលិតផលសាច់ផ្សេងៗមកប្រទេសជប៉ុន (តាមបញ្ញើរអន្តរជាតិ)។
- ក្រៅពីនេះ សូមធ្វើការងារដោយសុវត្ថិភាព ទៅតាមការណែនាំរបស់អ្នកទទួលខុសត្រូវនៅកន្លែងធ្វើការ។

I លក្ខណៈពិសេសនៃការចិញ្ចឹមសត្វ

1 កសិកម្មផលិតទឹកដោះ (គោចិញ្ចឹមយកទឹកដោះ)

1 គោទឹកដោះ

គោទឹកដោះនៅប្រទេសជប៉ុនភាគច្រើនជាគោពូជហុលស្តាញ (ប្រទេសកំណើត គឺហូឡង់) ដោយគោប្រភេទនេះអាចផលិតទឹកដោះជាមធ្យមលើសពី 8,000 គីឡូក្រាមក្នុងមួយឆ្នាំ។

គោទឹកដោះដែលធ្លាប់កើតកូនហើយហៅថាគោធ្លាប់កូន ហើយគោដែលបានកើតកូនជាលើកដំបូងហៅថាគោកូនដំបូង។

គោពូជហុលស្តាញ

ប្រភពរូបថត : នីតិបុគ្គលរដ្ឋបាលឯករាជ្យ
មជ្ឈមណ្ឌលកែលម្អសត្វចិញ្ចឹម

គោពូជចាជី

ប្រភពរូបថត : នីតិបុគ្គលរដ្ឋបាលឯករាជ្យ
មជ្ឈមណ្ឌលកែលម្អសត្វចិញ្ចឹម

គោពូជប្រោនស្វីស

2 ទំហំ និងទម្រង់នៃអាជីវកម្មកសិកម្មផលិតទឹកដោះ

(1) កសិកម្មផលិតទឹកដោះនៅក្នុងប្រទេសជប៉ុន ភាគច្រើនគឺជាអាជីវកម្មគ្រួសារ។

(2) ប៉ុន្តែ ថ្មីៗនេះ កសិករមួយចំនួនដែលបានរួបរួមគ្នាបង្កើតទៅជាអាជីវកម្មនីតិបុគ្គលឬអាជីវកម្មក្រុមហ៊ុនដែលគ្រប់គ្រងលើកសិកម្មផលិតទឹកដោះ គឺមានការកើនឡើង។

(3) កសិដ្ឋានផលិតទឹកដោះ ដែលមានគោចំនួនយ៉ាងច្រើនក្រៃលែង គេហៅថា កសិដ្ឋានខ្នាតយក្ស (mega farm)។

ចំនួនគ្រួសារកសិករផលិតទឹកដោះនៅក្នុងប្រទេសជប៉ុន មានការថយចុះជារៀងរាល់ឆ្នាំ ប៉ុន្តែ ចំនួនគោដែលចិញ្ចឹមនៅក្នុង1គ្រួសារកសិករផលិតទឹកដោះ មានការកើនឡើង។

ការប្រៀបប្រួលនៃចំនួនគោធ្លាប់មានកូនដែលចិញ្ចឹមនៅក្នុង1គ្រួសារកសិករផលិតទឹកដោះ

ឆ្នាំ2005 (Heisei 17)	ឆ្នាំ2010 (Heisei 22)	ឆ្នាំ2014 (Heisei 26)
38.1 ក្បាល	44.0 ក្បាល	48.0 ក្បាល

3 បរិមាណទឹកដោះរបស់គោធ្លាប់មានកូននៅប្រទេសជប៉ុន

បរិមាណទឹកដោះជាមធ្យមដែលគោធ្លាប់មានកូននៅក្នុងប្រទេសជប៉ុនផលិតបាននៅក្នុងរយៈពេល1ឆ្នាំ គឺមានការកើនឡើង។ នៅក្នុងឆ្នាំ2014 បរិមាណទឹកដោះដែលផលិតបាន គឺ8,316គីឡូក្រាម ប៉ុន្តែ វាមានការកើនឡើងច្រើនបើប្រៀបធៀបទៅនឹង10ឆ្នាំមុន ក្នុងឆ្នាំ2004 ដែលផលិតបាន 7,619 គីឡូក្រាម ។

4 វដ្តជីវិតនៃគោទឹកដោះ

· គោទឹកដោះដែលកើតបានរយៈពេលប្រហែល6ខែហៅថាកូនគោ បន្ទាប់ពីនោះរហូតដល់អាយុប្រហែល2ឆ្នាំ គេហៅថាគោលូតលាស់ ហើយក្រោយពេលកើតកូនជាលើកដំបូងហើយ គេហៅថាគោពេញវ័យ។

· ជាទូទៅ ក្រោយពេលគោញីកើតបានរយៈពេល14~15ខែ គេចាប់ផ្តើមអនុវត្តការបង្កកំណើតសិប្បនិម្មិត ហើយគោញីទាំងនោះនឹងចាប់ផ្តើមពពោះ។

· គម្លាតនៃការបង្កើតកូនរបស់គោទឹកដោះដែលល្អប្រសើរ គឺ365ថ្ងៃគឺមួយឆ្នាំកើតម្តង ប៉ុន្តែគម្លាតនៃការបង្កើតកូនរបស់គោទឹកដោះនៅក្នុងប្រទេសជប៉ុន មានរយៈពេលវែង។ នៅក្នុងឆ្នាំ1989 មានរយៈពេល405ថ្ងៃ ប៉ុន្តែនៅក្នុងឆ្នាំ2015 មានរយៈពេល433ថ្ងៃ។

· រយៈពេលពពោះរបស់គោទឹកដោះគឺ280ថ្ងៃ (9.3ខែ)។

· ក្រោយពេលគោញីកើតបានកូនគោ គេនឹងចាប់ផ្តើមធ្វើការច្របាច់យកទឹកដោះស្រស់រយៈពេល1ឆ្នាំ ដោយក្នុងអំឡុងពេលនោះ គេនឹងអនុវត្តការបង្កកំណើតសិប្បនិម្មិតចំពោះគោញីទាំងនោះ ដើម្បីអោយគោពពោះនិងកើតកូនបន្តទៀត។

· 2~3ខែមុនដល់ពេលកើតកូន គេនឹងបញ្ឈប់ការច្របាច់ទឹកដោះ ដើម្បីអោយមេនិងកូនគោក្នុងផ្ទៃអាចទទួលសារធាតុចិញ្ចឹមបានគ្រប់គ្រាន់។

· គោទឹកដោះនឹងឆ្លងកាត់វដ្តបែបនេះដែលមានរយៈពេល400~430ថ្ងៃម្តងហើយម្តងទៀត ដោយមានមេគោខ្លះអាចកើតកូនច្រើនដងគឺប្រហែល7~8ដង ប៉ុន្តែជាមធ្យមគឺកើតកូនបានប្រហែល4ដង។



វដ្តជីវិតនៃគោចិញ្ចឹមយកទឹកដោះ

5 រយៈពេលនៃការប្រើប្រាស់គោទឹកដោះ

(1) អំឡុងពេលបង្កាត់ពូជសម្រាប់បង្កើតកូនដំបូងរបស់គោទឹកដោះ ជាទូទៅគឺនៅក្នុងអាយុ14~15ខែ។

(2) បន្ទាប់ពីបង្កើតកូនរួច រយៈពេលដែលមិនពពោះ (មិនមានផ្ទៃពោះ) គេហៅថា ចំនួនថ្ងៃទំនេរពពោះ។ គម្លាតនៃការបង្កើតកូន គឺស្មើនឹងចំនួនថ្ងៃពពោះ បូកនឹងចំនួនថ្ងៃទំនេរពពោះ។

(3) ឧទាហរណ៍ ករណីដែលចំនួនថ្ងៃទំនេរពពោះ មានរយៈពេល120ថ្ងៃ (4ខែ) គម្លាតនៃការបង្កើតកូន គឺស្មើនឹង13.3ខែ (399ថ្ងៃ)។

(4) ក្រោយពីបង្កើតកូនដំបូងរួច គោដែលបង្កើតកូននៅពេលបន្ទាប់ហៅថា ការបង្កើតកូនលើកទី2 ការបង្កើតកូនលើកទី3 ការបង្កើតកូនលើកទី4 ・・・ គេហៅថា ការបង្កើតកូនបន្ទាប់។

(5) រយៈពេលប្រើប្រាស់គោទឹកដោះ(គោធ្លាប់មានកូន)របស់ប្រទេសជប៉ុន មានទំនោរទៅរកការកាត់បន្ថយខ្លីទៅៗ នៅក្នុងឆ្នាំ2002 គឺត្រឹមការបង្កើតលើកទី4.2 នៅក្នុងឆ្នាំ2007 គឺត្រឹមការបង្កើតលើកទី4 ហើយនៅក្នុងឆ្នាំ2015 គឺត្រឹមការបង្កើតលើកទី3.5។

(6) ការឈប់ប្រើប្រាស់ ដោយសារតែជំងឺដោះ (ជំងឺរលាកដោះជាដើម) ជំងឺទាក់ទងនឹងប្រព័ន្ធបន្តពូជ ជំងឺទាក់ទងនឹងក្រចកជើងគោ (ជម្ងឺក្រចកជើងគោ) ជំងឺទាក់ទងនឹងសរីរាង្គរំលាយអាហារ ការមិនអាចក្រោកឈរបាន (ជំងឺគ្រុនក្តៅទឹកដោះ milk fever) ជាដើម គឺជាដើមហេតុនៃការកាត់បន្ថយខ្លីទៅៗនៃរយៈពេលប្រើប្រាស់គោទឹកដោះ។

6 ចំណីសត្វ

・ចំណីដែលផ្តល់អោយគោទឹកដោះ រួមមាន ចំណីជីវជាតិ និង ចំណីមិនកែច្នៃ។
・ចំណីជីវជាតិភាគច្រើនគេប្រើក្នុងទម្រង់ជាចំណីលាយ។
・ចំណីមិនកែច្នៃ រួមមានចំណីផ្អាប់ដែលផលិតនៅក្នុងប្រទេស និង ស្មៅស្ងួតដែលនាំចូលពីប្រទេសក្រៅឬផលិតនៅប្រទេសជប៉ុនតែម្តង។
・ធញ្ញជាតិសំខាន់ដែលមាននៅក្នុងចំណីលាយគឺពោតនាំចូល។

7 ការពិនិត្យគុណភាពទឹកដោះ

・គុណភាពទឹកដោះនៃគោទឹកដោះនីមួយៗអាចមានលក្ខណៈខុសគ្នា។
・ទំនិញទឹកដោះគោដែលត្រូវបានបញ្ចេញដោយកសិករផលិតទឹកដោះនឹងត្រូវទទួលការត្រួតពិនិត្យគុណភាព ។
・ការត្រួតពិនិត្យគុណភាពទឹកដោះបែងចែកជាពីរគឺ ការត្រួតពិនិត្យលើសារធាតុនៅក្នុងទឹកដោះ រួមមានអត្រាជាតិខ្លាញ់ក្នុងទឹកដោះ អត្រាប្រូតេអ៊ីនក្នុងទឹកដោះនិងអត្រានៃសារធាតុក្រៅពីខ្លាញ់ ហើយនិងការត្រួតពិនិត្យលើគុណភាពអនាម័យ រួមមានចំនួនកោសិការាងកាយនិងចំនួនបាក់តេរី។

8 គោទឹកដោះនិងអាកាសធាតុក្តៅនៅរដូវក្តៅ

・តំបន់ដែលមានសីតុណ្ហភាព 13~18 អង្សាសេគឺសាកសមបំផុតសម្រាប់គោទឹកដោះពូជហុលស្តាញ ព្រោះគោប្រភេទនេះមិនសូវធន់នឹងកម្តៅនោះទេ។
・នៅពេលសំណើមបរិយាកាសឡើងខ្ពស់ ហើយសីតុណ្ហភាពបរិយាកាសឡើងដល់ប្រហែល30អង្សាសេ ធ្វើអោយការស៊ីអាហារស្ងួតរបស់គោទឹកដោះមានបរិមាណថយចុះ ហើយបរិមាណទឹកដោះនិងគុណភាពនៃសារធាតុចិញ្ចឹមនៅក្នុងទឹកដោះក៏ធ្លាក់ចុះផងដែរ។
・គោទឹកដោះមានសរីរាង្គដែលអាចផ្អាប់អាហារបាន ហៅថាក្រពះទី1 ដូច្នេះ វាមានសីតុណ្ហភាពក្នុងខ្លួនខ្ពស់ជាងមនុស្ស ដោយសីតុណ្ហភាពក្នុងខ្លួនជាធម្មតារបស់វាគឺ38.5អង្សាសេ។
・ដោយសារតែឥទ្ធិពលនៃការឡើងកម្តៅផែនដី ថ្ងៃក្តៅ (ថ្ងៃដែលមានសីតុណ្ហភាពខ្ពស់បំផុតលើសពី30អង្សាសេ) និងថ្ងៃក្តៅខ្លាំង (ថ្ងៃដែលមានសីតុណ្ហភាពខ្ពស់បំផុតលើសពី 35អង្សាសេ) នៅក្នុងរដូវក្តៅនៅប្រទេសជប៉ុនមានការកើនឡើងច្រើន។

· គោទឹកដោះ ដែលបានស្លាប់និងលែងត្រូវបានប្រើប្រាស់ដោយសារតែអាកាសធាតុក្តៅនៅក្នុងរដូវក្តៅក៏មានដែរ។ នៅក្នុងរដូវក្តៅឆ្នាំ2010 គោទឹកដោះដែលបានស្លាប់និងលែងត្រូវបានប្រើប្រាស់ ដោយសារតែអាកាសធាតុក្តៅ មានចំនួន 959ក្បាល។

· តារាងខាងក្រោមនេះ បង្ហាញពីស្ថានភាពរបស់គោទឹកដោះនៅក្នុងបរិស្ថានដែលមានសីតុណ្ហភាព 18អង្សាសេ 26អង្សាសេ និង30អង្សាសេ។ បរិមាណស៊ីចំណីរបស់វាមានការថយចុះ ទម្ងន់របស់វាក៏មានការថយចុះដែរ ហើយបរិមាណទឹកដោះក៏មានការថយចុះផងដែរ។

· សីតុណ្ហភាពនៅក្នុងខ្លួននិងចំនួនដកដង្ហើមមានការកើនឡើងទៅតាមការឡើងនៃសីតុណ្ហភាពបរិស្ថាន។

ការឡើងនៃសីតុណ្ហភាពបរិស្ថាននិងស្ថានភាពរបស់គោទឹកដោះ (ឧទាហរណ៍)

		18°C	26°C	30°C
បរិមាណស៊ីចំណីលាយ	គីឡូក្រាមថ្ងៃ	12.0	10.3	8.4
បរិមាណស៊ីស្មៅស្ងួត	គីឡូក្រាមថ្ងៃ	6.1	4.5	3.7
ទម្ងន់ (នៅពេលការប្រឡងបានបញ្ចប់)	គីឡូក្រាម	561	543	528
សីតុណ្ហភាពនៅក្នុងខ្លួន	អង្សាសេ	38.3	39.2	40.2
ចំនួនដកដង្ហើម	ដងនាទី	33.7	58.3	73.1
បរិមាណទឹកដោះ	គីឡូក្រាម	27.5	23.3	19.3

វាជាបញ្ហាដ៏ធំមួយសម្រាប់កសិកម្មផលិតទឹកដោះក្នុងការធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហាអាកាសធាតុក្តៅនៅក្នុងការចិញ្ចឹមគោទឹកដោះ។ ដើម្បីដោះស្រាយបញ្ហានេះ ការរៀបចំរចនាសម្ព័ន្ធនៃរោងចិញ្ចឹមគោ ការបំពាក់និងគ្រប់គ្រងបរិក្ខារធ្វើអោយត្រជាក់ដូចជាកង្ហារ ឧបករណ៍បាញ់ទឹកជាដើម ការដាំដើមឈើនៅជុំវិញរោងចិញ្ចឹមគោ ការគ្រប់គ្រងសារធាតុចិញ្ចឹមជាដើម គឺសុទ្ធសឹងជាកិច្ចការងារសំខាន់ៗ។

ម្យ៉ាងទៀត គោទឹកដោះគឺជាសត្វដែលផឹកទឹកច្រើន ហើយងាយទទួលរងផលប៉ះពាល់ដោយសារគុណភាពទឹក ជាពិសេសនៅរដូវក្តៅដែលមានអាកាសធាតុក្តៅ គេត្រូវរក្សាទឹកអោយមានអនាម័យនិងត្រជាក់ជានិច្ច ដើម្បីអោយគោអាចផឹកទឹកបានគ្រប់គ្រាន់គ្រប់ពេលវេលា។

9 ការទុកដាក់កាកសំណល់សត្វ

· ច្បាប់បានកំណត់ថាកសិដ្ឋានត្រូវធ្វើការទុកដាក់កាកសំណល់សត្វអោយបានត្រឹមត្រូវ ដើម្បីកុំអោយកើតមានបញ្ហាក្លិនស្អុយ។ល។

· វាជាការងារសំខាន់មួយ ដោយគេអាចប្រើប្រាស់កាកសំណល់សត្វសម្រាប់ធ្វើជីកំប៉ុស្តិ៍ដែលមានគុណភាពល្អនិងអាចប្រើប្រាស់នៅលើវាលស្មៅ ហើយគេក៏អាចផ្គត់ផ្គង់ទៅអោយកសិករធ្វើចំការឬកសិករផលិតស្រូវបានផងដែរ។

ចំនួនគោដែលកសិករផលិតទឹកដោះធ្វើការចិញ្ចឹមកំពុងមានការកើនឡើង ដូច្នេះ បរិមាណកាកសំណល់សត្វ

ដែលត្រូវបានបញ្ចេញពីកសិដ្ឋានក៏មានការកើនឡើងដែរ។ ប៉ុន្តែ ផ្ទៃដីសម្រាប់ធ្វើជាវាលស្មៅឬដាំដំណាំធ្វើជាចំណីសត្វមិនសូវមានការកើនឡើងសមាមាត្រទៅនឹងការកើនឡើងនៃចំនួនសត្វចិញ្ចឹមនោះទេ ដូច្នេះ ក្រៅអំពីកាកសំណល់ដែលប្រើប្រាស់នៅលើដីសម្រាប់ធ្វើវាលស្មៅរបស់កសិករខ្លួនឯង នៅមានកាកសំណល់ដែលសល់ពីនោះដោយសារការកើនឡើងហួសហេតុនៃបរិមាណកាកសំណល់ ដោយស្ថានភាពនេះបានបង្កជាបញ្ហាផ្សេងៗជាច្រើន ។

រោងផ្ទុកជីកំប៉ុស្ត៍

2 ការផលិតសាច់គោ (គោចិញ្ចឹមយកសាច់)

1 គោចិញ្ចឹមយកសាច់

គោចិញ្ចឹមយកសាច់នៅប្រទេសជប៉ុនដែលមានបរិមាណផលិតច្រើននោះ មាន3ប្រភេទគឺ ពូជគោជប៉ុនរោមខ្មៅ (ពូជគោជប៉ុន) គោក្រៀវនៃពូជគោទឹកដោះ(ពូជគោហុលស្តាញ) និង គោដែលបានពីការបង្កាត់ពូជគោជប៉ុនរោមខ្មៅ និងគោទឹកដោះ(F1)។ គោប្រភេទនីមួយៗមានរយៈពេលនៃការចិញ្ចឹមបំប៉នខុសៗពីគ្នា។

2 ទម្រង់នៃការចិញ្ចឹមគោយកសាច់

អាជីវកម្មផលិតគោចិញ្ចឹមយកសាច់នៅប្រទេសជប៉ុនមាន3ទម្រង់ដូចខាងក្រោម។

(1) អាជីវកម្មបង្កាត់ពូជ

គេធ្វើការចិញ្ចឹមពូជគោជប៉ុនញីដែលប្រើប្រាស់សម្រាប់បង្កាត់ពូជ ដើម្បីធ្វើការបង្កើតនិងចិញ្ចឹមកូនគោបានអាយុប្រហែល10ខែ រួចគេនឹងបញ្ជូនកូនគោទាំងនោះចេញទៅទីផ្សារដើម្បីលក់ធ្វើជាគោដើមសម្រាប់ការចិញ្ចឹមបំប៉នបន្តទៀត។

កសិករដាក់គោលដៅផលិតកូនគោឲ្យបាន1ដង ក្នុង1ឆ្នាំ។ គោញីដែលគេប្រើប្រាស់សម្រាប់បង្កាត់ពូជ ជាមធ្យមអាចផលិតបានប្រហែល 7ដង នៅក្នុងនោះកសិករដែលផលិតលើសពី10ដងក៏មានដែរ។

ការចិញ្ចឹមដោយព្រលែង

គោញី

(2) អាជីវកម្មចិញ្ចឹមបំប៉ន

គេទិញចូលពូជគោជប៉ុន(អាយុប្រហែល10ខែ) គោក្រៀវនៃពូជគោទឹកដោះ(កូនគោ) ពូជគោបង្កាត់(កូនគោឬគោអាយុប្រហែល8ខែ) ធ្វើជាគោដើមសម្រាប់ការចិញ្ចឹមបំប៉ន ដោយគេធ្វើការចិញ្ចឹមបំប៉នគោទាំងនេះរហូតដល់អាយុប្រហែល30ខែសម្រាប់ពូជគោជប៉ុន ហើយរហូតដល់អាយុ19~20ខែសម្រាប់គោក្រៀវនៃពូជគោទឹកដោះ និងរហូតដល់អាយុប្រហែល25ខែសម្រាប់ពូជគោបង្កាត់ មុននឹងធ្វើការបញ្ចេញលក់បន្ត។

(3) អាជីវកម្មបង្កាត់ពូជនិងចិញ្ចឹមបំប៉ន

អាជីវកម្មដែលបូករួមបញ្ចូលទាំងការងារបង្កាត់ពូជទាំងការងារចិញ្ចឹមបំប៉នបន្តបន្ទាប់គ្នាចូលក្នុងអាជីវកម្មតែមួយ ហៅថា អាជីវកម្មបង្កាត់ពូជនិងចិញ្ចឹមបំប៉ន ប៉ុន្តែ សម្រាប់ពូជគោជប៉ុន មិនសូវមានការធ្វើអាជីវកម្មក្នុងទម្រង់បែបនេះនៅឡើយទេ។

(4) ផ្សេងៗ

កសិករផលិតទឹកដោះ: ធ្វើការបង្កកំណើតសិប្បនិម្មិតដោយចាក់ទឹកកាមរបស់ពូជគោជប៉ុនទៅក្នុងគោញីនៃពូជគោទឹកដោះ: ដើម្បីបង្កើតកូនគោប្រភេទពូជបង្កាត់ រួចនាំចេញទៅទីផ្សារដើម្បីលក់ទៅឲ្យកសិករចិញ្ចឹមបំប៉នក៏មានដែរ។ កូនគោប្រភេទពូជបង្កាត់ នៅពេលទើបនឹងកើតវាមានទម្ងន់ប្រហែល 30គីឡូក្រាម តូចជាងកូនគោប្រភេទសម្រាប់យកទឹកដោះ: (ប្រហែល 45គីឡូក្រាម) ប៉ុន្តែចំណុចល្អរបស់វា គឺអាចទប់ស្កាត់ការពិបាកកើតកូនដំបូងរបស់គោទឹកដោះបាន។

■គោចិញ្ចឹមយកសាច់ (ករណីគោញីដែលចិញ្ចឹមដើម្បីបង្កើតកូនគោ)



■គោចិញ្ចឹមយកសាច់ (ករណីគោចិញ្ចឹមបំប៉ន)



3 ចំណីសត្វ និង ទម្រង់នៃការអោយចំណីសត្វ

(1) កូនគោ និង គោលូតលាស់

ចំណីរបស់គោសម្រាប់ពូជគោជប៉ុន គោក្រៀវនៃពូជគោទឹកដោះ និង គោបង្កាត់ ចាប់ពីពេលនៅជាកូនគោមកដល់វ័យលូតលាស់មានលក្ខណៈផ្លាស់ប្តូរទៅតាមដំណាក់កាល គឺ ទឹកដោះមេគោ →ទឹកដោះជំនួស→ទឹកដោះសិប្បនិម្មិត →ស្មៅស្ងួតនិងចំណីលាយ។

កូនគោ

(2) គោចិញ្ចឹមបំប៉ន

ចំណីសម្រាប់ដំណាក់កាលចិញ្ចឹមបំប៉ន គឺសម្រាប់ពូជគោជប៉ុនគេច្រើនប្រើចំណីលាយនិងចំបើងស្រូវ សម្រាប់គោក្រៀវនៃពូជគោទឹកដោះគេច្រើនប្រើចំណីផ្អាប់ (រួមមានស្រូវផ្អាប់ ស្មៅផ្អាប់ ពោតផ្អាប់) ស្មៅស្ងួតនិងចំណីលាយ ហើយសម្រាប់គោបង្កាត់គេច្រើនប្រើចំណីផ្អាប់ ស្មៅស្ងួត ចំបើងស្រូវ និង ចំណីលាយ។ បើគិតជាភាគរយនៃបរិមាណផ្គត់ផ្គង់ចំណីមិនកែច្នៃនិងចំណីជីវជាតិ គេប្រើចំណីលាយក្នុងភាគរយខ្ពស់សម្រាប់គោចិញ្ចឹមបំប៉ន។

គោចិញ្ចឹមបំប៉ន(សម្រាប់យកសាច់)

4 ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងការចិញ្ចឹមសត្វ

ខាងក្រោមនេះគឺជាបញ្ហាផ្សេងៗនៅក្នុងការគ្រប់គ្រងការចិញ្ចឹមគោយកសាច់។ វាមានសារៈសំខាន់ណាស់ក្នុងការគ្រប់គ្រងការចិញ្ចឹមសត្វដោយពិចារណាអោយបានម៉ត់ចត់ចំពោះបញ្ហាទាំងនេះជានិច្ច។

(1) ការធ្វើអោយការកើនទម្ងន់របស់គោទាំងអស់មានលក្ខណៈស្មើគ្នា

វាមានសារៈសំខាន់ណាស់ក្នុងការគិតពិចារណាអំពីការគ្រប់គ្រងជីវជាតិដ៏ត្រឹមត្រូវនិងការធ្វើអោយបរិមាណស៊ីចំណីរបស់គោមានលំនឹង ហើយធ្វើការទប់ស្កាត់កុំអោយមានការជល់គ្នារវាងគោគ្នាឯង ដើម្បីអាចទទួលបានគោដែលមានទម្ងន់ធ្ងន់និងសាច់មានគុណភាពល្អ។ ជាពិសេសសម្រាប់ពូជគោជប៉ុនដែលគេកំពុងផ្តោតការយកចិត្តទុកដាក់លើការផលិតជាសាច់គោពពាល។

(2) ការគ្រប់គ្រងសុខភាពរបស់កូនគោ

កូនគោងាយកើតជំងឺរលាកសួតនិងរាករូស ដូច្នេះ ការត្រួតពិនិត្យ ការថែទាំនិងការព្យាបាលសុខភាពកូនគោអោយបានម៉ត់ចត់គឺមានសារៈសំខាន់ណាស់។

ការរក្សាកម្តៅអោយកូនគោ (អាវរក្សាកម្តៅ)

(3) ការទប់ស្កាត់ការជ្រៀតចូលនៃវីរុស

គេចាំបាច់ត្រូវប្រុងប្រយ័ត្នអោយបានគ្រប់គ្រាន់កុំអោយកើតមានការជ្រៀតចូលនៃវីរុសទៅក្នុងកសិដ្ឋាន។

(4) ការទុកដាក់កាកសំណល់សត្វ

ចាំបាច់ត្រូវមានការខំប្រឹងប្រែងដូចក្នុងខ្លឹមសារដែលបានរៀបរាប់នៅក្នុងផ្នែកទី1ចំណុចទី6នៃកសិកម្មផលិតទឹកដោះ។

3 ការចិញ្ចឹមជ្រូក (សត្វជ្រូក)

1 ពូជជ្រូក

សត្វជ្រូកគឺជាសត្វដែលទទួលបានពីការផ្សាំងជ្រូកព្រៃរបស់មនុស្សអោយមានលក្ខណៈល្អប្រសើរឡើង ដើម្បីលើកកម្ពស់នៃលទ្ធភាពផលិតសាច់ ។ ពូជជ្រូកសំខាន់ៗដែលគេច្រើនចិញ្ចឹមនៅប្រទេសជប៉ុន រួមមាន ពូជជ្រូកឡែនរ៉េស ពូជជ្រូកយ៉កសៀរធំ និង ពូជជ្រូកឌុយរ៉ក។

ពូជជ្រូក

ពូជ(អក្សរកាត់)		រូបរាងខាងក្រៅ	លក្ខណៈពិសេស
ពូជជ្រូកឡែនរ៉េស		សម្បុរស ដងខ្លួនវែង។ មុខស្រួច ត្រចៀកធ្លាក់។	កើតកូនច្រើន។ កូនជ្រូកមានអត្រាធំធាត់ខ្ពស់។
ពូជជ្រូកយ៉កសៀរធំ		សម្បុរស ត្រចៀកបះ។	មានលទ្ធភាពបង្កាត់ពូជខ្ពស់។
ពូជជ្រូកឌុយរ៉ក		សម្បុរត្នោតឬខ្មៅ ត្រចៀកធ្លាក់។	គុណភាពសាច់ល្អ ធន់នឹងជំងឺ ឆាប់លូតលាស់។
ពូជជ្រូកប៊ែកសៀរ		ជ្រូកមានសម្បុរខ្មៅ ប៉ុន្តែចុងជើង ចុងមុខនិងចុងកន្ទុយមានពណ៌ស។ គេច្រើនហៅថាជ្រូកស6កន្លែង។	ទាំងចំនួនកូនទាំងការធំធាត់មាន លក្ខណៈអន់ជាងពូជកម្រិតខ្ពស់ ប៉ុន្តែមានគុណភាពសាច់ល្អ ។
ពូជជ្រូកហាំសៀរ		សម្បុរខ្មៅប៉ុន្តែមានឆ្នូតកាត់ទទឹង ពណ៌ស។	គេប្រើជ្រូកនេះសម្រាប់ធ្វើជាជ្រូក ឈ្មោលជំនួសអោយពូជជ្រូកឌុយរ៉ក នៅក្នុងការបង្កាត់ពូជបីសាសន៍។
ពូជជ្រូកយ៉កសៀរមធ្យម		មុខកន្ទឹប ត្រចៀកបះ។	លូតលាស់យឺត ប៉ុន្តែ គុណភាព សាច់ល្អ។

ប្រសិនបើបង្កាត់ពូជរវាងប្រភេទទាំង3នេះ អត្រាធំធាត់ខ្ពស់ ការលូតលាស់លឿន ហើយសាច់ក៏មានគុណ ភាពល្អផងដែរ។ ដំបូង គឺជាការបង្កាត់ពូជរវាងពូជជ្រូកឡែនរ៉េស (L) ជាមួយនឹងពូជជ្រូកយ៉កសៀរធំ (W)។ ដូច្នេះ គេចិញ្ចឹមជ្រូកញីដែលកើតមក ទុកសម្រាប់ធ្វើជាជ្រូកបង្កាត់ពូជ។ ហើយការចិញ្ចឹមបំប៉នកូនជ្រូកដែលកើតពីការ បង្កាត់រវាងភេទឈ្មោលនៃពូជជ្រូកឌុយរ៉ក (D) ជាមួយនឹងជ្រូកញីដែលកើតពីការបង្កាត់ខាងលើនេះ ជាជ្រូកចិញ្ចឹម បំប៉ន (LWD) គឺជារឿងធម្មតា។ ពោលគឺ ភាគច្រើននៃជ្រូកចិញ្ចឹមបំប៉នរបស់ប្រទេសជប៉ុន គឺជាប្រភេទពូជជ្រូកបង្កា

ត់។ តាមរយៈការបង្កាត់ពូជប្រភេទផ្សេងគ្នាបែបនេះ សមត្ថភាពកូនរបស់វា គឺមានការកើនឡើង ហើយគេហៅវាថា ពូជបង្កាត់ដែលខ្លាំង (heterosis)។ ប្រភេទផ្សេងក្រៅពីនេះមាន ពូជជ្រូកបែកសៀវ (ជ្រូកខ្មៅ) ពូជជ្រូកហាំសៀវ និង ពូជជ្រូកយ៉កសៀវមធ្យម។



ពូជជ្រូកឡែនរ៉េស ញី
(L)

×



ពូជជ្រូកយ៉កសៀវធំ ឈ្មោល
(W)

ជ្រូកមេនៃពូជបង្កាត់ជំនាន់ទី1

×



ពូជជ្រូកឌុយរ៉ក ឈ្មោល
(D)

ពូជបង្កាត់បីសាសន៍ (LWD)

ការដាក់បញ្ចូលគ្នានៃពូជបង្កាត់បីសាសន៍ដែលជាតំណាង

ក្រៅពីនេះ មានជ្រូកចិញ្ចឹមបំប៉ន ជ្រូកសម្រាប់បង្កាត់ពូជឈ្មោល និងញី ដែលត្រូវបានបង្កើតឡើងដោយការ បង្កាត់ពូជប្រភេទផ្សេងៗគ្នា ដែលគេហៅថា ជ្រូកកូនកាត់។ គេធ្វើបែបនេះក្នុងគោលដៅផ្គត់ផ្គង់ជ្រូកសម្រាប់បង្កាត់ ពូជដែលល្អៗដូចគ្នាក្នុងចំនួនច្រើន និងលុបបំបាត់នូវការចំណាយពេលវេលាច្រើនដែលជាចំណុចខ្វះខាតនៃការ បង្កាត់ពូជបីសាសន៍។

ឈ្មោះផ្នែកផ្សេងៗនៃរាងកាយរបស់ជ្រូក



1. ច្រមុះ 2. ត្រចៀក 3. ថ្ពាល់ 4. ក 5. ស្មា 6. ខ្នង 7. ចង្កេះ 8. ផ្នែកចំហៀងនៃពោះ
9. ក្លៀក 10. ចន្លោះភ្លៅ 11. គូទ 12. ភ្លៅ 13. ពោះ 14. ជើងមុខ 15. ជើងក្រោយ
16. កន្ទុយ 17. ត្រគាក 18. ជង្គង់ក្រោយ 19. គន្លាក់ក្រោយជើង 20. កជើង
21. ទ្រូង (រួមបញ្ចូលទាំងពោះ) 22. ទ្រូងមុខ 23. ម្រាមជើង

2 វដ្តជីវិតនៃសត្វជ្រូក

ទៅតាមរបៀបប្រើប្រាស់សត្វជ្រូក គេបែងចែកសត្វជ្រូកជា ជ្រូកចិញ្ចឹមបំប៉ន និង ជ្រូកបង្កាត់ពូជ។ ជ្រូកចិញ្ចឹមបំប៉នសំដៅលើជ្រូកដែលយើងយកមកបរិភោគសាច់។ គេក៏អាចហៅថាជ្រូកសាច់ផងដែរ។ ជ្រូកមេសំដៅលើជ្រូកដែលបានបង្កើតជ្រូកចិញ្ចឹមបំប៉ននោះ។ ហើយជ្រូកឈ្មោលដែលគេប្រើបង្កាត់ជាមួយជ្រូកមេហៅថាជ្រូកពូជ។ ជ្រូកពូជមានរបៀបហៅពីរបែបនៅក្នុងភាសាជប៉ុន (ស៊ិតុង ឬ ថាណិប៊ុតា)។ ជ្រូកមេធ្វើការបង្កាត់ពូជ ពពោះ បង្កើតកូន បំបៅដោះជាបន្តបន្ទាប់ម្តងហើយម្តងទៀត។

សត្វជ្រូកគឺជាសព្វាសីសត្វដែលអាចស៊ីចំណីផ្សេងៗជាច្រើន។ រចនាសម្ព័ន្ធមូលដ្ឋាននៃសរីរាង្គរំលាយអាហាររបស់សត្វជ្រូកមានលក្ខណៈដូចមនុស្សដែរ ព្រោះជាសព្វាសីសត្វដូចគ្នា។ ដំបូង ចំណីអាហារនឹងត្រូវរំលាយនៅក្នុងក្រពះ បន្ទាប់មកទទួលការរំលាយនៅក្នុងពោះវៀនតូចបន្ថែមទៀតមុននឹងស្រូបចូលទៅក្នុងរាងកាយ។ បន្ទាប់ពីនោះ អាហារដែលមិនត្រូវបានរំលាយមួយផ្នែកនឹងបំលែងធាតុ រួចស្រូបចូលទៅក្នុងរាងកាយបន្ថែមទៀត។

(1) ជ្រូកចិញ្ចឹមបំប៉ន (ជ្រូកសាច់)

ជ្រូកចិញ្ចឹមបំប៉ននៅពេលកើតចេញមកត្រូវទទួលការបីបាច់ដោយទឹកដោះពីជ្រូកមេដែលជាជ្រូកបង្កាត់ញីមួយរយៈពេលសិន។ ក្រោយពីកើតបាន រយៈពេល6ខែ(ប្រមាណ180ថ្ងៃ) ទម្ងន់ខ្លួនវានឹងសន្សំបានប្រហែល 115 គីឡូក្រាម ក្លាយជាសាច់។ រយៈពេលគិតចាប់ពីពេលជ្រូកមានទម្ងន់ប្រហែល30គីឡូក្រាមរហូតដល់ពេលគេបញ្ចេញលក់ ហៅថារយៈពេលចិញ្ចឹមបំប៉ន។

(2) ជ្រូកមេ (ជ្រូកបង្កាត់ញី ឬហៅថាមេជ្រូក)

ជ្រូកមេបន្ទាប់ពីកើតបានរយៈពេល8ខែនឹងមានទម្ងន់ប្រហែល120គីឡូក្រាម ហើយគេនឹងធ្វើការបង្កាត់ពូជជាលើកដំបូង។ ការពពោះមានរយៈពេល114ថ្ងៃ។ ចំនួនកូនមានពី10~15ក្បាល ហើយបន្ទាប់ពីកើតកូនបាន3~4សប្តាហ៍ ដែលជារយៈពេលបំបៅដោះបានចប់រួចរាល់ហើយ គេនឹងធ្វើការបង្កាត់ពូជម្តងទៀត។ ជ្រូកមេដែលបានទទួលការ

គ្រប់គ្រងផ្នែកសុខភាពបានល្អគឺអាចពពោះនិងកើតកូនបាន4~5ដងក្នុងរយៈពេល2ឆ្នាំ។ ជ្រូកមេនឹងឆ្លងកាត់វដ្តនេះម្តងហើយម្តងទៀត ហើយជាទូទៅវាអាចបង្កើតកូនបានពី6~10ដង។ វដ្តនៃការបន្តពូជរបស់សត្វជ្រូកមានរយៈពេល21ថ្ងៃ។

(3) ជ្រូកពូជ (ជ្រូកបង្កាត់ឈ្មោល ឬ ជ្រូកពូជឈ្មោល)

ជ្រូកពូជនឹងពេញវ័យអាចបន្តពូជបានក្នុងរយៈពេលប្រហែល7ខែ។ ការបង្កាត់ពូជរួមមាន ការបង្កាត់ដោយធម្មជាតិ (ការពាក់គ្នា) និង ការបង្កកំណើតដោយសិប្បនិម្មិត (AI)។ បច្ចុប្បន្ននេះ ការបង្កកំណើតដោយសិប្បនិម្មិតមានការកើនឡើង។



វដ្តជីវិតនៃជ្រូកបង្កាត់ពូជ(ជ្រូកមេ : ជ្រូកពូជ)/ជ្រូកចិញ្ចឹមបំប៉ន

3 ទម្រង់អាជីវកម្មនៃការចិញ្ចឹមជ្រូក

ទម្រង់អាជីវកម្មនៃកសិដ្ឋានចិញ្ចឹមជ្រូក ត្រូវបានបែងចែកជា3 គឺ "អាជីវកម្មបង្កាត់ពូជនិងចិញ្ចឹមបំប៉ន" "អាជីវកម្មបង្កាត់ពូជ" "ចិញ្ចឹមបំប៉ន"។

អាជីវកម្មបង្កាត់ពូជ គឺជាទម្រង់អាជីវកម្មមួយដែលគេចិញ្ចឹមជ្រូកមេ និងជ្រូកពូជ រួចយកកូនរបស់វាដាក់លក់នៅលើទីផ្សារធ្វើជាជ្រូកដើមសម្រាប់ការចិញ្ចឹមបំប៉ន។

អាជីវកម្មចិញ្ចឹមបំប៉ន គឺជាទម្រង់អាជីវកម្មមួយដែលគេទិញកូនជ្រូកពីអាជីវកម្មបង្កាត់ពូជមកចិញ្ចឹមបំប៉ន រួចយកទៅទីផ្សារដើម្បីលក់។

អាជីវកម្មបង្កាត់ពូជនិងចិញ្ចឹមបំប៉ន គឺជាទម្រង់អាជីវកម្មមួយដែលគេចិញ្ចឹមជ្រូកមេ ជ្រូកពូជ និងជ្រូកចិញ្ចឹមបំប៉នជាមួយគ្នា ដោយគេធ្វើការងារបន្តបន្ទាប់គ្នាចាប់តាំងពីការបង្កាត់ពូជ រហូតដល់ចិញ្ចឹមបំប៉ន។ បច្ចុប្បន្ន អាជីវកម្មបង្កាត់ពូជនិងចិញ្ចឹមបំប៉ន មានការកើនឡើងច្រើន។ មូលហេតុចំបង គឺដោយសារតែដើម្បីទប់ស្កាត់ការជ្រៀតចូលនៃជំងឺផ្សេងៗពីខាងក្រៅ និងដើម្បីពង្រីកទំហំអាជីវកម្មផងដែរ។

អាជីវកម្មបង្កាត់ពូជនាពេលបច្ចុប្បន្ន កំពុងក្លាយទៅជាទម្រង់មួយដែលធ្វើការផលិត និងធ្វើឲ្យប្រសើរនូវជ្រូកមេនិងជ្រូកពូជជាចំបង ដើម្បីលក់ទៅឲ្យអាជីវកម្មបង្កាត់ពូជនិងចិញ្ចឹមបំប៉ន។

ទំហំរបស់អាជីវកម្ម មានផ្សេងៗគ្នាជាច្រើន ចាប់ពីអាជីវកម្មខ្នាតធំដែលមានបុគ្គលិកចាប់ពី10នាក់រហូតលើស100នាក់ រហូតដល់អាជីវកម្មគ្រួសារខ្នាតតូច ។ អាជីវកម្មខ្នាតធំក៏ត្រូវបានហៅថា "ការចិញ្ចឹមជ្រូកបែបសហគ្រាស"

ផងដែរ។

មិនមែនត្រឹមតែការផលិតនៅក្នុងកសិដ្ឋានចិញ្ចឹមជ្រូកប៉ុណ្ណោះទេ ករណីដែលគេធ្វើអាជីវកម្មរួមគ្នាតែមួយដូចជាការផលិតផលិតផលសាច់ ការលក់ដុំនូវសាច់ជាអាហារ ការលក់រាយនូវសាច់ជាអាហារជាដើមក៏មានដែរ គេហៅវាថា សមាហរណកម្ម (integration)។

តាមការបែងចែកកសិដ្ឋានតាមរយៈការមើលទៅលើការគ្រប់គ្រងអនាម័យ ក្រៅពីកសិដ្ឋានជាទូទៅ មាន"កសិដ្ឋានSPF (គ្មានមេរោគជាក់លាក់មួយចំនួន)" ដែលការគ្រប់គ្រងទៅលើអនាម័យរបស់វាមានការតឹងរឹងជាងកសិដ្ឋានធម្មតា។ ប្រសិនបើប្រៀបធៀបជាមួយSPF កសិដ្ឋានជាទូទៅត្រូវបានគេហៅថា កសិដ្ឋានធម្មតា (conventional)។

4 ចំណីសត្វ និងទម្រង់នៃការផលិត ការទិញ និងការផ្តល់ចំណី

វត្ថុធាតុដើមនៃចំណីរបស់សត្វជ្រូកភាគច្រើនត្រូវបាននាំចូលពីបរទេស។

វត្ថុធាតុដើមដូចជាពោតដែលបាននាំចូលមកដល់កំពង់ផែជាដើម ត្រូវបានគេដាក់លក់ក្នុងទម្រង់ជាចំណីលាយ ក្រោយពីត្រូវបានកំទេចឲ្យល្អិតនៅរោងចក្រចំណីសត្វដើម្បីឲ្យមានភាពងាយស្រួលក្នុងការរំលាយ និងត្រូវបានលាយដោយគិតទៅលើតុល្យភាពនៃសារធាតុចិញ្ចឹមដើម្បីឲ្យសមស្របទៅនឹងដំណាក់កាលនៃការរីកធំធាត់របស់សត្វជ្រូក។ វត្ថុធាតុដើមដែលគេប្រើប្រាស់ច្រើនមាន ពោតនិងកាកសំណល់សណ្តែកសៀង (សណ្តែកសៀងដែលគេយកខ្លាញ់ចេញ)។

ទ្រង់ទ្រាយរបស់ចំណី មានដូចជា ចំណីម៉ត់ដែលត្រូវបានកំទេចឲ្យល្អិត ចំណីគ្រាប់តូចៗរាងស៊ីឡាំងដែលបានពីការគាបចំណីម៉ត់ និងចំណីគ្រាប់តូចៗដែលបានពីការកំទេចចំណីគ្រាប់តូចៗរាងស៊ីឡាំង។ ម៉្យាងទៀត គេក៏ប្រើប្រាស់ចំណីរាវសម្រាប់ផ្តល់ឲ្យសត្វក្នុងទម្រង់ជាសារធាតុរាវផងដែរ។

របៀបនៃការផ្តល់ចំណី មាន "ការផ្តល់ចំណីដោយសេរី" និង"ការផ្តល់ចំណីដោយមានកម្រិតកំណត់"។

ការផ្តល់ចំណីដោយសេរី គេអាចហៅម៉្យាងទៀតបានថា ការស៊ីចំណីជាលក្ខណៈសេរី វាគឺជារបៀបនៃការផ្តល់ចំណីដែលនៅក្នុងស្នូកដាក់ចំណីតែងតែមានចំណីជានិច្ច ដូច្នេះហើយសត្វជ្រូកអាចស៊ីចំណីបានគ្រប់ពេលវេលា។

ការផ្តល់ចំណីដោយមានកម្រិតកំណត់ គឺរបៀបនៃការផ្តល់ចំណីដែលគេផ្តល់ចំណីទៅតាមបរិមាណដែលបានកំណត់។

ចំពោះជ្រូកចិញ្ចឹមបំប៉ន ភាគច្រើនគេចិញ្ចឹមវាដោយវិធីផ្តល់ចំណីដោយសេរី ចំណែកឯជ្រូកសម្រាប់បង្កាត់ពូជវិញ ភាគច្រើនគេចិញ្ចឹមវាដោយវិធីផ្តល់ចំណីដោយមានកម្រិតកំណត់។

ចំណីម៉ត់

ចំណីគ្រាប់តូចៗរាងស៊ីឡាំង

ចំណីរាវ

ទ្រង់ទ្រាយរបស់ចំណី

5 សាច់ជាប់ឆ្អឹង និងសាច់តាមផ្នែក

ជ្រូកចិញ្ចឹមបំប៉ន (ជ្រូកសាច់) ដែលដាក់លក់នៅលើទីផ្សារ គឺត្រូវបានគេសម្លាប់ រួចដាក់លក់ក្នុងទម្រង់ជា "សាច់ជាប់ឆ្អឹង"។

សាច់ជាប់ឆ្អឹង គឺជាសាច់ដែលនៅសល់បន្ទាប់ពីគេយកផ្នែកក្បាល ជើងទាំងបួន និងគ្រឿងក្នុងចេញពីជ្រូកទាំងមូល។ គេអាចយកសាច់ជាប់ឆ្អឹងបាន 75គីឡូក្រាម ពីជ្រូកដែលមានទម្ងន់ 115គីឡូក្រាម ។ ដូច្នេះ សាច់ជាប់ឆ្អឹងដែលទទួលបានគឺប្រហែល 65%។ ហើយសាច់ដែលនៅសល់បន្ទាប់ពីបានកាត់ខាងឆ្វេងស្តាំចេញពីសាច់ជាប់ឆ្អឹង គេហៅថា សាច់ពាក់កណ្តាលរង្វង់។ សាច់ជាប់ឆ្អឹង ចំណាត់ថ្នាក់របស់វាត្រូវបានគេវាយតម្លៃទៅតាមស្តង់ដារនៃការរកស៊ីសាច់ជ្រូកជាប់ឆ្អឹង ដោយដាក់ចំណាត់ថ្នាក់ពីខ្ពស់ទៅទាប គឺល្អបំផុត ល្អបង្គួរ ល្អ កណ្តាល មធ្យម និងក្រោមស្តង់ដារជាដើម។ ដំបូង គេវាយតម្លៃលើទម្ងន់សាច់ជាប់ឆ្អឹង (សាច់ពាក់ កណ្តាលរង្វង់) និងកម្រាស់ខ្លាញ់ខ្នង បន្ទាប់មកគេវាយតម្លៃលើរូបរាងខាងក្រៅ និងគុណភាពរបស់សាច់។

សាច់ជាប់ឆ្អឹង នឹងត្រូវបានគេយកទៅកាត់ជាសាច់តាមផ្នែកបន្តទៀត។ បន្ទាប់មក គេយកសាច់តាមផ្នែក ទៅដាក់លក់ដោយហាន់ជាដុំតូចៗ ឬដាក់លក់បន្ទាប់ពីកែច្នៃឲ្យទៅជាសាច់បន្ទះ ឬសាច់ក្រក។

សាច់ពាក់កណ្តាលរង្វង់នៃសាច់ជាប់ឆ្អឹង



ផ្នែកដែលគេបែងចែកចំពោះសាច់ជាប់ឆ្អឹងនៅក្នុងប្រទេសជប៉ុន

ពណ៌សាច់ និងពណ៌ខ្លាញ់ គឺមានស្តង់ដារកំណត់ សាច់ដែលមានពណ៌ចាស់ពេក ឬស្រាលពេក គឺមិនល្អទេ សាច់ដែលមានពណ៌ស្រាលល្មម (ពណ៌ស្តើង) នៅកណ្តាល ទើបល្អប្រសើរ។ គេវាស់វាតាមរយៈស្តង់ដារពណ៌សាច់ជ្រូក (pork color standard)។ ចំពោះពណ៌ខ្លាញ់វិញ ពណ៌សគឺជាពណ៌ដែលគេចង់បាន ខ្លាញ់ដែលមានពណ៌លឿងគេមិនចង់បានទេ។ ករណីខ្លាញ់ទន់ គេហៅថា ជ្រូកខ្លាញ់ទន់ ហើយការឲ្យតម្លៃក៏ទាបដែរ។

6 ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងការចិញ្ចឹមសត្វ

(1) ការគ្រប់គ្រងកូនជ្រូក

កូនជ្រូកមានទម្ងន់ប្រមាណ1.4គីឡូក្រាម។ កូនជ្រូកដែលទើបនឹងកើតមានស្រទាប់ខ្លាញ់ក្រោមស្បែកស្តើង ធ្វើអោយមុខងារគ្រប់គ្រងសីតុណ្ហភាពនៅក្នុងរាងកាយនៅមិនទាន់មានលក្ខណៈពេញលេញនៅឡើយទេ។ ដើម្បីទប់

ស្តាត់ការស្លាប់ដោយឧបទ្ទវហេតុឬការឈប់លូតលាស់របស់កូនជ្រូក គេចាំបាច់ត្រូវធ្វើការគ្រប់គ្រងសីតុណ្ហភាពបរិស្ថានសម្រាប់ការចិញ្ចឹមអោយបានសមស្រប ។ ជាពិសេស នៅពេលកូនជ្រូកទើបនឹងកើតបាន1សប្តាហ៍ គេគួររក្សាបរិស្ថានអោយមានសីតុណ្ហភាពចាប់ពី30អង្សាសេឡើងទៅ។

ការរក្សាកម្តៅឲ្យកូនជ្រូក



ការសន្មតអំពីសីតុណ្ហភាពសមស្របសម្រាប់កូនជ្រូកទៅតាមអាយុគិតជាថ្ងៃ

(2) លទ្ធផលកើនទម្ងន់

ការស៊ីចំណីរបស់សត្វជ្រូកគឺសមាមាត្រទៅនឹងការលូតលាស់របស់វាដែរ។ បរិមាណនៃការកើនទម្ងន់ក្នុង1ថ្ងៃហៅថា"ទម្ងន់កើនប្រចាំថ្ងៃ(DG, Daily Gain)"។ បន្ទាប់ពីផ្តាច់ដោះ ការស៊ីចំណីរបស់កូនជ្រូកចាប់ផ្តើមកើនឡើងស្របជាមួយនឹងការកើនឡើងនៃទម្ងន់កើនប្រចាំថ្ងៃរបស់វា គឺ 0.78គីឡូក្រាមនៅពេលជ្រូកមានទម្ងន់30~50គីឡូក្រាម ហើយ0.85គីឡូក្រាមនៅពេលជ្រូកមានទម្ងន់50~115គីឡូក្រាម ដោយនេះគឺជាទម្ងន់កើនប្រចាំថ្ងៃលក្ខណៈស្តង់ដារ។

បរិមាណចំណីដែលត្រូវការចាំបាច់សម្រាប់ការកើនទម្ងន់1គីឡូក្រាមរបស់ជ្រូក ហៅថា"អត្រាទាមទារចំណី"។ ជាធម្មតា អត្រាទាមទារចំណីនេះស្ថិតក្នុងរង្វង់ពី3.2~3.6។ ប្រសិនបើអត្រានេះមានកម្រិតលើសពីនេះ គេចាំបាច់ត្រូវពិនិត្យមើលសារធាតុនៅក្នុងចំណីសារឡើងវិញ។



ពិន្ទុ	ស្ថានភាព	ទ្រង់ទ្រាយ
1	ស្គមពេក	ឆ្អឹងចង្កេះ និងឆ្អឹងខ្នង អាចមើលដឹងដោយភ្នែកទទេរ
2	ស្គម	គេអាចដឹងពីឆ្អឹងចង្កេះ និងឆ្អឹងខ្នងបានយ៉ាងងាយ នៅពេលចុចដោយបាតដៃ
3	ល្អប្រសើរ	គេអាចដឹងពីឆ្អឹងចង្កេះ និងឆ្អឹងខ្នងបាន នៅពេលចុចខ្លាំងដោយបាតដៃ
4	ធាត់	គេមិនអាចដឹងពីឆ្អឹងចង្កេះ និងឆ្អឹងខ្នងបានទេ
5	ធាត់ពេក	ឆ្អឹងចង្កេះ និងឆ្អឹងខ្នងគ្របដណ្តប់ដោយខ្លាញ់យ៉ាងក្រាស់

ពិន្ទុស្ថានភាពរាងកាយរបស់ជ្រូកមេ

(3) ជំងឺឆ្លង

ជំងឺរបស់សត្វជ្រូកមានច្រើន នៅក្នុងនោះមានជំងឺឆ្លងមួយចំនួនដែលមានចែងនៅក្នុងច្បាប់ ដូចជា ជំងឺក្រចកជើងនិងមាត់ ជំងឺអាសន្នរោគជ្រូក ជំងឺរលាកខួរក្បាលរាតត្បាត ហើយប្រសិនបើមានការកើតឡើងនៃជំងឺទាំងនេះ គេត្រូវធ្វើការជូនដំណឹងដល់មជ្ឈមណ្ឌលថែរក្សាអនាម័យនិងសុខុមាលភាពសត្វចិញ្ចឹមជាបន្ទាន់ និងត្រូវគោរពទៅតាមការណែនាំ។

នៅពេលផ្លាស់ប្តូរទីតាំងមនុស្ស ចំណីសត្វ ឬសម្ភារៈផ្សេងៗ ចាំបាច់ត្រូវគោរពទៅតាមវិធាននៃការទប់ស្កាត់ជំងឺឲ្យបានខ្ជាប់ខ្ជួន។

ជំងឺរបស់សត្វជ្រូកដែលគេធ្លាប់ជួបប្រទះនៅក្នុងកសិដ្ឋានរួមមានជាច្រើនប្រភេទ ហើយសម្រាប់ជំងឺដែលគេអាចទប់ស្កាត់បានដោយការចាក់វ៉ាក់សាំង គេនឹងធ្វើការចាក់វ៉ាក់សាំងទៅលើសត្វជ្រូកទាំងនោះ។ បច្ចុប្បន្ននេះ មិនសូវមានជំងឺដែលកើតឡើងទាន់ហន់ហើយធ្វើអោយសត្វងាប់ភ្លាមៗនោះទេ ប៉ុន្តែភាគច្រើនគឺជាជំងឺរ៉ាំរ៉ៃ។ ជំងឺដែលបណ្តាលមកពីវីរុស រួមមាន ជំងឺឆ្លងរលាកក្រពះពោះ រៀននៃសត្វជ្រូក(TGE) បណ្តុំរោគសញ្ញានៃជំងឺទាក់ទងនឹងប្រព័ន្ធបន្តពូជនិងប្រព័ន្ធផ្លូវដង្ហើមនៃសត្វជ្រូក(PRRS) ចំណែកឯបាក់តេរីដែលជាមេរោគបង្កជំងឺ រួមមាន ម៉ៃកូផ្លាស្មា(Mycoplasma) បាក់តេរីក្នុងពោះវៀនធំ(Escherichia coli) បាក់តេរីរាងមូលតជាខ្សែ(Streptococcus) ហើយសម្រាប់មេរោគបង្កជំងឺជាប៉ារ៉ាស៊ីត ភាគច្រើនជាព្រូនចង្កឹះនៅក្នុងសត្វជ្រូក។

(4) ការគ្រប់គ្រងក្លិនស្អុយនិងការទុកដាក់កាកសំណល់សត្វនៅក្នុងរោងចិញ្ចឹមជ្រូក

ជ្រូកសម្រាប់បង្កាត់ពូជ បញ្ចេញលាមក 2~3គីឡូក្រាម និងទឹកនោម 5.5គីឡូក្រាមក្នុង1ថ្ងៃ ចំណែកឯជ្រូកចិញ្ចឹមបំប៉នវិញ បញ្ចេញលាមក 1.9គីឡូក្រាម និងទឹកនោម 3.5គីឡូក្រាមក្នុង1ថ្ងៃ។ ក្លិនអាក្រក់ដែលកើតចេញពីកាកសំណល់ទាំងនេះ បានធ្វើឲ្យមានករណីប្តឹងមិនពេញចិត្តច្រើនបំផុតថាជាការបំពុលបរិស្ថានដោយសារតែការ

ចិញ្ចឹមសត្វ និងធ្វើឲ្យមានការយល់ឃើញមិនល្អចំពោះរបរចិញ្ចឹមជ្រូក ហើយជាដើមហេតុដែលធ្វើឲ្យប៉ះពាល់ដល់ការបន្តទៅមុខនៃអាជីវកម្ម។ មិនត្រឹមតែប៉ុណ្ណោះទេ ដោយសារតែវាក៏ជះឥទ្ធិពលមិនល្អដល់សុខភាពរបស់មនុស្ស និងសត្វជ្រូក និងធ្វើឲ្យខូចបរិស្ថានដោយសារតែការទាក់ទាញនិងការកើនឡើងនៃសត្វល្អិតចង្រៃដូចជារុយជាដើម ដូច្នេះហើយ ចាំបាច់ត្រូវធ្វើការទប់ស្កាត់ការកើតឡើងនូវបញ្ហានេះ។

ក្លិនស្អុយនៅក្នុងរោងចិញ្ចឹមជ្រូកច្រើនកើតឡើងពីសារធាតុអាម៉ូញាក់និងសមាសធាតុស្ពាន់ធ័រដែលចេញពីលាមកនិងទឹកនោម បូករួមនឹងអាស៊ីតខ្លាញ់ផ្សេងៗដែលមានលក្ខណៈងាយហើរដូចជាអាស៊ីតប៊ុយទីរិច អាស៊ីតប្រូពីអូនិច អាស៊ីតអាសេទិចជាដើម។

សារធាតុទាំងនេះមានផលប៉ះពាល់ទៅដល់ទាំងជ្រូកនិងទាំងមនុស្សដែលគ្រប់គ្រងនៅទីនោះ ដូច្នេះ គេចាំបាច់ត្រូវចាត់វិធានការកាត់បន្ថយការកើតឡើងនៃសារធាតុទាំងនេះ។ ដើម្បីកាត់បន្ថយសារធាតុទាំងនេះ គេត្រូវបែងចែកលាមកនិងទឹកនោមចេញពីគ្នាតាមដែលអាចធ្វើទៅបានដោយមិនត្រូវប៉ះពាល់វត្ថុទាំងនេះដោយផ្ទាល់នោះទេ ដោយការបែងចែកបែបនេះគឺដើម្បីទប់ស្កាត់ប្រតិកម្មរវាងអង់ស៊ីមនៅក្នុងលាមកនិងទឹកនោម ។

គេចាំបាច់ត្រូវទុកដាក់លាមកនិងទឹកនោមផ្សេងពីគ្នាអោយបានសមស្រប ដោយជាទូទៅគេបញ្ជូនលាមកទៅមជ្ឈមណ្ឌលផលិតជីកំប៉ុស្ដ៏ ហើយគេបញ្ជូនទឹកនោមទៅមជ្ឈមណ្ឌលសម្អាតទឹកកខ្វក់។ ក្រៅពីនេះ គេក៏មានវិធីក្នុងការកម្ចាត់ល្បាយលាមកនិងទឹកនោមផងដែរ ដោយគេហៅល្បាយលាមកនិងទឹកនោមនេះថាភក់ល្បាប់។

ជីកំប៉ុស្ដ៏ ភាគច្រើនបំផុតគឺជាអតិសុខុមប្រាណ ហើយវាជាផលិតផលដែលអតិសុខុមប្រាណត្រូវការអុកស៊ីសែននៅក្នុងលាមក ធ្វើការបំលែងជាចំបងនូវសារធាតុសរីរាង្គដែលរលួយ រួចហើយបង្កើតចំនួនរបស់វា។ ដើម្បីធ្វើជីកំប៉ុស្ដ៏ ចាំបាច់ត្រូវរៀបចំបរិស្ថានឲ្យមានលក្ខណៈសមស្របសម្រាប់អតិសុខុមប្រាណដែលត្រូវការអុកស៊ីសែនជាចាំបាច់។

(5) អាកាសធាតុក្ដៅ និងអាកាសធាតុត្រជាក់

ក្រពេញញើសរបស់សត្វជ្រូកមានការអន់ថយ ហើយពិបាកក្នុងការបញ្ចេញកម្ដៅរាងកាយតាម ស្បែក។ ជាពិសេស ដោយសារតែរដូវក្ដៅនៅប្រទេសជប៉ុនមានសីតុណ្ហភាពខ្ពស់ ហើយមានសំណើមក៏ខ្ពស់ ដូច្នេះហើយ វាមិនអាចធ្វើការបញ្ចេញកម្ដៅបាន។ ដូច្នេះហើយ ចាំបាច់ត្រូវធ្វើការដកយកសំណើមចេញពីក្នុងរោងចិញ្ចឹមជ្រូកនៅក្នុងរដូវក្ដៅ ដោយប្រើប្រាស់កង្ហាល់ជាដើម។

បរិស្ថានដែលមានសីតុណ្ហភាពខ្ពស់ដោយសារតែអាកាសធាតុក្ដៅនៅរដូវក្ដៅ ជះឥទ្ធិពលអាក្រក់ដល់ជ្រូក សម្រាប់បង្កាត់ពូជជាពិសេស។ វាធ្វើឲ្យចំនួនមេជីវិតរបស់សត្វឈ្មោលមានការថយចុះ កម្លាំងរបស់មេជីវិតក៏ចុះខ្សោយ ហើយចំណង់ក្នុងការបន្តពូជក៏ថយចុះដែរ ចំណែកសត្វញីវិញ លទ្ធផលជារួមនៃការបង្កាត់ពូជមានការថយចុះ ដូចជាការបន្តពូជមានភាពយឺតយ៉ាវ កូនកើតមកស្លាប់ កូនកើតមកមានទម្ងន់ស្រាលបរិមាណទឹកដោះមានការថយចុះដោយសារតែចំណង់អាហាររបស់វាថយចុះ។

ករណីជ្រូកចិញ្ចឹមបំប៉នវិញ ធ្វើឲ្យចំណង់អាហាររបស់វាមានការថយចុះ ដែលធ្វើឲ្យប៉ះពាល់ដល់ លទ្ធផលកើនទម្ងន់របស់វា។ ករណីដែលសីតុណ្ហភាពឡើងខ្លាំង អាចធ្វើឲ្យមានករណីស្លាប់ដោយសារតែជំងឺគ្រុនក្ដៅ (hyperthermia) ផងដែរ។

ផ្ទុយទៅវិញ នៅរដូវរងា ដោយសារតែសីតុណ្ហភាព និងអាកាសធាតុចុះត្រជាក់ ការបញ្ចេញកម្ដៅពីក្នុងខ្លួនគឺធ្វើឡើងហួសកម្រិត ខុសពីរដូវក្ដៅ។ ដូច្នេះហើយ នៅរដូវរងា ត្រូវប្រុងប្រយ័ត្នក្នុងការគ្រប់គ្រង សីតុណ្ហភាពនៅក្នុងរោងចិញ្ចឹមជ្រូក ជាពិសេសគឺគ្រប់គ្រងសីតុណ្ហភាពរបស់កូនជ្រូកដែលចាញ់អាកាសធាតុត្រជាក់។

4 ការចិញ្ចឹមមាន់

① មាន់ចិញ្ចឹមយកស៊ុត

1 ពូជមាន់ចិញ្ចឹមយកស៊ុត

នៅប្រទេសជប៉ុន ពូជមាន់ដែលគេចិញ្ចឹមសម្រាប់យកស៊ុត និងជាពូជដែលគេនិយមចិញ្ចឹមជាទូទៅជាងគេនោះ គឺពូជមាន់លឺហ្គានពណ៌សដែលមានសិរទោល (ប្រទេសកណើត គឺអ៊ីតាលី)។ សម្រាប់មាន់យកពងដែលផ្តល់ស៊ុតពណ៌ស គេច្រើនចិញ្ចឹមពូជមាន់លឺហ្គានពណ៌សនេះ ក៏ដូចជាមាន់បង្កាត់ពីពូជលឺហ្គាននេះផងដែរ។ ក្រៅពីនេះ សម្រាប់មាន់យកពងដែលផ្តល់ស៊ុតពណ៌ត្នោត គេច្រើនចិញ្ចឹមមាន់រ៉ូតអាយឡេនក្រហម (ប្រទេសកណើត គឺអាមេរិច) ឬមាន់បង្កាត់ពូជរបស់វា ហើយគេក៏ចិញ្ចឹមប្រភេទ (ពូជមាន់) ដែលផ្តល់ស៊ុតមានពណ៌កណ្តាលនៃពណ៌សនិងពណ៌ត្នោតផងដែរ។



ពូជលឺហ្គានពណ៌សមានសិរទោល

ពូជរ៉ូតអាយឡេនក្រហម

2 ទំហំនៃការចិញ្ចឹមមាន់យកស៊ុត និងទម្រង់នៃអាជីវកម្ម

គិតត្រឹមថ្ងៃទី1 ខែកុម្ភៈ ឆ្នាំ2018 មាន់ចិញ្ចឹមដែលជាមាន់ញីពេញវ័យមានចំនួន 139,030,000 ក្បាល ហើយចំនួននេះមិនមានការប្រែប្រួលខ្លាំងក្លាប៉ុន្មានទេក្នុងរយៈពេល20ឆ្នាំនេះ។ គ្រួសារដែលចិញ្ចឹមមាន់យកស៊ុតមានចំនួន 2,200គ្រួសារ ហើយមានការថយចុះជារៀងរាល់ឆ្នាំ ក្នុងចំណោមស្រទាប់អាជីវកម្មខ្នាតតូច។

ក្នុងចំណោមអាជីវកម្មចិញ្ចឹមមាន់យកស៊ុត អាជីវកម្មគ្រួសារកសិករមានចំនួន 75% ហើយអាជីវកម្មក្រុមហ៊ុនមានចំនួន 25%។ ចំពោះអាជីវកម្មក្រុមហ៊ុន ចំនួនគ្រួសារដែលចិញ្ចឹមមាន់មានចំនួនតិច ប៉ុន្តែធ្វើការចិញ្ចឹមមាន់ចំនួនប្រហែល 70%នៃចំនួនមាន់ចិញ្ចឹមទាំងអស់។ ភាគច្រើននៃអាជីវកម្មក្រុមហ៊ុន គឺជាសហគ្រាសបុគ្គល ឬសហគ្រាសគ្រួសារ។

ទម្រង់នៃអាជីវកម្ម មានដូចជាអាជីវកម្មដែលនាំចូលនូវកូនមាន់មធ្យម ឬកូនមាន់ធំ ហើយគ្រប់គ្រងលើមាន់ពេញវ័យជាចំបង ដោយប្រគល់ឲ្យកសិករចិញ្ចឹមកូនមាន់ធ្វើការចិញ្ចឹមកូនមាន់ និងអាជីវកម្មដែលគ្រប់គ្រងជារួមចាប់ពីការចិញ្ចឹមកូនមាន់រហូតដល់មាន់ពេញវ័យនៅក្នុងកសិដ្ឋានរបស់ខ្លួន។

3 វដ្តជីវិតនៃមាន់ចិញ្ចឹមយកស៊ុត

ប្រសិនបើគេចិញ្ចឹមដោយយកចិត្តទុកដាក់ សត្វមាន់អាចរស់បានពី5ឆ្នាំទៅ15ឆ្នាំ។ រូបគំនូសខាងក្រោមបង្ហាញអំពីវដ្តជីវិតនៃមាន់ចិញ្ចឹមយកស៊ុត ដោយផ្អែកលើការផលិតស៊ុតលក្ខណៈសដ្ឋកិច្ច។ ប្រសិនបើគេកម្តៅស៊ុតពូជ(ស៊ុតដែលមានការបង្កកំណើត)របស់មាន់ក្រោមល័ក្ខខ័ណ្ឌសីតុណ្ហភាពនិងសំណើមសមស្រប ស៊ុតនឹងញាស់ក្លាយជាកូនមាន់នៅថ្ងៃទី21។ កូនមាន់ញីនឹងក្លាយជាមាន់ពេញវ័យក្នុងរយៈពេល150ថ្ងៃ ហើយអាចចាប់ផ្តើមផលិតស៊ុតបាន(ហៅថាការចាប់ផ្តើមផលិតស៊ុត)។ ហើយនៅប្រហែលជាថ្ងៃទី210ក្រោយកើត គឺជាដំណាក់កាលដែលមាន់អាចពងបានច្រើនបំផុត(ចំណុចកំពូលនៃការផលិតស៊ុត)។ បន្ទាប់ពីនោះរយៈពេលប្រហែល1ឆ្នាំឬ1ឆ្នាំកន្លះ មាន់នៅតែអាចផលិតស៊ុតបាន ប៉ុន្តែ វានឹងចាប់ផ្តើមលែងពងវិញ ដូច្នេះ ក្រោយរយៈពេល2ឆ្នាំ គេនឹងបញ្ចេញមាន់ទាំងនោះយកទៅធ្វើជាសាច់កែច្នៃ(មាន់បញ្ចេញចោល)។



វដ្តជីវិតនៃមាន់ចិញ្ចឹមយកស៊ុត

4 ចំណីសត្វ និងទម្រង់នៃការផលិត ការទិញ និងការផ្តល់ចំណី

ដើម្បីធ្វើការចិញ្ចឹមមាន់ កសិដ្ឋានចិញ្ចឹមមាន់ភាគច្រើន ប្រើប្រាស់ចំណីលាយលក់នៅតាមទីផ្សារដែលត្រូវបានផ្សំឡើងដោយវត្ថុធាតុដើមមួយចំនួន ឲ្យសមស្របទៅនឹងតម្រូវការប្រើប្រាស់ និងដំណាក់កាលនៃការរីកធំធាត់។

វត្ថុធាតុដើមដូចជាពោត ស្មៅធញ្ញជាតិ កាកសំណល់សណ្តែកសៀងជាដើម ភាគច្រើនត្រូវបាននាំចូលមកពីបរទេស។

អ្នកផលិតចំណីសត្វ ដាក់លក់នូវផលិតផលផ្សំ ឬលាយផ្សេងៗជាច្រើន ប៉ុន្តែបច្ចុប្បន្ន ចំណីលាយសម្រាប់ចិញ្ចឹមមាន់ដែលផលិតនៅក្នុងប្រទេសជប៉ុន គឺមានការកើនឡើងច្រើន ហើយកាន់កាប់រហូតដល់ 42% នៃបរិមាណផលិតផលចំណីលាយទាំងមូល។

នៅក្នុងចំណោមចំណីលាយសម្រាប់ចិញ្ចឹមមាន់ ចំណីសត្វមាន់ពេញវ័យប្រើសម្រាប់មាន់យកស៊ុត មាន58.2% ចំណែកចំណីសម្រាប់កូនមាន់ មាន7.8%។ ហើយ 66% នៃចំណីលាយសម្រាប់ចិញ្ចឹមមាន់ គឺប្រើសម្រាប់មាន់យកស៊ុត។

ចំណីលាយដែលគេអភិវឌ្ឍដោយខ្លួនឯងសម្រាប់ប្រើនៅក្នុងកសិដ្ឋានចិញ្ចឹមមាន់ ដោយមិនពឹងផ្អែកលើផលិតផលរបស់អ្នកផលិតចំណីសត្វ គេហៅថា ចំណីលាយដោយខ្លួនឯង។

នៅក្នុងចំណីលាយសម្រាប់មាន់ពេញវ័យ មានផ្ទុកប្រភេទធញ្ញជាតិដូចជាពោតនិងស្រូវធញ្ញជាតិជាដើមដែលជាប្រភពថាមពល 60% ប្រភេទកាកសំណល់ប្រេងរុក្ខជាតិដូចជាសណ្តែកសៀងដែលជាប្រភពប្រូតេអ៊ីន 15% មានផ្ទុកប្រភេទចំណីផលិតពីសាច់សត្វដូចជាម្សៅផលិតពីត្រីជាដើម 10% និងមានផ្ទុកប្រភេទកន្ទក់កិនដូចជាកម្ទេចពោត 5% ប្រភេទសារធាតុអសរីរាង្គនិងវីតាមីន 10%។ ភាគរយផ្សំនៃសារធាតុចិញ្ចឹម វត្ថុធាតុដើម និងសារធាតុផ្សំផ្សេងៗ អាចប្រែប្រួលទៅតាមពូជ អាយុ និងបរិស្ថាននៃការចិញ្ចឹមសត្វមាន់។

5 ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងការចិញ្ចឹមសត្វ

(1) ការគ្រប់គ្រងអនាម័យ

គេចាត់វិធានការម៉ត់ចត់លើការរក្សាអនាម័យដើម្បីបង្ការជំងឺ។ ដំបូងគឺគេធ្វើការទប់ស្កាត់កុំអោយមេរោគជ្រៀតចូលទៅក្នុងតំបន់គ្រប់គ្រងការចិញ្ចឹមសត្វ ហើយបន្ទាប់មក គេធ្វើការកែលម្អបរិស្ថាននៃតំបន់ចិញ្ចឹមសត្វដែលមិនល្អ។ គេចាំបាច់ត្រូវកំណត់តំបន់គ្រប់គ្រងអនាម័យ និង ធ្វើការទប់ស្កាត់កុំអោយមានការនាំចូលមេរោគចូលទៅក្នុងតំបន់នោះ ដោយអនុវត្តទៅតាមបទដ្ឋានគ្រប់គ្រង អនាម័យក្នុងការចិញ្ចឹមសត្វដែលមានរៀបរាប់នៅក្នុងច្បាប់ស្តីអំពីការបង្ការជំងឺឆ្លងនៅលើសត្វចិញ្ចឹម។

នៅពេលរោងចិញ្ចឹមមាន់មានទំហំកាន់តែធំ ហើយការចិញ្ចឹមមាន់មានចំនួនកាន់តែច្រើន ការគ្រប់គ្រងសុខភាពរាងកាយរបស់មាន់ និង ការគ្រប់គ្រងអនាម័យមានដូចជាការរៀបចំបរិស្ថាន ការកម្ចាត់លាមកនិងការបោសសម្អាតនៅក្នុងរោងចិញ្ចឹមមាន់ជាដើមងាយនឹងមានលក្ខណៈមិនគ្រប់គ្រាន់ ដូច្នេះ គេចាំបាច់ត្រូវធ្វើការកម្ចាត់មូលហេតុនៃជំងឺនិងផលប៉ះពាល់ផ្សេងៗដោយចាត់វិធានការយ៉ាងម៉ត់ចត់។

[1] ការគ្រប់គ្រងអនាម័យនៅរោងចិញ្ចឹមមាន់និងអគារផ្សេងៗទៀត

ការចាត់វិធានការម៉ត់ចត់ក្នុងការកម្ចាត់លាមក ការបោសសម្អាត ការលាងសម្អាត និង ការសម្លាប់មេរោគ។

[2] ការគ្រប់គ្រងសុខភាពរាងកាយរបស់មាន់

គេចាំបាច់ត្រូវប្រុងប្រយ័ត្នចំពោះជំងឺទាក់ទងនឹងផ្លូវដង្ហើមដែលកើតឡើងដោយសារបម្រែបម្រួលបរិស្ថាន។

ចំពោះជំងឺដែលងាយរាតត្បាត គេត្រូវបង្កើតកម្មវិធីចាក់វ៉ាក់សាំង និង អនុវត្តការចាក់វ៉ាក់សាំងទាំងនោះនៅលើមាន់អោយបានត្រឹមត្រូវ។

(2) ជំងឺផ្តាសាយបក្សី

ការតាមដានព័ត៌មានថ្មីៗបំផុតទាក់ទងនឹងការទប់ស្កាត់ជំងឺរាតត្បាតលើសត្វចិញ្ចឹមគឺមានសារៈសំខាន់ណាស់ជាពិសេសព័ត៌មានពីមជ្ឈមណ្ឌលថែរក្សាអនាម័យនិងសុខុមាលភាពសត្វចិញ្ចឹមទាក់ទងនឹងវីរុសផ្តាសាយបក្សីដែលមានលទ្ធភាពបង្កអោគខ្ពស់ គឺត្រូវតាមដានជានិច្ច ព្រមទាំងត្រូវធ្វើតាមការណែនាំរបស់មជ្ឈមណ្ឌលថែរក្សាអនាម័យនិងសុខុមាលភាពសត្វចិញ្ចឹម។ នៅតំបន់ចិញ្ចឹមសត្វ ត្រូវបំពាក់សំណាញ់រារាំងសត្វស្លាបជាដើមនៅរោងចិញ្ចឹមមាន់ដើម្បីទប់ស្កាត់ការឈ្លានពានចូលនៃសត្វស្លាបព្រៃ និងត្រូវតាមដានស្ថានភាពសុខភាពរបស់មាន់ ហើយនៅពេលប្រទះឃើញភាពខុសប្រក្រតីនិងរោគសញ្ញាមួយចំនួន ត្រូវធ្វើការរាយការណ៍ជាបន្ទាន់។ ម្យ៉ាងទៀត វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ដំណឹងដល់អ្នកគ្រប់គ្រងជាបន្ទាន់ នៅពេលប្រទះឃើញសាកសពនៃសត្វស្លាបព្រៃជាដើមស្ថិតនៅជិតរោងចិញ្ចឹមមាន់ ។

② មាន់ចិញ្ចឹមយកសាច់

1 ប្រភេទមាន់ចិញ្ចឹមយកសាច់

មាន់ចិញ្ចឹមយកសាច់ មានមាន់ខ្ចីសម្រាប់យកសាច់ (ពូជប្រយ៉ឺ) ដែលឆាប់ធំធាត់ និងដែលត្រូវបានកែលម្អ ឲ្យប្រសើរខ្លាំងដើម្បីឲ្យឆាប់មានសាច់និងដើម្បីអាចដាក់លក់នៅក្នុងទីផ្សារក្នុងរយៈពេលខ្លី វាកាន់កាប់លើស 85% នៃមាន់ចិញ្ចឹមយកសាច់។ មាន់ប្រភេទនោះ គឺជាមាន់ក្នុងបម្រើបម្រាស់នៃប្រភេទមាន់បង្កាត់ជំនាន់ទី1 ដែលត្រូវ បានបង្កាត់ពូជរវាងមាន់ឈ្មោលប្រភេទខ្ចីនសពណ៌សជាមួយនឹងមាន់ញីប្រភេទភ្លីមៅរ៉ក់ពណ៌ស។ មាន់តំបន់ មាន អត្រាកាន់កាប់ជាមាន់យកសាច់តិចតួចត្រឹមតែ 1%ប៉ុណ្ណោះ ប៉ុន្តែវាជាប្រភេទមាន់យកសាច់ដែលមានគុណភាព ខ្ពស់ ដែលត្រូវបានផលិតឡើងធ្វើជាប្រភេទមាន់បង្កាត់ពូជដែលគេប្រើប្រាស់ប្រភេទផ្សេងៗដូចជា មាន់ជល់ ប្រភេទណាហ្គោយ៉ា ប្រភេទរ៉ូតអាយឡេនក្រហមជាដើម។

ខ្ចីនសពណ៌ស

ភ្លីមៅរ៉ក់ពណ៌ស។

2 ទំហំនៃការចិញ្ចឹមមាន់ខ្ចីយកសាច់ (ប្រយ៉ឺ) និងទម្រង់នៃអាជីវកម្ម

គិតត្រឹមថ្ងៃទី1 ខែកុម្ភៈ ឆ្នាំ2018 គ្រួសារដែលចិញ្ចឹមមាន់មានចំនួន 2,260គ្រួសារ ហើយមាន់ចិញ្ចឹមមានចំនួន 138,770,000ក្បាល ដូច្នេះ ចំនួនមាន់ដែលគ្រួសារនីមួយៗចិញ្ចឹម គឺមានចំនួន 61,400ក្បាល។ ចំនួនមាន់ដែល គ្រួសារនីមួយៗចិញ្ចឹម គឺមានការកើនឡើងជារៀងរាល់ឆ្នាំ ហើយការពង្រីកទំហំអាជីវកម្មកំពុងតែរីកចម្រើនទៅមុខ ឆ្ពោះទៅរកអាជីវកម្មដែលមានប្រសិទ្ធិភាពជាងមុន។

ពូជមាន់ប្រយ៉ឺភាគច្រើន ត្រូវបានគេធ្វើសមាហរណកម្មគ្រប់ដំណាក់កាលចាប់តាំងពីការចិញ្ចឹម ការទុកដាក់ រហូតដល់ការធ្វើចរាចរ បន្ទាប់មកចុះកិច្ចសន្យាចិញ្ចឹមជាមួយនឹងកសិករទាំងឡាយ ដោយក្រុមហ៊ុនជួញដូរទំនិញ គ្រប់មុខ សមាគមន៍សហប្រតិបត្តិការខាងវិស័យកសិកម្ម និងបុគ្គលជាចំបង។ ម៉្យាងវិញទៀត ដោយសារតែការរីក ចម្រើនយ៉ាងខ្លាំងនៃហាងលក់ទំនិញក្នុងចំនួនច្រើន (Mass retailer) ដូចជាផ្សារទំនើបជាដើម អ្នកធ្វើចរាចរសត្វ មាន់ប្រយ៉ឺ ក៏ត្រូវបានគេមើលឃើញថា បានធ្វើការផលិតពូជមាន់ប្រយ៉ឺ ហើយបានចាប់យករបៀបនៃការធ្វើស មាហរណកម្មការងារទាំងមូលផងដែរ។

3 វដ្តជីវិតនៃមាន់ខ្ចីយកសាច់ (ប្រយ៉ឺ)

រូបគំនូសខាងក្រោមបង្ហាញអំពីវដ្តជីវិតនៃមាន់ខ្ចីយកសាច់ (ប្រយ៉ឺ) ដែលគេប្រើប្រាស់សាច់វាធ្វើជា អាហា រ។ កូនមាន់ ដែលញាស់ចេញមកមានទំហំតូច គេអាចយកវាទៅដាក់លក់នៅលើទីផ្សារបានក្រោយពេលចិញ្ចឹមវារ យៈពេលប្រហែល 7សប្តាហ៍ ដោយមានទម្ងន់ប្រហែល 2.3គីឡូក្រាម។ ចំពោះកូនមាន់ដែលញាស់ចេញមកមាន

ទំហំធំ គេអាចយកវាទៅដាក់លក់នៅលើទីផ្សារបានក្រោយពេលចិញ្ចឹមវាយៈពេលប្រហែល 8សប្តាហ៍ ដោយមានទម្ងន់ប្រហែល 3.0គីឡូក្រាម។ ករណីមាន់តំបន់វិញ ចាំបាច់ត្រូវចិញ្ចឹមយ៉ាងហោចណាស់រយៈពេល 80ថ្ងៃ ហើយភាគច្រើនគេចិញ្ចឹមវាក្នុងរយៈពេល4~5ខែ ទើបយកវាទៅដាក់លក់នៅលើទីផ្សារ គឺដើម្បីឲ្យសាច់របស់វាមានរស់ជាតិឆ្ងាញ់ និងស្វិត។



វដ្តជីវិតនៃមាន់ខ្ចីយកសាច់

4 ចំណីសត្វ និងទម្រង់នៃការផលិត ការទិញ និងការផ្តល់ចំណី

នៅក្នុងការចិញ្ចឹមមាន់ប្រយឡឺ ករណីដែលគេប្រើប្រាស់ចំណីលាយដែលលក់នៅតាមទីផ្សារដែលត្រូវបានផ្សំឡើងដោយវត្ថុធាតុដើមមួយចំនួន ឲ្យសមស្របទៅនឹងដំណាក់កាលនៃការរីកធំធាត់ គឺស្ទើរតែទាំង ស្រុង។ អ្នកផលិតចំណីសត្វ ដាក់លក់នូវផលិតផលលាយផ្សេងៗជាច្រើន។ បច្ចុប្បន្ន ចំណីលាយសម្រាប់ចិញ្ចឹមមាន់ប្រយឡឺដែលផលិតនៅក្នុងប្រទេសជប៉ុន គឺមាន 14% នៃបរិមាណផលិតទាំងមូលនៃចំណីលាយ ហើយវាកាន់កាប់ 34% នៃចំណីលាយសម្រាប់ចិញ្ចឹមមាន់ (កាន់កាប់ 42%នៃចំណីលាយទាំងមូល)។

នៅក្នុងចំណីលាយសម្រាប់មាន់ប្រយឡឺ មានផ្ទុកច្រើនជាងគេបំផុតនូវប្រភេទធញ្ញជាតិដូចជាពោតនិងស្រូវធញ្ញជាតិជាដើមដែលជាប្រភពថាមពល ហើយមានផ្ទុកប្រភេទកាកសំណល់ប្រេងរុក្ខជាតិដូចជាសណ្តែកសៀងជាដើមដែលជាប្រភពប្រូតេអ៊ីន និងចំណីផលិតពីសាច់សត្វដូចជាម្សៅផលិតពីត្រីជាដើម។ ក្រៅពីនេះវាមានផ្ទុកប្រភេទកន្ទក់កិនដូចជាកម្ទេចពោតជាដើម ប្រភេទសារធាតុអសរីរាង្គ និងវីតាមីន។ ភាគរយផ្សំនៃសារធាតុចិញ្ចឹម វត្ថុធាតុដើម និងសារធាតុផ្សំផ្សេងៗ អាចប្រែប្រួលទៅតាមពូជ អាយុ និងបរិស្ថាននៃការចិញ្ចឹមសត្វមាន់។

5 ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងការចិញ្ចឹមសត្វ

(1) ការគ្រប់គ្រងអនាម័យ

គេចាត់វិធានការម៉ត់ចត់លើការរក្សាអនាម័យដើម្បីបង្ការជំងឺ។ ដំបូង គេធ្វើការទប់ស្កាត់កុំឲ្យ មេរោគជ្រៀតចូលទៅក្នុងតំបន់គ្រប់គ្រងការចិញ្ចឹមសត្វ ហើយបន្ទាប់មក គេធ្វើការកែលម្អបរិស្ថាននៃតំបន់ចិញ្ចឹមសត្វដែលមិនល្អ។ គេចាំបាច់ត្រូវកំណត់តំបន់គ្រប់គ្រងអនាម័យ និងធ្វើការទប់ស្កាត់កុំឲ្យមានការនាំចូលមេរោគចូលទៅក្នុងតំបន់នោះ ដោយអនុវត្តទៅតាមបទដ្ឋានគ្រប់គ្រង អនាម័យក្នុងការចិញ្ចឹមសត្វដែលមានការរៀបរាប់នៅក្នុងច្បាប់ស្តីអំពីការបង្ការជំងឺឆ្លងនៅលើសត្វចិញ្ចឹម។

ការកែលម្អប្រភេទមាន់ចិញ្ចឹមពូជប្រយឡឺ គឺមានលក្ខណៈគួរឲ្យសម្គាល់ ជាពិសេសលទ្ធភាពកើនទម្ងន់របស់វា គឺមានលក្ខណៈប្រសើរឡើងៗ។ ការចិញ្ចឹមមាន់ក្នុងចំនួនច្រើនគឺជារឿងធម្មតា ហើយរយៈពេលនៃការចិញ្ចឹមក៏ខ្លីដែរ ប៉ុន្តែវាក៏មានទំនោរទៅរកភាពយឺតយ៉ាវក្នុងការដោះស្រាយបញ្ហានៅក្នុងការគ្រប់គ្រងផងដែរ។ ដូច្នេះហើយ នៅក្នុងការគ្រប់គ្រងការចិញ្ចឹមមាន់ជាប្រចាំថ្ងៃ ចាំបាច់ត្រូវលុបបំបាត់ឲ្យបាននូវកត្តាផ្សេងៗដែលបង្កជាគ្រោះថ្នាក់ ឬឥទ្ធិពលអាក្រក់។

[1] ការគ្រប់គ្រងអានាម័យនៅក្នុងអគារ

នៅក្នុងរោងមាន់ ត្រូវចាត់វិធានការឲ្យបានម៉ត់ចត់ក្នុងការកម្ចាត់លាមក ការបោសសម្អាត ការលាងសម្អាត និងការសម្លាប់មេរោគ ដើម្បីកុំឲ្យអតិសុខុមប្រាណដែលជាដើមហេតុនៃជំងឺ សត្វល្អិតដែលបង្កគ្រោះថ្នាក់ ឬសាធាតុប្រឆាំងមេរោគ មាននៅសេសសល់។

[2] ការគ្រប់គ្រងសុខភាពរាងកាយរបស់មាន់

ត្រូវប្រុងប្រយ័ត្នចំពោះជំងឺទាក់ទងនឹងផ្លូវដង្ហើម ដោយមិនត្រូវធ្វេសប្រហែសក្នុងការគ្រប់គ្រងការផ្លាស់ប្តូរខ្យល់ឡើយ ចំពោះមាន់ប្រយឡឺដែលរីកធំធាត់លឿន។

ចំពោះជំងឺដែលងាយរាតត្បាត គេចាំបាច់ត្រូវបង្កើតកម្មវិធីចាក់វ៉ាក់សាំង និងអនុវត្តការចាក់វ៉ាក់សាំងទាំងនោះនៅលើមាន់ឲ្យបានត្រឹមត្រូវ។

(2) វិធានការចំពោះជំងឺផ្តាសាយបក្សី

គេចាំបាច់ត្រូវធ្វើការទប់ទល់ដូចគ្នាទៅនឹងមាន់ចិញ្ចឹមយកស៊ុតផងដែរ (ទំព័រ21)។

5 ផ្សេងៗ

① សេះទម្ងន់ស្រាល

1 សេះទម្ងន់ស្រាល (ប្រភេទពូជសុទ្ធ)

· សេះទម្ងន់ស្រាល មាន 5ប្រភេទ គឺសេះប្រភេទពូជសុទ្ធ សេះប្រភេទកូនកាត់ពូជសុទ្ធ សេះប្រភេទពូជអារ៉ាប់ សេះប្រភេទពូជអង់គ្លូអារ៉ាប់ និងសេះប្រភេទកូនកាត់អារ៉ាប់ ប៉ុន្តែ សេះទម្ងន់ស្រាលដែលគេផលិតនៅក្នុងប្រទេសជប៉ុនស្ទើរតែទាំងអស់ គឺជាសេះប្រភេទពូជសុទ្ធ។

· ចំនួននៃការផលិតសេះពូជសុទ្ធប្រចាំឆ្នាំ គឺប្រហែល7,000ក្បាល (ឆ្នាំ2018) ហើយតំបន់ផលិតជាចំបង មាន ហុកកៃដូ តូហុគឺ និងឃ្យូស៊ូ។ ក្នុងចំណោមតំបន់ទាំងអស់ ហុកកៃដូកាន់កាប់ចំនួននៃការផលិតលើសពី98%។

· សេះប្រភេទពូជសុទ្ធស្ទើរតែទាំងអស់ ត្រូវបានគេយកទៅប្រើប្រាស់ក្នុងការប្រណាំងសេះ បន្ទាប់ពីទទួលបានការបង្វឹកសម្រាប់រត់ប្រណាំងរួចហើយ។

· សេះប្រភេទពូជសុទ្ធដែលគេយកទៅរត់ប្រណាំង គឺមានតែសេះដែលគេផលិតឡើងដោយបង្កាត់ពូជតាមបែបធម្មជាតិតែប៉ុណ្ណោះ។

សេះដែលត្រូវបានផលិតដោយការបង្កកំណើតសិប្បនិម្មិត គឺមិនអាចយកទៅប្រើប្រាស់ក្នុងការរត់ប្រណាំងបានទេ។

· សេះពូជសុទ្ធ គឺជាសេះដែលពូជពង្សរបស់វាត្រូវបានគេគ្រប់គ្រងយ៉ាងតឹងរឹង តាមរយៈការចុះបញ្ជីពូជពង្ស។ មានតែសេះដែលកើតពីសេះបា (សេះឈ្មោលសម្រាប់បង្កាត់ពូជ) និងសេះមេ (សេះញីសម្រាប់បង្កាត់ពូជ) ដែលបានចុះបញ្ជីតែប៉ុណ្ណោះ ដែលអាចទទួលបានការចុះបញ្ជីពូងពង្ស។

ស្ថាប័នចុះបញ្ជី ធ្វើការចេញលិខិតបញ្ជាក់ការចុះបញ្ជីពូជពង្ស ចំពោះសេះដែលទទួលបានការចុះបញ្ជីពូជពង្ស។

2 វដ្តជីវិត

· របៀបហៅអាយុរបស់សេះគឺពិសេសប្លែកពីគេគឺ ឆ្នាំដែលកើតគេហៅថាអាយុសូន្យឆ្នាំ ហើយចាប់ពីឆ្នាំទី២ឡើងទៅ គេហៅអាយុ1ឆ្នាំ 2ឆ្នាំ។

· រយៈពេលពពោះរបស់សេះប្រភេទពូជសុទ្ធនេះ គឺ11ខែ នៅប្រទេសជប៉ុនភាគច្រើនវាកើតកូននៅក្នុងចន្លោះខែកុម្ភៈ ដល់ខែឧសភា។

· គេចិញ្ចឹមកូនសេះជាមួយនឹងមេរបស់វាចាប់តាំងពីពេលវាកើតរហូតដល់រដូវក្តៅ ហើយគេផ្តាច់ដោះវានៅក្នុងរដូវស្លឹកឈើជ្រុះ (រយៈពេល 6ខែក្រោយកើត) បន្ទាប់មកគេចិញ្ចឹមតែកូនសេះប៉ុណ្ណោះ។

· នៅពេលដែលកូនសេះមានអាយុប្រហែល1ឆ្នាំនៅក្នុងរដូវស្លឹកឈើជ្រុះ គេនឹងបំពាក់គ្រឿងសេះដូចជាកែប និងបង្ខាំជាដើម ហើយចាប់ផ្តើមបង្វឹកវាឲ្យស៊ាំដោយឲ្យមនុស្សជិះនៅលើខ្នង (ការបន្សាំការជិះ)។

· ក្រោយពីបន្សាំការជិះរួចហើយ គេចាប់ផ្តើមបង្វឹក (ការបង្ហាត់) ឲ្យរត់ដោយឲ្យមនុស្សជិះពីលើខ្នងរបស់វាដើម្បីបង្កើនកម្លាំងឲ្យវា។

· សេះដែលមានអាយុ 2ឆ្នាំ ហើយដែលមានការរីកចម្រើនក្នុងការហ្វឹកហាត់ ត្រូវបានគេបញ្ជូនទៅកន្លែងរត់ប្រណាំង ឬមជ្ឈមណ្ឌលហ្វឹកហាត់ ហើយទទួលការចុះឈ្មោះជាសេះប្រណាំង បន្ទាប់មកទទួលការហ្វឹកហាត់បន្ថែមដើម្បីចេញទៅរត់ប្រណាំង។

· ក្នុងចំណោមសេះប្រណាំងទាំងឡាយដែលបានចូលនិវត្តន៍ ជាពិសេសសេះដែលមានលទ្ធផលល្អក្នុងការប្រកួត ឬសេះដែលមានពូជពង្សល្អ នឹងត្រូវបានគេបញ្ជូនទៅកន្លែងផលិតធ្វើជាសេះសម្រាប់ង្កាត់ពូជ។

① ការបង្កាត់ពូជ (ខែមីនា~ឧសភា)
(រយៈពេលពពោះ:11ខែ)

② ការបង្កើតកូន
(នៅក្នុងខែកុម្ភៈ~ឧសភា ឆ្នាំបន្ទាប់)

③ ការបំបៅដោះ
(~អាយុ 6ខែ)

④ រដូវស្លឹកឈើជ្រុះ ការផ្តាច់ដោះ
(ប្រហែលអាយុ5~6ខែ)

⑤ រដូវរងា~រដូវក្តៅ ព្រលែងជាមួយកូនសេះដូចគ្នា (ញីឈ្មោលដោយឡែកពីគ្នា)
(អាយុ6ខែ~1ឆ្នាំ នៅក្នុងរដូវក្តៅ)

⑥ អាយុ1ឆ្នាំ នៅក្នុងរដូវស្លឹកឈើជ្រុះ
ការបន្សាំការដិះ

⑦ អាយុ1ឆ្នាំ នៅក្នុងរដូវរងា~2ឆ្នាំ ការបង្ហាត់

⑧ អាយុ2ឆ្នាំ4ខែ~
ការបង្ហាញជាលើកដំបូងនៅក្នុងការរត់ប្រណាំង

⑨ ការចូលនិវត្តន៍ មួយចំនួនត្រូវបានយកទៅប្រើប្រាស់សម្រាប់បង្កាត់ពូជ

3 ទម្រង់អាជីវកម្មនៃវាលស្មៅ

នៅលើវាលស្មៅចិញ្ចឹមសេះទម្ងន់ស្រាល មានទម្រង់អាជីវកម្ម 2ប្រភេទជាចំបង។

- វាលស្មៅសម្រាប់ការផលិត

  គេចិញ្ចឹមសេះមេ ដើម្បីឲ្យវាបង្កើតកូន រួចយកទៅដាក់លក់នៅផ្សារដេញថ្លៃជាដើម។

- វាលស្មៅសម្រាប់ចិញ្ចឹមសត្វ

  គេអនុវត្តនូវការបង្ហាត់ ឬបន្សាំការជិះចំពោះសេះក្មេងៗ។

ប៉ុន្តែ វាលស្មៅ ដែលគេប្រើសម្រាប់ការផលិតនិងសម្រាប់ការចិញ្ចឹមសត្វរួមគ្នាក៏មានដែរ។

វាលស្មៅសម្រាប់ការផលិត

វាលស្មៅសម្រាប់ចិញ្ចឹមសត្វ

② ការចិញ្ចឹមឃ្មុំ

1 ប្រភេទនិងលក្ខណៈពិសេសនៃសត្វឃ្មុំ

(1) ប្រភេទ

នៅប្រទេសជប៉ុន សត្វឃ្មុំមាន2ប្រភេទ គឺសត្វឃ្មុំលោកខាងលិច និងសត្វឃ្មុំជប៉ុន ប៉ុន្តែសត្វឃ្មុំដែលគេចិញ្ចឹមទុកជាសត្វចិញ្ចឹមនោះ ភាគច្រើនជាសត្វឃ្មុំលោកខាងលិច (ខាងក្រោមនេះហៅថា សត្វឃ្មុំ)។

(2) លក្ខណៈពិសេស

សត្វឃ្មុំ រស់នៅផ្គុំគ្នាជាហ្វូង ហើយវាមានតួនាទីផ្សេងៗគ្នានៅក្នុងហ្វូងរបស់វា។

・ឃ្មុំកម្មករ (ញី)

ឃ្មុំកម្មករ ត្រូវបានចិញ្ចឹមនៅក្នុងរន្ធក្នុងសម្បុកឃ្មុំធម្មតា (បន្ទប់តូចដែលមានរាង6ជ្រុងដែលបង្កើតទៅជាសម្បុករបស់សត្វឃ្មុំ) របស់វា។ កូនឃ្មុំទើបញាស់ នៅក្នុងដំណាក់កាលដំបូងគេឲ្យសារធាតុចាហួយ(royal jelly) ដល់វាជាចំណី នៅដំណាក់កាលក្រោយមកគេឲ្យលំអងផ្កា និងទឹកឃ្មុំដល់វាជាចំណី ហើយវាក្លាយទៅជាឃ្មុំពេញវ័យនៅក្នុងរយៈពេលប្រហែល 21ថ្ងៃ។ អាយុរបស់វា (រយៈពេលរស់នៅ) មានរយៈពេលប្រហែល1ខែប៉ុណ្ណោះ ប៉ុន្តែនៅក្នុងអំឡុងពេលដែលរងានារដូវរងា មានសត្វឃ្មុំខ្លះអាចរស់រហូតបានជាងកន្លះឆ្នាំ។ ក្រោយពេលក្លាយទៅជាឃ្មុំពេញវ័យ ជាដំបូងវាធ្វើការងារសម្អាតរន្ធនៅក្នុងសម្បុកជាដើម បន្ទាប់មកវាធ្វើការចិញ្ចឹមកូនឃ្មុំដែលទើបញាស់ ចុងក្រោយវាហើរចេញពីសម្បុកដើម្បីទៅរកចំណីជាដើម (ក្រេបយកលំអងផ្កា ឬទឹកឃ្មុំរបស់ផ្កា)។

・រាជិនីឃ្មុំ (ញី)

រាជិនីឃ្មុំ ពេលទើបញាស់ត្រូវបានចិញ្ចឹមដោយត្រូវបានផ្តល់ឲ្យសារធាតុចាហួយតែប៉ុណ្ណោះធ្វើជាចំណីនៅក្នុងរន្ធពិសេសនៅក្នុងសម្បុកដែលគេហៅថាបន្ទប់ស្តេច។ រាជិនីឃ្មុំ ជាធម្មតានៅក្នុងឃ្មុំ1ហ្វូង មានតែ1ក្បាលប៉ុណ្ណោះ ហើយមានតួនាទីផលិតពងឃ្មុំតែប៉ុណ្ណោះ។ រាជិនីឃ្មុំមានទម្ងន់ធ្ងន់ជាងឃ្មុំកម្មករ ហើយមានអាយុ2~3ឆ្នាំ។

・ឃ្មុំឈ្មោល

ឃ្មុំឈ្មោលកើតនៅក្នុងអំឡុងពេលបន្តពូជរបស់រាជិនីឃ្មុំ (នៅប្រទេសជប៉ុន ពេលវេលាដែលសមស្រប គឺចាប់ពីខែមេសា~មិថុនា) នៅពេលនោះឃ្មុំកម្មកររនឹងធ្វើការរៀបចំបន្ទប់ជាពិសេសសម្រាប់ឃ្មុំឈ្មោលនៅក្នុងសម្បុករបស់វា។ ឃ្មុំឈ្មោលធ្វើការបន្តពូជជាមួយរាជិនីឃ្មុំនៅក្នុងអាកាស ដោយមិនបាច់ធ្វើការនៅក្នុងសម្បុកទេ។



រន្ធក្នុងសម្បុករបស់ឃ្មុំកម្មករ (បន្ទប់តូចពាង6ជ្រុង)



មួយជីវិតរបស់ឃ្មុំកម្មករ



មួយជីវិតរបស់រាជិនីឃ្មុំ និងឃ្មុំឈ្មោល

2 ខ្លឹមសារសកម្មភាពរបស់សត្វឃ្មុំក្នុងរយៈពេល1ឆ្នាំ

រដូវ	ខ្លឹមសារសកម្មភាព
រដូវផ្ការីក (ការកសាងសម្បុក)	ចាប់ពីរដូវផ្ការីករហូតដល់រដូវក្តៅ គឺជាអំឡុងពេលដែលផ្កាភាគច្រើនរីក ដូច្នេះ សត្វឃ្មុំចាប់ផ្តើមសកម្មភាពប្រមូលចំណី និងបង្កាត់ពូជ។ នៅពេលឃ្មុំមួយហ្វូងធំដល់កម្រិតមួយ វាចាប់ផ្តើមធ្វើបន្ទប់ស្តេច និងផលិតឃ្មុំឈ្មោលសម្រាប់បង្កាត់ពូជ។ ប៉ុន្មានថ្ងៃមុនពេលរាជិនីឃ្មុំថ្មីកើតនៅក្នុងបន្ទប់ស្តេច រាជិនីឃ្មុំចាស់នឹងចាកចេញពីសម្បុកជាមួយឃ្មុំកម្មករប្រហែលពាក់កណ្តាល រួចហើយទៅធ្វើសម្បុកថ្មីនៅកន្លែងផ្សេង។ គេហៅវាថា ការចែកហ្វូងឃ្មុំ។
រដូវក្តៅ (ការឆ្លងរដូវក្តៅ)	វាក្លាយជាពេលវេលាដ៏តឹងតែងសម្រាប់ឃ្មុំដោយសារតែផ្កាមានចំនួនតិចតួច លើកលែងតែខ្ពង់រាបដែលសម្បូរផ្កាប៉ុណ្ណោះ។ ដូច្នេះហើយ ឃ្មុំខ្លះបានគេចចេញពីប្រអប់សម្បុកលែងត្រឡប់មកវិញ ដើម្បីទៅស្វែងរកទឹកដីថ្មី។ គេហៅវាថា ការគេចពីកាតព្វកិច្ច។
រដូវស្លឹកឈើជ្រុះ	វាគឺជារដូវកាលដែលត្រូវស្តុកទឹកឃ្មុំ (ស្តុកទឹកឃ្មុំនៅក្នុងរន្ធក្នុងសម្បុក) ទុកឲ្យបានគ្រប់គ្រាន់មុនពេលរដូវរងាចូលមកដល់។ ហើយវាខិតខំប្រឹងប្រែងប្រមូលទឹកឃ្មុំ សូម្បីពីផ្កាដែលមនុស្សស្អប់ក្លិនរបស់វា។
រដូវរងា (ការឆ្លងរដូវរងា)	សត្វឃ្មុំ ប្រឹងប្រជ្រៀតគ្នានៅក្នុងសម្បុកដើម្បីទប់ទល់នឹងអាកាសធាតុត្រជាក់។ អំឡុងរដូវរងា ការផលិតពងឃ្មុំ និងការចិញ្ចឹមកូនត្រូវបានបញ្ឈប់ ប៉ុន្តែពេលដែលរដូវផ្ការីកខិតជិតមកដល់ ការផលិតពងឃ្មុំនឹងត្រូវបានចាប់ផ្តើមឡើងវិញ។ ហើយនៅក្នុងអំឡុងពេលនេះ មានឃ្មុំខ្លះដាច់ពោះស្លាប់ នៅពេលអស់ចំណី ដោយសារតែការស្តុកទឹកឃ្មុំទុកមិនបានគ្រប់គ្រាន់ ។



លំហូរសកម្មភាពក្នុងរយៈពេល1ឆ្នាំ និងចំនួនសត្វឃ្មុំនៅក្នុងប្រអប់សម្បុក

6 សំណួរសាកល្បង

ចូរឆ្លើយសំណួរខាងក្រោម ដោយគូសសញ្ញារង្វង់ ○ ប្រសិនបើជាប្រយោគត្រឹមត្រូវ ហើយគូសសញ្ញាខ្វែង × ប្រសិនបើជាប្រយោគខុស។

<គោ>

1. បរិមាណទឹកដោះជាមធ្យមក្នុង1ឆ្នាំផលិតដោយគោទឹកដោះនៅប្រទេសជប៉ុនគឺប្រហែល 5,000គីឡូក្រាម។ ... ( )
2. រយៈពេលពពោះរបស់ពូជគោហុលស្តាញគឺ280ថ្ងៃ។ ... ( )
3. គុណភាពទឹកដោះដែលបញ្ចេញដោយគោទឹកដោះគឺមានលក្ខណៈដូចគ្នាសម្រាប់គោទាំងអស់។ ... ( )
4. នៅក្រោមអាកាសធាតុក្តៅនៅក្នុងរដូវក្តៅ បរិមាណចំណីដែលគោទឹកដោះបរិភោគមានការថយចុះ ហើយបរិមាណទឹកដោះក៏ថយចុះទៅតាមនោះដែរ។ ... ( )
5. គេអាចយកកាកសំណល់សត្វដែលចេញពីរោងចិញ្ចឹមគោទៅទុកចោលនៅលើវាលស្មៅ។ ... ( )
6. គោចិញ្ចឹមយកសាច់ដែលគេចិញ្ចឹមនៅប្រទេសជប៉ុនទាំងអស់ គឺជាប្រភេទគោជប៉ុនរោមខ្មៅ។ ... ( )
7. នៅក្នុងអាជីវកម្មចិញ្ចឹមបំប៉នពូជគោជប៉ុនរោមខ្មៅ គេធ្វើការទិញចូលនូវគោដែលមានអាយុប្រហែល10 ខែពីទីផ្សារ ហើយធ្វើការចិញ្ចឹមបំប៉នរហូតដល់អាយុប្រហែល30ខែ។ ... ( )
8. ចំពោះគោចិញ្ចឹមបំប៉ន ភាគរយនៃការផ្គត់ផ្គង់ចំណីមិនកែច្នៃខ្ពស់ជាងចំណីជីវជាតិ(ចំណីលាយ)។ ... ( )

<សត្វជ្រូក>

1. ជ្រូកចិញ្ចឹមបំប៉ននៅប្រទេសជប៉ុន មានការធំធាត់លឿន ដោយត្រឹមតែរយៈពេល5~6ខែ ជ្រូកនឹងមានទម្ងន់100~110គីឡូក្រាម។ ... ( )
2. ជ្រូកមេនៅប្រទេសជប៉ុន អាចបង្កើតកូនបានប្រហែល5ក្បាលជាមធ្យមក្នុងមួយដង។ ... ( )
3. ជ្រូកមេដែលកើតកូនរួចត្រូវបានដាក់អោយស្ថិតនៅជាមួយកូនជ្រូករយៈពេល2ខែ។ ... ( )
4. នៅប្រទេសជប៉ុន គេអាចធ្វើអោយជ្រូកមេពពោះនិងបង្កើតកូនបាន4~5ដងក្នុងរយៈពេល2ឆ្នាំ។ ... ( )
5. នៅក្នុងកសិដ្ឋានចិញ្ចឹមជ្រូកនៅប្រទេសជប៉ុន គេមិនត្រូវការរ៉ាក់សាំងនោះទេ ដោយសារតែជំងឺមានចំនួនតិចតួច។ ... ( )

<សត្វមាន់>

1. ការលូតលាស់របស់កូនមាន់បែងចែកជា4ដំណាក់កាល គឺកូនមាន់តូច កូនមាន់មធ្យម កូនមាន់ធំ និង មាន់ពេញវ័យ។ ... ( )
2. សម្រាប់ចំណីរបស់មាន់ចិញ្ចឹមយកស៊ុត គេនិយមប្រើចំណីលាយច្រើនជាងគេ។ ... ( )
3. ទោះជាឆ្លងជំងឺផ្តាសាយបក្សីក៏ដោយ ក៏មាន់នឹងមិនងាប់នោះទេ។ ... ( )
4. ការធំធាត់នៃមាន់ចិញ្ចឹមយកសាច់ (ពូជប្រយុទ្ធ) មានលក្ខណៈយឺតជាងមាន់ចិញ្ចឹមយកស៊ុត។ ... ( )
5. មាន់ឈ្មោលនៃពូជមាន់ប្រយុទ្ធដែលមានអាយុ7សប្តាហ៍ មានទម្ងន់ប្រមាណ5គីឡូក្រាម។ ... ( )

ចម្លើយ

<គោ>

1. ×(ហេតុផល : នៅប្រទេសជប៉ុន បរិមាណទឹកដោះជាមធ្យមក្នុង1ឆ្នាំផលិតដោយគោទឹកដោះពូជហុលស្ដាញគឺលើសពី 8,000 គីឡូក្រាម។)
2. ○
3. ×(ហេតុផល : គុណភាពទឹកដោះនៃគោនីមួយៗមានលក្ខណៈខុសគ្នាពីមួយក្បាលទៅមួយក្បាល។)
4.
5. ×(ហេតុផល : ច្បាប់បានកំណត់ថាត្រូវធ្វើការទុកដាក់កាកសំណល់សត្វអោយបានត្រឹមត្រូវ ដូចជាយកទៅធ្វើជាជីកំប៉ុស្ដ៍ ជាដើម។)
6. ×(ហេតុផល : ក្រៅអំពីពូជគោជប៉ុន នៅមានគោក្រៀវនៃពូជគោទឹកដោះ និង ពូជគោបង្កាត់(F1) គឺមាន3ប្រភេទ។)
7. ○
8. ×(ហេតុផល : ចំណីសម្រាប់ដំណាក់កាលចិញ្ចឹមបំប៉ន គឺ ចំណីលាយមានភាគរយច្រើនជាង។)

<សត្វជ្រូក>

1. ○
2. ×(ហេតុផល : ជ្រូកមេនៅប្រទេសជប៉ុន អាចបង្កើតកូនបាន 10~15 ក្បាលជាមធ្យមក្នុងមួយដង។)
3. ×(ហេតុផល : រយៈពេលបំបៅដោះកូនជ្រូកគឺ 3~4 សប្ដាហ៍។)
4. ○
5. ×(ហេតុផល : នៅកសិដ្ឋានចិញ្ចឹមជ្រូកមានជំងឺគ្រប់ប្រភេទ ដូច្នេះ ចាំបាច់ត្រូវធ្វើការចាក់វ៉ាក់សាំងអោយបានត្រឹមត្រូវ។)

<សត្វមាន់>

1. ○
2. ○
3. ×(ហេតុផល : នៅពេលឆ្លងវីរុសដែលមានលទ្ធភាពបង្កអោគខ្ពស់ មាន់អាចងាប់ក្នុងអំឡុងពេល1សប្ដាហ៍។)
4. ×(ហេតុផល : លក្ខណៈពិសេសនៃមាន់ពូជប្រយុទ្ធគឺល្បឿននៃការធំធាត់របស់វាមានលក្ខណៈលឿនជាងមាន់ចិញ្ចឹមយកស៊ុត។)
5. ×(ហេតុផល : មាន់ឈ្មោលនៃពូជមាន់ប្រយុទ្ធដែលមានអាយុ7សប្ដាហ៍ មានទម្ងន់ប្រមាណ3.3គីឡូក្រាម។)

II

ចំណេះដឹងមូលដ្ឋានទាក់ទងនឹង ការចិញ្ចឹមសត្វនិងចំណីសត្វ

1 គោចិញ្ចឹមយកទឹកដោះ

1 លក្ខណៈពិសេសនៃគោទឹកដោះ

គោទឹកដោះគឺជាសត្វដែលមានអារម្មណ៍ការពារខ្លួនឯងខ្លាំង ហើយងាយប្រតិកម្ម ដូច្នេះ មនុស្សត្រូវប្រើឥរិយាបថទន់ភ្លន់នៅពេលធ្វើការជាមួយវា។

ពេលខ្លះ គោទឹកដោះចូលចិត្តស៊ីចំណីជីវជាតិជាងចំណីមិនកែច្នៃ បែបនេះគេហៅថា"ការរើសចំណី"។

ក្រោមអាកាសធាតុក្តៅនៅរដូវក្តៅ គោទឹកដោះបង្កើនការដកដង្ហើមរបស់វានិងបញ្ចេញចំហាយទឹក ដើម្បីទប់ស្កាត់ការកើនឡើងនៃសីតុណ្ហភាពក្នុងខ្លួនរបស់វា។

ជាធម្មតា គេវាស់សីតុណ្ហភាពក្នុងខ្លួនរបស់គោទឹកដោះដោយស៊កឧបករណ៍វាស់សីតុណ្ហភាពចូលទៅក្នុងរន្ធគូទរបស់វា។

ក្រោយពីបង្កើតកូនរួច បរិមាណទឹកដោះរបស់គោទឹកដោះនឹងមានការកើនឡើងបន្តិចម្តងៗ ហើយក្នុងរយៈពេល5~7សប្តាហ៍ បរិមាណទឹកដោះក្នុង1ថ្ងៃរបស់គោនឹងមានកម្រិតអតិបរមា ដោយមានគោខ្លះអាចផលិតទឹកដោះរហូតដល់ប្រមាណ50Kgក្នុង1ថ្ងៃ។

នៅប្រហែល60ថ្ងៃមុនដល់ពេលបង្កើតកូន គេនឹងបញ្ចប់(ផ្អាក)ការច្របាច់ទឹកដោះពីគោទឹកដោះ ដែលគេហៅថារយៈពេលផ្អាកការច្របាច់ទឹកដោះ។

2 រចនាសម្ព័ន្ធនៃរោងចិញ្ចឹមគោ

របៀបចិញ្ចឹមគោទឹកដោះ អាចជាការប្រលែងនៅលើវាលស្មៅ ហៅថា"ការចិញ្ចឹមដោយព្រលែង"ឬក៏ ការចិញ្ចឹមនៅក្នុងរោងចិញ្ចឹមគោ ហៅថា"ការចិញ្ចឹមក្នុងរោងចិញ្ចឹមសត្វ" ប៉ុន្តែ នៅប្រទេសជប៉ុន ភាគច្រើនគឺការចិញ្ចឹមក្នុងរោងចិញ្ចឹមសត្វ។

ការចិញ្ចឹមក្នុងរោងចិញ្ចឹមសត្វ បែងចែកជា3វិធីទៀត គឺ"ការចិញ្ចឹមដោយចង" "ការចិញ្ចឹមដោយគ្មានរបាំងខណ្ឌ" និង "ការចិញ្ចឹមដោយមានរបាំងខណ្ឌ"។

ការចិញ្ចឹមដោយចង សំដៅលើរបៀបចិញ្ចឹមដោយចងភ្ជាប់គោទឹកដោះនីមួយៗទៅនឹងសសរដោយប្រើរបងគោខ្សែ ឬ ច្រវាក់ជាដើម។

សម្រាប់ឧបករណ៍ផ្តល់ទឹក គេច្រើនប្រើផ្តិលទឹក។ គេធ្វើការច្របាច់ទឹកដោះនៅកន្លែងដែលគេចងគោទឹកដោះទាំងនោះតែម្តង ហើយទឹកដោះគោដែលច្របាច់បាននឹងហូរឆ្លងកាត់បំពង់បញ្ជូនទឹកដោះដែលស្ថិតនៅពីលើក្បាលគោ រួចហូរចូលក្នុងទូទឹកកក(ធុងរក្សាទឹកដោះអោយត្រជាក់)។

រោងចិញ្ចឹមគោដែលមានរបងគោ

ការចិញ្ចឹមដោយចងទម្រង់ញ៉ូវយ៉ក

ការច្របាច់ទឹកដោះនៅរោងចិញ្ចឹមគោដោយចង



ប្រព័ន្ធនៃការច្របាច់ទឹកដោះ

រោងចិញ្ចឹមគោគ្មានរបាំងខណ្ឌគឺជារបៀបចិញ្ចឹមដែលអនុញ្ញាតអោយគោអាចធ្វើចលនាដោយសេរី ដោយមិនមានការចងភ្ជាប់ នៅក្នុងទឹកន្លែងធំទូលាយមានរបងព័ទ្ធជុំវិញនិងមានដំបូល។ ដីត្រូវបានក្រាលដោយសម្ភារៈក្រាលពេញ លើកលែងតែកន្លែងផ្តល់ចំណី។ គេច្រើនប្រើកម្ទេចរណារ(កម្ទេចឈើ) ជីកំប៉ុស្តិ៍សម្រាប់ប្រើឡើងវិញ(ជីកំប៉ុស្តិ៍ដែលផ្អាប់និងសម្ងួតរួចរាល់) ធ្វើជាសម្ភារៈក្រាល។ សម្រាប់ឧបករណ៍ផ្តល់ទឹក គេច្រើនប្រើស្នូកដាក់ទឹក។ ហើយគេធ្វើការច្របាច់ទឹកដោះនៅទីកន្លែងផ្សេងហៅថាអគារច្របាច់ទឹកដោះ ។

រោងចិញ្ចឹមគោគ្មានរបាំងខណ្ឌ

អគារច្របាច់ទឹកដោះ

គ្រឿងយន្តច្របាច់ទឹកដោះ

រោងចិញ្ចឹមគោមានរបាំងខណ្ឌ គឺជារោងដែលមានបំពាក់របាំងដើម្បីខណ្ឌកន្លែងដេករបស់គោនីមួយៗ(កន្លែងគោដេក) ដូចបង្ហាញនៅក្នុងរូបភាពខាងក្រោម។ នេះគឺជាចំណុចដែលខុសគ្នាពីរោងចិញ្ចឹមគោគ្មានរបាំងខណ្ឌ។

ស្នូកដាក់ចំណីនៅក្នុងរោងចិញ្ចឹមគោមានរបាំងខណ្ឌ

កន្លែងដេកនៅក្នុងរោងចិញ្ចឹមគោមានរបាំងខណ្ឌ(កន្លែងគោដេក)

ទាំងរោងចិញ្ចឹមគោមានរបាំងខណ្ឌ ទាំងរោងចិញ្ចឹមគោគ្មានរបាំងខណ្ឌ អាចមានករណីដែលគោខ្សោយត្រូវបានគោខ្លាំងដេញចេញឆ្ងាយពីស្នូកដាក់ចំណី ធ្វើអោយបរិមាណស៊ីចំណីរបស់វាមានការថយចុះ។

3 សរីរាង្គរំលាយអាហារបស់គោទឹកដោះ

· នៅក្នុងគោទឹកដោះមានក្រពះចំនួន4។
· ក្រពះដែលធំជាងគេគឺជាក្រពះទី1 ដែលគេហៅថា រូមេន (Rumen)។
· នៅក្នុងរូមេនរបស់គោមានអតិសុខុមប្រាណជាច្រើនរស់នៅ ហើយអតិសុខុមប្រាណទាំងនោះមានតួនាទីបំបែកចំណីដើម្បីផ្តល់សារធាតុចិញ្ចឹម(អាស៊ីតខ្លាញ់ដែលមានលក្ខណៈហើរ)ទៅក្នុងរាងកាយរបស់គោទឹកដោះ។
· គោទឹកដោះនឹងខ្លាក់ចំណីដែលវាស៊ីចូលម្តងហើយចូលទៅក្នុងមាត់ម្តងទៀត ហើយប្រើធ្មេញដើម្បីកិនបំបែកចំណីទាំងនោះអោយទៅជាតូចៗ បន្ទាប់មកទើបលេបទៅវិញសាជាថ្មី ដោយគេហៅសកម្មភាពនេះថាការខ្លាក់ចំណីមកទំពាឬការទំពា។
· ការខ្លាក់ចំណីមកទំពាឬការទំពារបស់សត្វគោអាចបំបែកចំណីទៅជាតូចៗ ធ្វើអោយសកម្មភាពបំបែកឬរំលាយអាហាររបស់អតិសុខុមប្រាណនៅក្នុងរូមេនអាចប្រព្រឹត្តទៅបានឆាប់រហ័ស។
· នៅក្នុងក្រពះទី1 (រូមេន) របស់គោទឹកដោះ អាស៊ីតខ្លាញ់ដែលមានលក្ខណៈហើរ (អាស៊ីតប៊ុយទីរិច អាស៊ីតប្រូពីនិច អាស៊ីតអាសេទិចជាដើម) កើតចេញពីម្សៅធញ្ញជាតិនិងអាហារដែលមានជាតិសរសៃនៃចំណីមិនកែច្នៃ វាត្រូវបានស្រូបចូលទៅក្នុងរាងកាយរបស់គោទឹកដោះ ហើយត្រូវបានប្រើប្រាស់សម្រាប់ការថែរក្សាសុខភាពរាងកាយនិងការផលិតទឹកដោះ។
· ប្រូតេអ៊ីនដែលចាំបាច់សម្រាប់ការថែរក្សាសុខភាពរាងកាយនិងការផលិតទឹកដោះរបស់គោទឹកដោះ ត្រូវបានបង្កើតឡើងពីអាមីណូអាស៊ីតដែលត្រូវបានស្រូបចូលទៅក្នុងរាងកាយតាមរយៈពោះវៀនតូច។

4 ចំណីសត្វ

· ចំណីមិនកែច្នៃដែលគេប្រើច្រើន រួមមាន ស្មៅផ្អាប់ ពោតផ្អាប់ ស្តៅផ្អាប់ ស្មៅស្ងួត ស្រូវផ្អាប់មិនកែច្នៃ (ស្រូវផ្អាប់

ប្រើគ្រាប់ទាំងមូល) ចំបើង។ល។

- ចំណីជីវជាតិដែលគេប្រើច្រើន រួមមាន ចំណីលាយ ពោត កាកសំណល់សណ្តែកសៀង កាកសំណល់រុក្ខជាតិណាថាណិ(Rapeseed) កន្ទក់ ផលិតផលបន្ទាប់បន្សំពីការផលិតអាហារ(កាកសំណល់តៅហ៊ូ កាកសំណល់ពីការផលិតស្រាបៀរ) កាកសំណល់ឆៃថាវស្ករ។ល។
- ចំណីលាយគឺជាចំណីដែលផលិតដោយធ្វើការលាយវត្ថុធាតុដើមនៃចំណីផ្សេងៗជាច្រើនប្រភេទនៅរោងចក្រផលិតចំណីលាយ ដោយគេច្រើនប្រើពោតដែលជាប្រភេទធញ្ញជាតិ និង កាកសំណល់សណ្តែកសៀងដែលជាប្រភេទកាកសំណល់ក្រោយផលិតប្រេង។
- ចំណីផ្អាប់គឺជាចំណីដែលគេផលិតដោយរក្សាស្មៅសម្រាប់ធ្វើចំណីសត្វ ឬ ស្រូវ ឬ ពោត (មានលាយដើម ស្លឹកនិងផ្លែ) ដែលគេកាត់ជាតូចៗ ទុកក្នុងស្ថានភាពគ្មានអុកស៊ីសែន(ខ្យល់អាកាស)និងបិទជិត។
- ស្មៅសម្រាប់ធ្វើចំណីសត្វដែលឆាប់ដល់រដូវច្រូតកាត់មានបរិមាណប្រូតេអ៊ីននិងអត្រារំលាយជាតិសរសៃខ្ពស់ជាងស្មៅដែលក្រដល់រដូវច្រូតកាត់។

ប្រភេទនៃចំណីសត្វ

ស្មៅស្ងួត

ចំណីផ្អាប់

ចំណីជីវជាតិ

អគារចំណីសត្វ

ប៉មផលិតចំណីផ្អាប់

រោងផលិតចំណីផ្អាប់

ធុងរក្សាទុកចំណីលាយ

5 តម្លៃសារធាតុចិញ្ចឹមរបស់ចំណី

(1) ធាតុផ្សំរបស់ចំណី ត្រូវបានបង្ហាញតាមរយៈបរិមាណប្រូតេអ៊ីនមិនសុទ្ធ ខ្លាញ់មិនសុទ្ធ កាបូអ៊ីដ្រាត ជាតិរ៉ែ និងវីតាមីន។

(2) នៅប្រទេសជប៉ុន តម្លៃសារធាតុចិញ្ចឹម (ថាមពល) របស់ចំណីប្រើប្រាស់សម្រាប់គោទឹកដោះ ត្រូវបានបង្ហាញដោយ TDN (បរិមាណសរុបនៃសារធាតុចិញ្ចឹមនៅក្នុងចំណីដែលនឹងត្រូវរំលាយនៅក្នុងក្រពះ)។

(3) ធញ្ញជាតិមានបរិមាណ TDN ខ្ពស់ ដោយសារតែវាសម្បូរទៅដោយជាតិម្សៅដែលមានអត្រារំលាយខ្ពស់ ហើយពោតមានបរិមាណ TDN ខ្ពស់ណាស់រហូតដល់ទៅ 93.6% នៅក្នុងចំណោមចំណីស្ងួត។

(4) ស្មៅសម្រាប់ធ្វើចំណីសត្វសម្បូរទៅដោយជាតិសរសៃ ហើយវាមានបរិមាណ TDN ទាបជាងពោត ដោយសារតែអត្រារំលាយរបស់វា គឺទាបជាងម្សៅនៃធញ្ញាជាតិ ។

(5) ស្មៅសម្រាប់ធ្វើចំណីសត្វជំពូកគ្រាប់ មានបរិមាណប្រូតេអ៊ីនមិនសុទ្ធនិងអត្រារំលាយនៃជាតិសរសៃប្រែប្រួលទៅតាមរដូវច្រូតកាត់ ដូចមានបង្ហាញនៅក្នុងតារាង។ ស្មៅសម្រាប់ធ្វើចំណីសត្វដែលឆាប់ដល់រដូវច្រូតកាត់ មានតម្លៃសារធាតុចិញ្ចឹមខ្ពស់។

រដូវច្រូតកាត់ស្មៅសម្រាប់ធ្វើចំណីសត្វ និងតម្លៃសារធាតុចិញ្ចឹម (ស្មៅអ៊ីតាលី ស្មៅទីម៉ូស៊ី)

	មុនពេលចេញកួរស្រូវ	ដំណាក់កាលចេញកួរស្រូវ	ដំណាក់កាលចេញផ្កា
ស្មៅអ៊ីតាលី			
បរិមាណប្រូតេអ៊ីនមិនសុទ្ធ ក្នុងចំណោមចំណីស្ងួត %	18.4	13.7	8.3
អត្រារំលាយនៃជាតិសរសៃសរុប %	75	60	50
ស្មៅទីម៉ូស៊ី			
បរិមាណប្រូតេអ៊ីនមិនសុទ្ធ ក្នុងចំណោមចំណីស្ងួត %	17.5	10.0	8.8
អត្រារំលាយនៃជាតិសរសៃសរុប %	70	60	47

6 ការផលិតចំណីសត្វ

(1) ចំណីផ្អាប់គឺជាចំណីដែលគេផលិតដោយរក្សាស្មៅសម្រាប់ចំណីសត្វ ឬស្រូវ ឬពោត (មានលាយដើមស្លឹក និងផ្លែ) ទុកក្នុងបរិស្ថានបិទខ្យល់ជិតដែលគ្មានអុកស៊ីសែន រួចទុកវាឲ្យឡើងឡាក់ទិចអាស៊ីត។

(2) ដើម្បីធ្វើចំណីផ្អាប់បានល្អ ចាំបាច់ត្រូវកាត់គ្រឿងផ្សំឲ្យតូចៗ ហើយត្រូវជាន់ឬសង្កត់ឲ្យណែន។

ការផលិតចំណីផ្អាប់ស្មៅសម្រាប់ធ្វើចំណីសត្វ

ឆ្នឹមផលិតចំណីសត្វ

ការច្រូតកាត់ដោយម៉ាស៊ីនច្រូតកាត់

ការងារប្រមូលផលស្មៅសម្រាប់ធ្វើចំណីសត្វ

ការធ្វើឆ្នឹមផលិតចំណីសត្វ

ឆ្នឹមផលិតចំណីសត្វ

នៃចំណីផ្អាប់ស្មៅសម្រាប់ធ្វើចំណីសត្វ

ប្រព័ន្ធរបុមរាងស៊ីឡាំង

ការច្រូតកាត់ដោយម៉ាស៊ីនច្រូតកាត់

ការងាររុំដោយម៉ាស៊ីនរុំរបុមរាងស៊ីឡាំង

ការខ្ចប់ដោយម៉ាស៊ីនខ្ចប់

ចំណីផ្អាប់របុមរាងស៊ីឡាំង

7 ការផ្តល់ចំណីសត្វ

· ការផ្តល់ចំណីមិនកៃថ្មៃនិងចំណីជីវជាតិដាច់ផ្សេងៗពីគ្នា ហៅថា ការផ្តល់ចំណីដាច់ដោយឡែក ចំណែកឯការផ្តល់ចំណីរួមជាមួយគ្នាដោយធ្វើការលាយចំណីទាំងពីរប្រភេទនេះជាមុនដោយប្រើម៉ាស៊ីនលាយ (Mixer) ហៅថាការផ្តល់ចំណីលាយ(TMR)។

· គោបញ្ចេញទឹកដោះ(គោច្របាច់ទឹកដោះ)នឹងស៊ីចំណីកាន់តែច្រើននៅពេលបរិមាណទឹកដោះចាប់ផ្តើមកើនឡើងក្រោយពេលវាបង្កើតកូនរួច។

· គោនឹងស៊ីចំណីជីវជាតិក្នុងបរិមាណកើនឡើងស្របទៅនឹងការកើនឡើងនៃការបញ្ចេញទឹកដោះ ប៉ុន្តែ ករណីផ្តល់ចំណីដាច់ដោយឡែក គេត្រូវពិចារណាអំពីភាគរយនៃចំណីមិនកៃថ្មៃនិងចំណីជីវជាតិ(តុល្យភាព) ដោយត្រូវប្រុងប្រយ័ត្នកុំអោយគោស៊ីចំណីជីវជាតិច្រើនហួសហេតុពេក។ ត្រង់ចំណុចនេះ គេអាចប្រើប្រាស់ចំណីលាយ(TMR) ដើម្បីផ្តល់ចំណីដែលមានតុល្យភាពរវាងចំណីទាំងពីរប្រភេទនេះ។

· សម្រាប់ការផ្តល់ចំណីដាច់ដោយឡែក មុនដំបូង គេធ្វើការផ្តល់ចំណីមិនកៃថ្មៃដូចជាស្មៅស្ងួតឬចំណីផ្អាប់ជាដើម បន្ទាប់ពីនោះ ទើបគេផ្តល់ចំណីជីវជាតិតាមក្រោយ នោះជាការល្អ។

តារាងខាងក្រោមនេះ បង្ហាញពីឧទហរណ៍នៃការផ្តល់ចំណីចំពោះគោច្របាច់ទឹកដោះ។

ខេត្តហុកកៃដូ បរិមាណទឹកដោះប្រចាំថ្ងៃ 40គីឡូក្រាម
ចំណីផ្អាប់ស្មៅសម្រាប់ធ្វើចំណីសត្វ 10គីឡូក្រាមចំណីផ្អាប់ពោត 14គីឡូក្រាម ចំណីលាយ 10 គីឡូក្រាម ស្មៅស្ងួតអាល់ហ្វាល់ហ្វា 2គីឡូក្រាម កាកសំណល់ឆៃថាវស្ករ 3គីឡូក្រាម

ខេត្តអ៊ីប៉ារ៉ាហ្គិ បរិមាណទឹកដោះប្រចាំថ្ងៃ 28គីឡូក្រាម
ស្មៅស្ងួតទីម៉ូស៊ី 4គីឡូក្រាមស្មៅស្ងួតអាល់ហ្វាល់ហ្វា 2.9គីឡូក្រាមស្មៅស្ងួតប៊ឺម៉ូដា 3.4 គីឡូក្រាមចំណីលាយ 6.3គីឡូក្រាមកាកសំណល់ឆៃថាវស្ករ 3គីឡូក្រាម

8 គុណភាពទឹកដោះគោនិងជំងឺរលាកដោះ

(1) គុណភាពរបស់ទឹកដោះ ត្រូវបានត្រួតពិនិត្យដោយទឹកដោះលាយរបស់គោដែលគេដាក់លក់នៅលើទីផ្សារ (ទឹកដោះដែលគេលាយបញ្ចូលគ្នាពីគោផ្សេងៗជាច្រើន)។

(2) តម្លៃដាក់លក់នៅលើទីផ្សារនៃទឹកដោះ គឺខុសគ្នាតាមរយៈលទ្ធផលនៃការពិនិត្យទឹកដោះលាយ។

(3) គុណភាពទឹកដោះរបស់គោនីមួយៗ គឺត្រូវបានគេពិនិត្យ1ខែ1ដង ករណីគេត្រួតពិនិត្យហ្វូងគោ។

ស្តង់ដារនៃគុណភាពទឹកដោះ (ឧទាហរណ៍)

	គុណភាពទឹកដោះដែលល្អប្រសើរ	គុណភាពទឹកដោះតាមស្តង់ដារ	គុណភាពទឹកដោះដែលចាំបាច់ត្រូវតែលម្អ
អត្រាជាតិខ្លាញ់នៅក្នុងទឹកដោះ %	ពី3.9ឡើង	3.5-3.89	3.0-3.49
អត្រាប្រូតេអ៊ីននៅក្នុងទឹកដោះ %	ពី3.4ឡើង	3.1-3.39	2.8-3.09
អត្រានៃសារធាតុក្រៅពីខ្លាញ់ %	ពី8.8ឡើង	8.5-8.79	8.0-8.49
ចំនួនកោសិការាងកាយ ម៉ឺនមីលីលីត្រ	ក្រោម10	10-29	30-99 · លើសពីនេះ

· ទឹកដោះដែលបញ្ចេញនៅក្រោយពេលគោបង្កើតកូនរួចភ្លាមៗ ហៅថាទឹកដោះដំបូង។
· ទឹកដោះដំបូងមានបរិមាណសារធាតុទឹកដោះខុសពីទឹកដោះគោធម្មតា(ទឹកដោះធម្មតា) ដូច្នេះ គេមិនអាចយកទឹកដោះដែលគោបញ្ចេញក្នុងអំឡុងពេល5ថ្ងៃដំបូងបន្ទាប់ពីកើតកូនដើម្បីបញ្ចេញលក់នោះទេ។
· ជំងឺរលាកដោះ គឺជាជំងឺដែលមានបាក់តេរីបង្កជំងឺស្ថិតនៅខាងក្នុងដោះរបស់គោទឹកដោះ។ នៅពេលគោមានជំងឺរលាកដោះ នៅក្នុងដោះរបស់គោមានសភាពរលាក ហើយគោនឹងបង្ហាញរោគសញ្ញាផ្សេងៗ ដូចជាក្តៅខ្លួន ហើមដោះឈឺចាប់។ល។ នៅពេលដោះរបស់គោឆ្លងបាក់តេរីបង្កជំងឺ គ្រាប់ឈាមសនៅក្នុងខ្លួនរបស់គោកើនឡើងនិងចាប់ផ្តើមធ្វើសកម្មភាពចាប់ស៊ីបាក់តេរីទាំងនោះ ហើយត្រូវបានបញ្ចេញចូលទៅក្នុងទឹកដោះ ធ្វើអោយចំនួនកោសិកាដែលគេឃើញជ្រុះនៅក្នុងទឹកដោះមានការកើនឡើង។ កោសិកានៅក្នុងទឹកដោះគឺជាលទ្ធផលនៃគ្រាប់ឈាមស និងកោសិកាស្រទាប់លើនៃក្រពេញទឹកដោះដែលដាច់ធ្លាក់។ កោសិការាងកាយរបស់គោទឹកដោះដែលមានសុខភាពល្អ ជាទូទៅមានក្រោម 20ម៉ឺនមីលីលីត្រ។ ម្យ៉ាងទៀត កោសិកានៅក្នុងទឹកដោះគោត្រូវបានគេប្រើប្រាស់ដើម្បីវាយតម្លៃលើគុណភាពផ្នែកអនាម័យរបស់ទឹកដោះគោ។

9 សរីរាង្គរំលាយអាហារ និងជំងឺក្រចកជើង

(1) គោទឹកដោះពីដំបូងឡើយគឺជាសត្វដែលស៊ីស្មៅជាអាហារក្នុងប្រភេទសត្វស៊ីស្មៅ ប៉ុន្តែបច្ចុប្បន្ននេះ ដើម្បីទទួលបានការផលិតទឹកដោះដែលមានតម្លៃថ្លៃ បរិមាណម្សៅធញ្ញជាតិដែលគេឲ្យជាចំណី គឺមានការកើនឡើង។
(2) ល្បឿននៃការរំលាយម្សៅធញ្ញជាតិនៅក្នុងក្រពះទី1 (រូមេន) គឺលឿនជាងការរំលាយជាតិសរសៃនៃស្មៅ សម្រាប់ធ្វើចំណីសត្វខ្លាំងណាស់ នៅពេលដែលឲ្យចំណីជាម្សៅធញ្ញជាតិច្រើន នោះបរិមាណនៃការផលិតអាស៊ីតខ្លាញ់ដែលមានលក្ខណៈហើរ និងឡាក់ទិចអាស៊ីត ក៏មានការកើនឡើងដែរ។
(3) ដូច្នេះហើយ នៅពេលដែលឲ្យចំណីជាម្សៅធញ្ញជាតិច្រើន វាធ្វើឲ្យ pH (កម្រិតអ៊ីយ៉ុងអ៊ីដ្រូសែន) នៅក្នុងរូមេន មានការថយចុះ ដែលធ្វើឲ្យមានគ្រោះថ្នាក់ដោយសារតែការកើតឡើងនៃជំងឺឡើងអាស៊ីតក្នុងរូមេន ដែលមិនទាន់ចេញរោគសញ្ញា និងជំងឺក្រចកជើង។
(4) នៅប្រទេសជប៉ុន ការឈប់ប្រើប្រាស់គោទឹកដោះ ដោយសារតែជំងឺទាក់ទងនឹងចុងជើង និងក្រចកជើង (ជំងឺរលាកក្រចកជើង និងជំងឺក្រចកជើង) គឺមានច្រើន។

(5) ជំងឺទាក់ទងនឹងចុងជើង និងក្រចកជើងនេះ ក៏កើតឡើងដោយសារតែការស៊ីចំណីរើស (ការរើសចំណី) នូវចំណីជីវជាតិរបស់គោទឹកដោះផងដែរ។

(6) នៅក្នុងតារាងបន្ទាប់នេះ មានបង្ហាញអំពីស្ថានភាពរបស់គោដែលមានជំងឺក្រពះទី4ប្តូរទីតាំង ជំងឺឡើងអាស៊ីតក្នុងរូមេន និងជំងឺរលាកក្រចកជើង។

ជំងឺទាក់ទងនឹងសរីរាង្គរំលាយអាហារ និងជំងឺរលាកក្រចកជើងរបស់គោទឹកដោះ

ជំងឺ	កត្តាផ្សេងៗដែលនាំឲ្យកើតជំងឺ	រោគសញ្ញារបស់គោទឹកដោះ
ជំងឺក្រពះទី4ប្តូរទីតាំង	វាងាយនឹងកើតឡើង ដោយសារតែការឲ្យចំណីជីវជាតិច្រើនពេក និងការឲ្យចំណីមិនកៃច្នៃមិនបានគ្រប់គ្រាន់ក្រោយពេលកើតកូនរួច	ការថយចុះនៃចំណង់អាហារ សុខភាពមិនល្អ ការធ្លាក់ចុះនៃបរិមាណទឹកដោះ
ជំងឺឡើងអាស៊ីត ក្នុងរូមេន	នៅក្នុងក្រពះទី1(រូមេន) មានផ្ទុកទ្រាក់ទិចអាស៊ីតច្រើន ដោយសារតែការស៊ីម្សៅធញ្ញជាតិច្រើន ហើយ pHមានការថយចុះខ្លាំង	ការថយចុះនៃចំណង់អាហារ ការថយចុះនៃចលនាក្រពះទី1 ការធ្លាក់ចុះនៃបរិមាណទឹកដោះ ការថយចុះនៃមុខងាររបស់ថ្លើម
ជំងឺរលាកក្រចកជើង	ទ្រាក់តិចអាស៊ីត និងហ៊ីស្តាមីន (histamine) ដែលកើតមានឡើងនៅពេលមានជំងឺឡើងអាស៊ីតក្នុងរូមេន ធ្វើឲ្យមានប្រតិកម្មទៅលើសរសៃឈាមតូចៗនៃស្បែកក្រចកជើង ហើយធ្វើឲ្យមានសភាពរលាក	មិនអាចទៅជិតឧបករណ៍ផ្តល់ទឹកនិងស្នូកដាក់ចំណីបាន ដោយសារតែពិបាកក្នុងការដើរ បរិមាណស៊ីចំណីធ្លាក់ចុះ ការថយចុះនៃបរិមាណទឹកដោះ

10 ការបង្កាត់ពូជគោទឹកដោះ

· គោទឹកដោះដែលបង្កើតកូនរួចនឹងបន្តបង្ហាញចំណង់ផ្លូវភេទរៀងរាល់21ថ្ងៃម្តង។

· វាមានសារៈសំខាន់ណាស់ដែលគេត្រូវសង្កេតអាការៈនៃការបង្ហាញចំណង់ផ្លូវភេទរបស់គោកុំអោយខកខាន ដើម្បីចាប់ផ្តើមការងារបង្កកំណើតសិប្បនិម្មិតទៅលើគោទាំងនោះ។ ថ្មីៗនេះ មិនត្រឹមតែការបង្កកំណើតសិប្បនិម្មិតប៉ុណ្ណោះទេ គេក៏និយមអនុវត្តបច្ចេកទេសផ្ទេរស៊ុតបង្កកំណើតរបស់ពូជគោជប៉ុនរោមខ្មៅផងដែរ។

· គេប្រើប្រាស់ទឹកកាមកកស្ទើរតែទាំងស្រុង។

· នៅពេលគោទឹកដោះចាប់ផ្តើមបង្ហាញចំណង់ផ្លូវភេទ គេអាចសម្គាល់បានដោយឃើញប្រដាប់ភេទរបស់វាឡើងក្រហម ហើយមានការបញ្ចេញទឹករំអិល។

· ដំណាក់កាលកំពូលនៃការបង្ហាញចំណង់ផ្លូវភេទរបស់គោ គឺនៅពេលមានគោផ្សេងជាន់លើខ្នងវាក៏ដោយ ក៏វានៅស្ងៀមព្រមអោយជាន់(ការបង្ហាញចំណង់ផ្លូវភេទលក្ខណៈជាន់) ដូច្នេះ គេត្រូវសង្កេតមើលសកម្មភាពទាំងនេះ។

· ការបង្កកំណើតនឹងត្រូវបញ្ជាក់ច្បាស់លាស់នៅពេលគោទទួលការពិនិត្យផ្ទៃពោះ។

· គម្លាតកើតកូនរបស់គោទឹកដោះគួរតែ1ឆ្នាំម្តងទើបជាការល្អ ។

ការបង្កកំណើតសិប្បនិម្មិត

11 ការបង្កើតកូន

· នៅពេលគោទឹកដោះបង្កើតកូន កូនគោមានទម្ងន់ប្រហែល45គីឡូក្រាម។

· ការកើតកូនដោយធម្មជាតិដែលមិនមានការចូលរួមពីមនុស្សគឺជាការល្អប្រសើរ ប៉ុន្តែ នៅពេលគោពិបាកបង្កើតកូន វាត្រូវការជំនួយពីមនុស្ស។

· នៅក្នុងពេលជួយបង្កើតកូនគោ គេត្រូវប្រុងប្រយ័ត្នកុំអោយបង្ករបួសដល់ផ្លូវបង្កើតកូនរបស់មេគោឬធ្វើអោយមានការឆ្លងបាក់តេរីដល់សត្វគោអោយសោះ។

· ក្រោយពេលកូនគោកើតចេញមកហើយ សុកនឹងត្រូវបញ្ចេញមកក្នុងអំឡុងពេល6ម៉ោងបន្ទាប់ពីកូនគោកើត។

· ក្រោយពេលកើត មេគោនឹងធ្វើការលិទ្ធខ្លួនកូនគោដើម្បីធ្វើអោយស្បែកកូនគោឆាប់ស្ងួត ប៉ុន្តែ គេគួរតែលើកកូនគោដាក់នៅលើសម្ភារៈក្រាលដែលស្ងួត ។

12 ការផ្តល់ទឹកដោះដំបូង

· វាមានសារៈសំខាន់ណាស់ដែលគេត្រូវអោយកូនគោដែលទើបនឹងកើតផឹកទឹកដោះដំបូង ព្រោះនៅក្នុងទឹកដោះដំបូងមានផ្ទុកអង់ទីករនៃប្រព័ន្ធភាពស៊ាំការពារជំងឺជាច្រើន ដែលអាចអោយកូនគោមានប្រព័ន្ធភាពស៊ាំសម្រាប់ការពារសុខភាពខ្លួនវា។

· គេគួរផ្តល់ទឹកដោះដំបូងដល់កូនគោយ៉ាងហោចណាស់រយៈពេល3ថ្ងៃបន្ទាប់ពីវាកើត ទើបជាការល្អ។

13 ការបំបៅដោះ និងការលូតលាស់របស់កូនគោ

(1) ការផ្តាច់ដោះមុនកាលកំណត់នៅក្នុងអាយុ 6សប្តាហ៍ គឺជាវិធីដែលសមស្រប ហើយរបៀបនៃការឲ្យចំណីចំពោះករណីនេះ មានដូចក្នុងតារាងខាងក្រោម។

ការឲ្យចំណីតាមវិធីនៃការផ្តាច់ដោះមុនកាលកំណត់ (ឧទាហរណ៍)

ទឹកដោះដំបូង	1-2លីត្រក្នុងរយៈពេល4ម៉ោងក្រោយពេលកើត 2លីត្រក្នុងរយៈពេល4-6ម៉ោង
ទឹកដោះជំនួស・ទឹកដោះមេ	ករណីដែលឲ្យតែទឹកដោះជំនួសដែលមានលក្ខណៈរាវតែមួយមុខ ត្រូវឲ្យបរិមាណ600ក្រាមក្នុង1ថ្ងៃ (ត្រូវឲ្យដោយរំលាយនៅក្នុងទឹកក្តៅ) ករណីដែលប្រើប្រាស់តែទឹកដោះតែមួយមុខ ត្រូវឲ្យបរិមាណ4.5គីឡូក្រាមក្នុង1ថ្ងៃ ក្នុងរយៈពេល 6សប្តាហ៍
ចំណីសម្រាប់កូនគោ	ចំណីជីវជាតិប្រើប្រាស់សម្រាប់ផ្តាច់ដោះ(ទឹកដោះសិប្បនិម្មិត) ឲ្យកូនគោចាប់ពីអាយុប្រហែល1សប្តាហ៍ក្រោយពេលកើត អាយុ 1-2សប្តាហ៍ 0.1គីឡូក្រាមថ្ងៃ អាយុ 2-3សប្តាហ៍ 0.2គីឡូក្រាមថ្ងៃ អាយុ 3-4សប្តាហ៍ 0.5គីឡូក្រាមថ្ងៃ អាយុ 4-5សប្តាហ៍ 0.8គីឡូក្រាមថ្ងៃ អាយុ 5-6សប្តាហ៍ 1.2គីឡូក្រាមថ្ងៃ (ក្រោយមកទៀត ត្រូវបង្កើនបរិមាណបន្តិចម្តងៗ ច្រើនបំផុតត្រឹម 2.5គីឡូក្រាមថ្ងៃ រហូតដល់អាយុ 3ខែ)
ស្មៅស្ងួត	ការស៊ីស្មៅស្ងួតដែលមានគុណភាពល្អដោយសេរី

(សៀវភៅស្តង់ដារចិញ្ចឹមសត្វនៅប្រទេសជប៉ុន・គោទឹកដោះ សៀវភៅប្រព័ន្ធនៃការព្យាបាលសត្វ・ចំពោះគោទឹកដោះភាគ1)

(2) នៅក្នុងដំណាក់កាលលូតលាស់របស់គោទឹកដោះ គេមានគោលដៅ 2 ដូចខាងក្រោម។

[1] ឲ្យចំណីមិនកៃថ្នែដែលគោចូលចិត្តស៊ី ហើយដែលមានគុណភាពល្អ ដើម្បីឲ្យក្រពះទី1 (រូមេន) លូតលាស់បានល្អ។

[2] ឲ្យគោហាត់ប្រាណឲ្យបានសមស្រប ដើម្បីធ្វើឲ្យសាច់ដុំ និងឆ្អឹងរបស់វារឹងមាំ។

14 ការគ្រប់គ្រងសុខភាពរបស់កូនគោ

・កូនគោងាយនឹងកើតជំងឺ ដូចជា រាករូស ផលប៉ះពាល់ធ្ងន់ធ្ងរលើសរីរាង្គដោយសារមេរោគ រលាកសួត ជាដើម។
・គេគួរចិញ្ចឹមកូនគោនៅក្នុងបរិស្ថានដែលមានខ្យល់ចេញចូលល្អ ទទួលពន្លឺព្រះអាទិត្យគ្រប់គ្រាន់និងមានអនាម័យ។
・គេច្រើនធ្វើការចិញ្ចឹមកូនគោនៅក្នុងកូនផ្ទះឬទ្រុងសម្រាប់កូនគោ។
・នៅក្នុងកូនផ្ទះឬទ្រុងសម្រាប់កូនគោ គេប្រើសម្ភារៈក្រាលយ៉ាងច្រើននិងរក្សាបរិស្ថានអោយមានអនាម័យជានិច្ច។

កូនផ្ទះសម្រាប់កូនគោ

15 ពិន្ទុស្ថានភាពរាងកាយ

(1) ស្ថានភាពរាងកាយ គឺសំដៅលើកម្រិតជាតិខ្លាញ់ដែលមាននៅក្រោមស្បែករបស់គោទឹកដោះ។

(2) តួលេខដែលបង្ហាញពីស្ថានភាពរាងកាយ គេហៅថា ពិន្ទុស្ថានភាពរាងកាយ វាបង្ហាញដោយ BCS។

(3) BCS ត្រូវបានបង្ហាញក្នុងរង្វង់ពី 2.0-5.0។

(4) ការវាស់ BCS គឺត្រូវបានសម្រេចឡើងដោយការពិនិត្យទៅលើ ឆ្អឹងត្រគាក ត្រគាក ឆ្អឹងត្រគាកផ្នែកខាងក្រោម ការឡើងប៉ោងនៅចំហៀង សរសៃពួរឆ្អឹងកំប៉ះគូទ សរសៃពួរឆ្អឹងកញ្ចុញគូទ។

(5) ដោយសារតែ BCS មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងលទ្ធផលនៃការបង្កាត់ពូជនិងការផលិតទឹកដោះ ដូច្នេះ តួលេខគោលដៅដែលសមស្របនឹងរដូវកាលផលិតទឹកដោះ ត្រូវបានកំណត់ដូចខាងក្រោម។

[1] នៅពេលបង្កើតកូន កម្រិតរបស់វាគឺ 3.50 ក្នុងរង្វង់ពី 3.25-3.75។

[2] ក្រោយពេលចាប់ផ្តើមចេញទឹកដោះ កម្រិតរបស់វាធ្លាក់ចុះខ្លាំងបំផុតរហូតដល់ 0.75-1.0។

[3] យ៉ាងយូរបំផុត 100ថ្ងៃក្រោយពេលបង្កើតកូន កម្រិតរបស់វានឹងប្រសើរឡើងវិញ។

[4] នៅពេលផ្អាកការច្របាច់ទឹកដោះ កម្រិតរបស់វាស្ថិតក្នុងរង្វង់ពី 3.25-3.75។

ស្ថានភាពរាងកាយ

<គម្រូនៃការកំណត់ពិន្ទុស្ថានភាពរាងកាយដែលងាយ>

BCSដែលងាយ=2 ស្គមកំព្រឹង

រាងកាយទាំងមូល:រូបភាពនេះត្រូវបានកំណត់ថាស្គមខ្លាំងណាស់។
មិនស្វាហាប់ ពោះរួញឡើង ហើយគេមិនសង្ឃឹមថាវាអាចផ្តល់ទិន្នផលល្អទេ

គូទ:អក្សរ V
ត្រគាក និងឆ្អឹងត្រគាកផ្នែកខាងក្រោម មានរាងជ្រុង

BCSដែលងាយ= 3 ធម្មតា

រាងកាយទាំងមូល:រូបភាពនេះបង្ហាញថា វាមានផ្ទុកខ្លាញ់បន្តិចបន្តួច
ហើយវាស្ថិតក្នុងចន្លោះដែលគេកំណត់ថាធម្មតា។
គ្រប់ផ្នែកនីមួយៗនៃរាងកាយបញ្ចេញទម្រង់ច្បាស់ៗ ហើយគេគិតថាវាអាចផ្តល់ទិន្នផលបានគ្រប់គ្រាន់

គូទ:អក្សរ V
ត្រគាក និងឆ្អឹងត្រគាកផ្នែកខាង។
ក្រោម មានរាងមូល

BCSដែលងាយ= 4 ធាត់ពេក

រាងកាយទាំងមូល:រូបភាពនេះត្រូវបានកំណត់ថាធាត់ខ្លាំងពេក។
មានជាតិខ្លាញ់នៅក្រោមស្បែកដែលលើសពីតម្រូវការ ហើយរាងកាយមិនបញ្ចេញទម្រង់ច្បាស់លាស់។
គេបារម្ភថាអាចមានបញ្ហាក្រោយពេលបង្កើតកូន។

គូទ:អក្សរ U
មានផ្ទុកខ្លាញ់នៅត្រង់ត្រគាក
និងឆ្អឹងត្រគាកផ្នែកខាងក្រោម។

ប្រភពរូបថត (រាងកាយទាំងមូល 3សន្លឹក):នីស៊ីអឺរ៉ា អាគិកុ ប្រធានបុគ្គលិកស្រាវជ្រាវនៃអង្គការស្រាវជ្រាវអំពីអាហារនិងកសិកម្មជាតិ (National Agriculture and Food Research Organization)
ប្រភពរូបថត(គូទ6សន្លឹក):មជ្ឈមណ្ឌលសាវ្រៃជ្រាវខាងវិស័យកសិកម្មទឹកដោះនិងសត្វចិញ្ចឹមនៃខេត្តតូឈិហ្គិ

16 ប្រភេទនៃកាកសំណល់សត្វ

· កាកសំណល់របស់គោទឹកដោះអាចមាន3ទម្រង់ គឺ កាកសំណល់រឹង ភក់ល្បាប់ ឬ កាកសំណល់រាវ។

· កាកសំណល់រឹងគឺជាកាកសំណល់ដែលគេបានបែងចែកចេញពីទឹកនោមសត្វ និងជាល្បាយនៃការលាយឡំលាមកជាមួយនឹងសម្ភារៈក្រាល ដែលគេអាចប្រើល្បាយនេះសម្រាប់ធ្វើជាជីកំប៉ុស្ត៍។

· កាកសំណល់រាវ គឺជាទឹកនោមសត្វដែលត្រូវបានបែងចែកពីលាមក។

· ភក់ល្បាប់ គឺជាលាមកដែលមានលាយលាមកនិងទឹកនោមបញ្ចូលគ្នា ហើយស្តុកទុកនៅក្នុងធុង ដើម្បីប្រើនៅក្នុងការផលិតជីឬឧស្ម័នមេតាន។

លាមកនិងសម្ភារៈក្រាលដែលប្រឡាក់ត្រូវបានដឹកជញ្ជូនចេញពីរោងចិញ្ចឹមគោដោយម៉ាស៊ីនជញ្ជូនកាកសំណល់។

អាងភក់ល្បាប់

17 ការផលិតនិងការប្រើប្រាស់ជីកំប៉ុស្ត៍

· ជីកំប៉ុស្ត៍គឺជាផលិតផលបានពីការបំលែងលាមកឬលាមកលាយសម្ភារៈក្រាលរបស់គោទឹកដោះក្រោមល័ក្ខខ័ណ្ឌមានអុកស៊ីសែន(ក្នុងបរិស្ថានដែលមានអុកស៊ីសែន) និងបញ្ចុះបរិមាណជាតិទឹកនៅក្នុងនោះ។

· ដើម្បីផលិតបានជីកំប៉ុស្ត៍ដែលមានគុណភាពល្អ គេចាំបាច់ផ្តល់ឱ្យល់អាកាសអោយបានគ្រប់គ្រាន់ ដូច្នេះគេត្រូវធ្វើការត្រឡប់ល្បាយចុះឡើង (កូរនិងលាយ)។

· ជីកំប៉ុស្ត៍ត្រូវបានប្រើសម្រាប់ធ្វើជាជីដាំដំណាំ។ ពេលខ្លះ គេយកជីកំប៉ុស្ត៍ដែលស្ងួតយកមកធ្វើជាសម្ភារៈក្រាលនៅក្នុងរោងចិញ្ចឹមគោសាជាថ្មីម្តងទៀត ដែលគេហៅថា "ជីកំប៉ុស្ត៍សម្រាប់ប្រើឡើងវិញ"។

· ជីកំប៉ុស្ត៍ដែលមានផ្ទុកបរិមាណជាតិទឹក 60-65% គឺជាជីដែលល្អបំផុត ដូច្នេះហើយគេផលិតជីកំប៉ុស្ត៍ដោយលាយជាមួយនឹងវត្ថុធាតុបន្ទាប់បន្សំ។

· នៅពេលដែលការធ្វើជីកំប៉ុស្ត៍ប្រព្រឹត្តទៅដោយរលូន កម្តៅនៅក្នុងជីមានការកើនឡើង។ ក្នុងករណីនោះវាមានសីតុណ្ហភាព 70-80អង្សាសេ ដែលអាចធ្វើឲ្យមេរោគដែលជាមូលហេតុនៃជំងឺ ប៉ារ៉ាសិត និងគ្រាប់របស់ស្មៅចង្រៃងាប់ដោយសារតែកម្តៅខ្ពស់របស់វា។

កន្លែងផ្ទុកដីកំប៉ុស្ត៍

2 គោចិញ្ចឹមយកសាច់

1 ពូជគោជប៉ុន (ពូជគោជប៉ុនរោមខ្មៅ)

គោជប៉ុន គឺជាគោរបស់ជប៉ុនដែលអ្នកចិញ្ចឹមបានធ្វើការកែប្រែឲ្យប្រសើរឡើងអស់រយៈពេលយូរមកហើយ ហើយត្រូវបានការពារជាសំខាន់។ គោប្រភេទនោះមាន ពូជគោជប៉ុនរោមខ្មៅ (ពណ៌ខ្មៅ) ពូជគោជប៉ុនរោមត្នោត (ពណ៌លឿងត្នោត) ពូជគោជប៉ុនស្នែងខ្លី ពូជគោជប៉ុនគ្មានស្នែង ប៉ុន្តែពូជគោដែលគេចិញ្ចឹមច្រើនជាងគេនោះ គឺពូជគោជប៉ុនរោមខ្មៅ។ បុគ្គលិកលក្ខណៈរបស់ពូជគោជប៉ុនរោមខ្មៅ គឺវាមានលក្ខណៈស្លូត។

(1) ការគ្រប់គ្រងសារធាតុចិញ្ចឹមសម្រាប់គោបង្កាត់ពូជញី

[1] ការគ្រប់គ្រងសារធាតុចិញ្ចឹមសម្រាប់គោបង្កាត់ពូជញីក្នុងករណីផ្តល់ទឹកដោះដោយធម្មជាតិ

○ ដំណាក់កាលចុងក្រោយនៃការពពោះ

· កូនគោក្នុងផ្ទៃមានសន្ទុះលូតលាស់ខ្លាំងចាប់ពីពេលពពោះ2ខែមុនពេលកើតរហូតដល់ពេលកើត។

· សារធាតុចិញ្ចឹមដែលត្រូវការចាំបាច់ រួមមាន សារធាតុចិញ្ចឹមសម្រាប់ការថែរក្សាសុខភាពរាងកាយរបស់មេគោ និង សារធាតុចិញ្ចឹមសម្រាប់ការលូតលាស់របស់កូនគោក្នុងផ្ទៃ។

○ដំណាក់កាលបំបៅដោះ

· គេចាំបាច់ត្រូវផ្តល់ចំណីស្របទៅតាមបរិមាណបញ្ចេញទឹកដោះរបស់មេគោ។

· គេចាំបាច់ត្រូវផ្លាស់ប្តូរបរិមាណចំណីដែលផ្តល់អោយមេគោស្របទៅតាមស្ថានភាពនៃសារធាតុចិញ្ចឹមរបស់មេគោ។

[2] ការគ្រប់គ្រងសារធាតុចិញ្ចឹមសម្រាប់គោបង្កាត់ពូជញីក្នុងករណីផ្តល់ទឹកដោះដោយសិប្បនិម្មិត

ក្នុងករណីនេះស្ទើរតែគ្មានដំណាក់កាលបំបៅដោះនោះទេ ប្រៀបធៀបទៅនឹងករណីមេគោផ្តល់ទឹកដោះដោយធម្មជាតិ។

○ដំណាក់កាលពពោះ

· វាមានលក្ខណៈដូចគ្នាទៅនឹងករណីមេគោផ្តល់ទឹកដោះដោយធម្មជាតិ។

○ដំណាក់កាលបំបៅដោះ

· បរិមាណចំណីដែលផ្តល់អោយមេគោក្នុងដំណាក់កាលនេះគឺត្រូវរក្សាអោយស្មើនឹងបរិមាណនៅដំណាក់កាលចុងក្រោយនៃការពពោះ។

· គេចាំបាច់ត្រូវផ្តល់ចំណីអោយមេគោស្របទៅតាមស្ថានភាពនៃសារធាតុចិញ្ចឹមរបស់មេគោ។

(2) ការបង្កាត់ពូជគោញីដែលជាគោចិញ្ចឹមយកសាច់

· គោញីចិញ្ចឹមយកសាច់ដែលបង្កើតកូនរួចនឹងបន្តបង្ហាញចំណង់ផ្លូវភេទរៀងរាល់21ថ្ងៃម្តង។

· វាមានសារៈសំខាន់ណាស់ដែលគេត្រូវសង្កេតអាការៈនៃការបង្ហាញចំណង់ផ្លូវភេទរបស់គោកុំអោយខកខាន ដើម្បីចាប់ផ្តើមការងារបង្កកំណើតសិប្បនិម្មិតទៅលើគោទាំងនោះ។

· ការផ្ទេរស៊ុតបង្កកំណើត និងទឹកកាមរបស់គោជប៉ុន គឺជារឿងដែលសំខាន់បំផុតសម្រាប់អ្នកចិញ្ចឹមជនជាតិជប៉ុន ដូច្នេះហើយ ការរក្សាទុកនៅកន្លែងដែលសមស្របគឺជារឿងសំខាន់ ដូចជារក្សាទុកនៅកន្លែងដែលអាចចាក់សោរទុកកុំឲ្យបាត់ជាដើម។

· នៅពេលគោញីចិញ្ចឹមយកសាច់ចាប់ផ្តើមបង្ហាញចំណង់ផ្លូវភេទ គេអាចសម្គាល់បានដោយឃើញប្រដាប់ភេទរបស់វាឡើងក្រហម ហើយមានការបញ្ចេញទឹករំអិល។
· ដំណាក់កាលកំពូលនៃការបង្ហាញចំណង់ផ្លូវភេទរបស់គោ គឺនៅពេលមានគោផ្សេងជាន់លើខ្នងវាក៏ដោយ ក៏វានៅស្ងៀមព្រមអោយជាន់(ការបង្ហាញចំណង់ផ្លូវភេទលក្ខណៈជាន់) ដូច្នេះ ត្រូវសង្កេតមើលសកម្មភាពទាំងនេះ។
· ការបង្កកំណើតនឹងត្រូវបញ្ជាក់ច្បាស់លាស់នៅពេលគោទទួលការវិនិច្ឆ័យ (ការពិនិត្យ) ផ្ទៃពោះ។
· គម្លាតកើតកូនរបស់គោញីចិញ្ចឹមយកសាច់គួរតែ1ឆ្នាំម្តងទើបជាការល្អ។

សកម្មភាពនៃការបង្ហាញចំណង់ផ្លូវភេទ

(3) ការបង្កើតកូន

· នៅពេលមេគោចិញ្ចឹមយកសាច់បង្កើតកូន កូនគោមានទម្ងន់ប្រហែល30គីឡូក្រាម។
· ការកើតកូនដោយធម្មជាតិដោយមិនមានការចូលរួមពីមនុស្សគឺជាការល្អប្រសើរ ប៉ុន្តែ នៅពេលគោពិបាកបង្កើតកូនវាត្រូវការជំនួយពីមនុស្ស។
· ក្នុងពេលជួយបង្កើតកូនគោ គេត្រូវប្រុងប្រយ័ត្នកុំអោយបង្ករបួសដល់ផ្លូវបង្កើតកូនរបស់មេគោឬធ្វើអោយមានការឆ្លងបាក់តេរីដល់សត្វគោអោយសោះ។
· ក្រោយពេលកូនគោកើតចេញមកហើយ សុកនឹងត្រូវបញ្ចេញមកក្នុងអំឡុងពេល6ម៉ោងបន្ទាប់ពីកូនគោកើត។
· ក្រោយពេលកើត មេគោនឹងធ្វើការលិទ្ធខ្លួនរបស់កូនគោដើម្បីធ្វើអោយស្បែកកូនគោឆាប់ស្ងួត ប៉ុន្តែ គេគួរលើកកូនគោដាក់នៅសម្ភារៈក្រាលដែលស្ងួត។

(4) ការគ្រប់គ្រងកូនគោរបស់ពូជគោជប៉ុនរោមខ្មៅ

[1] ទម្ងន់នៅពេលកើត

នៅពេលវាកើត កូនគោនៃពូជគោជប៉ុនរោមខ្មៅមានទម្ងន់ប្រហែល28គីឡូក្រាម ។

ក្រោយកើតភ្លាម

ការផ្តល់ទឹកដោះដោយធម្មជាតិ

ការផ្តល់ទឹកដោះដោយសិប្បនិម្មិត

[2] ការផ្តល់ទឹកដោះដំបូង

គេផ្តល់ទឹកដោះដំបូងដល់កូនគោរយៈពេល2~3ថ្ងៃក្រោយពេលកើត។ នៅក្នុងទឹកដោះដំបូងមានផ្ទុកអង់ទីករនៃប្រព័ន្ធភាពស៊ាំទប់ទល់នឹងជំងឺផ្សេងៗដែលអាចកើតមាននៅលើកូនគោ ដូច្នេះ គេត្រូវអោយកូនគោផឹកទឹកដោះដំបូងនេះកុំខាន។

[3] គម្រោងផ្តល់ចំណីដល់កូនគោក្រោយពេលកើត

គម្រោងឲ្យចំណីនៅពេលផ្តាច់ដោះមុនកាលកំណត់នៅក្នុងសៀវភៅស្តង់ដារនៃការចិញ្ចឹមសត្វនៅប្រទេសជប៉ុនចំពោះគោចិញ្ចឹមយកសាច់ (បោះពុម្ពឆ្នាំ2008) ត្រូវបានបង្ហាញដូចក្នុងតារាងខាងក្រោម។

ទឹកដោះជំនួស រួមមាន ម្សៅទឹកដោះគ្មានខ្លាញ់ ទឹកដោះថ្លាស្ងួត ម្សៅធញ្ញជាតិ។ល។ ទឹកដោះសិប្បនិម្មិត គឺជាចំណីរឹងដែលត្រូវផ្តល់អោយនៅដំណាក់កាលផ្តល់ទឹកដោះ ដោយរួមមានម្សៅផលិតពីស្រូវសាលី ស្រូវបាលី ពោត សណ្តែកសៀង។ល។

អាយុគិតជាថ្ងៃក្រោយពេលកើត	បរិមាណនៃការឲ្យទឹកដោះជំនួស (ចំណីស្ងួត ក្រាមថ្ងៃ)	បរិមាណនៃការឲ្យទឹកដោះសិប្បនិម្មិត (ចំណីស្ងួត ក្រាមថ្ងៃ)	ស្មៅស្ងួត
8—13 ថ្ងៃ	400		
14—17 ថ្ងៃ	500		
18—21 ថ្ងៃ	500	100	
22—28 ថ្ងៃ	500	200	
29—35 ថ្ងៃ	500	300	
36—42 ថ្ងៃ	500	500	ការស៊ីចំណីលក្ខណៈសេរី
43—49 ថ្ងៃ	250	800	
7— 8 សប្តាហ៍	(250)	1200	
8— 9 សប្តាហ៍	(250)	(1000)	
9—10 សប្តាហ៍	(250)	1400	
10—11 សប្តាហ៍		(1200)	
11—12 សប្តាហ៍		1500	
12—13 សប្តាហ៍		(1300)	
13—14 សប្តាហ៍		1600	
		1700	
		1800	
		1900	

ក្នុង ( ):បរិមាណនៃការឲ្យក្នុងករណីបន្តបំបៅដោះក្រោយអាយុ 7សប្តាហ៍

ទឹកដោះជំនួស:សីតុណ្ហភាពទឹកក្តៅសម្រាប់រំលាយទឹកដោះជំនួស ជាមូលដ្ឋានគេកំណត់ប្រហែល 38-40អង្សាសេ ឲ្យដូចទៅនឹងទឹកដោះមេនៅពេលកូនបៅ។ ដូច្នេះហើយ ការរំលាយដោយទឹកក្តៅដែលមានសីតុណ្ហភាព 45-50អង្សាសេ គឺល្អ។ នៅពេលរំលាយទឹកដោះជំនួស ជាដំបូងត្រូវរៀបចំទឹកក្តៅ បន្ទាប់មកដាក់ទឹកដោះជំនួសចូលទៅក្នុងនោះ រួចកូរនិងរំលាយវា (សមាគមអភិវឌ្ឍគោចិញ្ចឹមយកសាច់ទូទាំងប្រទេស (NBAFA) សមាគមឧស្សាហកម្មសត្វចិញ្ចឹម (Japan Livestock Industry Association) "បច្ចេកទេសគ្រប់គ្រងការចិញ្ចឹមសត្វគោយកសាច់ពូជចិញ្ចឹមយកទឹកដោះ" ឆ្នាំ2006)

[4] ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងកូនគោ

កូនគោដែលទើបនឹងកើតមិនសូវមានកម្លាំងទប់ទល់នឹងបាក់តេរីបង្កជំងឺនោះទេ ហើយដើម្បីទប់ស្កាត់ការឆ្លងបាក់តេរីពីមេគោ គេធ្វើការបញ្ជូននិងគ្រប់គ្រងកូនគោនៅទីកន្លែងដែលរៀបចំពិសេសសម្រាប់កូនគោដូចជាកូនផ្ទះជាដើម (សូមពិនិត្យមើលខ្លឹមសារនៃ "10 ការគ្រប់គ្រងសុខភាពរបស់កូនគោ"នៅទំព័រទី23 នៅក្នុងផ្នែកទាក់ទងនឹងគោទឹកដោះ)

គេរៀបចំទឹកដោះសិប្បនិម្មិតឬស្មៅស្ងួតដែលស្រស់ៗសម្រាប់ផ្តល់អោយកូនគោជារៀងរាល់ថ្ងៃ។ សម្រាប់ស្មៅស្ងួត គេជ្រើសរើសស្មៅដែលមានគុណភាពល្អសម្រាប់ផ្តល់ជាចំណីដល់កូនគោ។

គេត្រូវសង្កេតមើលអោយបានម៉ត់ចត់ក្រែងកូនគោមានអាការៈរាករូសឬលាមកទន់ ។

មេរោគនៃជំងឺរលាកសួតអាចឆ្លងទៅកូនគោ នៅពេលកូនគោស្ថិតក្នុងស្ថានភាពដូចជា"ប្រព័ន្ធភាពសាំធ្លាក់ចុះដោយសារអារម្មណ៍ស្ត្រេសឬកង្វះសារធាតុចិញ្ចឹម" "របួសនៅភ្នាសនៃទងសួតដោយសារអាកាសធាតុត្រជាក់ឬស្ងួត" "របួសនៅភ្នាសផ្សេងៗដោយសារឧស្ម័នអាម៉ូញាក់"។ ដើម្បីបង្ការជំងឺទាំងនេះ គេចាំបាច់ត្រូវអនុវត្តវិធានការ ដូចជា "ការកម្ចាត់អាម៉ូញាក់ពីរោងចិញ្ចឹមសត្វ" "ការសម្អាតរោងចិញ្ចឹមគោ" "ការរក្សាកម្តៅអោយកូនគោ" "ការផ្តល់ចំណីអោយបានគ្រប់គ្រាន់ដើម្បីកាត់បន្ថយស្ត្រេស" "ការផ្តល់ទឹកដោះដំបូង"។

(5) ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងនៅដំណាក់កាលលូតលាស់

ដំណាក់កាលលូតលាស់របស់គោចិញ្ចឹមយកសាច់គឺជារយៈពេលគិតចាប់ពីពេលផ្តាច់ដោះរហូតដល់ពេលចាប់ផ្តើមចិញ្ចឹមបំប៉ន។ ក្នុងរយៈពេលនេះ គេត្រូវផ្តល់ចំណីមិនកែច្នៃដែលមានគុណភាពល្អដល់គោអោយបានគ្រប់គ្រាន់ដើម្បីអោយការលូតលាស់នៃសរីរាង្គខាងក្នុងព្រមទាំងសាច់ដុំនិងឆ្អឹងរបស់គោមានលក្ខណៈពេញលេញគ្រប់គ្រាន់។

គេធ្វើការក្រៀវកូនគោឈ្មោល យ៉ាងយឺតបំផុតត្រឹមពេលគោមានអាយុ4~5ខែក្រោយកើត។

(6) ការចិញ្ចឹមបំប៉ន

ការចិញ្ចឹមបំប៉នពូជគោជប៉ុនរោមខ្មៅគឺចាប់ផ្តើមពីពេលគោមានអាយុ10ខែនិងមានទម្ងន់ប្រហែល300គីឡូក្រាម ហើយគេដាក់គោទាំងនោះប៉ុន្មានក្បាលក្នុងមួយក្រោល(ទ្រុង)។ គេអនុវត្តការចិញ្ចឹមបំប៉នដោយអោយចំណីជីវជាតិជាចម្បងរយៈពេលប្រហែល20ខែ។

[1] ការផ្តល់ចំណីនៅដំណាក់កាលចិញ្ចឹមបំប៉នរបស់ពូជគោជប៉ុនរោមខ្មៅ

សម្រាប់ចំណីនៅដំណាក់កាលចិញ្ចឹមបំប៉ន គេផ្តោតទៅលើចំណីជីវជាតិដែលមានធញ្ញជាតិ(ពោត ស្រូវបាលី)ជាចម្បង ចំណែងចំណីមិនកែច្នៃវិញ គេផ្តល់អោយគោនៅដំណាក់កាលដំបូងនៃការចិញ្ចឹមបំប៉ន (ពេលគោមានអាយុ10~16ខែ) ដោយរួមមានស្មៅស្ងួតនិងចំបើង ប៉ុន្តែបន្ទាប់ពីនោះ គេផ្តល់ចំណីមិនកែច្នៃដែលមានតែចំបើងតែប៉ុណ្ណោះ។ មានន័យថា ចាប់ពីដំណាក់កាលដំបូងដល់ដំណាក់កាលកណ្តាលនៃការចិញ្ចឹមបំប៉ន គេផ្តល់ចំណីជាចំបើងប្រហែល2គីឡូក្រាម ហើយនៅដំណាក់កាលចុងក្រោយនៃការចិញ្ចឹមបំប៉ន គេផ្តល់ត្រឹមប្រហែល1គីឡូក្រាមតែប៉ុណ្ណោះ។

[2] បរិមាណនៃការស៊ីចំណីនៅក្នុងដំណាក់កាលចិញ្ចឹមបំប៉ន និងលទ្ធផលនៃការចិញ្ចឹមបំប៉ន (ឧទាហរណ៍មួយនៅក្នុងការប្រឡង)

	បរិមាណស៊ីចំណី (ស្មៅស្ងួត គីឡូក្រាមថ្ងៃ)		ទម្ងន់កើនប្រចាំថ្ងៃ គីឡូក្រាមថ្ងៃ	ទម្ងន់នៅពេលដាក់លក់នៅលើទីផ្សារ គីឡូក្រាម
	ចំណីជីវជាតិ	ចំបើងស្រូវ		
ដំណាក់កាលដំបូង	6.2	1.8	0.97	
ដំណាក់កាលក្រោយ	7.2	0.9	0.67	725

ដំណាក់កាលដំបូង អាយុ10ខែ-អាយុ18ខែ ដំណាក់កាលក្រោយ អាយុ18ខែ-អាយុ27ខែ

[3] ចំណុចសំខាន់ៗនៃការគ្រប់គ្រងនៅដំណាក់កាលចិញ្ចឹមបំប៉ន

នៅដំណាក់កាលចុងក្រោយនៃការចិញ្ចឹមបំប៉ន អាចមានការកើតឡើងនូវ"ការមិនព្រមស៊ីចំណី"របស់សត្វគោ ដោយបរិមាណស៊ីចំណីរបស់វាមិនមានលក្ខណៈថេរដោយសារនៅរយៈពេលខ្លះ ចំណង់អាហាររបស់គោមានលក្ខណៈធ្លាក់ចុះខ្លាំងភ្លាមៗ។ ដូច្នេះ គេត្រូវសង្កេតចំពោះបម្រែបម្រួលនៃបរិមាណស៊ីចំណីរបស់គោដោយប្រុងប្រយ័ត្នជាប្រចាំថ្ងៃ ហើយនៅពេលឃើញមានអាការៈនៃ"ការមិនព្រមស៊ីចំណី"របស់គោ គេត្រូវពិភាក្សាជាមួយពេទ្យសត្វ ដើម្បីស្វែងរកមូលហេតុនិងវិធីផ្តល់ចំណីដែលសមស្រប។ មូលហេតុនៃការមិនព្រមស៊ីចំណីរបស់គោ ភាគច្រើនគឺដោយសារជំងឺឡើងអាស៊ីតក្នុងក្រពះទីមួយ(រូមេន)។ ជំងឺនេះបណ្តាលមកពីការផ្តល់ចំណីធញ្ញជាតិច្រើនដល់គោ។

ជំងឺទាក់ទងនឹងប្រព័ន្ធតម្រងនោមដែលច្រើនកើតមាននៅក្នុងការចិញ្ចឹមបំប៉នគោក្រៀវ គឺជំងឺក្រួសក្នុងប្រព័ន្ធតម្រងនោម។ នៅដំណាក់ដំបូងនៃជំងឺនេះ គេឃើញមានក្រួសពណ៌ប្រផេះតូចៗនៅតាមប្រដាប់ភេទរបស់គោ។ ករណីធ្ងន់ធ្ងរ ជំងឺនេះអាចធ្វើអោយគោមានអាការៈដូចជា ឈឺចាប់នៅផ្នែកចង្កេះ នោមមិនចេញ មិនស៊ីចំណីទាល់តែសោះ ធ្លាយថ្លោកនោម សារធាតុទឹកនោមចូលក្នុងឈាម ដែលអាចបណ្តាលអោយសត្វគោងាប់។ ដូច្នេះ គេត្រូវសង្កេតមើលអាការៈដើម្បីរកឃើញជំងឺនៅដំណាក់កាលដំបូង និងអោយគោទទួលការពិនិត្យពីពេទ្យសត្វ ។

ជំងឺដែលអាចកើតមាននៅដំណាក់កាលចិញ្ចឹមបំប៉ន ក្រៅអំពីជំងឺក្រួសក្នុងប្រព័ន្ធតម្រងនោមនិងជំងឺឡើងអាស៊ីតនៅក្រពះទីមួយ ក៏នៅមានរោគសញ្ញានៃខ្យល់ក្នុងក្រពះទីមួយដែលអាចកើតមានលើគោចិញ្ចឹមបំប៉នផងដែរ។ រោគសញ្ញានេះកើតឡើងនៅពេលដែលខ្យល់កើតមានក្នុងក្រពះទីមួយរបស់គោមិនអាចបញ្ចេញមកក្រៅបានដោយរលូន។

សត្វគោប្រើជើងទាំង4ដើម្បីទ្រទម្ងន់ដ៏ធ្ងន់របស់វា ដូច្នេះការថែរក្សាក្រចកជើងគោអោយស្ថិតនៅទម្រង់ប្រក្រតីគឺជាល័ក្ខខ័ណ្ឌដែលមិនអាចខ្វះបានទេសម្រាប់ការគ្រប់គ្រងសុខភាពរបស់គោចិញ្ចឹមបំប៉ន ហេតុនេះហើយទើបគេចាំបាច់ត្រូវធ្វើការកាត់ក្រចកជើងគោអោយបានទៀងទាត់។

ក្រចកជើងគោដែលមានប្រវែងធម្មតា

ក្រចកជើងគោដែលដុះវែងជ្រុល

[4] ការធ្វើចំណាត់ថ្នាក់សាច់ជាប់ឆ្អឹងរបស់គោជប៉ុន

ការលក់ដូរសាច់គោ គឺត្រូវបានធ្វើឡើងដោយយកលទ្ធផលនៃការធ្វើចំណាត់ថ្នាក់សាច់ជាប់ឆ្អឹងជាមូលដ្ឋាន។

សាច់ជាប់ឆ្អឹង គឺជាសាច់ដែលនៅសល់បន្ទាប់ពីគេយកគ្រឿងក្នុង និងស្បែកជាដើម ចេញពីរាងកាយរបស់គោ។ ការធ្វើចំណាត់ថ្នាក់ គឺជាការចាត់ថ្នាក់ បន្ទាប់ពីការវាយតម្លៃទៅលើសាច់លាយខ្លាញ់ ពណ៌របស់សាច់ ភាពរឹងនិងណែននៃសាច់ ពណ៌និងគុណភាពខ្លាញ់របស់សាច់ដែលទទួលបានក្រោយពីកាត់ឆ្អឹងជំនីទី6-7ចេញពីសាច់ជាប់ឆ្អឹង។ លក្ខណៈពិសេសរបស់ពូជគោជប៉ុនរោមខ្មៅ គឺសាច់ជាប់ខ្លាញ់របស់វាមានចំណាត់ថ្នាក់ល្អជាងគោផ្សេងៗ (គោពូជបង្កាត់ និងគោហុលស្តាញក្រៀវជាដើម)។

មូលហេតុ1 ដែលគេចិញ្ចឹមបំប៉នពូជគោជប៉ុនរោមខ្មៅក្នុងរយៈពេលយូរ គឺដោយសារតែគេទាមទារចំណាត់ថ្នាក់នៃសាច់ជាប់ខ្លាញ់កាន់តែខ្ពស់។ សាច់ជាប់ខ្លាញ់ ត្រូវបានគេហៅម៉្យាងទៀតថា "ថ្មម៉ាប (marble)"។

ដើម្បីបង្កើនគុណភាពសាច់ជាប់ខ្លាញ់ ការឲ្យចំណីដែលមានវីតាមីន A បន្ថែមក៏មានដែរ។

2 គោក្រៀវពូជហុលស្តាញ

កូនគោឈ្មោលនៃពូជគោទឹកដោះហុលស្តាញនឹងត្រូវគេក្រៀវហើយចិញ្ចឹមធ្វើជាគោចិញ្ចឹមយកសាច់។ ជាទូទៅ គេហៅថា ការចិញ្ចឹមបំប៉នគោក្រៀវពូជហុលស្តាញ។

(1) ការគ្រប់គ្រងកូនគោពូជហុលស្តាញ

[1] ទម្ងន់របស់កូនគោពូជហុលស្តាញនៅពេលកើត

ទម្ងន់ជាមធ្យមរបស់កូនគោពូជហុលស្តាញនៅពេលកើត គឺប្រហែល 45គីឡូក្រាម។

[2] ការឲ្យទឹកដោះដំបូង

ដូចគ្នាទៅនឹងករណីពូជគោជប៉ុនរោមខ្មៅ ដែលមាននៅក្នុងទំព័រ (ទំព័រ49) មុនដែរ។ ការឲ្យទឹកដោះដំបូងគឺជាជំហានទី1 ក្នុងការចិញ្ចឹមគោឲ្យមានសុខភាពល្អ។

[3] គម្រោងឲ្យចំណីក្រោយពេលកើត

គម្រោងឲ្យចំណីនៅក្នុងអំឡុងពេលបំបៅដោះ គឺត្រូវអនុវត្តឡើងទៅតាមកម្មវិធីដូចគ្នានឹងពូជគោជប៉ុនរោមខ្មៅដែរ។ ពោលគឺ ក្រោយពីឲ្យទឹកដោះដំបូងបានគ្រប់គ្រាន់ហើយ ត្រូវឲ្យទឹកដោះជំនួសនិងទឹកដោះសិប្បនិម្មិតបន្ទាប់មកទៀតត្រូវឲ្យស្មៅខ្ចីទៅកូនគោ (សូមមើលទំព័រមុនៗ)។ ដោយសារតែកូនគោងាយនឹងកើតជំងឺរាករូសដូច្នេះនៅពេលផ្លាស់ប្តូរពីទឹកដោះដំបូងទៅទឹកដោះជំនួស ត្រូវដាក់ទឹកដោះដំបូងលាយទៅក្នុងទឹកដោះជំនួសហើយចាំបាច់ត្រូវផ្លាស់ប្តូរបន្តិចម្តងៗ ដោយពិនិត្យមើលលើស្ថានភាពរបស់កូនគោ។

នៅក្នុងតារាងខាងក្រោមនេះ មានបង្ហាញពីស្ថានភាពលាមកកូនគោទើបនឹងកើតថ្មីៗដែលមានលក្ខណៈធម្មតា។

លាមកកូនគោដែលមានលក្ខណៈធម្មតា

ការបែងចែកលាមក	ស្ថានភាពលក្ខណៈរបស់លាមក
1សប្តាហ៍ក្រោយពេលកើត	ពណ៌របស់លាមក គឺពណ៌លឿង-ពណ៌គ្មោតស្រាល វាមានភាពស្អិតអន្ទឹលៗដែលមានស្ថានភាពដូចបបរ-ស្ថានភាពដូចខ្លាញ់សត្វ ហើយវាគ្មានសារធាតុរឹងទេ។
ក្រោយពេលផ្លាស់ប្តូរទៅទឹកដោះជំនួស	ពណ៌របស់លាមក ប្រែពីពណ៌លឿងទៅពណ៌ស្រអាប់។ ហើយនៅពេលដែលវាចាប់ផ្តើមស៊ីស្មៅស្ងួតឬចំបើង លាមករបស់វាមានស្ថានភាពជាម្សៅស្អិតៗដូចខ្លាញ់សត្វដែលមានសារធាតុរឹងនៅក្នុងនោះ។

(2) ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងកូនគោ

ចំណុចនេះមានខ្លឹមសារដូចទៅនឹង"ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងកូនគោ"នៅក្នុងផ្នែកពូជគោជប៉ុនរោមខ្មៅដែលមានរៀបរាប់នៅផ្នែកខាងលើផងដែរ(ទំព័រទី26 ចំណុច (4))។ រូបថតខាងក្រោមបង្ហាញអំពីការចិញ្ចឹមកូនគោនៅក្នុងកូនផ្ទះសម្រាប់កូនគោ។

កូនគោពូជហុលស្តាញ និង កូនផ្ទះសម្រាប់កូនគោ

[1] ការកាត់ស្នែង

នៅពេលគេធ្វើការគ្រប់គ្រងសត្វគោជាហ្វូង ប្រសិនបើគេទុកអោយស្នែងគោដុះ វាអាចបង្កអោយមាន"គ្រោះថ្នាក់ដល់អ្នកគ្រប់គ្រង"និង"របួសដោយសារការជល់ស្នែងរវាងគោគ្នាឯង" កើនឡើង ដូច្នេះ សម្រាប់ពូជហុលស្តាញ គេធ្វើការកាត់ស្នែងកូនគោក្នុងអំឡុងពេល3ខែក្រោយពេលវាកើត។

[2] ការក្រៀវសត្វ

ដើម្បីកាត់បន្ថយការប្រជែងគ្នាក្នុងចំណោមសត្វគោ និង ដើម្បីធ្វើអោយគុណភាពសាច់មានលក្ខណៈល្អប្រសើរ គេចាំបាច់ត្រូវធ្វើការក្រៀវគោនៅពេលវាមានអាយុលើសពី3ខែ។

(3) ចំណុចសំខាន់ៗនៃការគ្រប់គ្រងនៅដំណាក់កាលលូតលាស់

ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងនៅដំណាក់កាលលូតលាស់ដែលគោមានអាយុ4~10ខែ រួមមាន "ការជម្រុញការលូតលាស់នៃក្រពះសម្រាប់ការខ្លាក់ចំណីមកទំពានិងរោមនៅលើភ្នាសនៃក្រពះទីមួយ"និង "ការធ្វើអោយសាច់ដុំនិងឆ្អឹងមានលក្ខណៈរឹងមាំពេញលេញ"។ ក្នុងគោលបំណងនេះ វាមានសារៈសំខាន់ណាស់ដែលគេត្រូវផ្តល់ស្មៅស្ងួតដែលមានគុណភាពល្អជាប្រចាំដល់សត្វគោ ស្របពេលជាមួយនឹងការផ្តល់ចំណីលាយក្នុងបរិមាណសមស្របទៅអោយសត្វគោ។ បរិមាណនៃចំណីលាយដែលគេគួរផ្តល់អោយសត្វគោគឺ 5គីឡូក្រាមសម្រាប់គោដែលមានអាយុ5ខែ ហើយ6គីឡូក្រាមសម្រាប់គោដែលមានអាយុ6ខែ។

(4) ការចិញ្ចឹមបំប៉នគោក្រៀវពូជហុលស្តាញ

គេចាប់ផ្តើមចិញ្ចឹមបំប៉នគោក្រៀវពូជហុលស្តាញចាប់ពីកូនគោមានអាយុ7~8ខែ និងមានទម្ងន់ប្រហែល280គីឡូក្រាមរហូតដល់ពេលវាមានអាយុប្រហែល20ខែ។

ឧទាហរណ៍នៃការឲ្យចំណីនៅក្នុងការចិញ្ចឹមបំប៉នគោក្រៀវពូជហុលស្តាញនៅតំបន់ឃ្យូហ្សូ គឺមានបង្ហាញដូចខាងក្រោម។

ឧទាហរណ៍នៃការផ្តល់ចំណីរបស់កសិករចិញ្ចឹមបំប៉ននៅតំបន់ឃ្យូហ្សូ

អាយុជាខែនៃការចិញ្ចឹមបំប៉ន		7～11	11～18	18～22
បរិមាណនៃការឡើងទម្ងន់នៅចន្លោះអាយុនិមួយៗ	គីឡូក្រាមថ្ងៃ	1.3	0.7	0.8
ចំបើងស្រូវ	គីឡូក្រាមថ្ងៃ	3	1	0.6
ស្មៅស្ងួត	គីឡូក្រាមថ្ងៃ	1	0	0
ចំណីលាយ	គីឡូក្រាមថ្ងៃ	4	10～11	12

(5) ចំណុចសំខាន់ៗនៃការគ្រប់គ្រងនៅដំណាក់កាលចិញ្ចឹមបំប៉ន

ដូចដែលមានរៀបរាប់នៅក្នុងផ្នែកនៃគោចិញ្ចឹមបំប៉នពូជគោជប៉ុនរោមខ្មៅដូច្នោះដែរ គឺគេចាំបាច់ត្រូវធ្វើការសង្កេតមើលជាប្រចាំថ្ងៃទាក់ទងនឹងជំងឺឡើងអាស៊ីតក្នុងក្រពះទីមួយនិងជំងឺក្រូសក្នុងប្រព័ន្ធតម្រងនោមរបស់គោ ហើយត្រូវពិភាក្សានិងទទួលការព្យាបាលពីពេទ្យសត្វអោយបានត្រឹមត្រូវ។

3 ពូជបង្កាត់ (F1)

គេធ្វើការបង្កកំណើតសិប្បនិម្មិតដោយចាក់ទឹកកាមរបស់ពូជគោជប៉ុនរោមខ្មៅទៅក្នុងគោញីនៃពូជគោទឹកដោះហុលស្តាញ ហើយកូនគោដែលកើតដោយការបង្កកំណើតបែបនេះ ហៅថា ពូជបង្កាត់ (F1)។ ទម្ងន់របស់គោក្រៀវនៅពេលកើតស្តិតនៅចន្លោះពូជគោជប៉ុនរោមខ្មៅនិងពូជគោហុលស្តាញគឺប្រហែល40គីឡូក្រាម។ វាមានទំហំតូចជាងពូជគោហុលស្តាញ ដោយនេះជាគុណប្រយោជន៍មួយដែរ ព្រោះវាធ្វើអោយការកើតកូនដំបូងនៃមេគោហុលស្តាញអាចប្រព្រឹត្តទៅបានងាយស្រួលជាងធម្មតា។

(1) គោលបំណងនៃការបង្កាត់ពូជគោF1

គោលបំណងនៃការប្រើប្រាស់ពូជគោបង្កាត់ គឺដើម្បីបង្កើតបានគោចិញ្ចឹមយកសាច់ដែលរួមបញ្ចូលលក្ខណៈពិសេសនៃពូជគោជប៉ុនរោមខ្មៅដែលមានសាច់ជាប់ឆ្អឹងលាយជាមួយខ្លាញ់ល្អ និង លក្ខណៈពិសេសនៃពូជគោហុលស្តាញដែលកើនទម្ងន់បានល្អ ។

(2) ការគ្រប់គ្រងកូនគោ ការគ្រប់គ្រងនៅដំណាក់កាលលូតលាស់ និង ការគ្រប់គ្រងការចិញ្ចឹមបំប៉ន

ចំណុចនេះមានខ្លឹមសារមូលដ្ឋានដូចទៅនឹងខ្លឹមសារដែលគេបានរៀបរាប់ខាងលើទាក់ទងនឹងពូជគោជប៉ុនរោមខ្មៅនិងគោក្រៀវពូជហុលស្តាញផងដែរ ដូច្នេះ សូមពិនិត្យខ្លឹមសារទាំងនេះ ប្រសិនបើត្រូវធ្វើការងារដូចគ្នាទាក់ទងនឹងពូជគោបង្កាត់។

(3) ការចិញ្ចឹមបំប៉នពូជគោបង្កាត់

គេចាប់ផ្តើមធ្វើការចិញ្ចឹមបំប៉នពូជគោបង្កាត់នៅពេលវាមានអាយុ7ខែនិងមានទម្ងន់ប្រហែល250គីឡូក្រាម ហើយជាទូទៅ គេបញ្ចេញគោទាំងនោះសម្រាប់លក់នៅពេលវាមានអាយុ25ខែនិងមានទម្ងន់ប្រហែល730គីឡូក្រាម។

ឧហរណ៍មួយនៃប្រព័ន្ធចិញ្ចឹមសត្វនៅក្នុងការចិញ្ចឹមបំប៉នគោពូជបង្កាត់ មានបង្ហាញដូចខាងក្រោមនេះ។

ប្រព័ន្ធនៃការចិញ្ចឹមបំប៉នពូជបង្កាត់ (ឧទាហរណ៍)

	ដំណាក់កាលដំបូង	ដំណាក់កាលកណ្តាល	ដំណាក់កាលក្រោយ
	អាយុ 7-11.5ខែ	អាយុ 11.5-18.5ខែ	អាយុ 11.5-25ខែ
ទម្ងន់កើនប្រចាំថ្ងៃ គីឡូក្រាម	1.0—1.17	1.17—0.83	0.67—0.33
ចំណីលាយ គីឡូក្រាមថ្ងៃ	5.0—8.5	9.0—11.0	8.5—7.5
ដុំអាល់ហ្វាល់ហ្វា	1.2—0.7	0.5 (-13.5ខែ)	0
ចំបើងស្រូវ	0.6—1.0	1.0	0.8—0.6

＊ចំណីលាយនៅក្នុងដំណាក់កាលក្រោយក្នុងអាយុ 22-25ខែ មានស្រូវសាលីនៅក្នុងចំណី

3 សត្វជ្រូក

1 ការបន្តពូជនិងការគ្រប់គ្រងជ្រូកបង្កាត់ពូជ

វដ្តនៃការបង្ហាញចំណង់ផ្លូវភេទរបស់ជ្រូកញីគឺមានរយៈពេល21ថ្ងៃ ដោយជ្រូកនឹងឆ្លងកាត់ម្តងហើយម្តងទៀតនូវ ដំណាក់កាលដំបូងនៃការបង្ហាញចំណង់ផ្លូវភេទ ដំណាក់កាលបង្ហាញចំណង់ផ្លូវភេទ ដំណាក់កាលចុងក្រោយនៃការបង្ហាញចំណង់ផ្លូវភេទ និង ដំណាក់កាលផ្អាកការបង្ហាញចំណង់ផ្លូវភេទដែលពុំឃើញមានអាការៈទាក់ទងនឹងចំណង់ផ្លូវភេទនោះទេ។ ជ្រូកបង្កាត់ពូជញីធ្វើការបន្តពូជដោយស្ទាបស្ទង់ពេលវេលាសមស្របបំផុតសម្រាប់ការបន្តពូជ។ ការបន្តពូជអាចជា ការបន្តពូជដោយធម្មជាតិ ការបង្កកំណើតសិប្បនិម្មិត(AI) ឬករណីទាំងពីររួមគ្នា។ នៅរយៈពេល21ថ្ងៃក្រោយការបន្តពូជ ប្រសិនបើពុំឃើញជ្រូកមានអាការៈបង្ហាញចំណង់ផ្លូវភេទនោះទេ គេអាចវិនិច្ឆ័យបានថាជ្រូកចាប់ផ្តើមពពោះហើយ។

ក្នុងអំឡុងពេលពពោះ គេធ្វើការចិញ្ចឹមជ្រូកនៅក្នុងទ្រុងដាច់ដោយឡែកតែឯង ហើយនៅពេលជិតដល់ពេលជ្រូកកើតកូន គេនឹងប្តូរទីតាំងដោយយកជ្រូកទៅដាក់ក្នុងទ្រុងជ្រូកដែលមានរបងព័ទ្ធដែលប្រើសម្រាប់ពេលជ្រូកបង្កើតកូន។

នៅពេលជ្រូកបង្កើតកូន មិនសូវកើតមានការលំបាកក្នុងការបង្កើតនោះទេ ហើយជ្រូកមេអាចបង្កើតកូនបានម្តង1ក្បាលនិងមានគម្លាតពីគ្នាប្រហែល10នាទី។ នៅពេលកូនជ្រូកកើតអស់ហើយ សុកនឹងចាប់ផ្តើមចេញមក ហើយបញ្ចប់ទៅវិញក្នុងរយៈពេល2~3ម៉ោង។ ក្នុងអំឡុងពេលបំបៅដោះកូនក្រោយបង្កើតកូនរួច ជ្រូកមេនឹងមិនបង្ហាញចំណង់ផ្លូវភេទនោះទេ។ នៅក្រោយពេលកូនជ្រូកផ្តាច់ដោះបាន4~5ថ្ងៃ ជ្រូកមេនឹងចាប់ផ្តើមវដ្តនៃការបង្ហាញចំណង់ផ្លូវភេទសាជាថ្មី។

ការលើសទម្ងន់នៃជ្រូកដែលកំពុងពពោះអាចធ្វើអោយកូនជ្រូកក្នុងផ្ទៃលូតលាស់មិនបានល្អឬជាមូលហេតុធ្វើអោយការបង្កើតកូនមានការលំបាក ដូច្នេះ គេចាំបាច់ត្រូវពិនិត្យមើលស្ថានភាពរាងកាយរបស់ជ្រូកមេ និង ធ្វើការផ្តល់ចំណីដោយមានកម្រិតកំណត់។ នៅដំណាក់កាលចុងក្រោយនៃការពពោះ គេធ្វើការបង្កើនបរិមាណចំណីដល់ជ្រូកមេបន្តិចដើម្បីបំពេញនូវការលូតលាស់របស់កូនជ្រូកក្នុងផ្ទៃ។

ជ្រូកបង្កាត់ពូជដែលស្ថិតក្នុងដំណាក់កាលបំបៅដោះងាយនឹងថយចុះទម្ងន់ដោយសារការបញ្ចេញទឹកដោះ ដូច្នេះ គេចាំបាច់ត្រូវបន្ថែមបរិមាណចំណីដល់ជ្រូកទាំងនេះ។

ក្រោយពេលបង្កើតកូន គេនឹងចាប់ផ្តើមបង្កើនបរិមាណចំណីដល់សត្វជ្រូកបន្តិចម្តងៗ ហើយប្រសិនបើចំណីឆាប់អស់មិនទាន់ការស៊ីរបស់ជ្រូក គេអាចប្រើវិធីបង្កើនចំនួនដងនៃការអោយចំណី។ល។ នៅពេលកូនជ្រូកផ្តាច់ដោះ ហើយដំណាក់កាលបំបៅដោះបានបញ្ចប់ គេត្រូវប្រុងប្រយ័ត្នចំពោះស្ថានភាពរាងកាយរបស់ជ្រូកមេនិងធ្វើការគ្រប់គ្រងបរិមាណចំណីអោយបានសមស្រប។

គេប្រើជ្រូកបង្កាត់ពូជឈ្មោល(ជ្រូកពូជឈ្មោល) បន្ទាប់ពីធ្វើការពិនិត្យទឹកកាមរបស់វាដើម្បីដឹងអំពីចំនួននិងកម្លាំងសកម្មរបស់មេជីវិតឈ្មោល។ ក្នុងករណីចិញ្ចឹមជ្រូកឈ្មោលសម្រាប់ធ្វើការបន្តពូជដោយធម្មជាតិ គេចាំបាច់ត្រូវធ្វើការគ្រប់គ្រងដើម្បីទប់ស្កាត់កុំអោយជ្រូកឈ្មោលធំធាត់និងមានមាឌធំខ្លាំងលើសទំហំរាងកាយរបស់ជ្រូកញី។

2 ការបំបៅដោះនិងការលូតលាស់របស់កូនជ្រូក

នៅដំណាក់កាលបំបៅដោះនិងក្រោយពេលផ្តាច់ដោះភ្លាមៗ អត្រានៃការកើតមានឧបទ្ទវហេតុចំពោះកូនជ្រូកមានការកើនឡើងខ្ពស់បំផុត។ កូនជ្រូកកើតចេញមកដោយមានរាងកាយមិនទាន់ពេញលក្ខណៈនៅឡើយទេ

ដោយបន្ទាប់ពីកើត វានឹងចាប់ផ្តើមបំពេញនូវសមត្ថភាពនៃប្រព័ន្ធភាពស៊ាំនិងប្រព័ន្ធរំលាយអាហារយ៉ាងឆាប់រហ័ស ហើយវានឹងចាប់ផ្តើមលូតលាស់យ៉ាងខ្លាំងក្លា ដោយនៅពេលផ្តាច់ដោះ កូនជ្រូកនឹងមានទម្ងន់លើសពី6ដងធ្ងន់ជាងពេលទើបនឹងកើត។ ប៉ុន្តែ ក្នុងដំណាក់កាលនេះ វាងាយនឹងកើតមានអតុល្យភាពនៅក្នុងរាងកាយ។ ប្រសិនបើគេឃើញកន្ទុយរបស់កូនជ្រូកធ្លាក់សំយុងចុះក្រោម មានន័យថាកូនជ្រូកកំពុងមិនស្រួលខ្លួន។ ជ្រូកដែលមានសុខភាពល្អនឹងមិនមានសារធាតុបញ្ចេញដែលជាប់នៅនឹងរន្ធកនោះទេ ហើយច្រមុះមានជាតិសំណើមគ្រប់គ្រាន់ កន្ទុយក៏មានលក្ខណៈខ្វៀន និងរោមមានលក្ខណៈភ្លឺ។

គេចាំបាច់ត្រូវផ្តល់ទឹកដោះរបស់ជ្រូកមេ(ទឹកដោះដំបូង)ដល់កូនជ្រូកដែលទើបនឹងកើតភ្លាមអោយបានគ្រប់គ្រាន់។ ទឹកដោះដំបូងគឺសំដៅលើទឹកដោះរបស់ជ្រូកមេគិតចាប់ពីពេលកើតកូនភ្លាមរហូតដល់ថ្ងៃទី2។ នៅក្នុងទឹកដោះដំបូងមានផ្ទុកអង់ទីករ(អង់ទីករនៃប្រព័ន្ធភាពស៊ាំ)ទប់ទល់នឹងជំងឺផ្សេងៗដែលអាចកើតមាននៅលើកូនជ្រូក ដូច្នេះ គេត្រូវអោយកូនជ្រូកផឹកទឹកដោះដំបូងនេះ ទើបរាងកាយរបស់វាអាចទទួលបាននូវកម្លាំងទប់ទល់នឹងជំងឺពីខាងក្រៅ។

ម្យ៉ាងទៀត កូនជ្រូកអាចនឹងខ្វះជាតិដែកដែលជាវត្ថុធាតុសម្រាប់ផលិតគ្រាប់ឈាមក្រហមនៅក្នុងរាងកាយ ដូច្នេះ ត្រូវផ្តល់ថ្នាំជាតិដែកទៅអោយកូនជ្រូកទៅតាមការចាំបាច់។

ក្រោយពេលកើតបានប៉ុន្មានថ្ងៃ គេក៏ត្រូវបំបៅដោះជាមួយគ្នាក្នុងរយៈខ្លីផងដែរ។ ជាធម្មតាគេបំបៅដោះប្រហែល 24ដងក្នុង 1ថ្ងៃ។ ស្ថានភាពសុខភាពរបស់ជ្រូកមេ និងបរិមាណចេញទឹកដោះ មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងការរីកធំធាត់របស់កូនជ្រូក។ ក្រោយពេលកើតមួយសប្តាហ៍ គេក៏ត្រូវឲ្យចំណី (ទឹកដោះសិប្បនិម្មិត) សម្រាប់ការចាប់ផ្តើមឲ្យចំណីផងដែរ គឺដើម្បីឲ្យវាស៊ាំនឹងចំណីរឹងក្រៅពីទឹកដោះមេរបស់វា។

ការផ្តាច់ដោះពីជ្រូកមេ ជាធម្មតាគេធ្វើឡើងនៅក្នុងរយៈពេល 3-4សប្តាហ៍ក្រោយពេលកើត។ ករណីផ្តាច់ដោះមុនកាលកំណត់ដែលលឿនជាងការផ្តាច់ដោះធម្មតា ដែលគេហៅថា SEW ក៏មានដែរ ប៉ុន្តែប្រសិនបើផ្តាច់ដោះមុនរយៈពេល 2សប្តាហ៍ អាចធ្វើឲ្យមានឥទ្ធិពលអាក្រក់ដល់វដ្តនៃការបង្ហាញចំណង់ផ្លូវភេទ និងអត្រានៃការបង្កកំណើត។

ចំណីដែលត្រូវឲ្យក្រោយការផ្តាច់ដោះ គឺទឹកដោះសិប្បនិម្មិតA ប៉ុន្តែគេក៏ត្រូវឲ្យចំណីសម្រាប់ការចាប់ផ្តើមឲ្យចំណីលាយជាមួយគ្នាផងដែរ ក្នុងរយៈពេលប៉ុន្មានថ្ងៃរហូតដល់ត្រឹមពេលនោះ។



ឧទាហរណ៍នៃការគ្រប់គ្រងការចិញ្ចឹម និងការរីកធំធាត់របស់កូនជ្រូក

3 របៀបចិញ្ចឹមជ្រូកចិញ្ចឹមបំប៉ន និង អគារ/បរិក្ខារ

ជាទូទៅ គេធ្វើការគ្រប់គ្រងជ្រូកចិញ្ចឹមបំប៉នដោយចិញ្ចឹមជាហ្វូងចំនួនចាប់ពី10ក្បាលឡើងទៅ(ការចិញ្ចឹមជាហ្វូង)។ ជាទូទៅ រោងចិញ្ចឹមបំប៉នជ្រូក(រោងចិញ្ចឹមជ្រូកយកសាច់) ជារោងចិញ្ចឹមជ្រូកដែលមានកម្រាលជាបន្ទះក្តារតម្រៀប ។ នៅពេលដង់ស៊ីតេជ្រូកមានការកើនឡើង ជ្រូកអាចទទួលអារម្មណ៍ស្ត្រេសដោយសារសកម្មភាពវាយប្រហារគ្នាជាដើម ដូច្នេះ គេចាំបាច់ត្រូវធានាអោយមានផ្ទៃក្រឡាសម្រាប់ជ្រូក1ក្បាលទម្ងន់50គីឡូក្រាមគឺ0.7m² និង 1.0m² សម្រាប់ជ្រូកទម្ងន់100គីឡូក្រាម។ ប្រសិនបើផ្ទៃក្រឡានៃកន្លែងចិញ្ចឹមជ្រូកមានលក្ខណៈតូចចង្អៀតជាងនេះ វានឹងផ្តល់ឥទ្ធិពលអាក្រក់ដល់លទ្ធភាពផលិតកម្ម។

ជាទូទៅ គេអោយចំណីដល់ជ្រូកចិញ្ចឹមបំប៉នជាលក្ខណៈសើរ។ គេប្រើឧបករណ៍ផ្តល់ចំណីដោយសើរ(ឧបករណ៍ស៊ីចំណីដោយខ្លួនឯង) ដើម្បីធ្វើអោយជ្រូកអាចស៊ីចំណីបានគ្រប់ពេលវេលា។ នៅក្នុងរោងចិញ្ចឹមជ្រូក មុននឹងទៅដល់ឧបករណ៍ផ្តល់ចំណី(ស្នូកដាក់ចំណី) គេរៀបអោយមានឧបករណ៍ផ្តល់ចំណីដោយស្វ័យប្រវត្តិ។ គឺគេបំពាក់ឧបករណ៍ផ្តល់ចំណីជារចនាសម្ព័ន្ធអាចអោយគេអនុវត្តការផ្តល់ចំណីដោយសើរដល់សត្វជ្រូក ម្យ៉ាងទៀត គេក៏មានឧបករណ៍បន្សើមចំណីដែលមានរចនាសម្ព័ន្ធអាចអោយជ្រូកស៊ីចំណីដោយលាយជាមួយនឹងទឹកបណ្តើរ។

4 ទម្លាប់របស់សត្វជ្រូក និង របៀបធ្វើការងារជាមួយសត្វជ្រូក

ជ្រូកជាសត្វដែលរស់នៅជាហ្វូង ដោយវាមានទម្លាប់រស់នៅដោយប្រមូលផ្តុំគ្នាបង្កើតជាហ្វូង។ នៅពេលគេចិញ្ចឹមសត្វជាហ្វូង វាអាចកើតមាននូវការបែងចែងរវាងសត្វខ្សោយនិងសត្វខ្លាំង ដូច្នេះ ចាំបាច់ធ្វើយ៉ាងណាអោយជ្រូកដែលខ្សោយក៏អាចស៊ីចំណីបានគ្រប់គ្រាន់ផងដែរ។ ម្យ៉ាងទៀត សត្វជ្រូកជាសត្វដែលស្លូត ចូលចិត្តជិតស្និទ្ធជាមួយមនុស្ស និងមានសមត្ថភាពបែងចែកដឹងមនុស្ស។ ជាពិសេស ឃានវិញ្ញាណនិងសោតវិញ្ញាណរបស់សត្វជ្រូកមានលក្ខណៈមុតស្រួច។ ប៉ុន្តែ វាជាសត្វដែលកំសាក ងាយប្រតិកម្មទៅនឹងចលនាឬសម្លេងផ្សេងៗ។ ដូច្នេះ គេត្រូវប៉ះពាល់ជ្រូកដោយទន់ភ្លន់ មិនត្រូវធ្វើអោយវាភ្ញាក់នោះទេ។ នៅពេលបញ្ចេញលក់ក៏ដូចគ្នាដែរ គឺគេត្រូវលើកដាក់សត្វជ្រូកកុំអោយវាទទួលអារម្មណ៍ស្ត្រេស។ ការមានអារម្មណ៍ស្ត្រេសនឹងមានឥទ្ធិពលទៅលើគុណភាពសាច់របស់សត្វជ្រូក។

គេធ្វើការបែងចែកនិងកំណត់កន្លែងច្បាស់លាស់សម្រាប់បន្ទោរបង់លាមក បន្ទោរបង់ទឹកនោម និង កន្លែងសម្រាប់ដេកអោយសត្វជ្រូក។ កន្លែងដែលទាបនិងមានសំណើមងាយស្លាយជាកន្លែងសម្រាប់បន្ទោរបង់។ ម្យ៉ាងទៀត ប្រសិនបើជ្រូកដែលស្ថិតនៅទ្រុងជាប់គ្នាមានលក្ខណៈប្រជែងគ្នា នោះសត្វជ្រូកអាចនឹងមានទម្លាប់បន្ទោរបង់លាមកនៅរបងដែលជាខ្សែព្រំដែនរវាងជ្រូកដែលមិនត្រូវគ្នានោះ។

5 ចំណីរបស់សត្វជ្រូក

គេបែងចែកចំណីសត្វជ្រូកជាបីធំៗ គឺ ទឹកដោះសិប្បនិម្មិតសម្រាប់កូនជ្រូក ចំណីសម្រាប់ការលូតលាស់ ចំណីសម្រាប់ការចិញ្ចឹមបំប៉ន។ បរិមាណសារធាតុចិញ្ចឹមដែលជ្រូកត្រូវការមានភាពខុសប្លែកគ្នាទៅតាមដំណាក់កាលលូតលាស់របស់សត្វជ្រូក ដូច្នេះ គេធ្វើគម្រោងរៀបចំការផ្តល់សារធាតុចិញ្ចឹមដែលស្របទៅនឹងដំណាក់កាលនីមួយៗរបស់ជ្រូក។ ដើម្បីដឹងអំពីតួលេខច្បាស់លាស់នៃបរិមាណសារធាតុចិញ្ចឹមដែលជ្រូកត្រូវការ គេពិនិត្យមើលព័ត៌មាននៅក្នុងបទដ្ឋាននៃការចិញ្ចឹមសត្វ។ ប្រការដែលត្រូវពិនិត្យមើលទាក់ទងនឹងសារធាតុចិញ្ចឹម រួមមាន ថាមពល (ភាគច្រើនសំដៅលើកាបូអ៊ីដ្រាតនិងជាតិខ្លាញ់) ប្រូតេអ៊ីន ជាតិរ៉ែ និង វីតាមីន។

ទឹកដោះសិប្បនិម្មិតគឺជាចំណីទម្រង់ជាម្សៅសម្រាប់ផ្តល់អោយកូនជ្រូក ហើយមានផ្ទុកម្សៅទឹកដោះគ្មានជាតិខ្លាញ់។ ទឹកដោះសិប្បនិម្មិតនេះបែងចែកជាប្រភេទបន្តទៀត រួមមាន ទឹកដោះសិប្បនិម្មិតសម្រាប់ការចាប់ផ្តើមអោយ

ចំណី ទឹកដោះសិប្បនិម្មិតA ទឹកដោះសិប្បនិម្មិតB ជាដើម ហើយគេនឹងផ្តល់ចំណីទៅតាមលំដាប់លំដោយរហូតដល់កូនជ្រូកមានទម្ងន់15គីឡូក្រាម។ ទឹកដោះសិប្បនិម្មិតAគឺសម្រាប់ដំណាក់កាលដំបូងនៃការផ្តាច់ដោះ ហើយទឹកដោះសិប្បនិម្មិតBគឺសម្រាប់ដំណាក់កាលចុងក្រោយនៃការផ្តាច់ដោះ។ បន្ទាប់ពីនោះ ត្រូវផ្តល់ចំណីដូចជា ចំណីសម្រាប់ការលូតលាស់របស់កូនជ្រូកដែលមានផ្ទុកពោតច្រើន ចំណីសម្រាប់ដំណាក់កាលដំបូងនិងដំណាក់កាលចុងក្រោយនៃការចិញ្ចឹមបំប៉ន។ ចំណីសម្រាប់ដំណាក់កាលចុងក្រោយនៃការចិញ្ចឹមបំប៉នមិនត្រូវមានផ្ទុកសារធាតុបន្ថែមក្នុងចំណីដែលជាសារធាតុប្រឆាំងមេរោគនោះទេ។

ទឹកដោះសិប្បនិម្មិត

ចំណីសម្រាប់ការចិញ្ចឹមបំប៉ន

6 វិធីកែច្នៃដើម្បីកាត់បន្ថយការចំណាយលើចំណីសត្វ

អាជីវកម្មចិញ្ចឹមជ្រូកត្រូវការចំណាយច្រើនលើការទិញចំណីសត្វ គឺស្មើនឹង60~70ភាគរយនៃការចំណាយលើផលិតកម្មសរុប។ ដូច្នេះ គេមានបំណងកាត់បន្ថយការចំណាយលើចំណីសត្វ ដោយប្រើប្រាស់វត្ថុធាតុដើមដែលគេអាចរកបាននៅទីកន្លែងជិតហើយថោកដើម្បីផលិតជាចំណីសត្វ។ ឧទាហរណ៍ កាកសំណល់អាហារដែលសល់ពីការផលិតចំណីអាហារឬសល់ពីការលក់ចំណីអាហារ។ ពេលនោះ គេចាំបាច់ត្រូវចងចាំអំពីគម្រោងនៃការរៀបចំសារធាតុចិញ្ចឹមសម្រាប់សត្វ។ ជាពិសេស ប្រសិនបើជាតិខ្លាញ់នៅក្នុងចំណីសត្វមានកម្រិតខ្ពស់ នោះវានឹងមានឥទ្ធិពលមិនល្អលើគុណភាពសាច់។ គេធ្វើការផ្សំនិងផ្តល់ចំណីសត្វស្របទៅតាមបរិមាណចាំបាច់នៃសារធាតុចិញ្ចឹមសម្រាប់ដំណាក់កាលលូតលាស់នីមួយៗរបស់ជ្រូក ដោយយោងទៅតាមបទដ្ឋាននៃការចិញ្ចឹមសត្វនៅប្រទេសជប៉ុន។ ជាពិសេស គេត្រូវរក្សាតុល្យភាពនៃការផ្តល់ចំណីរវាងថាមពល (TDN ឬ DE) និងបរិមាណប្រូតេអ៊ីនបានពីចំណី ព្រមទាំងត្រូវប្រុងប្រយ័ត្នចំពោះកង្វះជាតិរ៉ែ ដូចជា កាល់ស្យូម ផូស្វ័រ ។ល។

7 រយៈពេលនៃការចិញ្ចឹមបំប៉ន ការឡើងទម្ងន់ និងបរិមាណនៃការផ្តល់ចំណីលាយ

នៅក្នុងរយៈពេលនៃការចិញ្ចឹមបំប៉នពីទម្ងន់30គីឡូក្រាមរហូតដល់110-120គីឡូក្រាមដែលអាចបញ្ចេញលក់ ស្របពេលជាមួយគ្នាបរិមាណស៊ីចំណីកើនឡើង ទម្ងន់របស់វាក៏កើនឡើងយ៉ាងឆាប់រហ័សដែរ។ នៅពេលដែលមានទម្ងន់លើស50គីឡូក្រាម វាចាប់ផ្តើមស៊ីចំណីលើសពី 2គីឡូក្រាមក្នុង1ថ្ងៃ ហើយចុងក្រោយវាស៊ីចំណីលើសពី3គីឡូក្រាម។ ទម្ងន់កើនប្រចាំថ្ងៃនៅក្នុងចន្លោះពេលនោះគឺ0.85គីឡូក្រាម។

ការរីកធំធាត់នៃរាងកាយ គឺប្រព្រឹត្តទៅតាមលំដាប់ពីឆ្អឹង សាច់ដុំ (សាច់ក្រហម) និងខ្លាញ់។ ដូច្នេះហើយ នៅដំណាក់កាលដំបូងនៃការចិញ្ចឹមបំប៉ន ត្រូវឲ្យចំណីកុំឲ្យមានការខ្វះខាតប្រូតេអ៊ីនដែលចាំបាច់ចំពោះសាច់ដុំ។ នៅក្នុងដំណាក់កាលក្រោយ ត្រូវបន្ថយបរិមាណប្រូតេអ៊ីនដើម្បីឲ្យបរិមាណផ្ទុកជាតិខ្លាញ់មានការកើនឡើង ហើយត្រូវឲ្យចំណីជាតិម្សៅឲ្យបានច្រើនដើម្បីឲ្យខ្លាញ់មានភាពរឹងល្មមនិងមានរសជាតិឆ្ងាញ់។



8 ជំងឺរបស់សត្វជ្រូកនិងការទប់ស្កាត់

គេចាត់វិធានការដោយផ្អែកលើទស្សនវិស័យចំនួន3ដើម្បីទប់ទល់នឹងជំងឺរបស់សត្វជ្រូក។

[1] ការបំបែកជ្រូកមានជំងឺនិងជ្រូកមានផ្ទុកបាក់តេរីឆ្លងដែលអាចជាប្រភពនៃការឆ្លងជំងឺអោយឆ្ងាយពីជ្រូកផ្សេងទៀត

គេចាត់វិធានការកុំអោយមានការរីករាលដាលនៃមេរោគបង្កជំងឺ ដោយធ្វើការព្យាបាលឬដកសត្វដែលមានបញ្ហាចេញ។

[2] ការទប់ស្កាត់ផ្លូវចម្លង

គេធ្វើការទប់ស្កាត់ការជាប់មកជាមួយឬការជ្រៀតចូលនៃមេរោគបង្កជំងឺតាមរយៈមនុស្ស សត្វកណ្តុរ សត្វស្លាបព្រៃ រថយន្ត ចំណីសត្វ ទឹក សម្ភារៈឧបករណ៍ ។ល។ ក្នុងគោលបំណងនេះ គេអនុវត្តការសម្លាប់មេរោគដែលជាវិធីទប់ស្កាត់ផ្លូវចម្លងដោយធ្វើការកម្ចាត់មេរោគបង្កជំងឺជាមួយនឹងការប្រើថ្នាំពីខាងក្រៅរាងកាយ។ វិធីទប់ស្កាត់ដោយប្រើសម្ភារៈរួមមាន ការប្រើសម្លៀកបំពាក់និងស្បែកជើងកវែងសម្រាប់ប្រើនៅក្នុងរោងចិញ្ចឹមជ្រូកតែប៉ុណ្ណោះ គឺហាមប្រើនៅបរិស្ថានខាងក្រៅ។ គេនឹងធ្វើការដាក់កំណត់លើការចញចូលរោងចិញ្ចឹមជ្រូករបស់មនុស្សមកពីក្រៅ។ ករណីត្រូវអោយពួកគេចេញចូលរោងចិញ្ចឹមសត្វដោយខានពុំបាន គេត្រូវតម្រូវអោយប្រើសម្លៀកបំពាក់ការពារជំងឺឆ្លងនិងស្បែកជើងកវែង។ សម្រាប់ថ្នាំសម្លាប់មេរោគ គេធ្វើការជ្រើសរើសនិងប្រើប្រាស់ថ្នាំស្របទៅតាមគោលដៅនីមួយៗ។ គេអនុវត្តការសម្លាប់មេរោគដោយប្រើអាងជាន់ត្រាំសម្លាប់មេរោគអោយបានម៉ត់ចត់។ ម្យ៉ាងទៀត គេធ្វើការកម្ចាត់សត្វកណ្តុរនិងទប់ស្កាត់មិនអោយមានការចូលនៃសត្វស្លាបឬសត្វផ្សេងៗទៀត។

[3] ការពង្រឹងកម្លាំងទប់ទល់នឹងជំងឺរបស់សត្វជ្រូកដែលមិនទាន់មានជំងឺឆ្លង

សំដៅទៅលើការពង្រឹងប្រព័ន្ធភាពស៊ាំឬកម្លាំងទប់ទល់នឹងជំងឺរបស់ជ្រូកដែលមានសុខភាពល្អមិនទាន់ឆ្លងមេរោគបង្កជំងឺ តាមរយៈការចាក់វ៉ាក់សាំងជាដើម។ ការចាក់វ៉ាក់សាំងការពារត្រូវប្រព្រឹត្តទៅតាមកម្មវិធីចាក់វ៉ាក់សាំងដែលស្របទៅតាមស្ថានភាពបច្ចុប្បន្ននៅកន្លែងចិញ្ចឹមជ្រូកនីមួយៗ។

ជ្រូកSPF នៅកសិដ្ឋានSPF គឺជាសត្វដែលមិនមានជំងឺសូតបង្កដោយមេរោគម៉ៃកូប្លាស្មា រោគមូល ជំងឺAR (ជំងឺឫសដូងច្រមុះ) ជំងឺអូជេស្គី (Aujeszky disease) ជំងឺតុកសូប្លាស្មា (Toxoplasomosis)។ គេផលិតសត្វដែលគ្មានផ្ទុកមេរោគធ្វើជាមេ តាមរយៈការសម្រាលកូនដោយវះកាត់ ឬការវះកាត់កូនជ្រូកចេញពីស្បូនរបស់ជ្រូកមេដែលគ្មានផ្ទុកមេរោគបង្កជំងឺទាំងអស់នេះ។ ដោយសារតែវាគ្មានការលំបាកក្នុងការផលិតដោយសារជំងឺ ដូច្នេះលទ្ធភាពក្នុងការផលិតរបស់វា គឺខ្ពស់។ ដើម្បីរក្សាស្ថានភាពអនាម័យនេះ ចាំបាច់ត្រូវបំបែកវាពីពិភពខាងក្រៅ និងកម្ចាត់មេរោគឲ្យបានតឹងរឹង លើសពីកសិដ្ឋានចិញ្ចឹមជ្រូកធម្មតា។

9 របៀបទុកដាក់កាកសំណល់សត្វ

គេប្រមូលលាមកសត្វដោយប្រើម៉ាស៊ីនសម្អាតលាមក(ម៉ាស៊ីនកៀរលាមក) ដើម្បីយកទៅធ្វើជីកំប៉ុស្ត៍ ដោយធ្វើការគ្រប់គ្រងទុកដាក់លាមកទាំងនោះនៅទីកន្លែងដែលមានដំបូលជានិច្ច។ គេមិនត្រូវទុកលាមកសត្វចោលនៅទីវាលនោះទេ។

ចំណុចសំខាន់ៗដែលចាំបាច់សម្រាប់ការផលិតជីកំប៉ុស្ត៍មានដូចខាងក្រោម។

[1] ការផ្គត់ផ្គង់អុកស៊ីសែន

គេចាំបាច់ត្រូវផ្តល់អុកស៊ីសែនដល់អតិសុខុមប្រាណដែលត្រូវការអុកស៊ីសែនអាចធ្វើសកម្មភាពបំបែកកាកសំណល់បានងាយស្រួល។

[2] ការគ្រប់គ្រងបរិមាណជាតិទឹក

ប្រសិនបើមានជាតិទឹកច្រើនជ្រុល នោះខ្យល់ចេញចូលនឹងមិនមានលក្ខណៈល្អនោះទេ ដូច្នេះ គេធ្វើការសម្រួលបរិមាណជាតិទឹកដោយលាយវត្ថុធាតុបន្ទាប់បន្សំដើម្បីបញ្ចុះកម្រិតជាតិទឹកអោយមកនៅត្រឹមប្រមាណ60%។

[3] ការកើនឡើងនៃកម្តៅនៅក្នុងជីកំប៉ុស្ត៍

តាមរយៈសកម្មភាពដ៏សកម្មរបស់អតិសុខុមប្រាណ ធ្វើអោយសីតុណ្ហភាពនៅក្នុងជីកំប៉ុស្ត៍មានការកើនឡើង។ បរិស្ថានបែបនេះនឹងធ្វើអោយពងរបស់សត្វល្អិត មេរោគបង្កជំងឺ គ្រាប់របស់ស្មៅចង្រៃជាដើមងាប់ ហើយគេអាចទទួលបានជីកំប៉ុស្ត៍ដែលមានសុវត្ថិភាព។

សម្រាប់ទឹកកខ្វក់ដែលចេញពីរោងចិញ្ចឹមជ្រូក រួមទាំងទឹកនោមរបស់សត្វជ្រូកផងដែរ គេត្រូវបង្ហូរចោលបន្ទាប់ពីទឹកនោះទទួលបានការបន្សុទ្ធរួចហើយ។ ក្រោយពេលធ្វើការបែងចែកទឹកនោមនិងលាមកចេញពីគ្នាហើយ ត្រូវអនុវត្តវិធីលក្ខណៈជីវសាស្ត្រ ដូចជា វិធីប្រើភក់សកម្ម ជាដើម ហើយក្រោយពេលដែលកករនៃភក់កខ្វក់ធ្លាក់ចុះក្រោម ត្រូវបង្ហូរផ្នែកថ្លាដែលនៅផ្នែកខាងលើនៃល្បាយចេញ។

4 ការចិញ្ចឹមមាន់

① មាន់ចិញ្ចឹមយកស៊ុត

1 របៀបចិញ្ចឹមមាន់យកស៊ុត និង អគារ/បរិក្ខារ

(1) របៀបចិញ្ចឹម

ការចិញ្ចឹមមាន់យកស៊ុត រួមមាន របៀបចិញ្ចឹមដោយដាក់មាន់នៅក្នុងទ្រុងហៅថាការចិញ្ចឹមក្នុងទ្រុង របៀបចិញ្ចឹមមាន់នៅក្នុងរបងព័ន្ធជុំវិញដោយសំណាញ់ហៅថាការចិញ្ចឹមដោយព្រលែង និង របៀបចិញ្ចឹមនៅលើដីរាបនៅក្នុងរោងចិញ្ចឹមមាន់ហៅថាការចិញ្ចឹមលើផ្ទៃរាប ប៉ុន្តែ ភាគច្រើនគឺគេប្រើប្រាស់វិធីចិញ្ចឹមក្នុងទ្រុង។

[1] ការចិញ្ចឹមក្នុងទ្រុង

ការចិញ្ចឹមនៅក្នុងទ្រុង អាចជាការចិញ្ចឹមក្នុងទ្រុងលក្ខណៈទោលដែលគេដាក់មាន់មួយក្បាលសម្រាប់ទ្រុង1 និង ការចិញ្ចឹមក្នុងទ្រុងលក្ខណៈច្រើនដែលគេដាក់មាន់ចាប់ពី2ក្បាលឡើងទៅនៅក្នុងទ្រុងតែមួយ។ ក្នុងទម្រង់នេះ មាន់ស្ថិតនៅឃ្លាតឆ្ងាយពីលាមកដែលនៅលើដីឬបាតនៃទ្រុង ធ្វើអោយការឆ្លងជំងឺពីការប៉ះពាល់លាមកមានតិចតួចតែប៉ុណ្ណោះ។ ជាទូទៅ គេតម្រៀបទ្រុងជាច្រើនថ្នាក់ ធ្វើអោយដង់ស៊ីតេនៃការចិញ្ចឹមខ្ពស់ឡើង ដែលអាចជួយសន្សំសំចៃផ្នែកសេដ្ឋកិច្ច ប៉ុន្តែ គេចាំបាច់ត្រូវប្រុងប្រយ័ត្នចំពោះឥទ្ធិពលអាក្រក់ដែលអាចប៉ះពាល់ដល់សុខភាពរបស់មាន់។

ការចិញ្ចឹមក្នុងទ្រុង

[2] ការចិញ្ចឹមលើផ្ទៃរាប

នេះគឺជាវិធីចិញ្ចឹមមាន់ដែលស្របទៅនឹងសកម្មភាពពីធម្មជាតិរបស់មាន់ ដោយវាអាចអោយមាន់ធ្វើចលនាបានដោយសេរីមួយកម្រិតនៅក្នុងបរិវេណដីឬផ្ទៃកម្រាល។ ប៉ុន្តែ នៅពេលមាន់រស់នៅជាហ្វូង ពួកវាអាចមានសកម្មភាពវាយប្រហារគ្នា ដូចជាប្រើចំពុះចឹកគ្នាឬហក់ជាន់គ្នាទៅវិញទៅមក។ នេះគឺជាសកម្មភាពពីធម្មជាតិរបស់មាន់ដើម្បីកំណត់លំដាប់លំដោយសម្រាប់មាន់នីមួយៗ ដោយធ្វើបែបនេះ សត្វមាន់អាចរក្សាភាពរៀបរយនៅក្នុងការរស់នៅជាហ្វូងរបស់ពួកវា។ គេហៅថា លំដាប់នៅក្នុងហ្វូង។ ម្យ៉ាងទៀត ប្រសិនបើមាន់ស្ថិតនៅក្នុងទីកន្លែងចង្អៀតឬបរិស្ថានដែលមានសីតុណ្ហភាពនិងសំណើមខ្ពស់ជាដើម ឬ កំពុងខ្វះសារធាតុចិញ្ចឹម នោះមាន់អាចបញ្ចេញសកម្មភាពដូចជាចឹកគ្នាទៅវិញទៅមកឬចឹកគូទមាន់ផ្សេងទៀត(ការចឹកគូទ)។ ពេលខ្លះការចឹកនេះមានសភាពធ្ងន់ធ្ងរធ្វើអោយមាន់ជាដៃគូចឹកងាប់បាន ហើយប្រសិនបើគេទុកចោលដោយបណ្តោយ

អោយមាន់ចឹកគ្នា វាអាចរីករាលដាលពេញក្នុងហ្វូងទាំងមូល។ នេះហៅថា ការវាយប្រហារគ្នាឯង។ ទាក់ទងនឹងផ្នែកអនាម័យវិញ ការចិញ្ចឹមបែបនេះអាចធ្វើអោយមាន់ប៉ះផ្ទាល់ទៅនឹងលាមកនៅលើដី ដូច្នេះមាន់ងាយឆ្លងជំងឺដោយផ្ទាល់ពីលាមក។ ហេតុនេះហើយ ការចិញ្ចឹមបែបនេះគឺមិនសាកសមសម្រាប់ករណីចិញ្ចឹមមាន់ក្នុងចំនួនច្រើននោះទេ។

ការចិញ្ចឹមលើផ្ទៃរាប

(2) ទម្រង់នៃរោងចិញ្ចឹមមាន់

រោងចិញ្ចឹមមាន់ រួមមាន រោងចិញ្ចឹមមាន់លក្ខណៈបើកចំហដែលមានពន្លឺចូលក្នុងរោងដោយផ្ទាល់ និងរោងចិញ្ចឹមមាន់គ្មានបង្អួច។

[1] រោងចិញ្ចឹមមាន់លក្ខណៈបើកចំហ

គឺជារោងចិញ្ចឹមមាន់ដែលគេខណ្ឌចែករោងចិញ្ចឹមមាន់ពីបរិស្ថានខាងក្រៅដោយប្រើបង្អួចឬវាំងនន ប៉ុន្តែរោងបែបនេះនឹងទទួលឥទ្ធិពលពីការប្រែប្រួលនៃបរិស្ថានខាងក្រៅដោយផ្ទាល់ដូចជាសីតុណ្ហភាពបរិយាកាស ភ្លៀងខ្យល់ កាំរស្មីពន្លឺព្រះអាទិត្យ។ល។

[2] រោងចិញ្ចឹមមាន់គ្មានបង្អួច

គឺជារោងចិញ្ចឹមមាន់ដែលប្រើជញ្ជាំងព័ទ្ធជុំវិញដោយគ្មានបង្អួច ដើម្បីកុំអោយកាំរស្មីពន្លឺព្រះអាទិត្យចាំងចូលក្នុងរោងបាន ហើយគេប្រើសារធាតុទប់កម្តៅនៅលើជញ្ជាំងនិងពិតាន(ដំបូល)។ ម្យ៉ាងទៀត គេប្រើអំពូលភ្លើងដើម្បីគ្រប់គ្រងពន្លឺ និង ប្រើកង្ហារផ្តាស់ប្តូរខ្យល់ដើម្បីធ្វើការផ្លាស់ប្តូរខ្យល់នៅក្នុងរោង។ រោងចិញ្ចឹមក្នុងទម្រង់នេះអាចចិញ្ចឹមមាន់ក្នុងដង់ស៊ីតេខ្ពស់ជាងរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ ដូច្នេះ គេងាយស្រួលប្រើប្រាស់គ្រឿងយន្តនៅក្នុងការគ្រប់គ្រង ហើយទម្រង់នេះសាកសមសម្រាប់កន្លែងចិញ្ចឹមមាន់ដែលមានខ្នាតធំ។

(3) បរិក្ខារនិងម៉ាស៊ីននៅក្នុងរោងចិញ្ចឹមមាន់

នៅកន្លែងចិញ្ចឹមមាន់ខ្នាតធំដែលចិញ្ចឹមមាន់ចំនួនច្រើន គេប្រើប្រាស់គ្រឿងយន្តនៅក្នុងការងារផ្តល់ចំណីផ្តល់ទឹក ប្រមូលស៊ុត និង សម្អាតលាមក ហើយការងារផ្សេងៗទៀតក៏កំពុងត្រូវបានជំនួសដោយម៉ាស៊ីនស្វ័យប្រវត្តិផងដែរ។ ប៉ុន្តែ ដើម្បីកុំអោយប៉ះពាល់ដល់សុខភាពរបស់មាន់និងកុំអោយកើតមានឧបទ្ទវហេតុក្នុងពេលធ្វើការងារ ការប្រើប្រាស់គ្រឿងយន្តអោយបានសមស្របទៅនឹងទំហំនៃកន្លែងចិញ្ចឹមមាន់ គឺជាការសំខាន់។

[1] ឧបករណ៍ផ្តល់ចំណី

នៅក្នុងការចិញ្ចឹមក្នុងទ្រុង គេបំពាក់ឧបករណ៍ផ្តល់ចំណីទម្រង់ជាទ ដោយមានរទេះចែកចំណីដើរដោយស្វ័យប្រវត្តិសម្រាប់ធ្វើជាឧបករណ៍ចែកចំណី និង ឧបកណ៍ផ្តល់ចំណីស្វ័យប្រវត្តិដែលអាចកំណត់បរិមាណ និងពេលវេលានៃការផ្តល់ចំណីបាន។

នៅក្នុងការចិញ្ចឹមលើផ្ទៃរាប ជាទូទៅ គេធ្វើការផ្តល់ចំណីដោយប្រើដៃរួមជាមួយនឹងឧបករណ៍ផ្តល់ចំណីរាងមូល(ការផ្តល់ចំណីដោយដៃ) ឬ ប្រើឡាវធំក្នុងការផ្តល់ចំណីដោយស្វ័យប្រវត្តិ។

[2] ឧបករណ៍ផ្តល់ទឹក

នៅក្នុងការចិញ្ចឹមក្នុងទ្រុង គេច្រើនប្រើឧបករណ៍ផ្តល់ទឹកទម្រង់ជាទ ឬ ឧបករណ៍ផ្តល់ទឹកទម្រង់ក្បាលដោះដែលជាឧបករណ៍ផ្តល់ទឹកខ្នាតតូច។

នៅក្នុងការចិញ្ចឹមលើផ្ទៃរាប ក្រៅពីឧបករណ៍ទាំងនេះ គេក៏ប្រើឧបករណ៍ផ្តល់ទឹកទម្រង់ជាជ្រុងដែលមានរាងសំយុងចុះក្រោមផងដែរ។

[3] ឧបករណ៍ប្រមូលស៊ុតស្វ័យប្រវត្តិ

នៅក្នុងការចិញ្ចឹមលើផ្ទៃរាប គេច្រើនធ្វើការប្រមូលស៊ុតដោយផ្អៀងបាតនៃប្រអប់ផលិតស៊ុតដើម្បីអោយស៊ុតរអិលធ្លាក់លើខ្សែពាន ចំណែកឯនៅក្នុងការចិញ្ចឹមក្នុងទ្រុងវិញ នៅផ្នែកទទួលស៊ុតគេបំពាក់ខ្សែពានរាងសំណាញ់ដើម្បីទទួលស៊ុត និងប្រើខ្សែពានវិលដើម្បីដឹកជញ្ជូនទៅដល់កន្លែងប្រមូលស៊ុតដោយស្វ័យប្រវត្តិ។

[4] ឧបករណ៍សម្អាតលាមកដោយស្វ័យប្រវត្តិ

មានជាទម្រង់កៀរដោយប្រើខ្សែលួសទាញក្តារប្រមូលលាមកនិងផ្តុំលាមកទាំងនោះនៅម្ខាង និង មានជាទម្រង់ដែលគេបំពាក់សំណាញ់វិលទម្រង់ជាខ្សែពានវិលនៅក្រោមទ្រុងដែលទម្រង់នេះសាកសមសម្រាប់ការចិញ្ចឹមក្នុងទ្រុង។

2 រចនាសម្ព័ន្ធនៃសរីរាង្គរំលាយអាហារ និង ការរំលាយ/ការស្រូបយកចំណី

(1) សារធាតុចិញ្ចឹមដែលចាំបាច់

សត្វមាន់ទទួលសារធាតុប្រូតេអ៊ីន ជាតិខ្លាញ់ កាបូអ៊ីដ្រាត វីតាមីន សារធាតុអសរីរាង្គ ជាដើមពីចំណីដែលវាស៊ីដើម្បីប្រើប្រាស់នៅក្នុងការលូតលាស់និងការថែរក្សារាងកាយ ព្រមទាំងនៅក្នុងការផលិតស៊ុតផងដែរ។ ការផ្តល់សារធាតុចិញ្ចឹមទាំងនេះកុំអោយមានការខ្វះខាតគឺជាការសំខាន់។ បរិមាណនៃសារធាតុចិញ្ចឹមដែលចាំបាច់សម្រាប់ការចិញ្ចឹមសត្វ ត្រូវបានកំណត់នៅក្នុងបទដ្ឋាននៃការចិញ្ចឹមសត្វនៅប្រទេសជប៉ុន។

(2) រចនាសម្ព័ន្ធនៃសរីរាង្គរំលាយអាហារ

រូបភាពខាងក្រោមបង្ហាញអំពីរចនាសម្ព័ន្ធនៃសរីរាង្គរំលាយអាហាររបស់មាន់។

.



សរីរាង្គរំលាយអាហាររបស់មាន់

(3) លក្ខណៈពិសេសនៃសរីរាង្គរំលាយអាហារ

[1] ចំពុះ

នៅក្នុងមាត់របស់មាន់គ្មានធ្មេញទេ ប៉ុន្តែនៅខាងចុងរឹងដូចស្នែង ហើយមានរាងសាកសមនឹងចឹកសត្វល្អិតនៅក្នុងដី លើដី និងគ្រាប់ធញ្ញជាតិ ស៊ីចំណី ឬការពារខ្លួន។

[2] តែ

វានៅកណ្តាលបំពង់អាហារ មានមុខងាររក្សាចំណីទុកមួយរយៈពេល ហើយវាធ្វើឲ្យចំណីទន់ដោយទឹករំអិលចេញពីបំពង់រំលាយអាហារ ឬរន្ធមាត់និងដើមក ក្រៅពីទឹក។

[3] ក្រពះ

មានក្រពេញក្រពះ និងកោះ។ ក្រពេញក្រពះ បញ្ចេញនូវអាស៊ីតក្រពះនិងរសក្រពះ។ កោះ កិននិងកូរចំណីដោយចលនារួមនៃសាច់ដុំ។ សត្វមាន់ដែលគេចិញ្ចឹមដោយឲ្យដើរហើរដោយសេរី ចឹកស៊ីគ្រាប់គ្រួស (សំណាញ់លួស) ហើយរក្សាវាទុកនៅក្នុងកោះ រួចប្រើវាក្នុងការកិនចំណីរឹងដូចជាធញ្ញជាតិជាដើម។ ប្រសិនបើជាចំណីគ្រាប់។ ដូចជាពោតនាពេលបច្ចុប្បន្ននេះ មិនចាំបាច់ឲ្យគ្រាប់គ្រួសទេ ប៉ុន្តែករណីឲ្យចំណីដូចជាធញ្ញជាតិមានសម្បកជាដើម ចាំបាច់ត្រូវឲ្យគ្រាប់គ្រួស។

[4] ពោះវៀន

ចំណីដែលបានស៊ី ត្រូវបានរំលាយនិងស្រូបយកដោយសរីរាង្គរំលាយអាហារ (ពោះវៀនតូចជាចំបង)។

ពោះវៀនតូចរបស់វា មានប្រវែងខ្លីនិងចំណុះតិចជាងសត្វចិញ្ចឹមផ្សេងៗ។ ដូច្នេះហើយ ចំណីចូលទៅក្នុងក្រពះរបស់វា រួចបញ្ចេញមកក្រៅក្នុងរយៈពេលខ្លី។ ចំណីលាយ ត្រូវបានបញ្ចេញមកក្រៅក្នុងរយៈពេល 2.5ម៉ោងក្រោយពីស៊ីរួចហើយ និងត្រូវបានបញ្ចេញមកក្រៅទាំងអស់នៅក្នុងរយៈពេល 7ម៉ោង។ ដូច្នេះហើយ ការរំលាយចំណីដែលត្រូវការរយៈពេលយូរដើម្បីរំលាយដូចជាជាតិសរសៃជាដើម មានលក្ខណៈអន់ជាងសត្វចិញ្ចឹមផ្សេងៗទៀតខ្លាំងណាស់។ ប៉ុន្តែ សារធាតុផ្សេងក្រៅពីនេះ គឺមិនមានភាពខុសគ្នាពីសត្វគោ ឬសត្វជ្រូកនោះទេ ចំពោះធញ្ញជាតិវិញ គឺមានលក្ខណៈប្រសើរជាងគេ។

[5] ខ្មែងពោះវៀន

ខ្មែងពោះវៀន មានចំនួនមួយគូរ វារក្សាចំណីមួយផ្នែកដែលបានស៊ីនៅក្នុងរយៈពេលយូរបង្គួរ ហើយបញ្ចេញមកក្រៅក្រោយពេលរំលាយនិងស្រូបយកគ្រប់គ្រាន់ហើយ។ លាមករបស់វាមានពណ៌ត្នោត ហើយមានកម្រិតរំអិលខ្ពស់ វាបញ្ចេញមកក្រៅ 4-5ដងក្នុង 1ថ្ងៃ និងមានក្លិនស្អុយខ្លាំង។

[6] ពោះវៀនធំនិងចុងពោះវៀន

ពោះវៀនធំនិងចុងពោះវៀន មានប្រវែងខ្លីខ្លាំងណាស់ វាស្តុកលាមកនៅរន្ធបញ្ចេញកាកសំណល់មួយរយៈរួចបញ្ចេញមកក្រៅជាមួយនឹងទឹកនោម។

(4) ប្រភេទនិងលក្ខណៈពិសេសនៃចំណីសត្វ

សត្វមាន់មានសមត្ថភាពខ្សោយក្នុងការរំលាយអាហារដែលមានជាតិសរសៃ ដូច្នេះ ចំណីរបស់មាន់ជាចម្បងគួរជាចំណីជីវជាតិដែលសម្បូរកាបូអ៊ីដ្រាតនិងប្រូតេអ៊ីននិងងាយស្រួលក្នុងការរំលាយអាហារ។ ម្យ៉ាងទៀត សត្វមាន់មានសមត្ថភាពប្រើប្រាស់ចំណីជីវជាតិដើម្បីផ្តល់នូវផលិតផលកសិកម្មដូចជាស៊ុតនិងសាច់ជាដើមបានខ្ពស់ជាងសត្វគោនិងជ្រូក។

[1] ធញ្ញជាតិ

សំដៅលើពោតឬស្ពៅធញ្ញជាតិជាដើមដែលមានផ្ទុកច្រើននៅក្នុងចំណីដែលគេប្រើសម្រាប់ការចិញ្ចឹមមាន់។ ភាគច្រើន គេប្រើវាជាប្រភពថាមពលសម្រាប់សត្វ។ ជាពិសេស ពោតគឺជាប្រភពចំណីសម្រាប់ការចិញ្ចឹមមាន់ដែលមានសារៈសំខាន់ជាងគេមួយ។

ពោត

[2] កាកសំណល់ប្រេងរុក្ខជាតិ

គេច្រើនប្រើវាធ្វើជាប្រភពប្រូតេអ៊ីនសម្រាប់សត្វ។ ភាគច្រើន គេប្រើកាកសំណល់សណ្តែកសៀង ប៉ុន្តែដោយសារកាកសំណល់សណ្តែកសៀងខ្វះសារធាតុមេត្យូនីនដែលជាអាមីណូអាស៊ីតចាំបាច់មួយ ដូច្នេះ គេប្រើវារួមជាមួយនឹងម្សៅផលិតពីត្រី។ ក្រៅពីនោះ គេក៏ប្រើគ្រាប់កប្បាសឬកាកសំណល់ប្រេងណាថាណិជាដើមផងដែរ។

កាកសំណល់សណ្តែកសៀង

[3] ប្រភេទកន្ទក់

ជាចំណីដែលគេប្រើប្រាស់តាំងពីសម័យមុន បន្ថែមពីលើធញ្ញជាតិនិងកាកសំណល់ប្រេងរុក្ខជាតិដើម្បីបន្ថែមថាមពលនិងបំពេញសារធាតុចិញ្ចឹមដែលសត្វត្រូវការក្នុងបរិមាណតិច។ កន្ទក់ស្រូវគ្មានខ្លាញ់ គឺជាផលិតផលដែលគេច្រោះយកខ្លាញ់ពីកន្ទក់ស្រូវ។

[4] ប្រភពប្រូតេអ៊ីនបានពីសាច់សត្វ

នៅក្នុងម្សៅផលិតពីត្រីរួមមានបន្សំនៃអាមីណូអាស៊ីតបានល្អប្រសើរ ជាពិសេសវាសម្បូរទៅដោយសារធាតុលីស៊ីននិងមេតីនីន ហើយគេច្រើនប្រើវាធ្វើជាវត្ថុធាតុដើមសម្រាប់ធ្វើជាចំណីសត្វ។

[5] វត្ថុធាតុដើមផ្សេងៗទៀតសម្រាប់ធ្វើជាចំណីសត្វ

គេច្រើនប្រើគ្រាប់ម្សៅអាល់ហ្វាល់ហ្វាធ្វើជាចំណីបៃតង ព្រោះវាមានផ្ទុកវីតាមីនគ្រប់ប្រភេទនិងសារធាតុពណ៌លឿង(Xanthophyll)ផងដែរ។ ស្ពៃពណ៌បៃតង ស្មៅសម្រាប់សត្វស៊ី ស្មៅព្រៃជាដើម សុទ្ធសឹងជាវត្ថុធាតុដើមសម្រាប់ធ្វើជាចំណីសត្វដែលនៅក្បែរខ្លួនងាយស្រួលរក។ មាន់ចិញ្ចឹមយកស៊ុតត្រូវការជាតិកាល់ស្យូមនិងផូស្វ័រជាច្រើន ដូច្នេះ គេប្រើសម្បកលាសគ្រំ កាល់ស្យូមកាបូណាត កាល់ស្យូមផូស្វាតជាដើមធ្វើជាចំណីអសរីរាង្គ។ ម្យ៉ាងទៀត គេចាំបាច់ត្រូវផ្តល់ជាតិអំបិលដល់សត្វមាន់ជានិច្ច។

3 ចំណីសម្រាប់មាន់ចិញ្ចឹមយកស៊ុត

(បរិមាណទាមទារសារធាតុចិញ្ចឹមនៅក្នុងអំឡុងពេលលូតលាស់ ភាគរយនិងបរិមាណឲ្យចំណីលាយ)

(1) បរិមាណទាមទារសារធាតុចិញ្ចឹម

ចំណីលាយរបស់សត្វមាន់ ផ្សំឡើងពីសត្វ រុក្ខជាតិ និងរូបធាតុរ៉ែ ដែលមានផ្ទុកសារធាតុចិញ្ចឹមទាំងអស់ដូចជាថាមពល ប្រូតេអ៊ីន រ៉ែ និងវីតាមីន។

សារធាតុចិញ្ចឹមនៅក្នុងចំណីអាហារ ត្រូវបានបែងចែកជាផ្នែកដែលអាចរំលាយនិងស្រូបយកបាន និងផ្នែកដែលមិនអាចរំលាយ។ សារធាតុចិញ្ចឹមដែលអាចរំលាយនិងស្រូបយកបាន ត្រូវបានបែងចែកជាសារធាតុចិញ្ចឹមដែលត្រូវបានប្រើប្រាស់សម្រាប់រាងកាយ និងសារធាតុចិញ្ចឹមដែលត្រូវបញ្ចេញចោល (ទឹកនោម) ដោយមិនត្រូវបានប្រើប្រាស់។ នៅក្នុងចំណោមនោះ សារធាតុចិញ្ចឹមដែលត្រូវបានប្រើប្រាស់សម្រាប់រាងកាយ ត្រូវបានប្រើប្រាស់សម្រាប់រក្សារាងកាយមាន់ ការលូតលាស់ និងការផលិតស៊ុត ចំណែកឯសារធាតុដែលលើសត្រូវបានស្តុកទុកជាខ្លាញ់។

ដោយសារតែសត្វមាន់ស្រូបយកថាមពលពីចំណោមសារធាតុចិញ្ចឹមទាំងឡាយជាសំខាន់ បរិមាណស៊ីចំណីត្រូវបានកំណត់ដោយបរិមាណស្រូបយកថាមពលរបស់វា។ ដូច្នេះហើយ សារធាតុចិញ្ចឹមផ្សេងៗទៀត ត្រូវតែមានផ្ទុកក្នុងបរិមាណដែលមិនលើសខ្លាំងនៅក្នុងទំហំបរិមាណស៊ីចំណីនោះ។ បើគិតទៅតាមចំណុចនេះ កម្រិតដែលបង្ហាញពីបរិមាណ (អត្រា) សារធាតុចិញ្ចឹមមានផ្ទុកនៅក្នុងចំណីដែលអាចបំពេញបរិមាណទាមទារសារធាតុចិញ្ចឹមរបស់សត្វមាន់បាន គឺជាស្តង់ដារនៃការចិញ្ចឹមមាន់របស់ប្រទេសជប៉ុន។ បរិមាណទាមទារនៃប្រូតេអ៊ីនមិនសុទ្ធ (CP) និងថាមពលដែលបានពីការបំលែងអាហារ (ME) ដែលត្រូវបានបង្ហាញនៅក្នុងស្តង់ដារនៃការចិញ្ចឹមមាន់របស់ប្រទេសជប៉ុន បានកំណត់ថា អំឡុងពេលកូនមាន់តូច CP19%ME2,900គីឡូកាឡូរី អំឡុងពេលកូនមាន់មធ្យម CP16%ME2,800គីឡូកាឡូរី អំឡុងពេលកូនមាន់ធំ CP13%ME2,700គីឡូកាឡូរី អំឡុងពេលផលិតស៊ុត CP15.5%ME2,800គីឡូកាឡូរី។

សម្រាប់កូនមាន់តូច

សម្រាប់កូនមាន់មធ្យម-កូនមាន់ធំ

សម្រាប់មាន់ពេញវ័យ

ចំណីសម្រាប់សត្វមាន់

(2) ភាគរយនិងបរិមាណឲ្យចំណីលាយ

ចំពោះមាន់ចិញ្ចឹមយកស៊ុត ជាទូទៅគេឲ្យចំណីលាយដែលលក់នៅតាមទីផ្សារ។ នៅតាមទីផ្សារមានលក់ចំណីលាយដែលសមស្របនឹងដំណាក់កាលរីកធំធាត់នៅក្នុងដំឡុងពេលលូតលាស់ ហើយក៏មានចំណីលាយដែលឆ្លើយតបទៅនឹងអំឡុងពេលផលិតស៊ុតនៅពេលមាន់ពេញវ័យផងដែរ។ ចំណីលាយនៅលើទីផ្សារ ត្រូវបានគេកំណត់ CPនិងME រាងខ្ពស់បន្តិច ហើយមិនមែនតែភាគរយនៃការផ្សំនោះទេ ទ្រង់ទ្រាយចំណីក៏មានច្រើនដូចជាប្រភេទម្សៅហ្មត់ដែលគេកិនកម្ទេចវត្ថុធាតុដើម ប្រភេទគ្រាប់ៗដែលគេផ្គុំជាគ្រាប់ ប្រភេទដុំៗដែលគេសូនពីប្រភេទគ្រាប់ជាដើម ពោលគឺចំណីជាច្រើនត្រូវគេកែច្នៃឲ្យងាយស្រួលស៊ីនិងរំលាយ។

ជាទូទៅ ការឲ្យចំណីសម្រាប់ការចាប់ផ្តើមឲ្យចំណីនៅក្នុងអំឡុងពេលលូតលាស់ (CP22% ME3,150គីឡូកាឡូរី) ធ្វើឡើងតាមរបៀបនៃការស៊ីចំណីលក្ខណៈសេរី ចំពោះការឲ្យចំណីសម្រាប់កូនមាន់តូចវិញ ធ្វើឡើងតាមរបៀបនៃការស៊ីចំណីលក្ខណៈសេរី ត្រឹមបរិមាណស៊ីចំណី35ក្រាមថ្ងៃ។

ក្រោយមកទៀត គេអាចធ្វើការផ្លាស់ប្តូរពីចំណីសម្រាប់កូនមាន់មធ្យម (CP18%ME2,800គីឡូកាឡូរី) ទៅចំណីសម្រាប់កូនមាន់ធំ (CP15%ME2,800គីឡូកាឡូរី) ដោយមើលទៅលើទម្ងន់របស់វា។ ហើយក៏មានការឲ្យចំណីទៅតាមសៀវភៅណែនាំអំពីពូជមាន់នីមួយៗ ដើម្បីឲ្យទម្ងន់របស់វាខិតជិតទៅនឹងទម្ងន់ស្តង់ដារសម្រាប់ពូជមាន់នីមួយៗ។

បរិមាណឲ្យចំណីសម្រាប់មាន់ពេញវ័យ (CP18%ME2,850គីឡូកាឡូរី) នៅពេលមាន់ពេញវ័យ (អំឡុងពេលផលិតស៊ុត) គឺខុសគ្នាទៅតាមប្រភេទមាន់ ប៉ុន្តែជាទូទៅគេឲ្យចំណីទៅតាមសៀវភៅណែនាំដែលមានគោលដៅត្រឹម 115ក្រាមថ្ងៃ។ ហើយក៏មានរបៀបនៃការឲ្យចំណីដែលបែងចែកជាចំណីក្នុងដំណាក់កាលដំបូងក្នុងអំឡុងពេលផលិតស៊ុត (CP18.5%ME2,870គីឡូកាឡូរី) និងដំណាក់កាលក្រោយក្នុងអំឡុងពេល ផលិតស៊ុត (CP17%ME2,870គីឡូកាឡូរី) ទៅតាមប្រភេទចំណីលាយ។ ម៉្យាងវិញទៀត ក៏មានការផ្លាស់ប្តូរភាគរយនៃការលាយទៅតាមរដូវកាលផងដែរ (រដូវក្តៅ CP18.5% រដូវរងា CP17.5%)។

4 ការជ្រើសរើសស៊ុតពូជ និងការភ្ញាស់

(1) ការជ្រើសរើសស៊ុតពូជ

ស៊ុតពូជ (ស៊ុតដែលមានការបង្កកំនើត) គេអាចទទួលបានពីការបង្កាត់ពូជរវាងមាន់ញីនិងឈ្មោល។ គេទទួលបានស៊ុតពូជដោយការចិញ្ចឹមមាន់ឈ្មោល1ក្បាល ជាមួយមាន់ញីមួយក្រុមដែលមានចំនួន10-15ក្បាល ដោយឲ្យធ្វើការបន្តពូជនៅលើដីរាបតាមបែបធម្មជាតិ ។ ចំពោះការចិញ្ចឹមក្នុងទ្រុងវិញ គេធ្វើការបង្កកំណើតបែបសិប្បនិម្មិត។ ស៊ុតពូជត្រូវបានផលិតក្នុងរយៈពេល 3ថ្ងៃក្រោយការបន្តពូជ ហើយសត្វមាន់ធ្វើការផលិតស៊ុតក្នុង

រយៈពេលប្រហែល 10ថ្ងៃ ក្រោយការបង្កកំណើត។

គេជ្រើសរើសស៊ុតពូជដែលស្អាត មានទំហំ54-65ក្រាម និងមានទ្រង់ទ្រាយធម្មតា។ គេធ្វើការសំអាតជាតិពុលចេញ រួចហើយដាក់ចុងទាលទៅខាងលើ រួចយកវាទៅរក្សាទុកនៅកន្លែងដែលមានសីតុណ្ហភាព15-20អង្សាសេ និងសំណើម40-70%។ ការរក្សាទុកស៊ុតក្នុងរយៈពេល 1សប្តាហ៍ វាគឺមានលក្ខណៈល្អប្រសើរ ក្រោយពីនោះទៅអត្រានៃការញាស់របស់វាថយចុះបន្តិចម្តងៗ។



ស៊ុតពូជដែលត្រូវបានគេតម្រៀបនៅលើទម្រស៊ុតនៅក្នុងឧបករណ៍ភ្ញាស់ស៊ុត

(2) ការភ្ញាស់ស៊ុត

[1] របៀបដំណើរការនៃការភ្ញាស់ស៊ុត

នៅពេលផ្តល់កម្តៅ(37.8អង្សាសេ) និងសំណើម(60%)ក្នុងកម្រិតមួយទៅឲ្យស៊ុតពូជ អំប្រ៊ីយ៉ុងរបស់វានឹងមានការលូតលាស់។ ជាដំបូង ជីវាណូមូល (blastodisc) ចាប់ផ្តើមធំឡើងៗ បន្ទាប់មកសរសៃប្រសាទនិងសរសៃឈាមត្រូវបានបង្កើតឡើង។ ជាបន្តទៀត គ្រោងឆ្អឹង ខួរក្បាល សរីរាង្គផ្លូរដង្ហើម និងចរន្តឈាមជាដើមត្រូវបានបង្កើត ហើយនៅក្នុងថ្ងៃទី21 វានឹងញាស់ ដោយចាក់ទម្លុះសម្បកដោយចំពុះ (ធ្មេញសម្រាប់បំបែកសម្បក) រួចបំបែកសម្បកដោយក្បាល និងជើងរបស់វា។

[2] ប្រភេទម៉ាស៊ីនភ្ញាស់ស៊ុត

មាន់ក្នុងបម្រើបម្រាស់ទាំងអស់ ញាស់ដោយសិប្បនិម្មិត ដោយម៉ាស៊ីនភ្ញាស់ស៊ុត។ ម៉ាស៊ីនភ្ញាស់ស៊ុត មានប្រភេទប្លង់រាបមួយជាន់ និងប្រភេទច្រើនជាន់ថ្នាក់។ ប្រភេទប្លង់រាបមួយជាន់ ភាគច្រើនមានទំហំតូច ហើយត្រូវបានគេប្រើប្រាស់ក្នុងករណីនៃការពិសោធន៍។ ប្រភេទច្រើនជាន់ថ្នាក់ គឺមានទំហំធំ ហើយអាចដាក់ស៊ុតបានរាប់ម៉ឺនគ្រាប់។

[3] ការងារមុនពេលភ្ញាស់

ម៉ាស៊ីនភ្ញាស់ស៊ុត មុននឹងប្រើ ត្រូវយកវាទៅបោសសម្អាត លាងទឹក រួចកម្ចាត់មេរោគចេញ បន្ទាប់មកធ្វើការពិនិត្យម៉ាស៊ីនគ្រប់គ្រងសីតុណ្ហភាពនិងសំណើម។ ត្រូវកម្ចាត់មេរោគពីស៊ុតពូជដោយប្រើសាប៊ូកាចុង (cationic detergent) ឬថ្នាំកម្ចាត់មេរោគដែលមានជាតិហ្វេណុល។

[4] ការគ្រប់គ្រងពេលកំពុងភ្ញាស់

តម្រៀបស៊ុតពូជដាក់លើទម្រស៊ុត ឬថាសដោយដាក់ចុងទាលទៅខាងលើ រួចគូសសញ្ញាដើម្បីឲ្យដឹងពីប្រភេទនិងពូជរបស់វា បន្ទាប់មកចាប់ផ្តើមធ្វើការភ្ញាស់។ នៅក្នុងអំឡុងពេលនេះ ត្រូវបញ្ជូនខ្យល់បរិសុទ្ធទៅឲ្យស៊ុតដោយធ្វើការផ្លាស់ប្តូរខ្យល់។ ម៉្យាងវិញទៀត ត្រូវធ្វើការបង្វិលស៊ុតឲ្យបាន10-20ដងក្នុង 1ថ្ងៃ ដើម្បីកុំឲ្យអំប្រីយ៉ុងនៅក្នុងស៊ុតស្អិតជាប់នឹងភ្នាសសម្បក ចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដាក់ស៊ុតចូលរហូតដល់ថ្ងៃទី18 ក្រោយដាក់ស៊ុតចូល។

[5] ការត្រួតពិនិត្យស៊ុត

ការងារដកស៊ុតដែលគ្មានការបង្កកំណើតនិងស៊ុតដែលឈប់លូតលាស់ចេញ គេហៅថា ការត្រួតពិនិត្យស៊ុត ហើយករណីដែលគេធ្វើការត្រួតពិនិត្យនៅក្នុងថ្ងៃទី7 ក្រោយការដាក់ស៊ុតចូល គឺមានច្រើន។ នៅក្នុងការត្រួតពិនិត្យស៊ុត គឺគេធ្វើការពិនិត្យផ្នែកខាងក្នុងនៃស៊ុតដោយដាក់ចុងទាលនៃស៊ុតឲ្យត្រូវពន្លឺ ដោយម៉ាស៊ីនបញ្ចាំងពន្លឺសម្រាប់ត្រួតពិនិត្យស៊ុត។

[6] ការរិនច្ជួយភេទញីឈ្មោលរបស់កូនមាន់ទើបកើត និងការដាក់លក់នៅលើទីផ្សារ

កូនមាន់ដែលទើបញាស់ភ្លាម។ គេហៅថាកូនមាន់ទើបកើត ហើយកូនមាន់ដែលគេរើសចេញពីកន្លែងកើតទៅដាក់នៅក្នុងបន្ទប់កូនមាន់ គឺត្រូវបានគេរិនច្ជួយភេទញីឈ្មោល តាមលក្ខណៈខុសគ្នានៃភេទញីឈ្មោល។ នៅក្នុងការរិនច្ជួយភេទញីឈ្មោលទៅលើកូនមាន់មានពីររបៀប គឺរបៀបរិនច្ជួយលើទ្វារធំ ដែលគេបែងចែកភេទញីឈ្មោលតាមរយៈទ្រង់ទ្រាយរន្ធបញ្ចេញកាកសំណល់របស់កូនមាន់ និងរបៀបរិនច្ជួយលើរោមនិងស្លាបដែលគេបែងចែកភេទញីឈ្មោលតាមរយៈពណ៌រោម ស្លាប និងជើង និងតាមភាពខុសគ្នារវល្បឿននៃការលូតលាស់ស្លាបចំបងរបស់វា បច្ចុប្បន្ននេះ របៀបរិនច្ជួយលើរោមនិងស្លាបត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយ។ កូនមាន់ញីដែលត្រូវបានជ្រើសរើសចេញមក ត្រូវបានគេចាក់វ៉ាក់សាំងឲ្យវា បន្ទាប់មកត្រូវបានគេបញ្ចេញលក់។ ករណីដែលបញ្ចេញលក់ដោយកាត់ចំពុះចេញ (debeak)ក៏មានដែរ។

5 ការលូតលាស់នៃកូនមាន់ចិញ្ចឹមយកស៊ុត

ការចិញ្ចឹមកូនមាន់ សំដៅលើការចិញ្ចឹមកូនមាន់(ការធ្វើអោយលូតលាស់)ដើម្បីអោយពូកវាក្លាយទៅជាមាន់ចិញ្ចឹមយកស៊ុតទៅថ្ងៃអនាគត។ រយៈពេលចិញ្ចឹមកូនមាន់ គិតចាប់ពីពេលចាប់ផ្តើមអោយចំណីដល់កូនមាន់រហូតដល់ពេលមាន់ចាប់ផ្តើមជលិតស៊ុត ដោយគេបែងចែកជា3ដំណាក់កាល គឺដំណាក់កាលកូនមាន់តូច(អាយុ0~4សប្តាហ៍) ដំណាក់កាលកូនមាន់មធ្យម(អាយុ4~10សប្តាហ៍) និង ដំណាក់កាលកូនមាន់ធំ (អាយុ10~20សប្តាហ៍រហូតដល់ពេលមាន់ផលិតស៊ុត)។ មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងការចិញ្ចឹមកូនមាន់ រួមមាន ការរៀបចំលំទ្ធខ័ណ្ឌបរិស្ថានដែលសមស្របបំផុតសម្រាប់ការចិញ្ចឹមកូនមាន់ និង ធ្វើអោយកូនមាន់អាចលូតលាស់បានដោយមានសុខភាពរឹងមាំ ។ ម្យ៉ាងទៀត ដើម្បីទប់ស្កាត់ការកើតឡើងនៃជំងឺ ការអនុវត្តគម្រោងគ្រប់គ្រងអនាម័យដូចជាការចាក់វ៉ាក់សាំងជាដើមគឺជាកិច្ចការសំខាន់។

(1) របៀបចិញ្ចឹមកូនមាន់

[1] របៀបចិញ្ចឹមដោយប្រើឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាប្រអប់

ឧបករណ៍ចិញ្ចឹមមាន់ទម្រង់ជាប្រអប់ គឺជាបរិក្ខារនៅជំហានដំបូងបង្អស់ ដោយភ្ជាប់ផ្នែកដែលជាប្រភពកម្តៅនៅក្នុងប្រអប់ធ្វើពីឈើ។ ទម្រង់នេះសាកសមសម្រាប់ការចិញ្ចឹមកូនមាន់ពីប្រហែល50~100ក្បាល។

[2] របៀបចិញ្ចឹមកូនមាន់ទម្រង់ជាធ្នើរ

ឧបករណ៍ចិញ្ចឹមមាន់ទម្រង់ជាធ្នើរគឺជាបរិក្ខារដែលសាកសមសម្រាប់ការចិញ្ចឹមកូនមាន់ជាច្រើនក្បាល ដោយសារទម្រង់នេះមិនសូវប្រើកន្លែងច្រើន ដោយគេបន្តុបកញ្ច្រែងចិញ្ចឹមមាន់ជាន់លើគ្នាដែលមានផ្នែកនៃប្រភពកម្តៅនិងបាតធ្វើឡើងអំពីសំណាញ់លោហៈ សំណាញ់ញឹក ឬ បន្ទះក្តារតម្រៀប។
ជាមួយនឹងការលូតលាស់របស់កូនមាន់ គេធ្វើការផ្លាស់កូនមាន់តូចទៅទ្រុងកូនមាន់មធ្យមនិងបន្តទៅទ្រុងកូនមាន់ធំ ដើម្បីចិញ្ចឹមបន្តបន្ទាប់។ ការចិញ្ចឹមក្នុងទម្រង់នេះនឹងមិនត្រូវការចំណាយថវិកាច្រើនទេ ប៉ុន្តែ នៅរដូវរងាគេអាចជួបបញ្ហាក្នុងការរក្សាកម្តៅអោយមានលក្ខណៈស្មើគ្នានៅក្នុងឧបករណ៍ចិញ្ចឹម។

[3] របៀបចិញ្ចឹមកូនមាន់លើផ្ទៃរាប

គឺជាវិធីចិញ្ចឹមកូនមាន់នៅលើផ្ទៃកម្រាលនៅក្នុងរោងចិញ្ចឹមមាន់ ដោយប្រើឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាឆ័ត្រ ឬប្រើបំពង់ទឹកក្តៅដែលបំពាក់នៅក្រោមផ្ទៃកម្រាលឬទ្រុងដើម្បីបន្ថែមកម្តៅ(ការកម្តៅតាមផ្ទៃកម្រាល) ឬប្រើខ្យល់ក្តៅដើម្បីកម្តៅរោងចិញ្ចឹមកូនមាន់ទាំងមូល។ ទម្រង់នេះសាកសមសម្រាប់ការចិញ្ចឹមមាន់ច្រើនក្បាល ហើយគេធ្វើការចិញ្ចឹមបែបនេះរហូតដល់ពេលត្រូវបញ្ចូលកូនមាន់ទៅក្នុងទ្រុងកូនមាន់ធំឬទៅក្នុងទ្រុងមាន់ពេញវ័យដោយផ្ទាល់តែម្តង។ សីតុណ្ហភាពមានលក្ខណៈស្មើគ្នាគ្រប់កន្លែង ហើយគេអាចសន្សំកម្លាំងសម្រាប់ការងារសម្លាប់មេរោគជាដើម ប៉ុន្តែ ការរៀបចំជាទម្រង់នេះត្រូវការចំណាយប្រាក់ច្រើន។

(2) ការគ្រប់គ្រងនៅដំណាក់កាលកូនមាន់តូច

[1] ការបញ្ចូលកូនមាន់ក្នុងឧបករណ៍ចិញ្ចឹម (ការទទួលកូនមាន់ចូល)

កូនមាន់ដែលទើបនឹងកើត បន្ទាប់ពីភ្ញាស់ ទម្រាំគេបញ្ជូនពួកវាដល់កន្លែងចិញ្ចឹមមាន់គឺត្រូវការពេលវេលាគួរសមដែរ ដូច្នេះ នៅពេលទៅដល់ភ្លាម គេត្រូវផ្តល់ទឹកដល់កូនមាន់ ហើយដាក់ពួកវានៅក្នុងបន្ទប់ងងឹតនៅស្ងប់ស្ងៀមមួយរយៈពេលសិន ដើម្បីអោយកូនមាន់មានកម្លាំងឡើងវិញ។ ឧបករណ៍ចិញ្ចឹមកូនមាន់ដែលរួមមានទម្រង់ជាធ្នើរ ទម្រង់ឆ័ត្រនៅលើផ្ទៃរាប(ប្រើប្រាស់របងព័ទ្ធ) និង ទម្រង់ផ្តល់កម្តៅតាមផ្ទៃកម្រាល(ប្រើប្រាស់របងព័ទ្ធ) ទោះក្នុងករណីណាក៏ដោយ ក៏គេត្រូវកម្តៅឧបករណ៍ទាំងនោះអោយស្ថិតនៅសីតុណ្ហភាពប្រហែល32~35អង្សាសេ និងរក្សាសំណើមអោយស្ថិតនៅប្រហែល65%ទុកជាមុន។ គេធ្វើការបញ្ចូលកូនមាន់ទៅក្នុងឧបករណ៍ចិញ្ចឹមកូនមាន់ ដោយសង្កេតមើលស្ថានភាពរបស់កូនមាន់យ៉ាងដិតដល់។ ប្រសិនបើឃើញមានកូនមាន់ដែលមានសុខភាពខ្សោយ គេនឹងដកកូនមាន់នោះចេញ។ នេះហៅថា ការបញ្ចូលកូនមាន់ក្នុងឧបករណ៍ចិញ្ចឹម។ របងព័ទ្ធគឺជារបងដែលមានរាងជារង្វង់ មានកម្ពស់ប្រហែល30សង់ទីម៉ែត្រ ដែលអាចអោយគេចិញ្ចឹមនិងផ្តល់កម្តៅដល់កូនមាន់ដែលនៅក្នុងនោះ។

កូនមាន់ដែលមានសុខភាពរឹងមាំ

កូនមាន់ដែលមានសុខភាពខ្សោយ

[2] ការចាប់ផ្តើមអោយចំណី

រយៈពេលនៃការចាប់ផ្តើមឲ្យចំណី ជាញឹកញាប់គឺនៅពេលដែលផ្នែកលឿងនៃស៊ុតដែលមាននៅសល់ក្នុងរាងកាយរបស់កូនមាន់ត្រូវបានរំលាយអស់ភាគច្រើន ដែលគេគួរតែឲ្យចំណីនៅក្នុងរយៈ25-60ម៉ោងក្រោយពេលញាស់ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង ករណីដែលគេឲ្យចំណីទៅតាមការកំណត់ពេលវេលាចាប់ផ្តើមឲ្យចំណីនៅកន្លែងភ្លាស់ក៏មានដែរ។

នៅពេលគេបញ្ចូលកូនមាន់ក្នុងឧបករណ៍ចិញ្ចឹមហើយ គេនឹងរៀបចំចំណីលាយជាមួយទឹកអោយទៅជាជ្រាយសម្រាប់ផ្តល់អោយកូនមាន់ ដោយគេដាក់ចំណីនោះនៅលើក្រដាសឬប្រអប់ដែលមានគែមរាក់(ចានសម្រាប់កូនមាន់)ដែលគេដាក់នៅលើបាតនៃផ្នែកផ្តល់កម្តៅនៅក្នុងឧបករណ៍ចិញ្ចឹមកូនមាន់។ នេះហៅថាការចាប់ផ្តើមអោយចំណី។ ការចាប់ផ្តើមអោយចំណីធ្វើឡើងដោយ1ថ្ងៃ5~6ដងសម្រាប់រយៈពេល3ថ្ងៃ ហើយបន្ទាប់ពីនោះ គេនឹងបន្តយចំនួនដងមកត្រឹម1ថ្ងៃ4ដង។ គេតម្រៀបឧបករណ៍ផ្តល់ចំណីនិងឧបករណ៍ផ្តល់ទឹកអោយឆ្ងាស់គ្នា ដើម្បីអោយកូនមាន់អាចស៊ីចំណីបានស្រួល។ នៅប្រហែល1សប្តាហ៍ដំបូង គេគួរតែបំពាក់អំពូលភ្លើងដើម្បីអោយកូនមាន់ដឹងអំពីទីកន្លែងដែលមានចំណីនិងទឹកផឹក។

[3] ការកាត់ចំពុះ (ការកាត់ចុងចំពុះ ឬ ការតម្រឹមចំពុះ)

ការកាត់ចំពុះមានប្រសិទ្ធិភាពទប់ស្កាត់ទម្លាប់អាក្រក់នៃការចឹកគូទឬស្លាបជាដើមនៅក្នុងហ្វូងមាន់ ចាប់ពីដំណាក់កាលកូនមាន់មធ្យមទៅ។ ជាទូទៅ គេធ្វើការដុតនិងកាត់ចំពុះលើនិងក្រោមប្រវែង1/2ដោយប្រើឧបករណ៍កាត់ចំពុះ ក្នុងអំឡុងពេលកូនមាន់មានអាយុ1~2សប្តាហ៍។

[4] ដង់ស៊ីតេនៃការចិញ្ចឹម

ករណីរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ សម្រាប់ការចិញ្ចឹមទម្រង់ជាធ្មើរ គេគួរចិញ្ចឹមកូនមាន់ចំនួន33~34ក្បាល/ម៉ែត្រការេរហូតដល់កូនមាន់មានអាយុ6សប្តាហ៍ ហើយសម្រាប់ការចិញ្ចឹមលើផ្ទៃរាប គេគួរចិញ្ចឹមកូនមាន់ចំនួន18~20ក្បាល/ម៉ែត្រការេរហូតដល់កូនមាន់មានអាយុ6សប្តាហ៍។ ម្យ៉ាងទៀត ករណីរោងចិញ្ចឹមមាន់ដែលគ្មានបង្អួច វាមានល័ក្ខខ័ណ្ឌបរិស្ថានល្អជាងរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ ដូច្នេះ ដង់ស៊ីតេនៃការចិញ្ចឹមមានកម្រិតខ្ពស់ជាង។

(3) ការគ្រប់គ្រងនៅដំណាក់កាលកូនមាន់មធ្យម

នៅដំណាក់កាលកូនមាន់មធ្យម គេត្រូវព្យាយាមធ្វើអោយកូនមាន់ហាត់ប្រាណអោយបានច្រើន និង ធ្វើអោយវាសំាទៅនឹងបរិយាកាសខាងក្រៅតាមដែលអាចធ្វើទៅបាន ដើម្បីអោយកូនមាន់មានរូបរាងកាយរឹងមាំ។ នៅក្នុងឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាធ្មើរ នៅពេលកូនមាន់មានអាយុប្រហែល4សប្តាហ៍ គេនឹងប្តូរកូនមាន់ទាំងនោះទៅ

កាន់ផ្ទើរសម្រាប់កូនមាន់មធ្យមវិញ។ សម្រាប់ចំនួនកូនមាន់ដែលគេបញ្ចូលក្នុងផ្ទើរនីមួយៗ គឺគេកំណត់ត្រឹមចំនួនដែលអាចអោយកូនមាន់ក្នុងផ្ទើរនោះតម្រៀបគ្នានៅឧបករណ៍ផ្តល់ចំណីបានទាំងអស់គ្នានិងដោយងាយស្រួល។ ដង់ស៊ីតេនៃការចិញ្ចឹមអាចមានឥទ្ធិពលដល់ការលូតលាស់និងស្ថានភាពសុខភាពរបស់កូនមាន់នៅពេលក្រោយ។ ការប្តូរកន្លែងគឺជាស្ត្រេសដ៏ធំមួយសម្រាប់កូនមាន់ ព្រោះវាក៏ជាពេលដែលគេត្រូវផ្លាស់ប្តូរចំណីទៅជាចំណីសម្រាប់កូនមាន់មធ្យមផងដែរ ដូច្នេះ គេត្រូវប៉ះពាល់កូនមាន់ក្នុងអំឡុងពេលនេះដោយទន់ភ្លន់។ ដើម្បីកាត់បន្ថយស្ត្រេសនិងទប់ស្កាត់ការកើតជំងឺផ្សេងៗរបស់កូនមាន់ គេគួរធ្វើការលាយថ្នាំប្រឆាំងមេរោគឬថ្នាំវីតាមីនផ្សេងៗនៅក្នុងទឹក រួចផ្តល់អោយកូនមាន់រយៈពេល2~3ថ្ងៃជាការល្អ។

[1] ការលូតលាស់របស់កូនមាន់

នៅរយៈពេលពាក់កណ្តាលដំបូងនៃដំណាក់កាលចិញ្ចឹមកូនមាន់ ការលូតលាស់របស់កូនមាន់មានភាពឆាប់រហ័សណាស់។ ជាពិសេស នៅដំណាក់កាលដំបូងនៃការចិញ្ចឹម កូនមាន់អាចលូតលាស់បានទម្ងន់លើសពី65ក្រាមនៅអាយុ1សប្តាហ៍ និង បានទម្ងន់លើសពី120ក្រាមនៅអាយុ2សប្តាហ៍ ហើយបានទម្ងន់លើសពី190ក្រាមនៅអាយុ3សប្តាហ៍ដំបូង។ បន្ទាប់ពីនោះ អត្រាកើនទម្ងន់មានលក្ខណៈថយចុះបន្តិចម្តងៗមកវិញ ប៉ុន្តែ ការកើនទម្ងន់ក្នុង1ថ្ងៃនៅតែមានការកើនឡើងឆាប់រហ័សរហូតដល់កូនមាន់មានអាយុប្រហែល10សប្តាហ៍(ទម្ងន់លើសពី850ក្រាម) លុះចូលដល់រយៈពេលចុងក្រោយនៃដំណាក់កាលចិញ្ចឹមកូនមាន់ អត្រាកើនទម្ងន់មានការថយចុះស្របពេលនឹងការចាប់ផ្តើមពេញវ័យរបស់មាន់ ហើយសន្ទុះនៃការលូតលាស់របស់មាន់មានលក្ខណៈយឺតៗវិញ។

[2] ការថ្លឹងទម្ងន់កូនមាន់ និងទម្ងន់ជាមធ្យម

ដោយសារតែគេចិញ្ចឹមកូនមាន់ក្នុងគោលដៅឲ្យមានទម្ងន់តាមស្តង់ដារដែលមានបង្ហាញនៅក្នុងសៀវភៅណែនាំអំពីពូជមាន់ ដូច្នេះការថ្លឹងទម្ងន់ គឺជាការចាំបាច់។ កូនមាន់ដែលមានទម្ងន់ស្រាលពេក គឺមិនល្អទេ ដូច្នេះចាំបាច់ត្រូវរក្សាទម្ងន់របស់វាកុំឲ្យខុសគ្នាខ្លាំង (ទម្ងន់ដូចគ្នា) ពីមាន់ផ្សេងៗនៅក្នុងហ្វូង ដោយកុំឲ្យមានទម្ងន់ធ្ងន់ ឬស្រាលជាងគេ។

(4) ការគ្រប់គ្រងនៅដំណាក់កាលកូនមាន់ធំ

គោលដៅនៃការចិញ្ចឹមមាន់ក្នុងដំណាក់កាលកូនមាន់ធំគឺ ដើម្បីធ្វើអោយមាន់មានរាងកាយរឹងមាំគ្រប់គ្រាន់អាចទប់ទល់នឹងរយៈពេលវែងនៃការផលិតស៊ុតបាន និង ដើម្បីធ្វើអោយមាន់អាចចាប់ផ្តើមផលិតស៊ុតនៅអាយុដែលសមស្រប។ ករណីការចិញ្ចឹមទម្រង់ជាផ្ទើរ នៅពេលគេផ្លាស់ប្តូរកូនមាន់ទៅផ្ទើរសម្រាប់កូនមាន់ធំ គេត្រូវធ្វើការបញ្ចូលកូនមាន់ដែលមានការលូតលាស់ប្រហាក់ប្រហែលគ្នាទៅក្នុងផ្ទើរដូចគ្នា។ សម្រាប់ចំនួននៃកូនមាន់ដែលបញ្ចូលក្នុងផ្ទើរមួយ គឺដូចទៅនឹងដំណាក់កាលកូនមាន់មធ្យមដែរ ដោយកំណត់ត្រឹមចំនួនដែលអាចអោយកូនមាន់តម្រៀបគ្នានៅឧបករណ៍ផ្តល់ចំណីបានគ្រប់គ្នានិងដោយងាយស្រួល។

គេក៏ត្រូវប្តូរចំណីពីចំណីសម្រាប់កូនមាន់មធ្យមទៅជាចំណីសម្រាប់កូនមាន់ធំផងដែរ។ បរិមាណស៊ីចំណីរបស់កូនមាន់មានការកើនឡើងស្របទៅតាមការកើនឡើងនៃទម្ងន់របស់វា ហើយការបញ្ចេញលាមកក៏មានបរិមាណកើនឡើងដែរ។ ប្រសិនបើគេទុកលាមកទាំងនោះចោល វានឹងបញ្ចេញឧស្ម័នអាម៉ូញាក់ជាដើមដែលជាឧស្ម័នពុល ដូច្នេះការបោសសម្អាតរួមទាំងការសម្អាតលាមកគឺមិនអាចខ្វះបាននោះទេ។ កូនមាន់ធំដែលឆាប់ពេញវ័យអាចចាប់ផ្តើមផលិតស៊ុតចាប់ពីអាយុប្រហែល130ថ្ងៃទៅ ដូច្នេះ គេត្រូវបញ្ជូនមាន់ទាំងនោះទៅរោងចិញ្ចឹមមាន់ពេញវ័យអោយបានមុនពេលនោះ។

[1] ដង់ស៊ីតេនៃការចិញ្ចឹម

ករណីរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ សម្រាប់ការចិញ្ចឹមទម្រង់ជាផ្ទើរ គេគួរចិញ្ចឹមមាន់ចំនួន22~25 ក្បាល/ម៉ែត្រការេរហូតដល់មាន់មានអាយុ18សប្តាហ៍ ហើយសម្រាប់ការចិញ្ចឹមលើផ្ទៃរាប គេគួរចិញ្ចឹមមាន់ចំនួន 7~8ក្បាល/ម៉ែត្រការេរហូតដល់មាន់មានអាយុ18សប្តាហ៍។ ម្យ៉ាងទៀត ករណីរោងចិញ្ចឹមមាន់ដែលគ្មានបង្អួច វាមានល័ក្ខខ័ណ្ឌបរិស្ថានល្អជាងរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ ដូច្នេះ ដង់ស៊ីតេនៃការចិញ្ចឹមមានកម្រិតខ្ពស់ជាង។

[2] ការគ្រប់គ្រងពន្លឺ

នៅដំណាក់កាលកូនមាន់ធំ គេធ្វើការគ្រប់គ្រងពន្លឺដោយបើកអំពូលភ្លើងនៅក្នុងរោងចិញ្ចឹមមាន់ ដើម្បីសម្រួលរយៈពេលនៃពេលថ្ងៃ (រយៈពេលនៃពេលថ្ងៃ + រយៈពេលបំភ្លឺភ្លើង)។ គេធ្វើបែបនេះដើម្បីសម្រួលរយៈពេលនៃការលូតលាស់ពេញវ័យរបស់កូនមាន់ ដោយប្រសិនបើពេលថ្ងៃមានរយៈពេលខ្លី ការលូតលាស់ពេញវ័យរបស់កូនមាន់មានល្បឿនយឺត ផ្ទុយទៅវិញ ប្រសិនបើពេលថ្ងៃមានរយៈពេលវែង ការលូតលាស់ពេញវ័យរបស់កូនមាន់មានល្បឿនលឿន។ ជាទូទៅ មាន់ក្នុងបម្រើបម្រាស់មានទំនោរឆាប់លូតលាស់ពេញវ័យណាស់ ដូច្នេះ នៅរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ គេធ្វើការគ្រប់គ្រងពន្លឺដើម្បីពន្យឺតការលូតលាស់ពេញវ័យរបស់មាន់ទាំងនោះ។ ការបំភ្លឺភ្លើងនៅដំណាក់កាលចិញ្ចឹមកូនមាន់ធ្វើឡើងក្នុងគោលបំណងអោយមាន់ចាប់ផ្តើមពេញវ័យ(ចាប់ផ្តើមផលិតស៊ុត)នៅអាយុដែលសមស្រប។ អាយុពេញវ័យរបស់មាន់មានលក្ខណៈខុសគ្នាទៅតាមពូជមាន់នីមួយៗ ដូច្នេះ គេគួរធ្វើការគ្រប់គ្រងដោយផ្អែកទៅលើអាយុពេញវ័យដែលសមស្របបំផុតសម្រាប់ពូជមាន់នីមួយៗ។

នៅរោងចិញ្ចឹមមាន់ដែលគ្មានបង្អួច មិនមានការទទួលឥទ្ធិពលពីរយៈពេលនៃពេលថ្ងៃនោះទេ ដូច្នេះ គេអាចគ្រប់គ្រងពន្លឺទៅតាមគម្រោងដែលបានរៀបចំ។ គេគួរកំណត់កម្រិតពន្លឺត្រឹម5~10លុចនៅទីកន្លែងដែលមាន់ស្ថិតនៅ ហើយគេមិនគួរកាត់បន្ថយរយៈពេលបំភ្លឺភ្លើងទេចាប់ពីដំណាក់កាលមាន់ពេញវ័យទៅ។

[3] ការថ្លឹងទម្ងន់ និងការកម្រិតចំណីដែលត្រូវឲ្យ

ការគ្រប់គ្រងទម្ងន់របស់កូនមាន់ធំ គឺជារឿងសំខាន់ តាមរយៈការធ្វើឲ្យទម្ងន់របស់វាខិតជិតទៅនឹងទម្ងន់ស្តង់ដារ នៅពេលក្រោយ អាចឲ្យគេទទួលបានលទ្ធផលផលិតស៊ុតដែលល្អៗច្រើន ។ ជារៀងរាល់សប្តាហ៍ គេធ្វើការថ្លឹងទម្ងន់ រួចធ្វើការកំណត់បរិមាណចំណីដែលត្រូវផ្តល់ឲ្យនៅសប្តាហ៍បន្ទាប់។ នៅក្នុងករណីដែលវាលូតលាស់ហួសទម្ងន់ស្តង់ដារ គេត្រូវចាប់យករបៀបនៃការកម្រិតបរិមាណចំណីដែលត្រូវឲ្យ។

6 ការផលិតស៊ុតរបស់មាន់ចិញ្ចឹមយកស៊ុត និង ការគ្រប់គ្រងនៅដំណាក់កាលមាន់ពេញវ័យ

(1) ការចាប់ផ្តើមផលិតស៊ុត

មាន់ចិញ្ចឹមយកស៊ុតចាប់ផ្តើមផលិតស៊ុតនៅពេលវាមានអាយុប្រហែល18សប្តាហ៍(ប្រហែល130ថ្ងៃ) បន្ទាប់ពីនោះរយៈពេល2~4ខែ ការផលិតស៊ុតមានបរិមាណច្រើនបំផុត ហើយបន្ទាប់ពីនោះទៀត ការផលិតស៊ុតនឹងមានការថយចុះបន្តិចម្តងៗ។ ការប្រែប្រួលបរិមាណផលិតស៊ុតបែបនេះ ហៅថា បម្រែបម្រួលនៃការផលិតស៊ុត។ ថ្ងៃដែលសត្វមាន់ផលិតស៊ុតជាលើកដំបូង ហៅថា អាយុផលិតស៊ុតដំបូង ហើយក៏ជាពេលដែលមាន់ពេញវ័យផងដែរ។ ការឆាប់ឬក្រពេញវ័យរបស់មាន់មានឥទ្ធិពលខ្លាំងដល់លទ្ធផលនៃការផលិតស៊ុតនៅពេលក្រោយ។ ការឆាប់ឬក្រពេញវ័យអាចបណ្តាលមកពីតំណពូជ ប៉ុន្តែវាក៏ទទួលឥទ្ធិពលខ្លាំងពីរយៈពេលនៃពេលថ្ងៃនិងការផ្គត់ផ្គង់សារធាតុចិញ្ចឹមផងដែរ។ ហេតុនេះហើយ ទើបនៅដំណាក់កាលចិញ្ចឹមកូនមាន់ គេប្រើប្រាស់វិធីគ្រប់គ្រងពន្លឺនិងការផ្តល់ចំណី ដើម្បីធ្វើអោយមាន់ពេញវ័យនៅអាយុដែលសមស្រប។

[1] ការកកើតស៊ុត និង ការបញ្ចេញស៊ុត

នៅក្នុងក្រពេញអូវែររបស់មាន់ដែលចាប់ផ្តើមផលិតស៊ុតមានផ្កុកកន្សោមស៊ុតជាច្រើនដែលមានអង្កត់ផ្ចិត 1~35មីលីម៉ែត្រនិងស្ថិតនៅដំណាក់កាលលូតលាស់ផ្សេងៗពីគ្នា។ នៅពេលកន្សោមស៊ុតលូតលាស់រហូតដល់ទំហំធំផុតហើយ ភ្នាសខាងក្រៅរបស់វានឹងរហែក ដើម្បីបញ្ចេញអូរុល(ផ្នែកលឿងនៃស៊ុត)ឆ្លងកាត់ផ្នែករាងជាឡាវចូលទៅដៃស្បូន។ ផ្នែកលឿងនៃស៊ុតនឹងចាប់ផ្តើមកកើតផ្នែកសនៃស៊ុតនៅត្រង់ទីតាំងដែលជាផ្នែករីកធំនៅក្នុងស្បូនមាន់ ហើយភ្នាសនៃសម្បកស៊ុតកកើតនៅផ្នែកចង្កៀត ចំណែកសម្បកស៊ុតកកើតនៅផ្នែកស្បូនរបស់មាន់ ដោយស៊ុតដែលទទួលបាននឹងត្រូវបញ្ចេញតាមរន្ធបញ្ចេញស៊ុត ។ ពីការបញ្ចេញស៊ុតមួយទៅការបញ្ចេញស៊ុតមួយទៀតមានរយៈពេល25~26ម៉ោង។



សរីរាង្គបន្តពូជបស់សត្វមាន់

[2] វដ្តនៃការផលិតស៊ុត

ការផលិតស៊ុតរបស់សត្វមាន់ គឺបង្ហាញនូវវដ្តដែលវាធ្វើការផលិតស៊ុតក្នុងរយៈពេលប៉ុន្មានថ្ងៃ បន្ទាប់ពីនោះវាផ្អាកការផលិតរយៈពេល 1ថ្ងៃ (ឬ2-3ថ្ងៃ) ក្រោយពីផ្អាករួចហើយវាបន្តផលិតស៊ុតក្នុងរយៈពេលប៉ុន្មានថ្ងៃទៀត។ វដ្តបែបនេះ គេហៅថា វដ្តនៃការផលិតស៊ុត ហើយការផលិតជាស៊េរីជាបន្តបន្ទាប់ គេហៅថា ពងមួយសម្បុក (clutch)។

[3] ការប្រែប្រួលរដូវនៃការផលិតស៊ុត

សត្វមាន់ ផលិតស៊ុតច្រើននៅក្នុងរដូវដែលមានថ្ងៃយូរ វាផលិតបានច្រើននៅរដូវផ្ការីក ហើយផលិតបានតិចនៅរដូវស្លឹកឈើជ្រុះ នៅក្រោមថ្ងៃយូរនៃធម្មជាតិ ។ ដូច្នេះហើយ ទម្រង់នៃការផលិតស៊ុត គឺខុសគ្នាទៅតាមរដូវនៃការញាស់ ហើយកូនមាន់ដែលញាស់ត្រូវបានបង្ហាញពីទម្រង់នៃការផលិតស៊ុតដែលមានលក្ខណៈផ្ទុយគ្នារវាងរដូវផ្ការីកនិងរដូវស្លឹឈើជ្រុះ រដូវរងានិងរដូវក្តៅ។ សីតុណ្ហភាពដែលសមស្របសម្រាប់ការផលិតស៊ុត គឺ12-25អង្សាសេ។

(2) ការគ្រប់គ្រងនៅដំណាក់កាលមាន់ពេញវ័យ

[1] ការផ្គត់ផ្គង់ចំណីនិងទឹក

ចំណីនៅដំណាក់កាលមាន់ពេញវ័យ ជាទូទៅ គេបែងចែកបរិមាណចំណីសម្រាប់1ថ្ងៃជាពីរពេលគឺពេលព្រឹកនិងពេលរសៀល ហើយគេផ្តល់ចំណីអោយមាន់ដោយសង្កេតមើលស្ថានភាពស៊ីចំណីរបស់វា។ គេអាចប្រើឧបករណ៍ផ្តល់ចំណីដោយស្វ័យប្រវត្តិដើម្បីផ្តល់ចំណីច្រើនដងក្នុង1ថ្ងៃ ធ្វើបែបនេះអាចបំបាត់ការរើសចំណីឬសល់ចំណីរបស់មាន់ និងធ្វើអោយការស៊ីចំណីមានលក្ខណៈថេរ។

នៅដំណាក់កាលដំបូងនៃការផលិតស៊ុត មាន់ផលិតស៊ុតយ៉ាងឆាប់រហ័សស្របពេលជាមួយនឹងការលូតលាស់របស់វា ដូច្នេះ គេផ្តល់ចំណីដែលមានជាតិប្រូតេអ៊ីនខ្ពស់ ហើយគេចាប់ផ្តើមកាត់បន្ថយកម្រិតនៃប្រូតេអ៊ីនមិនសុទ្ធ(CP)នៅដំណាក់កាលកណ្តាលនៃការផលិតស៊ុត(អាយុប្រហែល40~60សប្តាហ៍) និងដំណាក់កាលចុងក្រោយ (ចាប់ពីអាយុប្រហែល60សប្តាហ៍ទៅ) ស្របទៅតាមកម្រិតនៃការផលិតស៊ុតនិងការលូតលាស់របស់មាន់។

គេផ្តល់ទឹកថ្មីៗអោយមាន់ដើម្បីអោយវាអាចផឹកទឹកបានគ្រប់ពេលវេលា ជាពិសេសនៅរដូវក្តៅគឺមិនត្រូវអោយដាច់ទឹកនោះទេ ម្យ៉ាងទៀត គេចាំបាច់ត្រូវគ្រប់គ្រងកុំអោយសីតុណ្ហភាពទឹកកើនឡើងខ្ពស់ ហើយកុំអោយទឹកប្រែក្លាយជាកកនៅរដូវរងា។

[2] ការប្រមូលស៊ុត

ការផលិតស៊ុតស្ទើរតែទាំងអស់គឺបញ្ចប់នៅពេលព្រឹក។ នៅកន្លែងចិញ្ចឹមមាន់ដែលមានបំពាក់ឧបករណ៍ប្រមូលស៊ុតដោយស្វ័យប្រវត្តិ គេធ្វើការប្រមូលស៊ុតច្រើនដងក្នុង1ថ្ងៃ រួចធ្វើការបញ្ចេញទំនិញតែម្តង។ នៅកន្លែងចិញ្ចឹមមាន់ដែលមិនមានបំពាក់ឧបករណ៍ប្រមូលស៊ុតដោយស្វ័យប្រវត្តិ គេប្រើកញ្រ្ចែងប្រមូលស៊ុតឬថាសរៀបស៊ុតឬកញ្រ្ចែងរៀបស៊ុត ហើយដើម្បីរក្សាភាពស្រស់របស់ស៊ុត គេធ្វើការប្រមូលស៊ុតដោយដៃបែបនេះដោយបែងចែកការប្រមូលជាច្រើនដងក្នុង1ថ្ងៃតាមដែលអាចធ្វើទៅបាន។

[3] ការសម្អាតលាមក និង ការបោសសម្អាត

ដើម្បីរក្សាអនាម័យនៅក្នុងរោងចិញ្ចឹមមាន់ គេអនុវត្តការងារសម្អាតលាមកជាប្រចាំ។ ជាពិសេស ចាប់ពីរដូវផ្ការីកដល់រដូវស្លឹកឈើជ្រុះដែលជារដូវមានការកើតឡើងនៃសត្វរុយច្រើន គេត្រូវធ្វើការសម្អាតលាមកអោយបានម៉ត់ចត់ និងធ្វើការកម្ចាត់លាមកទាំងនោះអោយបានឆាប់រហ័សនៅអគារកម្ចាត់លាមកមាន់។ ម្យ៉ាងទៀត សម្រាមឬធូលីនៅតាមទ្រុង ឧបករណ៍ ពិតាន ជញ្ជាំងជាដើមដែលស្ថិតនៅជុំវិញមាន់ចិញ្ចឹមយកស៊ុត នឹងក្លាយជាកន្លែងរស់វានសម្រាប់សត្វល្អិតពីខាងក្រៅជាដើម ដូច្នេះ វាមានសារៈសំខាន់ណាស់ដែលគេត្រូវធ្វើការបោសសម្អាតនិងកម្ចាត់ចោលសម្រាមទាំងនោះ ដើម្បីរក្សាអនាម័យនៅក្នុងរោងចិញ្ចឹមមាន់។

[4] ការគ្រប់គ្រងបរិស្ថាន

សីតុណ្ហភាពនៃមាន់ពេញវ័យដែលមានសុខភាពល្អ គឺប្រហែល 41អង្សាសេ។

i ប្រតិកម្មទៅនឹងអាកាសធាតុក្តៅនិងការគ្រប់គ្រងនៅរដូវក្តៅ

នៅពេលសីតុណ្ហភាពបរិយាកាសឡើងខ្ពស់ សត្វមាន់នឹងមានប្រតិកម្មបញ្ចេញកម្តៅក្នុងខ្លួនដូចជាដកដង្ហើមដោយហាមាត់ ចំនួនដកដង្ហើមកើនឡើង(ការដកដង្ហើមសម្រួល ឬ Panting) បើកស្លាប ជាដើម ដើម្បីទប់ស្កាត់ការឡើងខ្ពស់នៃកម្តៅក្នុងខ្លួនរបស់វា។ ម្យ៉ាងទៀត បរិមាណផឹកទឹកក៏កើនឡើង ហើយលាមកវាមានលក្ខណៈរាវដូចទឹក។ ប្រសិនបើសីតុណ្ហភាពបរិយាកាសកើនលើស30អង្សាសេ វានឹងអាចមានឥទ្ធិពលដល់អត្រាផលិតស៊ុតនិងគុណភាពរបស់ស៊ុត។ មានន័យថា នៅពេលមានសីតុណ្ហភាពខ្ពស់ បរិមាណស៊ុ

ចំណីរបស់មាន់មានការថយចុះ ដូច្នេះ ទម្ងន់ស៊ុតក៏មានលក្ខណៈតូចទៅ ហើយសម្បកស៊ុតក៏មានលក្ខណៈស្តើងផងដែរ។

ii ប្រតិកម្មទៅនឹងអាកាសធាតុត្រជាក់និងការគ្រប់គ្រងនៅរដូវរងា

នៅពេលសីតុណ្ហភាពបរិយាកាសធ្លាក់ចុះ សត្វមាន់នឹងរមូលខ្លួន ព្រមទាំងបញ្ឈរអោម ដើម្បីកុំអោយបាត់បង់កម្តៅពីក្នុងខ្លួន។ បរិមាណស៊ីចំណីនឹងកើនឡើង ប៉ុន្តែការផលិតស៊ុតមានការថយចុះ។

iii ការគ្រប់គ្រងពន្លឺ

គឺជាបច្ចេកទេសគ្រប់គ្រងដោយគេធ្វើការបើកអំពូលភ្លើងនៅរោងចិញ្ចឹមមាន់ និងផ្តល់រយៈពេលបំភ្លឺ(រយៈពេលនៃពេលថ្ងៃ+រយៈពេលបំភ្លឺភ្លើង)អោយបានសមស្រប ដើម្បីគ្រប់គ្រងការលូតលាស់ពេញវ័យ និង ជម្រុញការផលិតស៊ុតរបស់មាន់។ នៅដំណាក់កាលមាន់ពេញវ័យក្នុងរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ សម្រាប់ដំណាក់កាលដំបូងនៃការផលិតស៊ុត គេកំណត់រយៈពេលបំភ្លឺ(រយៈពេលនៃពេលថ្ងៃ+រយៈពេលបំភ្លឺភ្លើង)អោយមានរយៈពេល14~15ម៉ោងគ្រប់ទាំងអស់ ហើយនៅពេលគេសម្គាល់ឃើញច្បាស់ថាការផលិតស៊ុតមានការថយចុះ គេចាប់ផ្តើមពន្យាររយៈពេលបំភ្លឺអោយវែងទៅៗ(កំណើនបន្តិចម្តងៗ : 30នាទីក្នុង2សប្តាហ៍) ហើយនៅពេលរយៈពេលបំភ្លឺកើនឡើងដល់17ម៉ោង គេនឹងបន្តរក្សាកម្រិតនេះតទៅ។ ទោះជាគេពន្យាររយៈពេលបំភ្លឺអោយកាន់តែវែងជាងនេះ ក៏មិនអាចជម្រុញការផលិតស៊ុតបន្ថែមលើសពីនេះទៀតបានដែរ។

នៅរោងចិញ្ចឹមមាន់ដែលគ្មានបង្ហួច រយៈពេល2សប្តាហ៍បន្ទាប់ពីគេចាប់ផ្តើមអោយចំណី គេធ្វើការបំភ្លឺរយៈពេល24ម៉ោង ហើយនៅពេលកូនមាន់មានអាយុ2សប្តាហ៍ហើយ គេនឹងបំភ្លឺរយៈពេល19ម៉ោង បន្ទាប់ពីនោះគេនឹងបន្តយរយៈពេលបំភ្លឺ30នាទីរៀងរាល់2សប្តាហ៍ (ការបន្តយបន្តិចម្តងៗ) ហើយនៅពេលមាន់មានអាយុ18សប្តាហ៍ គេនឹងកំណត់រយៈពេលបំភ្លឺត្រឹម14.5ម៉ោង។ បន្ទាប់ពីនោះ នៅដំណាក់កាលមាន់ពេញវ័យ គេអនុវត្តដូចគ្នាទៅនឹងរោងចិញ្ចឹមមាន់លក្ខណៈបើកចំហផងដែរ។

iv ការផ្លាស់ប្តូរស្លាបដោយបង្ខំ និងរបៀបនៃការផ្លាស់ប្តូរ

រយៈពេល1ឆ្នាំក្រោយពីបង្កើតកូនដំបូងរួច ការផលិតស៊ុតគឺមានការថយចុះ សម្បកស៊ុតក៏មានភាពស្តើង ហើយគុណភាពស៊ុតក៏ថយចុះផងដែរ។ វាជ្ឈកការផលិតស៊ុតក្នុងរយៈពេល2-4ខែ ចាប់ពីរដូវស្លឹកឈើជ្រុះដល់រដូវរងាដែលមានថ្ងៃខ្លី ហើយនៅក្នុងចន្លោះពេលនោះ កើតមានឡើងនូវការផ្លាស់ប្តូរស្លាបដោយធម្មជាតិ ដោយវាជ្រុះស្លាបចាស់ពីធម្មជាតិ ហើយជំនួសវិញដោយស្លាបថ្មី។ ប្រសិនបើគេធ្វើការផ្លាស់ប្តូរស្លាបតាមបែបសិប្បនិម្មិតមុនពេលផ្លាស់ប្តូរស្លាបដោយធម្មជាតិ គុណភាពសម្បកស៊ុតមានលក្ខណៈប្រសើរ ហើយអាចពន្យាររយៈពេលនៃការប្រមូលស៊ុតបានផងដែរ។ មធ្យោបាយនេះ គេហៅថាការផ្លាស់ប្តូរស្លាបដោយបង្ខំ។

មធ្យោបាយដែលគេអនុវត្តជាទូទៅ គឺគេបង្អត់ចំណីវារយៈពេល10-14ថ្ងៃនៅក្នុងរដូវក្តៅ និង7-10ថ្ងៃនៅក្នុងរដូវរងា នៅក្នុងអាយុប្រហែល 60សប្តាហ៍ ហើយគេផ្តាច់ភ្លើងស្របពេលជាមួយគ្នាផងដែរ។ បន្ទាប់ពីរយៈពេលបង្អត់ចំណីត្រូវបានបញ្ចប់ គេឲ្យចំណីវាដោយបន្ថែមបរិមាណបន្តិចម្តងៗក្នុងរយៈពេលប៉ុន្មានថ្ងៃ។

v ការដកមាន់ដែលឥតបានការ

មាន់ដែលមានសុខភាពមិនល្អ ហើយការផលិតស៊ុតមានការថយចុះ ទោះបីជាចិញ្ចឹមក៏ដោយក៏លទ្ធផលនៃការផលិតស៊ុតមិនមានការកើនឡើងទេ ហើយវាក៏មិនផ្តល់ផលចំណេញដល់អាជីវកម្មផងដែរ។ មាន់ដែលឥតបានការបែបនេះ បើគេឃើញមាននៅក្នុងការគ្រប់គ្រងប្រចាំថ្ងៃ គេនឹងដកវាចេញ។

7 គុណភាពស៊ុតមាន់

ស៊ុតមាន់ភាគច្រើនត្រូវបានបញ្ចេញលក់ជាស៊ុតមានសំបកដែលត្រូវបានពងមកស្រាប់ដោយធ្វើឲ្យស្របតាមស្តង់ដារនៃការជួញដូរ។ គុណភាពស៊ុតមាន់កំណត់ដោយសភាពនៃសំបកស៊ុត ពងលឿង ពងសជាដើម។

(1) ស្តង់ដារនិងគុណភាពស៊ុតមាន់

ប្រភេទស្តង់ដារនិងលក្ខណៈវិនិច្ឆ័យគឺ ចំពោះLLគឺស៊ុតមាន់1មានទម្ងន់ស្មើឬលើស70ក្រាមតែតិចជាង76ក្រាម L គឺស្មើឬលើស64ក្រាមតែតិចជាង70ក្រាម Mគឺស្មើឬលើស58ក្រាមតែតិចជាង64ក្រាម MSគឺស្មើឬលើស52ក្រាមតែតិចជាង58ក្រាម Sគឺស្មើឬលើស46ក្រាមតែតិចជាង52ក្រាម SSគឺស្មើឬលើស40ក្រាមតែតិចជាង46ក្រាម។

ស៊ុតមាន់ដែលល្អគឺ រូបរាងធម្មតា គ្មានប្រឡាក់ សំបករលោងល្មមហើយរឹងមាំ ហើយគ្មានស្នាមប្រេះ។ ម្យ៉ាងទៀតស៊ុតល្អគឺនៅពេលបំបែកវា ផ្នែកខាប់នៃពងសនឹងផុសឡើងមកលើ ហើយមិនឃើញមានលាយឡំវត្ថុផ្សេង(ឈាម កម្ទេចសាច់)។



ស៊ុតដែលអាចបញ្ចេញលក់បាន



ស៊ុតដែលមិនអាចបញ្ចេញលក់បាន

(2) កត្តាកំណត់គុណភាព

គុណភាពរបស់ស៊ុតមាន់ទទួលរងឥទ្ធិពលពី កត្តាតំណពូជ ចំណី រដូវ អាយុសត្វមាន់និងបរិស្ថានចិញ្ចឹមជាដើម។

[1] សំបកស៊ុត

វាផ្សំឡើងជាចម្បងដោយជាតិកាល់ស្យូមកាបូណាត ហើយកាន់តែក្រឡាញឹកនិងក្រាស់គឺកាន់តែរឹងមាំ ហើយបើស្តើងហើយមិនរឹងមាំគឺនឹងភាគច្រើននឹងបែកឬរបូសដែលធ្វើឲ្យតម្លៃវានឹងធ្លាក់ចុះយ៉ាងខ្លាំង។

ភាពរឹងមាំនៃសំបកស៊ុតជាទូទៅនឹងថយចុះដោយសារតែ កង្វះជីវជាតិពិសេសគឺជាតិអសរីរាង្គដូចជាកាល់ស្យូមជាដើម កម្តៅខ្លាំងនៅរដូវក្តៅ និងវ័យចំណាស់នៃសត្វមាន់ជាដើម។

[2] ពងស

មានសភាពថ្លាពណ៌លឿងព្រឿងៗឬលឿងបៃតងព្រឿងៗ ហើយមានពីរផ្នែកគឺផ្នែករាវដូចទឹក(ផ្នែករាវនៃពងស)និងផ្នែកដែលខាប់(ផ្នែកខាប់នៃពងស)។ ផ្នែកខាប់នៃពងសកាន់តែផុសឡើងខ្ពស់គឺកាន់តែល្អ។ កម្ពស់ផុសឡើងនៃផ្នែកខាប់នៃពងសនឹងធ្លាក់ចុះទៅតាមចំនួនថ្ងៃដែលស្តុកទុក ហេតុនេះវាក្លាយជារង្វាស់នៃភាពថ្មីស្រស់របស់ស៊ុត។ ម្យ៉ាងទៀត កម្ពស់ផុសឡើងនេះនឹងកាន់តែខ្ពស់បើអាយុមាន់កាន់តែក្មេង។

អាស្រ័យហេតុនេះហើយ ដោយផ្អែកលើកម្ពស់នៃផ្នែកខប់របស់ពងសនិងទម្ងន់ស៊ុត តម្លៃលេខឈ្មោះថាហោយូនីត(Haugh unit) ត្រូវបានកំណត់ឡើងជាសន្ទស្សន៍នៃភាពថ្មីស្រស់របស់ស៊ុត។ តំណក់ឈាម(ដុំឈាម)ឬដុំរាងដូចសាច់(ដុំសាច់)ដែលលាយឡំក្នុងពងស គឺមិនផ្តល់ផលប៉ះពាល់ទេ ប៉ុន្តែគេមិនចង់ឲ្យមានទេ។

[3] ពងលឿង

ជាតិពណ៌នៃពណ៌លឿងនេះគឺបានមកពីជាតិពណ៌ដែលមានពោតនិងចំណីបៃតងដែលមានក្នុងចំណី។ ពងលឿងមានភាពយឺត ហើយបើកាន់តែមូលនិងផុសឡើងគឺកាន់តែល្អ។ ការផុសឡើងនេះនឹងទៅជារាបស្មើទៅតាមពេលវេលាហើយទីបំផុតភ្នាសពងលឿងនឹងរហែកខូចទ្រង់ទ្រាយ។

ស៊ុតដែលផ្តល់ពោតជាអាហារ

ស៊ុតដែលផ្តល់ម្សៅអង្ករជាអាហារ

8 ជំងឺរបស់មាន់

(1) ការសង្កេតមើលមាន់ និង ការរកឃើញជំងឺ

នៅពេលដែលរោងចិញ្ចឹមមាន់កាន់តែធំ ហើយចំនួនមាន់កាន់តែច្រើន ការផ្លាស់ប្តូរខ្យល់នៅក្នុងរោងងាយនឹងមានលក្ខណៈមិនល្អប្រសើរ ហើយកម្រិតឧស្ម័នពុលនិងសំណើមក៏កើនឡើង ធ្វើអោយមាន់ងាយកើតជំងឺផ្លូវដង្ហើម។ ម្យ៉ាងទៀត ប្រសិនបើអ្នកគ្រប់គ្រងមានចំនួនតិច វាងាយនឹងធ្វើអោយការគ្រប់គ្រងប្រចាំថ្ងៃ ការសម្អាតលាមក ការសង្កេតមើលស្ថានភាពសុខភាព និង ការគ្រប់គ្រងអនាម័យមានលក្ខណៈមិនគ្រប់គ្រាន់ ដូច្នេះ គេត្រូវប្រុងប្រយ័ត្នចំពោះបញ្ហានេះ។

នៅក្នុងចំណោមជំងឺទាំងអស់ ជំងឺដែលសំខាន់ពិសេសជាងគេនោះគឺ "ជំងឺឆ្លងដែលមានចែងនៅក្នុងច្បាប់" ជាជំងឺដែលគេត្រូវអនុវត្តតាមការកំណត់នៅក្នុងច្បាប់ស្តីអំពីការបង្ការជំងឺឆ្លងនៅលើសត្វចិញ្ចឹម។ ជំងឺឆ្លងដែលមានចែងនៅក្នុងច្បាប់ រួមមាន ជំងឺអាសន្នរោគមាន់ ជំងឺផ្តាសាយបក្សីដោយវីរុសដែលមានលទ្ធភាពបង្កគ្រោះថ្នាក់ខ្ពស់ ជំងឺញ៉ូវកាសល់ (Newcastle disease) ជំងឺឆ្លងបាក់តេរីសាល់ម៉ូនេឡាមាន់(ជំងឺរាកស ឬ Pullorum disease)។

[1] សកម្មភាពនៃមាន់ឈឺ

· គ្មានកម្លាំង ចលនាមិននឹងនរ មិនស៊ីចំណី។

· បរិមាណលាមកថយចុះ ពណ៌លាមកប្រែ រាករូស។

· មាន់ពេញវ័យអាចនឹងឈប់ផលិតស៊ុត ឬផលិតស៊ុតដែលទន់ឬខុសទម្រង់ប្រក្រតី។

· ពេលខ្លះ មាន់បញ្ចេញសម្លេងប្លែកៗ។

[2] រូបរាងខាងក្រៅរបស់មាន់ឈឺ

· រោមបះ និង ស្លាបធ្លាក់។

· សិរមាន់មានពណ៌ស្លេក ឬ ក៏មានពណ៌ស្វាយចាស់។

· មានប្រឡាក់ទឹកភ្នែកនៅភ្នែក និង សម្បារនៅច្រមុះ។ មាន់ឧស្សាហ៍បិទភ្នែក។

· ដកដង្ហើមដោយបើកមាត់។

(2) វិធានការទប់ទល់នឹងជំងឺរបស់មាន់

[1] ការទប់ស្កាត់ការជ្រៀតចូល និង ការរាតត្បាលនៃមេរោគ

នៅក្នុងចំណោមជំងឺឆ្លងទាំងអស់ ប្រសិនបើគេចិញ្ចឹមសត្វនៅក្នុងបរិស្ថានដែលល្អ គេនឹងអាចទប់ស្កាត់ការកើតមានជំងឺឆ្លងមួយចំនួន ប៉ុន្តែ ក៏មានជំងឺមួយចំនួនដែលកើតឡើងដោយសារមេរោគមានលទ្ធភាពចម្លងខ្លាំងក្លា ធ្វើអោយគេមិនអាចទប់ស្កាត់ដោយត្រឹមវិធីខាងលើបាននោះទេ។ ដំបូង គេចាំបាច់ត្រូវធ្វើការបំបាត់មេរោគនៅរោងចិញ្ចឹមមាន់ ព្រមទាំងធ្វើការទប់ស្កាត់ការជ្រៀតចូលនៃមេរោគពីខាងក្រៅ(វិធានការចំពោះសត្វព្រៃ) និង ត្រូវប្រយ័ត្នកុំអោយមានការនាំចូលមេរោគទាំងនោះពីខាងក្រៅ(តាមរយៈមនុស្ស រថយន្ត ចំណីសត្វ សម្ភារៈ។ល។)។ ម្យ៉ាងទៀត អ្នកគ្រប់គ្រងត្រូវអនុវត្តការសម្លាប់មេរោគលើដៃនិងជើង ប្រើប្រាស់សម្លៀកបំពាក់និងស្បែកជើងសម្រាប់ធ្វើការងារនៅរោងចិញ្ចឹមមាន់នីមួយៗ ដើម្បីកុំអោយមានការចម្លងមេរោគរវាងរោងចិញ្ចឹមមាន់ដែលនៅក្បែរគ្នា។

នៅក្នុងច្បាប់ស្តីអំពីការបង្ការជំងឺឆ្លងនៅលើសត្វចិញ្ចឹម មានការកំណត់បទដ្ឋានគ្រប់គ្រងអនាម័យក្នុងការចិញ្ចឹមសត្វ ដូច្នេះ ការគោរពនិងអនុវត្តទៅតាមបទដ្ឋាននោះអោយបានម៉ត់ចត់ជាការសំខាន់។

[2] ការបង្ការជំងឺតាមរយៈការចាក់វ៉ាក់សាំងនិងថ្នាំបង្ការ

ចំពោះជំងឺដែលការចាក់វ៉ាក់សាំងមានប្រសិទ្ធិភាពការពារ (រួមមាន ជំងឺញ៉ូវកាសល់ ជំងឺរលាកទងសួតមាន់លក្ខណៈឆ្លង ជំងឺអុតមាន់ ជំងឺម៉ារិក(Marek's disease)) គេត្រូវរៀបចំកម្មវិធីសម្រាប់ការចាក់វ៉ាក់សាំង និងអនុវត្តអោយបានត្រឹមត្រូវនិងច្បាស់លាស់ (ការបង្ការជំងឺដោយការចាក់វ៉ាក់សាំង)។ របៀបចាក់វ៉ាក់សាំងអាចធ្វើតាមរយៈទឹកផឹក ការបន្តក់តាមច្រមុះ ការបន្តក់តាមភ្នែក ថ្នាំបាញ់ ថ្នាំចាក់ ឬ តាមការចាក់បញ្ចូលក្នុងខ្លួនជាដើម ដោយគេត្រូវជ្រើសរើសវិធីដែលសមស្របយោងទៅតាមប្រភេទវ៉ាក់សាំង អាយុ និង ស្ថានភាពសុខភាពរបស់មាន់។

ចំពោះជំងឺឡឺកូស៊ីតូហ្សូន(leucocytozoonosis)ដែលចម្លងដោយមូសឈ្មោះនីវ៉ាតូរីនុកា (Culicoides arakawae) គេធ្វើការបន្ថែមថ្នាំស៊ុលហ្វានៅក្នុងចំណីរបស់សត្វមាន់ឬ តាមទឹកផឹកដើម្បីព្យាបាលជំងឺនេះ ប៉ុន្តែគេចាំបាច់ត្រូវចាត់វិធានការកម្ចាត់សត្វល្អិតដើម្បីទប់ស្កាត់ការកើតឡើងនូវមូសនីវ៉ាតូរីនុកាដែលចេញពេលយប់។ ថ្នាំថាយរ៉ូស៊ីន(Tylosin)និងថ្នាំស្ពីរ៉ាម៉ៃស៊ីន(Spiramycin) មានប្រសិទ្ធិភាពបង្ការជំងឺឆ្លងម៉ៃកូផ្លាស្មាដែលបង្កជំងឺនៅសរីរាង្គផ្លូវដង្ហើមរបស់សត្វ។ ម្យ៉ាងទៀត នៅក្នុងការចិញ្ចឹមលើផ្ទៃរាប អាចកើតមានជំងឺកុកស៊ីឌីអូស៊ីសមាន់ដែលកើតឡើងដោយសារប៉ារ៉ាស៊ីតបង្កជំងឺនៅតាមពោះវៀន ដោយជំងឺនេះមិនសូវកើតមាននៅក្នុងការចិញ្ចឹមក្នុងទ្រុងឬទម្រង់ជាធ្នើរនោះទេ។ ជំងឺនេះច្រើនកើតឡើងជាលក្ខណៈស្រួចស្រាវនៅលើកូនមាន់តូចឬមធ្យមប៉ុន្តែ អាចជាជំងឺរ៉ាំរ៉ៃនៅលើកូនមាន់ធំ។ ថ្នាំស៊ុលហ្វាមានប្រសិទ្ធិភាពនៅក្នុងការព្យាបាលជំងឺនេះ ប៉ុន្តែ ការបង្ការជំងឺនេះដោយលាយថ្នាំបង្ការនៅក្នុងចំណីគឺមានប្រសិទ្ធិភាពជាង។

(3) ការកម្ចាត់សត្វល្អិតចង្រៃបង្កការខូចអនាម័យ

ថ្មីៗនេះ មានការកើតឡើងច្រើននូវចៃវ៉ាគឺម៉ុដែលជាប៉ារ៉ាស៊ីតពីខាងក្រៅ ដោយវាបង្កផលប៉ះពាល់ដូចជា ការកើតមានស៊ីតកង្វក់ដោយសារការជាប់នូវសារធាតុបញ្ចេញពីចៃឬឈាមរបស់ចៃ ការធ្វើអោយមាន់ងាប់ ការធ្វើអោយមាន់មានអាការៈខ្វះឈាម ការផលិតស៊ីតធ្លាក់ចុះ ការឈប់ធ្វើការងាររបស់អ្នកគ្រប់គ្រងដោយសារអារម្មណ៍ខ្ពើម ការចម្លងមេរោគនៃជំងឺឆ្លងដែលកើតមានលើសត្វនិងមនុស្ស។ល។ វិធានការកម្ចាត់ រួមមាន ការរកឃើញនិងការកម្ចាត់ចៃវ៉ាគឺម៉ុនៅដំណាក់កាលដំបូង ការទប់ស្កាត់ការជ្រៀតចូលនៃចៃ ការបោសនិងលាងសម្អាតប្រចាំថ្ងៃអោយបានម៉ត់ចត់ ការបាញ់ថ្នាំសម្លាប់សត្វល្អិត ។ល។ ក្រៅពីនេះ គេត្រូវកម្ចាត់ចៃតូរីសាស៊ីនិងមូសនីវ៉ាតូរីនុកា (ដែលចម្លងជំងឺឡឹកូស៊ីតូហ្សូន) ដូចគ្នានេះដែរ។

ម៉ាស៊ីនកម្ចាត់ចៃវ៉ាគឺម៉ុ

(4) ការកម្ចាត់សត្វព្រៃ

គេធ្វើការទប់ស្កាត់ការលាយឡំសារធាតុបញ្ចោញចោលរបស់ពពួកសត្វព្រៃដូចជាកណ្តុរឬសត្វស្លាបព្រៃជាដើមនៅក្នុងបរិក្ខារផ្តល់ចំណីនិងបរិក្ខារផ្តល់ទឹកឬទីកន្លែងរក្សាទុកចំណីសត្វនៅរោងចិញ្ចឹមមាន់ ដោយធ្វើការទប់ស្កាត់ការជ្រៀតចូលនៃសត្វទាំងនោះតាមរយៈការបំពាក់សំណាញ់ការពារសត្វស្លាបនៅរោងចិញ្ចឹមមាន់ជាដើម។ ផលប៉ះពាល់ដោយសារសត្វកណ្តុរ រួមមាន ការខូចបង់ចំណីសត្វ ការខូចខាតសំណង់ ការចម្លងមេរោគនៃជំងឺឆ្លងដែលកើតមានលើសត្វនិងមនុស្ស។ល។ វិធានការទប់ស្កាត់ រួមមាន ការឃាំងនូវផ្លូវដែលសត្វទាំងនោះអាចជ្រៀតចូលបាន ក្រៅពីនេះគេអាចប្រើអង្គប់ឬថ្នាំសម្លាប់សត្វកណ្តុរជាដើម។ ជាពិសេស ការជ្រៀតចូលនៃសត្វស្លាបព្រៃជាមូលហេតុធំនៃការបង្កអោយមានជំងឺផ្តាសាយបក្សី ដែលជាការគម្រាមកំហែងមួយ ដូច្នេះ គេចាំបាច់ត្រូវអនុវត្តវិធានការទប់ស្កាត់អោយបានម៉ត់ចត់។

9 ជំងឺផ្តាសាយបក្សីនិងការទប់ស្កាត់

(1) ជំងឺផ្តាសាយបក្សី

ជំងឺផ្តាសាយបក្សីគឺជាជំងឺរបស់ពពួកសត្វស្លាបរួមទាំងសត្វស្លាបចិញ្ចឹមផងដែរ ដោយជំងឺនេះបង្កឡើងតាមរយៈការឆ្លងវីរុសផ្តាសាយធំ (វីរុសAI) ហើយចំពោះសត្វមាន់ គេបែងចែកវីរុសបង្កជំងឺទៅតាមបុគ្គលិកលក្ខណៈឬកម្រិតបង្កជំងឺរបស់វា ជា"វីរុសដែលមានលទ្ធភាពបង្កជំងឺខ្ពស់"និង"វីរុសដែលមានលទ្ធភាពបង្កជំងឺទាប" ហើយគេបែងចែកទៅតាមភាពខុសគ្នានៃសារធាតុពុលរបស់វីរុសទាំងនោះ ជា"ប្រភេទពុលខ្លាំង"និង"ប្រភេទពុលខ្សោយ"។ សម្រាប់វីរុសAIដែលជា"វីរុសដែលមានលទ្ធភាពបង្កជំងឺខ្ពស់"និងស្ថិតក្នុង"ប្រភេទពុលខ្លាំង" គឺអត្រាងាប់របស់មាន់មានកម្រិត100%នៅក្នុងអំឡុងពេល4~5ថ្ងៃបន្ទាប់ពីរកឃើញការឆ្លងវីរុស។

(2) វិធានការទប់ស្កាត់ជំងឺផ្តាសាយបក្សី

ជំងឺផ្តាសាយបក្សីស្ថិតក្នុងជំងឺដែលមានចែងនៅក្នុងច្បាប់ស្តីអំពីការបង្ការជំងឺឆ្លងនៅលើសត្វចិញ្ចឹម ដោយច្បាប់នេះបានកំណត់បទដ្ឋានគ្រប់គ្រងអនាម័យក្នុងការចិញ្ចឹមសត្វទាក់ទងនឹងការបង្ការការកើតឡើងនិងការទប់ស្កាត់ការរាតត្បាតនៃជំងឺផ្សេងៗ ដូច្នេះ គេត្រូវគោរពនិងអនុវត្តតាមបទដ្ឋានកំណត់ទាំងនោះ។

[1] ការទប់ស្កាត់ការជ្រៀតចូលនៃសត្វស្លាបព្រៃទៅក្នុងតំបន់នៃរោងចិញ្ចឹមមាន់

[2] ការរកឃើញជំងឺក្នុងដំណាក់កាលដំបូងតាមរយៈការអនុវត្តការត្រួតពិនិត្យជាដើម

[3] ការដកសត្វឈឺចេញក្នុងដំណាក់កាលដំបូងនៅពេលរកឃើញវីរុស(ទប់ស្កាត់កុំអោយពុលខ្លាំង)

[4] ការអនុវត្តការតាមដាន

[5] ការរក្សាស្ថានភាពអនាម័យនៅរោងចិញ្ចឹមមាន់

[6] ការអនុវត្តការសង្កេតមើលស្ថានភាពសុខភាពរបស់មាន់

[7] ការពិនិត្យរករោគសញ្ញាមួយចំនួននៃជំងឺផ្តាសាយបក្សីដោយវីរុសដែលមានលទ្ធភាពបង្កជំងឺខ្ពស់

រោគសញ្ញា : នៅពេលអត្រាមាន់ងាប់ក្នុង1ថ្ងៃកើនឡើងលើសពី2ដងនៃអត្រាមាន់ងាប់ជាមធ្យម នៅរោងចិញ្ចឹមមាន់ដូចគ្នាក្នុងរយៈពេលកំណត់មួយ។

10 វិធីកម្ចាត់លាមកមាន់

បច្ចុប្បន្ននេះ ស្ទើរតែទាំងអស់ គេធ្វើការកម្ចាត់លាមកមាន់ដោយប្រើវិធីផ្អាប់ ដើម្បីយកលាមកទាំងនោះទៅប្រើប្រាស់ធ្វើជាជីកំប៉ុស្ត៍។ វិធីផ្អាប់ រួមមាន វិធីគរជាគំនរ វិធីកូរលក្ខណៈបើកចំហ វិធីកូរលក្ខណៈបិទជិត ។ល។ ប៉ុន្តែប្រសិនបើគេស្ថិតនៅក្នុងបរិស្ថានដែលអាចសាងសង់អគារសម្ងួតលាមកមាន់ ដូចជានៅតំបន់ភ្នំល្មមនិងតំបន់កណ្តាលគេគួរធ្វើការផលិតលាមកមាន់ស្ងួត ទើបផ្តល់អត្ថប្រយោជន៍ជាង។ ករណីគេផលិតជីកំប៉ុស្ត៍ធ្វើពីលាមកមាន់ នៅក្នុងរោងចិញ្ចឹមដែលមានមាន់តិចជាង10,000ក្បាល គេគួរប្រើប្រាស់សម្ភារៈគ្រប់គ្រងជាតិទឹកហើយធ្វើរោងផលិតជីកំប៉ុស្ត៍ឬរោងសម្រាប់ផ្អាប់លាមករាងជាប្រអប់ជាការល្អ។ ប៉ុន្តែ ប្រសិនបើមានមាន់ចាប់ពី30,000ក្បាលឡើង គេចាំបាច់ត្រូវប្រើរោងផ្អាប់លាមកទម្រង់បើកចំហឬទម្រង់បិទជិតដែលមានបំពាក់ឧបករណ៍កូរ ហើយការរៀបចំអោយមានសម្ភារៈគ្រប់គ្រងជាតិទឹកសម្រាប់ទម្រង់បើកចំហ និង ឧបករណ៍កម្តៅសម្រាប់ទម្រង់បិទជិត ធ្វើអោយការផលិតមានលក្ខណៈសុវត្ថិភាព ។

11 ផែនការចិញ្ចឹម និងការវាយតម្លៃសមត្ថភាព

(1) ផែនការចិញ្ចឹម

ក្នុងការដាក់បញ្ចូលកូនមាន់ គេកំណត់ចំនួនដងនៃការដាក់បញ្ចូលនិងចំនួនក្បាលដាក់បញ្ចូលឲ្យមានតុល្យភាពជាមួយការផលិតស៊ុតមាន់ក្នុងកសិដ្ឋានចិញ្ចឹមមាន់ទាំងមូល ហើយដែលល្អបំផុតគឺធ្វើការប្តូរជំនួសទាំងស្រុងនូវចំនួនក្បាលដូចគ្នា(ចូលទាំងអស់ចេញទាំងអស់)ក្នុងគម្លាតដូចគ្នាចំពោះរោងមាន់និមួយៗ។

(2) ការអង្កេតនិងវាយតម្លៃសមត្ថភាព

[1] អត្រាផលិតស៊ុត

អត្រាផលិតស៊ុតគឺជាតម្លៃលេខដែលបង្ហាញភាគរយនៃសត្វមាន់ដែលបានផលិតស៊ុតជាក់ស្តែង ដែលបានដោយយកចំនួនស៊ុតផលិតបានក្នុងរយៈពេលកំណត់មួយរបស់ហ្វូងមាន់ ចែកនឹងចំនួនសត្វមាន់ដែលចិញ្ចឹមក្នុងរយៈពេលកំណត់ដូចគ្នា ហើយគុណនឹង100 (គិតជា%)។ ឧទាហរណ៍អត្រាផលិតស៊ុតសាមញ្ញគឺ បើសត្វមាន់100ក្បាលក្នុងមួយថ្ងៃផលិតស៊ុតបាន90គ្រាប់ នោះអត្រាផលិតស៊ុតគឺ90%។

អត្រាផលិតស៊ុតគឺប្រហែល200ថ្ងៃក្រោយផលិតស៊ុតដំបូង នឹងឡើងដល់កំពូលគឺរហូតដល់ប្រហែល90% ហើយបន្តរក្សាកម្រិតផលិតស៊ុតខ្ពស់រយៈពេលប្រមាណ60ថ្ងៃ បន្ទាប់មកធ្លាក់ចុះបន្តិចម្តងៗ ហើយនៅពេលដល់អាយុដកចេញគឺពេលអាយុ550ថ្ងៃ វានឹងចុះដល់65%។ ម្យ៉ាងទៀតទម្ងន់ស៊ុតនឹងកាន់តែធ្ងន់ទៅតាមអាយុមាន់។ ការបង្កើនអត្រាផលិតស៊ុតគឺជាបច្ចេកទេសចាំបាច់បំផុតក្នុងការចិញ្ចឹមមាន់ ហើយផលចំណេញនៃអាជីវកម្មនឹងខុសគ្នាខ្លាំងអាស្រ័យលើបច្ចេកទេសនេះ។

[2] បរិមាណផលិតស៊ុត

ទម្ងន់ស៊ុតក្នុងពេល1ឆ្នាំចាប់ពីពេលផលិតស៊ុតដំបូង នឹងបន្តកើនឡើងដោយជាមធ្យមគឺ 61-65ក្រាម។ បើគិតតាមបរិមាណផលិតស៊ុតសរុប ក្នុងមួយឆ្នាំមួយក្បាលគឺ 17-20គីឡូក្រាម។ បរិមាណផលិតស៊ុតក្នុងមួយក្បាលក្នុងមួយថ្ងៃដែលបានដោយយកបរិមាណស៊ុតផលិតបានសរុបក្នុងមួយថ្ងៃរបស់ហ្វូងមាន់ចែកនឹងចំនួនមាន់ដែលចិញ្ចឹម គឺហៅថា បរិមាណផលិតស៊ុតក្នុងមួយថ្ងៃ។ បរិមាណផលិតស៊ុតក្នុងមួយថ្ងៃគឺមានទំនាក់ទំនងនឹងបរិមាណទាមទារសារធាតុចិញ្ចឹមរបស់មាន់ចិញ្ចឹមយកស៊ុត ហើយបើមិនបានផ្តល់ចំណីឲ្យបានគ្រប់គ្រាន់នឹងបរិមាណផលិតស៊ុតទេនោះ បរិមាណផលិតស៊ុតនឹងធ្វើចុះ។

② មាន់ចិញ្ចឹមយកសាច់

1 វិធីសាស្ត្រចិញ្ចឹមមាន់យកសាច់ និងកសិដ្ឋាន · បរិក្ខារ

(1) វិធីសាស្ត្រចិញ្ចឹម

ពូជមាន់ប្រយឡឺធំធាត់លឿនខ្លាំងជាងមាន់ចិញ្ចឹមយកស៊ុតដោយភាគច្រើនគេបញ្ចេញលក់នៅពេលប្រហែលអាយុ8សប្តាហ៍។ ជាទូទៅគេប្រើវិធីចិញ្ចឹមលើផ្ទៃរាបដែលចិញ្ចឹមមាន់នៅលើផ្ទៃរាបស្មើលើកម្រាលបាតផ្ទាល់ ដោយវាសមស្របសម្រាប់ការគ្រប់គ្រងជាហ្វូងនិងងាយស្រួលប្រើប្រាស់ម៉ាស៊ីនគ្រប់គ្រងដែលកាត់បន្ថយកម្លាំងហេតុនេះហើយវាក្លាយជាវិធីសាស្ត្រចិញ្ចឹមស្តង់ដារនៃពូជប្រយឡឺ។ យ៉ាងណាមិញ ដើម្បីបង្កើនបរិមាណផលិតដង់ស៊ីតេនៃការចិញ្ចឹមនឹងមានទំនោរកើនខ្ពស់ ហេតុនេះត្រូវប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់ចំពោះការគ្រប់គ្រងសុខភាពសត្វមាន់។ ហេតុនេះហើយ នៅលើផ្ទៃកម្រាលបាតគេក្រាលសម្ភារៈក្រាលដែលស្រូបជាតិទឹកបានល្អកម្រាស់យ៉ាងហោច10សង់ទីម៉ែត្រដូចជា កម្ទេចឈើពីដែកឈូស អាចម៍រណារ ចំបើងខ្លីៗជាដើម។ កម្រាលនេះមានប្រសិទ្ធភាពជួយកាត់បន្ថយបន្ទុកទម្ងន់ទៅលើជើងរបស់សត្វមាន់ដោយសារតែទម្ងន់មាន់ប្រយឡឺកើនលឿនខ្លាំង។ ម្យ៉ាងទៀត ពេលមាន់ប្រយឡឺអង្គុយ នឹងមានបន្ទុកទម្ងន់ដូចគ្នានេះចំពោះឆ្អឹងទ្រូងដែលងាយបង្កឲ្យកើតជំងឺរលាក(ហើមដោយទឹកដក់ក្នុងខ្លួន) ហេតុនេះវាក៏មានប្រយោជន៍ក្នុងការបង្ការបញ្ហានេះដែរ។

កន្លែងចិញ្ចឹមមាន់ប្រយឡឺ

ពូជមាន់ក្នុងស្រុកបើប្រៀបធៀបនឹងមាន់ប្រយឡឺ ផលិតភាពនៃសាច់គឺទាបជាង ប៉ុន្តែសម្រាប់គោលបំណងផលិតសាច់មាន់គុណភាពខ្ពស់គឺគេចិញ្ចឹមដោយមានលក្ខណៈពិសេសគឺផ្តល់ចំណីពិសេសនិងប្រើវិធីសាស្ត្រចិញ្ចឹមដូចជា ចិញ្ចឹមរយៈពេលវែងដែលចាប់ពី80-150ថ្ងៃឡើងទៅ ចិញ្ចឹមលើផ្ទៃរាប ចិញ្ចឹមដោយព្រលែងចិញ្ចឹមដោយដង់ស៊ីតេទាបជាដើម។

(2) ទម្រង់នៃរោងចិញ្ចឹមមាន់

[1] រោងចិញ្ចឹមមាន់បែបបើកចំហ

គេខណ្ឌរោងចិញ្ចឹមមាន់ដោយបង្គួចឬរាំងនន ហើយវាងាយនឹងទទួលបំរែបំរួលបរិយាកាសខាងក្រៅដូចជាសីតុណ្ហភាព ភ្លៀងខ្យល់ ពន្លឺព្រះអាទិត្យជាដើម។

[2] រោងចិញ្ចឹមមាន់គ្មានបង្អួច

ជារោងចិញ្ចឹមមាន់គ្មានបង្អួចដែលពន្លឺព្រះអាទិត្យមិនអាចចូលមកបាន ដោយជញ្ជាំងនិងពិដាន(ដំបូល)គឺគេប្រើវត្ថុធាតុដើមដែលមិនចម្លងកម្តៅ។ គេគ្រប់គ្រងពន្លឺដោយប្រើអំពូល ហើយធ្វើការផ្លាស់ប្តូរខ្យល់ដោយប្រើកង្ហារផ្លាស់ប្តូរខ្យល់។ បើប្រៀបធៀបនឹងរោងចិញ្ចឹមមាន់បែបបើកចំហគឺការចិញ្ចឹមមានដង់ស៊ីតេខ្ពស់ជាង ហេតុនេះងាយស្រួលគ្រប់គ្រងដោយម៉ាស៊ីនដែលសក្តិសមសម្រាប់កសិដ្ឋានចិញ្ចឹមមាន់ខ្នាតធំ។ ម្យ៉ាងទៀត ដោយសារតែបិទរោងជិតតែម្តង កម្រិតអនាម័យគឺខ្ពស់ខ្លាំង។ យ៉ាងណាមិញ ត្រូវការវិនិយោគបរិក្ខារច្រើន។

(3) វិធីសាស្ត្រផ្តល់កម្តៅ

ក្នុងការផ្តល់កម្តៅ មានវិធីសាស្ត្រចិញ្ចឹមរាងដូចឆ័ត្រដែលបន្តោកម៉ាស៊ីនកម្តៅរាងដូចឆ័ត្រ និងវិធីសាស្ត្រផ្តល់កម្តៅពីកម្រាលបាត។

[1] វិធីសាស្ត្រចិញ្ចឹមរាងដូចឆ័ត្រឬរាងដូចនំផេនខេក

គេបន្តោកម៉ាស៊ីនកម្តៅរាងដូចឆ័ត្រឬនំផេនខេកពីពិដានផ្តល់កម្តៅពីលើកូនមាន់។

ភាគច្រើនគេប្រើឧស្ម័នហ្គាសជាវត្ថុធាតុចំហេះ ហើយចាំបាច់ត្រូវធ្វើការប៉ះបូរបន្តិចបន្តួចដោយកម្តៅភ្លើងទៅតាមស្ថានភាពនៃកូនមាន់។ នៅលើកម្រាលបាតគេក្រាលសម្ភារៈក្រាលឲ្យក្រាស់ ប៉ុន្តែបើផ្ទៃកម្រាលបាតធំ គឺពិបាកបង្កើតបរិយាកាសដែលដូចគ្នា ហេតុនេះចាំបាច់ត្រូវកែច្នៃប្រើប្រាស់វត្ថុធាតុមិនចម្លងកម្តៅដែលការពាររចនាសម្ព័ន្ធនៃកម្រាលបាតពីសំណើមនិងការចុះត្រជាក់ខ្លាំង។

[2] វិធីសាស្ត្រផ្តល់កម្តៅពីកម្រាលបាត

នៅក្នុងកសិដ្ឋានធំៗ គេបង្កប់បំពង់នៅក្រោមកម្រាលបាតបេតុងហើយបង្ហូរទឹកក្តៅជាដើមឲ្យហូរកាត់ដើម្បីផ្តល់កម្តៅពីកម្រាលបាត។ វិធីនេះត្រូវការការវិនិយោគលើបរិក្ខារ ប៉ុន្តែសក្តិសមនឹងប្រទេសជប៉ុនដែលមានសំណើមខ្ពស់ ហើយវាងាយស្រួលតាមដានកូនមាន់ និងអាចចិញ្ចឹមកូនមាន់ក្រោមលក្ខខណ្ឌបរិយាកាសដូចគ្នា។ គេជឿថាកត្តានេះគឺជួយឲ្យកូនមាន់ក៏ឆាប់ធំ ហើយសាច់ក៏ពេញល្អ។ វាក៏មានចំណុចល្អដោយវាធ្វើឲ្យលាមកស្ងួតងាយគ្រប់គ្រង ប៉ុន្តែបើការសម្ងួតនោះហួសកម្រិតនោះនឹងបង្កជំងឺប្រព័ន្ធដង្ហើម ហេតុនេះចាំបាច់ត្រូវធ្វើការគ្រប់គ្រងសីតុណ្ហភាព។

(4) បរិក្ខារ ឧបករណ៍ម៉ាស៊ីន

[1] របងព័ទ្ធ

គេហ៊ុមព័ទ្ធកូនមាន់ជារង្វង់ដោយរបង(ស័ង្កសីខ្នាតវែង)កម្ពស់ប្រហែល30សង់ទីម៉ែត្រសម្រាប់ប្រើក្នុងការចិញ្ចឹមកូនមាន់ទើបកើត ហើយនៅក្នុងនោះ គេដាក់សម្ភារៈក្រាល ប្រភពកម្តៅ ឧបករណ៍ផ្តល់ចំណី ឧបករណ៍ផ្តល់ទឹក។ គេដាក់ឧបករណ៍ចិញ្ចឹមរាងដូចឆ័ត្រនៅម្តុំកណ្តាលនៃកម្រាលបាត ហើយគេព័ទ្ធរបងជុំវិញជារង្វង់ដោយឲ្យឃ្លាតពីឆ័ត្រប្រហែល50សង់ទីម៉ែត្រ។ ចំពោះវិធីផ្តល់កម្តៅពីកម្រាលបាត គេក៏ប្រើរបងព័ទ្ធដូចគ្នាដែរ។

គេពង្រីករង្វង់នៃរបងបន្តិចម្តងៗជារៀងរាល់ថ្ងៃទៅតាមការធំធាត់របស់កូនមាន់ចាប់ពីថ្ងៃទី4ទៅ។ ហើយនៅរដូវក្តៅ គេដករបងចេញនៅពេលអាយុ10ថ្ងៃ នៅរដូវរងាគេដកចេញនៅពេលអាយុ13ថ្ងៃ។

[2] ឧបករណ៍ផ្តល់ចំណី

ក្នុងការឲ្យចំណីដំបូង គេប្រើប្រអប់រាបស្មើដែលមានគែមរាក់(ចានសម្រាប់កូនមាន់)។

ក្នុងករណីប្រើឧបករណ៍ផ្តល់ចំណីដោយស្វ័យប្រវត្តិ មានទម្រង់បង្ហូរចំណីពីលើដែលគេបំពាក់បំពង់ផ្តល់ចំណីនៅពិដាននៃរោងចិញ្ចឹមមាន់ហើយបង្ហូរទម្លាក់ចំណីចូលទៅចានចំណី និងទម្រង់តម្រៀបចានចំណីនៅកម្ពស់ទាបត្រង់ជួរដែលគេបំពាក់បំពង់ផ្តល់ចំណីទៅតាមកម្ពស់សត្វមាន់និងរំកិលឡើងចុះតាមការធំធាត់។ ទោះជាទម្រង់ណាក៏ដោយ គេធ្វើការកែសម្រួលទៅតាមសត្វមាន់នូវបំពង់ផ្តល់ចំណី កម្ពស់ឧបករណ៍ផ្តល់ចំណី និងបរិមាណ

ចំណីក្នុងជីឡាវដាក់ចំណី។

[3] ឧបករណ៍ផ្តល់ទឹក

នៅពេលឲ្យចំណីដំបូង ត្រូវប្រើបន្ទះផ្តល់ទឹកឬឧបករណ៍ជំនួយផ្តល់ទឹកដើម្បីឲ្យកូនមាន់ងាយស្រួលផឹកទឹក។

ករណីប្រើឧបករណ៍បញ្ចេញទឹកទម្រង់ជាក្បាលដោះឬឧបករណ៍ផ្តល់ទឹកទម្រង់ជាជួង ត្រូវកែសម្រួលកម្ពស់និងសម្ពាធទឹកធ្វើយ៉ាងណាឲ្យកូនមាន់ទាំងអស់អាចផឹកទឹកបាន។



ប្រអប់ចំណីសម្រាប់ឲ្យចំណីដំបូង(ចានចំណីកូនមាន់)

ឧបករណ៍ជំនួយផ្តល់ទឹក

2 ចំណីសម្រាប់មាន់ចិញ្ចឹមយកសាច់(បរិមាណសារធាតុចិញ្ចឹមចាំបាច់នៅដំណាក់កាលលូតលាស់ និងកំហាប់និងបរិមាណដាក់ចំណីចំពោះចំណីលាយ)

ចំពោះមាន់ប្រយឡឺគេដាក់ចំណីដោយមិនកំណត់(ដាក់ចំណីជាប់រហូត ឲ្យស៊ីដោយសេរី)នូវចំណីលាយដែលលក់នៅទីផ្សារ(ចំណីសម្រាប់ដំណាក់កាលដំបូងនិងចំណីសម្រាប់ដំណាក់កាលចុងក្រោយ) ដោយមិនផ្លាស់ប្តូរ ហើយនៅពេលបញ្ចេញលក់ជាអាហារ គេឲ្យចំណីដែលគ្មានជាតិថ្នាំដូចជាសារជាតិប្រឆាំងបាក់តេរី(ផ្អាកផ្តល់ចំណីមានជាតិថ្នាំ)រយៈពេលយ៉ាងហោច7ថ្ងៃមុនពេលពិឃាត។

យោងតាមសៀវភៅស្តង់ដារចិញ្ចឹមសត្វរបស់ប្រទេសជប៉ុនសម្រាប់សត្វបក្សីស្រុកនិពន្ធឆ្នាំ2011 បរិមាណ

សារធាតុចិញ្ចឹមចាំបាច់សម្រាប់មាន់ប្រយឡឺនៅដំណាក់កាលដំបូង(អាយុ0-3សប្តាហ៍)គឺ ថាមពលមេតាបូលីស (ME) 3,100kcal ប្រូតេអ៊ីនមិនទាន់បម្លែង (CP) 20.0% ហើយនៅដំណាក់កាលចុងក្រោយ(អាយុ3សប្តាហ៍ឡើងទៅ) ME 3,100 kcal និង CP 16.0% ហើយចំណីលក់នៅលើទីផ្សារគឺភាគច្រើនCPខ្ពស់ជាងនេះប្រមាណ2%។

ចំណីមានដូចជា ប្រភេទម្សៅហ្មត់ដែលគេកិនកម្ទេចវត្ថុធាតុដើម ប្រភេទគ្រាប់ៗដែលគេផ្គុំជាគ្រាប់ ប្រភេទដុំៗដែលគេសូនពីប្រភេទគ្រាប់ជាដើម ប៉ុន្តែភាគច្រើនគេប្រើប្រភេទគ្រាប់ៗនិងប្រភេទដុំៗដែលមាន់ប្រយឡឺងាយស៊ីបានច្រើន។ រីឯបរិមាណផ្តល់ចំណីគឺ6.3គីឡូក្រាមក្នុងមួយក្បាលក្នុងកំឡុងពេលចិញ្ចឹម(បរិមាណចំណីដែលស៊ីគឺស្មើ2.1ដងនៃទម្ងន់បញ្ចេញលក់ដែលប្រហែល3.0គីឡូក្រាម។

មាន់ស្រុកបើប្រៀបធៀបនឹងមាន់ប្រយឡឺកម្រិតធំធាត់គឺទាបជាងហើយរយៈពេលចិញ្ចឹមគឺវែង ហេតុនេះ ដើម្បីបញ្ជៀសការកើនឡើងនៃការចំណាយលើចំណីនិងការលើសជាតិខ្លាញ់

ភាគច្រើនគេប្រើប្រាស់ចំណីថោកនិងមាន

សារធាតុចិញ្ចឹមតិចដោយមិនចាំបាច់ប្រើចំណីដែលផ្តល់ថាមពលខ្ពស់និងប្រូតេអ៊ីនខ្ពស់។ ជាទូទៅចំណីដែលមានប្រូតេអ៊ីនខ្ពស់ ចំណាយលើចំណីគឺខ្ពស់ ហើយចំណីដែលផ្តល់កាឡូរីខ្ពស់ គឺនឹងធ្វើឲ្យលើសជាតិខ្លាញ់។ ម្យ៉ាងទៀតចំណីដែលអាចពង្រឹងគុណភាពសាច់គឺមានចំណីដែលលាយកាកស្រាបៀរឬកាកសារធាតុផ្អាប់បង្កើតជាតិ

អាល់កុលសម្រាប់ស្រាវីស្គី។ ចំណីដែលផ្តោតលើសុខភាពនិងមុខងាររាងកាយគឺគេអាចប្រើសារធាតុបន្ថែមដូចជាខ្លាញ់ត្រីជាដើម។

3 ការធំធាត់និងបំរែបំរួលទម្ងន់របស់មាន់ចិញ្ចឹមយកសាច់

(1) ការធំធាត់របស់មាន់ចិញ្ចឹមយកសាច់(ប្រយឡឺ)

ដំណាក់កាលដំបូងនៃការលូតលាស់របស់មាន់ប្រយឡឺ(អាយុ0-3សប្តាហ៍) គឺជាដំណាក់កាលដែលឆ្អឹងនិងសរីរាង្គជាដើមលូតលាស់ បរិមាណចំណីដែលស៊ីគឺតិច ហើយសមត្ថភាពរំលាយអាហារនៅមិនទាន់លូតលាស់គ្រប់គ្រាន់។ ទម្ងន់ពេលឲ្យចំណីដំបូងគឺប្រហែល40ក្រាម ហើយពេលអាយុ3សប្តាហ៍ ទម្ងន់ឡើងដល់ប្រហែល850ក្រាម។ ទម្ងន់នឹងកើនឡើងហើយកម្រិតរំញោចទៅនឹងការប្រែប្រួលសីតុណ្ហភាពក៏កើនខ្ពស់ ធ្វើឲ្យបរិមាណផ្លាស់ប្តូរខ្យល់ដែលចាំបាច់ក៏កើនឡើងលឿនខ្លាំង។ នៅដំណាក់កាលចុងក្រោយឬដំណាក់កាលសម្រេច(អាយុ4-8សប្តាហ៍) ជាដំណាក់កាលដែលសាច់ដុំលូតលាស់ហើយទម្ងន់កើនលឿនជារៀងរាល់ថ្ងៃ។ មុខងារសម្របនឹងសីតុណ្ហភាពក្នុងខ្លួនបានអភិវឌ្ឍចប់សព្វគ្រប់ ហើយការប្តូរអោមក៏បញ្ចប់។ កូនមាន់ពេលដែលហ្វូងទាំងមូលកាន់តែរីកធំ សមត្ថភាពសម្របនឹងបរិយាកាសរបស់វាក៏កើនឡើង ប៉ុន្តែក្នុងរោងនឹងចង្អៀតខ្លាំងធ្វើឲ្យបរិយាកាសងាយនឹងទៅជាអាក្រក់ ហេតុនេះចាំបាច់ត្រូវធ្វើការគ្រប់គ្រងការផ្លាស់ប្តូរខ្យល់ជាបន្ត បន្ទាប់។ ពេលបញ្ចេញលក់ដែលអាយុ7-8សប្តាហ៍ ទម្ងន់មាន់កើនដល់ប្រហែល3.0គីឡូក្រាម។

(2) ការធំធាត់របស់មាន់ស្រុក

វាមានភាពខុសគ្នាទៅតាមពូជនិងម៉ាករបស់មាន់ស្រុក ហើយដោយសារតែការចិញ្ចឹមមានរយៈពេលវែង ទម្ងន់របស់មាន់ឈ្មោលនិងញីគឺខុសគ្នាខ្លាំង។ ពេលអាយុចាប់ពី20សប្តាហ៍ មាន់ឈ្មោលទម្ងន់3.0គីឡូក្រាម មាន់ញី2.0គីឡូក្រាម គឺខុសគ្នាប្រមាណ1.0គីឡូក្រាម។ ប្រាកដណាស់ បរិមាណចំណីដែលស៊ីក្នុងកំឡុងពេលចិញ្ចឹមគឺច្រើនដោយមាន់ឈ្មោលប្រហែល13.0គីឡូក្រាម មាន់ញីប្រហែល10.0គីឡូក្រាម។

4 ការគ្រប់គ្រងការចិញ្ចឹម(ពីពេលដាក់បញ្ចូលកូនមាន់ក្នុងឧបករណ៍ចិញ្ចឹមរហូតដល់បញ្ចេញលក់)

គេហៅដំណាក់កាលពីពេលដាក់បញ្ចូលកូនមាន់ក្នុងឧបករណ៍ចិញ្ចឹមហើយឲ្យចំណីដំបូងរហូតដល់អាយុ3សប្តាហ៍ថា ដំណាក់កាលដំបូង ហើយបន្ទាប់ពីនេះគឺគេហៅថាដំណាក់កាលចុងក្រោយ។ មាន់ប្រុយឡឺទូទៅពេលអាយុ8សប្តាហ៍ ទម្ងន់វាកើនដល់លើស3គីឡូក្រាមសម្រាប់មាន់ឈ្មោល និងជិត3គីឡូក្រាមសម្រាប់មាន់ញី។

ការចិញ្ចឹមមាន់ប្រុយឡឺជាមូលដ្ឋានគឺមិនខុសគ្នានឹងការចិញ្ចឹមមាន់ដែលចិញ្ចឹមយកស៊ុតទេ ប៉ុន្តែសម្រាប់មាន់ប្រុយឡឺគោលបំណងគឺចិញ្ចឹមបំប៉ន។ ហេតុនេះហើយ ដើម្បីបង្កើនបរិមាណផលិតក្នុងមួយឯកតាផ្ទៃក្រឡា ភាគច្រើនគេចិញ្ចឹមដោយលក្ខខណ្ឌដែលមិនល្អចំពោះសុខភាពដូចជា បង្កើនដង់ស៊ីតេនៃការចិញ្ចឹម កំហិតការធ្វើចលនា ផ្តល់ចំណីដែលមានប្រូតេអ៊ីនខ្ពស់កាឡូរីខ្ពស់ជាដើម។ តែបើគ្រប់គ្រងមិនបានល្អគ្រប់គ្រាន់ទេនោះ នឹងងាយបង្កជាជំងឺ ហេតុនេះចាំបាច់ត្រូវប្រុងប្រយ័ត្ន។

(1) ការគ្រប់គ្រងនៅដំណាក់កាលដំបូង

នៅដំណាក់កាលដំបូងសម្រាប់មាន់ប្រុយឡឺ បើក្នុងករណីចិញ្ចឹមលើផ្ទៃរាប គេចាំបាច់ត្រូវក្រាលសម្ភារៈក្រាលលើកម្រាលបាតនៃរោងចិញ្ចឹមមាន់និងបន្ថែមកម្តៅដោយឧបករណ៍ផ្តល់កម្តៅរយៈពេល2-4សប្តាហ៍។ ការគ្រប់គ្រងសីតុណ្ហភាពនៃការចិញ្ចឹមគឺសំខាន់ខ្លាំង គឺបើសីតុណ្ហភាពទាប នោះនឹងងាយកើតជំងឺទឹកចូលពោះ(ពោះហើមធំខុសធម្មតា)។ ម្យ៉ាងទៀតមាន់ដែលធំធាត់មិនល្អ ភាគច្រើនដើងវាខុសធម្មតា ហេតុនេះត្រូវឆាប់បំបែកវាចេញ។

[1] ការដាក់បញ្ចូលកូនមាន់ក្នុងឧបករណ៍ចិញ្ចឹម(ការទទួលកូនមាន់ចូល)

ករណីចិញ្ចឹមលើផ្ទៃរាប ត្រូវផ្តល់កម្តៅទុកជាមុនដោយប្រើឧបករណ៍ចិញ្ចឹមរាងដូចឆ័ត្រឬឧបករណ៍ផ្តល់កម្តៅពីកម្រាលបាត ដោយព័ទ្ធរបងជារង្វង់ជុំវិញឲ្យឧបករណ៍ផ្តល់កម្តៅនៅកណ្តាល។ កូនមាន់ដែលបានបញ្ជូនទៅដល់ត្រូវដាក់បញ្ចូលក្នុងរបងហើយឲ្យសម្រាក។ សីតុណ្ហភាពនិងសំណើមក្នុងរបងគឺសំខាន់ណាស់ ហើយគេត្រូវកែសម្រួលសីតុណ្ហភាព(32អង្សាសេ) និងសំណើម(ប្រហែល65%) ដើម្បីឲ្យកូនមាន់នៅរាយប៉ាយដោយមានជាសុកភាព។

[2] ការឲ្យចំណីដំបូង

ចំពោះឧបករណ៍ផ្តល់ចំណីគឺគេប្រើប្រអប់ដាក់ចំណីសម្រាប់ឲ្យចំណីដំបូង(ចានចំណីកូនមាន់)ដែលរាបស្មើនិងតែមរាក់ ឬចានចំណីមាន់ធ្វើយ៉ាងណាឲ្យវាមានលំនឹងទោះដាក់លើសម្ភារៈក្រាល។ ចំពោះឧបករណ៍ផ្តល់ទឹកគេបំពាក់ឧបករណ៍ផ្តល់ទឹករាងក្បាលដោះឬរាងជួង ហើយបន្ថែមឧបករណ៍ជំនួយផ្តល់ទឹកដើម្បីងាយស្រួលផឹក។ គេតម្រៀបឧបករណ៍ផ្តល់ចំណីនិងឧបករណ៍ផ្តល់ទឹកទាំងនេះឆ្លាស់គ្នា និងរៀបចំធ្វើយ៉ាងណាឲ្យកូនមាន់អាចស៊ីនិងផឹកដោយមានចន្លោះគ្រប់គ្រាន់។ ចំពោះចំណីសម្រាប់ការឲ្យចំណីដំបូង គេច្របល់ចំណីនិងធ្វើជាចំណីរោយ ហើយដាក់ឲ្យស៊ីក្នុងបរិមាណតិចតែច្រើនដង នោះកូនមាន់នឹងចេះស៊ីកាន់តែបានច្រើនទៅៗ។ ការផ្តល់ចំណីបន្ទាប់ពីឲ្យចំណីដំបូង គឺត្រូវអនុវត្តតាមសៀវភៅណែនាំអំពីការគ្រប់គ្រងសត្វមាន់ដែលអនុវត្តជាក់ស្តែង។

[3] ដង់ស៊ីតេនៃការចិញ្ចឹម

ដង់ស៊ីតេនៃការចិញ្ចឹមដែលល្អគឺប្រហែល15ក្បាលក្នុងមួយម៉ែត្រការេនៃផ្ទៃកម្រាលបាតរបស់រោងចិញ្ចឹមមាន់។ ការចិញ្ចឹមញីឈ្មោលដាច់ពីគ្នានឹងធ្វើឲ្យងាយស្រួលចិញ្ចឹម ហើយទិន្នផលដែលជាទម្ងន់ខ្លួនក៏កើនខ្ពស់ ប៉ុន្តែដើម្បីកាត់បន្ថយពេលវេលាបែងចែកញីឈ្មោល ជាទូទៅគេចិញ្ចឹមលាយឡំគ្នា។

[4] ការគ្រប់គ្រងសំណើម

ចំពោះការចិញ្ចឹមលើផ្ទៃរាប ក្នុងពេលកំពុងផ្តល់កម្តៅ វាពិបាករក្សាសំណើម ធ្វើឲ្យស្ងួតខ្លាំងពេក ហេតុនេះគេបាចទឹកទៅផ្នែកកណ្តាលនៃសម្ភារៈក្រាលនៅពេលខ្លះ។ សំណើម(ចាប់ពី50%)កំឡុងពេលផ្តល់កម្តៅ មានឥទ្ធិពលខ្លាំងចំពោះការធំធាត់របស់មាន់នៅពេលបន្ទាប់។

[5] ការគ្រប់គ្រងសីតុណ្ហភាព

គេបញ្ចុះសីតុណ្ហភាពចិញ្ចឹមជាបន្តបន្ទាប់ដោយមើលតាមស្ថានភាពកូនមាន់។ គេបញ្ចុះសីតុណ្ហភាពបន្តិចម្តងៗឲ្យបានដល់ត្រឹម29អង្សាសេនៅពេលអាយុ7ថ្ងៃ។ គេកែសម្រួលធ្វើយ៉ាងណាឲ្យបានចន្លោះសីតុណ្ហភាពដែលកូនមាន់អាចនៅរាយប៉ាយស្មើល្អ។ ក្រោយពេលដាក់បញ្ចូលកូនមាន់ ប្រសិនបើមិនបញ្ចុះសីតុណ្ហភាពក្នុងរោងចិញ្ចឹមមាន់ទេនោះ នៅពេលឲ្យចំណីដំបូងពេលអាយុ2-3ថ្ងៃ បរិយាកាសនឹងក្តៅ ហើយសីតុណ្ហភាពដំណាក់កាលដំបូងបែបនេះនឹងធ្វើឲ្យបរិមាណស៊ីចំណីថយចុះ ប៉ះពាល់ការធំធាត់នៅពេលក្រោយដែលជាមូលហេតុធ្វើឲ្យទម្ងន់មាន់និមួយៗខុសគ្នាខ្លាំង ហេតុនេះត្រូវប្រុងប្រយ័ត្ន។

[6] ការបញ្ឈប់កម្តៅ

ការឈប់ផ្តល់កម្តៅហៅថា ការបញ្ឈប់កម្តៅ។ នៅរោងចិញ្ចឹមមាន់បែបបើកចំហ គេធ្វើវានៅពេលអាយុប្រហែល2សប្តាហ៍ចំពោះរដូវក្តៅ និងនៅអាយុ3សប្តាហ៍ចំពោះរដូវរងា។ យ៉ាងណាមិញ សម្រាប់រោងចិញ្ចឹមមាន់គ្មានបង្អួច មិនមានការបញ្ឈប់កម្តៅនោះទេហើយតុល្យភាពរវាងសីតុណ្ហភាពក្នុងរោងនិងការផ្គត់ផ្គង់បរិមាណផ្លាស់ប្តូរខ្យល់ទើបជារឿងសំខាន់។

[7] ការគ្រប់គ្រងការផ្តល់ទឹកនិងចំណី

កូនមាន់ធំធាត់លឿន ហេតុនេះចំពោះឧបករណ៍ផ្តល់ទឹករាងក្បាលដោះ ឧបករណ៍ផ្តល់ទឹករាងជួង ត្រូវកែសម្រួលកម្ពស់ សម្ពាធទឹក កម្រិតទឹក ទៅតាមការធំធាត់។



ឧបករណ៍ផ្តល់ទឹករាងក្បាលដោះ : ត្រឹមកម្ពស់ងាយផឹក



ឧបករណ៍ផ្តល់ចំណី : ឲ្យតែមចាននៅកម្ពស់តែរបស់កូនមាន់ញី



ឧបករណ៍ផ្តល់ទឹករាងជួង : ឲ្យបាតចាននៅកម្ពស់ស្មារបស់កូនមាន់ញី

[8] ការគ្រប់គ្រងរបងព័ទ្ធ

ក្រោយពេលឲ្យចំណីដំបូង គេពង្រីករង្វង់ទៅតាមការធំធាត់របស់កូនមាន់។ នៅអាយុប្រហែល10-13ថ្ងៃ កូនមាន់អាចផ្លោះរំលងរបងបាន ហេតុនេះគេដកវាចេញនៅពេលនោះ។

[9] ការផ្លាស់ប្តូរខ្យល់

ដោយសារដង់ស៊ីតេចិញ្ចឹមខ្ពស់ ហើយហ្វូងធំ ហេតុនេះត្រូវប្រុងប្រយ័ត្នជាពិសេសចំពោះការផ្លាស់ប្តូរខ្យល់។

[10] ការគ្រប់គ្រងពន្លឺ

ករណីរោងចិញ្ចឹមមាន់គ្មានបង្អួច ការបំភ្លឺភ្លើងគឺមកដល់ត្រឹមអាយុ1សប្តាហ៍ កម្រិតពន្លឺ5លុច(lux) បំភ្លឺ24ម៉ោង នៅអាយុ2-3សប្តាហ៍គឺ3លុច(lux) បន្ទាប់ពីនេះមកគឺកម្រិតពន្លឺទាបប្រហែល0.5លុច(lux) បំភ្លឺ23ម៉ោង។ នៅរោងចិញ្ចឹមបែបបើកចំហ នៅពេលថ្ងៃគេប្រើពន្លឺធម្មជាតិហើយនៅពេលយប់គេបំភ្លឺដោយកម្រិតពន្លឺនេះ។

(2) ការគ្រប់គ្រងនៅដំណាក់ចុងក្រោយ

ពេលដល់អាយុ4សប្តាហ៍ គេប្តូរចំណីពីចំណីសម្រាប់ដំណាក់កាលដំបូងឬដំណាក់កាលលូតលាស់ ទៅចំណីសម្រាប់ដំណាក់កាលចុងក្រោយឬដំណាក់កាលសម្រេច។ នៅពេលការលូតលាស់របស់កូនមាន់ចេះតែវិវឌ្ឍន បរិមាណស៊ីចំណីកើនឡើង ហើយបរិមាណលាមកកើនឡើង។ ម្យ៉ាងទៀត ពីពេលនេះទៅ វានឹងទៅជាស្ថានភាពចិញ្ចឹមបញ្ជៀត ហេតុនេះត្រូវធ្វើឲ្យមានការផ្លាស់ប្តូរខ្យល់។ ជាពិសេស ចំពោះការចិញ្ចឹមលើផ្ទៃរាប ការថ្មែឲ្យខ្យល់ហូរកាត់ផ្ទៃកម្រាលបាតគឺជារឿងសំខាន់។ ធ្វើដូច្នេះ សម្ភារៈក្រាលនឹងស្ងួតល្មមហើយមិនសូវកើតមានឧស្ម័នពុល។

ពេលដល់ដំណាក់កាលចុងក្រោយ ការកើនឡើងទម្ងន់នឹងនាំឲ្យមាន់ទៅជាធ្វើចលនាយឺតស្ទក់ ហើយនឹងមានគម្លាតនៃការលូតលាស់ខ្លាំងរវាងមាន់ឈ្មោលនិងញី។ នៅដំណាក់កាលនេះសីតុណ្ហភាពក្នុងរោងចិញ្ចឹមគឺ19-23អង្សាសេ ហើយបរិមាណចំណីដែលស៊ីគឺខ្ពស់បំផុត ហើយជាមួយគ្នានេះ កម្រិតធំធាត់ក៏ខ្លាំងផងដែរ។ ប៉ុន្តែនៅពេលក្តៅខ្លាំងក្នុងរដូវក្តៅ ចាំបាច់ត្រូវចាត់វិធានការប្រឆាំងភាពក្តៅដូចជាបាញ់ខ្យល់ កំហិតចំណីជាដើម។ គួរកត់សំគាល់ថា នៅពេលសីតុណ្ហភាពឡើងខ្ពស់លឿនចាប់ពី30អង្សាសេឡើងទៅ មាន់ងាយនឹងកើតជំងឺក្តៅខ្លួន ហេតុនេះត្រូវប្រុងប្រយ័ត្ន។

(3) ការបញ្ចេញលក់

គេបញ្ចេញលក់កូនមាន់ញីនៅពេលអាយុប្រហែល6-7សប្តាហ៍(បញ្ចេញលក់មួយចំនួនមុន)។ នេះដោយសារតែមាន់ញីនឹងលែងសូវធំធាត់តទៅទៀត។ ការបញ្ចេញលក់មួយចំនួនមុន នឹងធ្វើឲ្យកន្លែងចិញ្ចឹមមាន់ឈ្មោលទូលាយតាមចំនួនដែលបញ្ចេញលក់។ ក្រោយបញ្ចេញលក់មួយចំនួនមុន នៅអាយុប្រហែល9សប្តាហ៍ គេនឹងបញ្ចេញលក់កូនមាន់ទាំងអស់។ ដោយគិតទាំងការបញ្ចេញលក់មួយចំនួនមុន ទម្ងន់ខ្លួនឆៅក្នុង1ម៉ែត្រការេដែលបញ្ចេញលក់ជាស្តង់ដារគឺ32-35គីឡូក្រាម។

5 ការគ្រប់គ្រងអនាម័យរបស់មាន់ចិញ្ចឹមយកសាច់(ចូលទាំងអស់ចេញទាំងអស់ និងការសម្លាប់មេរោគ)

(1) ការសម្អាតបន្ទាប់ពីបញ្ចេញលក់និងមុនដាក់កូនមាន់បញ្ចូលចិញ្ចឹម

មាន់ប្រយឡឺជាទូទៅគេប្រើវិធីសាស្ត្រដែលគេហៅថា ចូលទាំងអស់ចេញទាំងអស់ គឺដាក់បញ្ចូលកូនមាន់ទាំងអស់ដែលញាស់ក្នុងថ្ងៃតែមួយទៅក្នុងរោងចិញ្ចឹមតែមួយ(ចូលទាំងអស់) ហើយចិញ្ចឹមនិងបញ្ចេញលក់(ចេញទាំងអស់)។

រោងចិញ្ចឹមអាចនឹងមានបន្សល់ប្រភពជំងឺផ្សេងៗទៅតាមពេលវេលាដែលកន្លង ដោយសារតែវាត្រូវបានប្រើប្រាស់ម្តងហើយម្តងទៀតសម្រាប់ការគ្រប់គ្រងការចិញ្ចឹម(ពីពេលដាក់បញ្ចូលចិញ្ចឹមដល់បញ្ចេញលក់)ក្នុងរយៈពេលកំណត់មួយ។ គោលបំណងនៃការសម្លាប់មេរោគគឺកម្ចាត់ទាំងស្រុងនូវ មេរោគបង្កជំងឺ ប៉ារ៉ាស៊ីតបង្កជំងឺ សត្វល្អិតចង្រៃជាដើម ដែលបន្សល់ទុកដោយសត្វមាន់ដែលចិញ្ចឹមលើកមុន។ រោងចិញ្ចឹមមាន់ដែលទំនេរ ក្រោយពីបញ្ចេញលក់ចប់ ត្រូវសម្អាតលាមកចេញឲ្យបានឆាប់។ មុនដាក់កូនមាន់បន្ទាប់ចូល ត្រូវតែដកសម្ភារៈក្រាលទាំងអស់ចេញ សម្លាប់សត្វល្អិត លាងទឹកសព្វទាំងអស់ និងធ្វើការសម្លាប់មេរោគសព្វទាំងអស់។ ម្យ៉ាងទៀត មិនត្រឹមតែនៅខាងក្នុងរោងចិញ្ចឹមមាន់ប៉ុណ្ណោះទេ នៅបរិវេណជុំវិញរោងក៏ត្រូវសម្អាត សម្លាប់សត្វល្អិត លាងទឹក និងសម្លាប់មេរោគផងដែរ។

(2) ការការពារការលុកលុយនៃសត្វព្រៃ

គេបំពាក់សំណាញ់លួស សំណាញ់ការពារបក្សី ដើម្បីការពារមិនឲ្យសត្វកណ្តុរ បក្សីព្រៃ ចូលលុកលុយក្នុងរោងចិញ្ចឹមមាន់។

(3) ការប្រើប្រាស់វ៉ាក់សាំង ថ្នាំបង្ការ

ចំពោះជំងឺញូវកាសល(Newcastle Disease) ជំងឺរលាកទងសួតដែលឆ្លង ជំងឺរលាកបំពង់ខ្យល់ដល់ទងសួតដែលឆ្លង ជំងឺថង់ក្រពេញហ្វាប្រីកៀស(Bursa of Fabricius)ដែលឆ្លង ជំងឺអុតមាន់ ជំងឺម៉ារិក (Marek′s disease) ជាដើម ការចាក់វ៉ាក់សាំងគឺមានប្រសិទ្ធភាពការពារ ហើយចំពោះវ៉ាក់សាំងនិមួយៗ ត្រូវអនុវត្តតាមកម្មវិធីចាក់វ៉ាក់សាំងឲ្យបានខ្ជាប់ខ្ជួន។ ចំពោះមាន់ប្រយឡឺ ជាទូទៅគេប្រើកម្មវិធីដែលផ្តោតលើវ៉ាក់សាំងរស់។

6 វិធីកម្ចាត់លាមកមាន់

បច្ចុប្បន្ន លាមកមាន់ភាគច្រើនត្រូវបានផ្ទាប់ដើម្បីប្រើប្រាស់ជាជីកំប៉ុស្ដ៍។ វិធីផ្ទាប់រួមមាន វិធីគរជាគំនរ វិធីកូរលក្ខណៈបើកចំហ វិធីកូរលក្ខណៈបិទជិតជាដើម។ ក្នុងការកម្ចាត់លាមកមាន់ប្រយឡឺ ភាគច្រើនគេប្រើរោងផ្ទាប់បែបបើកចំហ។ ដោយសារតែល្បាយនៃលាមកមាន់ប្រយឡឺនិងសម្ភារៈក្រាលភាគច្រើនមានជាតិទឹកតិច ប្រសិនបើធ្វើការផ្ទាប់ក្នុងរោងផលិតជីកំប៉ុស្ដ៍ឬរោងផ្ទាប់រាងប្រអប់ ចាំបាច់ត្រូវធ្វើការកែសម្រួលកម្រិតជាតិទឹកដំណាក់កាលដំបូង។ ម្យ៉ាងទៀត នៅរោងផ្ទាប់បែបបិទជិត ការកម្ចាត់លាមកគឺចប់លឿន ប៉ុន្តែអាចមានសារធាតុដែលប៉ះពាល់ដល់ការលូតលាស់ដែលជាសម្ភារៈក្រាលដូចជាអាចម៍រណារជាដើម មិនត្រូវបានបំបែកគ្រប់គ្រាន់ ហេតុនេះត្រូវប្រុងប្រយ័ត្ន។

7 ផែនការចិញ្ចឹមនិងការវាយតម្លៃសមត្ថភាព

(1) ផែនការចិញ្ចឹម

បច្ចុប្បន្ន មាន់ប្រយឡឺភាគច្រើនគឺគេចិញ្ចឹមដោយផលិតតាមកិច្ចសន្យាជាមួយក្រុមហ៊ុនចំណីសត្វ សមាគមជំនួញជាដើម។ ថ្ងៃដាក់បញ្ចូលកូនមាន់ ចំនួនក្បាលដាក់បញ្ចូល អាយុបញ្ចេញលក់ជាដើមគឺត្រូវកំណត់ដោយកិច្ចសន្យា ហេតុនេះចាំបាច់ត្រូវសិក្សាទុកជាមុនពីរោងនិងកាលវិភាគការងារ។

(2) វិធីសាស្ត្រអង្កេតសមត្ថភាព

សត្វមាន់ធំធាត់លឿន ហើយចំរវេលាចិញ្ចឹមខ្លី ហេតុនេះត្រូវថ្លឹងទម្ងន់ជារៀងរាល់សប្ដាហ៍និងវាស់បរិមាណចំណីដែលស៊ី។ ពីលទ្ធផលនេះ គេអាចគណនាសមត្ថភាពដូចជាកំណើនទម្ងន់ខ្លួនជាដើម។ អាស្រ័យលើអត្រាបញ្ចេញលក់(ផលធៀបនៃចំនួនក្បាលដាក់ចូលចិញ្ចឹមទៅនឹងចំនួនអាចបញ្ចេញលក់) និងបរិមាណទម្ងន់បញ្ចេញលក់(បរិមាណទម្ងន់បញ្ចេញលក់មាន់រស់ក្នុងមួយឯកតាផ្ទៃក្រឡា) ផលចំណេញអាជីវកម្មគឺនឹងខុសគ្នាខ្លាំង។

5 ក្រៅពីនេះ

① សេះទម្ងន់ស្រាល

1 លក្ខណៈពិសេសនៃសេះប្រភេទពូជសុទ្ធ

· សេះប្រភេទពូជសុទ្ធគឺជាសត្វដែលប្រុងប្រយ័ត្នខ្លាំង។ វាអាចនឹងភ្ញាក់ផ្អើលរត់ចេញឬកញ្ជ្រោលដោយសារការយិការលឿនៗរបស់អ្នកមើលថែវា។ នៅពេលប៉ះសេះ ចាំបាច់ត្រូវដើរចូលពីមុខ ប្រើសម្លេងស្រទន់ដើម្បីឲ្យសេះទុកចិត្តបាន។

· សេះមានពោះវៀនវែងជាងសត្វដទៃនិងងាយកើតជំងឺចុកពោះ(ឈឺពោះ) ហេតុនេះចាំបាច់ត្រូវប្រយ័ត្នក្នុងការគ្រប់គ្រងចំណី។

2 ឈ្មោះអវយវៈសំខាន់ៗរបស់សេះប្រភេទពូជសុទ្ធ(ប្រៀបធៀបនឹងមនុស្ស)



① សក់ខាងមុខ
② សក់កសេះ
③ ផ្នែកភ្ជាប់កនិងខ្នង(ឫក)
④ ខ្នង
⑤ គូទ
⑥ កន្ទុយ
⑦ កម្ពស់ខ្លួន
⑧ ជង្គង់ក្រោយ(ជង្គង់មនុស្ស)
⑨ កែងដៃ(កែងដៃមនុស្ស)
⑩ សន្លាក់ជើងមុខ(កដៃមនុស្ស)
⑪ សន្លាក់ជើងក្រោយ(កជើងមនុស្ស)
⑫ សន្លាក់ប្រអប់ជើង(ឆ្អឹងភ្ជាប់ម្រាមដៃនិងប្រអប់ដៃ)
⑬ ក្រចកជើង(ក្រចកម្រាមដៃកណ្តាលមនុស្ស)

3 ការសំគាល់អត្តសញ្ញាណសេះ

គេធ្វើការសំគាល់អត្តសញ្ញាណសេះពូជសុទ្ធដោយ សម្បុររោម លក្ខណៈពិសេស(ស្នាមភ្លឺ ក្រយៅជាដើម) បន្ទះឈីបតូចជាដើម។ ព័ត៌មានទាំងនេះនឹងត្រូវកត់ត្រាក្នុងលិខិតបញ្ជាក់ការចុះបញ្ជីពូជពង្ស។

(1) សម្បុររោម

សម្បុររោមរបស់សេះពូជសុទ្ធមាន8ប្រភេទដូចខាងក្រោម។

រោមពណ៌គ្រាប់កៅឡាក់ភ្លឺ

រោមពណ៌គ្រាប់កៅឡាក់ងងឹត

រោមពណ៌ដូចក្តាន់

រោមពណ៌ដូចក្តាន់ខ្មៅ

រោមពណ៌ដូចក្តាន់ខ្មៅ

រោមពណ៌ខ្មៅ

រោមពណ៌ប្រផេះ

រោមពណ៌ស

(2) លក្ខណៈពិសេស

· លក្ខណៈពិសេសគឺសំដៅស្នាមភ្លឺនៅលើមុខឬជើង ឬក្រយៅលើខ្លួនទាំងអស់។

(3) បន្ទះឈីបតូច

· មុនចុះបញ្ជីពូជពង្ស គេបង្កប់វាទៅក្នុងចំណុចកណ្តាលនៃកចំហៀងខាងឆ្វេង។

· លេខបន្ទះឈីបតូច នឹងត្រូវបានកត់ត្រាក្នុងលិខិតបញ្ជាក់ការចុះបញ្ជីពូជពង្ស។

· ដើម្បីប្រើប្រាស់សេះពូជសុទ្ធជាសេះប្រណាំង ចាំបាច់ត្រូវធ្វើការបង្កប់បន្ទះឈីបតូច។

4 ចំណី

· ចំណីដែលផ្តល់ឲ្យសេះប្រភេទពូជសុទ្ធមាន ចំណីជីវជាតិ និងចំណីមិនកែច្នៃ។

· ចំណីជីវជាតិសំខាន់ៗមានដូចជាពពួកធញ្ញជាតិដូចជាស្រូវសាលីoat កន្ទក់ស្រូវសាលីជាដើម ហើយក្រៅពីនេះគឺចំណីលាយ។

· ចំណីមិនកែច្នៃគឺស្មៅស្ងួតដែលនាំចូលពីបរទេសឬផលិតខ្លួនឯង។

5 សម្ភារៈក្រាល

· បន្ទប់ដែលត្រូវបានខណ្ឌដោយឡែកៗនៅរោងចិញ្ចឹមសេះហៅថា ក្រោលសេះ ហើយចំបើងជាដើមដែលក្រាលធ្វើជាកម្រាលដេកក្នុងក្រោលសេះហៅថា សម្ភារៈក្រាល។

· សម្ភារៈក្រាលដែលគេប្រើប្រាស់សំខាន់ៗគឺមាន ចំបើងស្រូវ ចំបើងស្រូវសាលី ស្មៅផលិតខ្លួនឯង កម្ទេចឈើ ឈូសឬអាចម៍រណារ។

· នៅវាលស្មៅសម្រាប់ផលិត គេប្រើចំបើងស្រូវឬស្មៅផលិតខ្លួនឯង ប៉ុន្តែនៅវាលស្មៅសម្រាប់ចិញ្ចឹម ភាគច្រើនគេប្រើចំបើងស្រូវសាលីឬកម្ទេចឈើឈូស អាចម៍រណារដើម្បីការពារកុំឲ្យសេះស៊ីសម្ភារៈក្រាល។

② ការចិញ្ចឹមឃ្មុំ

1 រចនាសម្ព័ន្ធនៃប្រអប់សំបុក

(1) ប្រអប់សំបុក ប្រអប់បន្ត

គេចិញ្ចឹមសត្វឃ្មុំនៅក្នុងប្រអប់សំបុក(រាប់ថា1ហ្វូង)។ ប្រអប់សំបុកធម្មតាអាចដាក់បានបន្ទះសំបុកពី8-10បន្ទះ ហើយមានឃ្មុំកម្មករប្រហែល2ម៉ឺនក្បាលរស់នៅ។ នៅពេលហ្វូងរីកធំ គេដាក់សំបុកបន្តដែលគ្មានបាតបន្តពីលើប្រអប់សំបុកដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃចំនួនឃ្មុំ។

ប្រអប់សំបុក



ប្រអប់បន្ត

(2) បន្ទះសំបុក(ផ្ទៃសំបុក)

បណ្តុំនៃរន្ធក្នុងសំបុកឃ្មុំហៅថាបន្ទះសំបុក(ផ្ទៃសំបុក)។ វាគឺជាផ្ទៃកម្ទេចដ្ឋាននៃសំបុករបស់ឃ្មុំ ហើយគេកំណត់ទំហំនៃហ្វូងដោយចំនួនបន្ទះសំបុកដែលដាក់បញ្ចូលក្នុងប្រអប់សំបុក ឬក៏គេដាក់បញ្ចូលទៅក្នុងប្រអប់សំបុកនូវបន្ទះសំបុកដែលចំនួនគឺស្របទៅតាមទំហំហ្វូង។



បន្ទះសំបុក

(3) ឧបករណ៍ផ្តល់ចំណី

ឧបករណ៍ផ្តល់ចំណីជាឧបករណ៍សម្រាប់ផ្តល់ចំណី(ទឹកស្ករជាដើម)ឲ្យសត្វឃ្មុំ។ បើដាក់ក្នុងប្រអប់សំបុក គេផ្តល់ចំណីដោយដាក់វានៅផ្នែកខាងក្រៅបំផុតនៃបន្ទះសំបុក។



ឧបករណ៍ផ្តល់ចំណី

2 អាហាររបស់ឃ្មុំនិងចំណី

(1) ទឹកដមនិងលម្អងផ្កា

អាហាររបស់សត្វឃ្មុំគឺមានតែទឹកដមនិងលម្អងផ្កាប៉ុណ្ណោះ។ ទឹកដមផ្កាគឺជាប្រភពថាមពល ហើយលម្អងផ្កាផ្តល់

សារជាតិរ៉ែនិងប្រូតេអ៊ីនជាដើម។ សារធាតុចាហួយឃ្មុំដែលផ្តល់ឲ្យរាជិនីឃ្មុំនិងដង្កូវឃ្មុំទើបញាស់ គឺត្រូវបានបញ្ចេញដោយឃ្មុំកម្មករដែលស៊ីលម្អងផ្កា។

(2) ការឲ្យចំណីឃ្មុំ

សត្វឃ្មុំគឺមិនចាំបាច់ឲ្យចំណីជាប្រចាំថ្ងៃនោះទេ។ ប៉ុន្តែ នៅពេលមិនអាចប្រមូលទឹកដមបាន គេអាចផ្តល់ចំណី(ទឹកស្ករជាដើម)ដើម្បីឲ្យឃ្មុំអាចបន្តរស់បានដោយខ្លួនឯង។ ម្យ៉ាងទៀត នៅពេលលម្អងផ្កាមានតិចតួច គេអាចផ្តល់អាហារ(លម្អងផ្កាជំនួស)ដែលលក់នៅទីផ្សារជាដើមជំនួសឲ្យលម្អងផ្កា។

3 សកម្មភាពរកអាហាររបស់សត្វឃ្មុំ

ករណីសត្វឃ្មុំទៅរកទឹកដមឬលម្អងផ្កា គេនិយាយថាជាធម្មតាវាហោះជុំវិញបរិវេណ2km ប៉ុន្តែបើគ្មានផ្កាទេនោះ វានឹងបន្តហោះរហូតដល់10km។ សត្វឃ្មុំចូលចិត្តផ្កាដែលបរិមាណទឹកដមច្រើនហើយកំហាប់ជាតិស្ករខ្ពស់។ ម្យ៉ាងទៀតដើម្បីមិនឲ្យចំណាយកម្លាំងដោយខាតបង់ បើមានផ្កាដែលទឹកដមល្អនិងផ្កាទឹកដមមិនសូវល្អហើយនៅចម្ងាយប្រហែលគ្នាពីប្រអប់សំបុក វានឹងមិនរវល់នឹងផ្កាដែលមិនល្អនោះទេ។ សត្វឃ្មុំពិចារណាជារួមលើកត្តា3គឺ "គុណភាព បរិមាណ ចម្ងាយ" ហើយការសម្រេចចិត្តថាទៅរកផ្កាណាគឺអាស្រ័យលើស្ថានភាពរបស់ផ្កាដែលនៅជុំវិញ។

ម្យ៉ាងទៀត សត្វឃ្មុំត្រូវបានបែងចែកជាក្រុមទៅរកទឹកដមផ្កានិងក្រុមទៅរកលម្អងផ្កា ប៉ុន្តែក៏មានករណីដែលទៅរកទាំងពីរអាស្រ័យលើស្ថានភាព។

ទឹកដមនិងលម្អងផ្កានៅក្នុងរន្ធក្នុងសំបុកឃ្មុំ



ប្រអប់សំបុកនិងបន្ទះសំបុកដែលឃ្មុំរស់នៅ

4 ជំងឺរបស់សត្វឃ្មុំ

(1) ជំងឺរលួយដង្កូវឃ្មុំ(ជំងឺរលួយដង្កូវឃ្មុំអាមេរិច ជំងឺរលួយដង្កូវឃ្មុំអឺរ៉ុប)

ពេលឆ្លងជំងឺរលួយដង្កូវឃ្មុំ វានឹងងាប់នៅក្នុងដំណាក់កាលជាដង្កូវឃ្មុំ។ ដង្កូវឃ្មុំទើបញាស់ដែលងាប់ដោយឆ្លងជំងឺរលួយដង្កូវឃ្មុំអាមេរិច នឹងរលួយហើយស្អិត។ និងបង្កក្លិនស្អុយឈួល(ជាតិអន្ទិលស្អុយ)។ រីឯដង្កូវឃ្មុំទើបញាស់ដែលងាប់ដោយឆ្លងជំងឺរលួយដង្កូវឃ្មុំអឺរ៉ុបវិញ មិនស្អិត។នោះទេ ហើយក្លិនស្អុយបែបជូរអាស៊ីត គឺខុសពីជំងឺរលួយដង្កូវឃ្មុំអាមេរិច។

នៅប្រទេសជប៉ុន ទឹកសូលុយស្យុងថៃឡាន(Tylan)ត្រូវបានទទួលស្គាល់ជាថ្នាំបង្ការជំងឺរលួយដង្កូវឃ្មុំ ប៉ុន្តែហ្វូងដែលបានឆ្លងជំងឺរលួយដង្កូវឃ្មុំហើយ ត្រូវតែដុតបំផ្លាញចោល។

(2) ជំងឺវ៉ារ៉ូអា Varroa disease (ប្រជុំរោគសញ្ញាចៃវ៉ារ៉ូអា)

ស្ថានភាពមិនប្រក្រតីដោយសារកើតមានចៃវ៉ារ៉ូអាហៅថាជំងឺវ៉ារ៉ូអា។ ដោយរងការជញ្ជក់ឈាមពីចៃវ៉ារ៉ូអា សត្វឃ្មុំ(ឃ្មុំពេញវ័យ ដង្កូវឃ្មុំទើបញាស់ ដង្កូវឃ្មុំជិតប្តូររូប) នឹងចុះទន់ខ្សោយ។ ម្យ៉ាងទៀត វីរុសជាច្រើនឆ្លងតាមរយៈចៃនេះ។

នៅប្រទេសជប៉ុន ថ្នាំនីកូអាពីស្ថាននិងថ្នាំអាពីវ៉ា ត្រូវបានទទួលស្គាល់ជាថ្នាំសម្លាប់ចៃ។

(3) ក្រៅពីនេះ

ក្រៅពីជំងឺខាងលើ មានដូចជា ជំងឺណូហ្សីម៉ាNosema disease(ឃ្មុំកម្មករមានរោគសញ្ញាដូចជារោគហើយហ្វូងឃ្មុំចុះខ្សោយ) ជំងឺដីស(ដង្កូវឃ្មុំជិតប្តូររូបស្លាប់ដោយសារទៅជារឹងពណ៌សដូចដីស)។



ដង្កូវឃ្មុំទើបញាស់ដែលឆ្លងជំងឺរលួយដង្កូវឃ្មុំអាមេរិច
(ប្រភពរូបភាព ក្រសួងកសិកម្មអាមេរិច)



ដង្កូវឃ្មុំទើបញាស់ដែលឆ្លងជំងឺរលួយដង្កូវឃ្មុំអឺរ៉ុប
(ប្រភពរូបភាព ក្រសួងកសិកម្មអាមេរិច)

ដង្កូវឃ្មុំទើបញាស់ដែលកើតចៃវ៉ារ៉ូអា

ឃ្មុំពេញវ័យដែលកើតចៃវ៉ារ៉ូអាធ្ងន់ធ្ងរ

6 សំណួរសាកល្បង

ចូរឆ្លើយនឹងសំណួរខាងក្រោម ដោយគូសសញ្ញារង្វង់○ ប្រសិនបើជាប្រយោគត្រឹមត្រូវ ហើយគូសសញ្ញាខ្វែង× ប្រសិនបើជាប្រយោគខុស។

<គោ>

1. នៅពេលមានអាកាសធាតុក្តៅ ចំនួនដកដង្ហើមរបស់គោទឹកដោះនឹងកើនឡើង។ ..... ( )
2. នៅក្នុងរោងចិញ្ចឹមគោមានរបាំងខណ្ឌមិនមានកន្លែងដេកសម្រាប់គោនោះទេ ប៉ុន្តែនៅក្នុងរោងចិញ្ចឹមគោគ្មានរបាំងខណ្ឌមានកន្លែងដេកសម្រាប់គោនីមួយៗ។ ..... ( )
3. សត្វគោមានក្រពះចំនួន1ដូចមនុស្សដែរ។ ..... ( )
4. "ការមិនព្រមស៊ីចំណី"របស់គោកើតឡើងដោយសារគោស៊ីចំណីមិនកែច្នៃច្រើនពេក។ ..... ( )
5. នៅពេលគោទឹកដោះមានជំងឺរលាកដោះ ការជ្រុះកោសិកាមានការថយចុះ។ ..... ( )
6. មេគោក្រោយកើតកូននឹងបន្តបង្ហាញចំណង់ផ្លូវភេទរៀងរាល់21ថ្ងៃ។ ..... ( )
7. គេចិញ្ចឹមកូនគោដោយដាក់នៅក្នុងរបង និង ចាំងកុំអោយត្រូវពន្លឺព្រះអាទិត្យ។ ..... ( )

<សត្វជ្រូក>

1. ពូជជ្រូកដែលគេចិញ្ចឹមច្រើននៅក្នុងប្រទេសជប៉ុនគឺ ពូជជ្រូកឡែនរ៉ែស ពូជជ្រូកយ៉កសៀរធំ និង ពូជជ្រូកហាំសៀរ។ ..... ( )
2. នៅប្រទេសជប៉ុន ការបង្កាត់ជ្រូកមានតែការបង្កាត់ដោយធម្មជាតិតែប៉ុណ្ណោះ។ ..... ( )
3. នៅពេលជ្រូកបង្កើតកូន កម្រនឹងកើតមានករណីដែលមេជ្រូកលំបាកក្នុងការបង្កើតកូនណាស់។ ..... ( )
4. កូនជ្រូកនៅពេលកើត ជាទូទៅ មានទម្ងន់ប្រហែល0.5គីឡូក្រាម។ ..... ( )
5. កូនជ្រូកទទួលកម្លាំងទប់ទល់នឹងជំងឺផ្សេងៗពីទឹកដោះដំបូង។ ..... ( )
6. គេអោយចំណីដល់ជ្រូកចិញ្ចឹមបំប៉នម្តងក្នុង1ថ្ងៃក្នុងបរិមាណកំណត់ច្បាស់លាស់។ ..... ( )
7. សត្វជ្រូកគឺជាសត្វដែលរស់នៅជាហ្វូង ដូច្នេះ នៅពេលគេចិញ្ចឹមជ្រូកជាហ្វូង ជ្រូកទាំងអស់អាចស៊ីចំណីក្នុងបរិមាណស្មើៗគ្នាបាន។ ..... ( )

<សត្វមាន់>

1. ស៊ុតពូជនឹងភ្ញាស់ក្នុងរយៈពេល10ថ្ងៃនៅក្នុងឧបករណ៍ភ្ញាស់ស៊ុតសិប្បនិម្មិត។ ..... ( )
2. សត្វមាន់ផលិតស៊ុតបានច្រើននៅរដូវដែលពេលថ្ងៃមានរយៈពេលវែង។ ..... ( )
3. ក្រោយពីសត្វមាន់បន្តផលិតស៊ុតរយៈពេលប៉ុន្មានថ្ងៃមក វានឹងផ្អាកការផលិត1~3ថ្ងៃ បន្ទាប់មក វានឹងបន្តផលិតស៊ុតរយៈពេលប៉ុន្មានថ្ងៃជាថ្មីម្តងទៀត។ ..... ( )
4. ស៊ុតមាន់ដែលគេដាក់លក់ជាទំនិញមានទម្ងន់30ក្រាមដែលនេះជាទម្ងន់ជាមធ្យម។ ..... ( )
5. អត្រាផលិតស៊ុតរបស់មាន់មានការកើនឡើងយ៉ាងឆាប់រហ័សនៅពេលវាមានអាយុលើសពី13~14ខែ។ ..... ( )
6. នៅពេលសីតុណ្ហភាពកើនឡើងខ្ពស់ បរិមាណស៊ុតរបស់សត្វមាន់មានការថយចុះ។ ..... ( )

7. រោងចិញ្ចឹមមាន់ រួមមាន រោងចិញ្ចឹមមាន់លក្ខណៈបើកចំហដែលពន្លឺព្រះអាទិត្យអាចចាំងចូលបាន និង
រោងចិញ្ចឹមមាន់គ្មានបង្អួចដែលចាំងពន្លឺមិនអោយចូល។..... ( )

ចម្លើយ

<គោ>

1. ○
2. × (ហេតុផល : រោងចិញ្ចឹមគោមានរបាំងខណ្ឌគឺមានកន្លែងដេកសម្រាប់គោនីមួយៗ រីឯរោងចិញ្ចឹមគោគ្មានរបាំងខណ្ឌគឺមិនមានកន្លែងដេកនោះទេ។)
3. × (ហេតុផល : សត្វគោមានក្រពះចំនួន4។)
4. × (ហេតុផល : ការមិនព្រមស៊ីចំណីគឺកើតឡើងដោយសារការផ្តល់ចំណីលាយដែលផ្ទុកធញ្ញជាតិក្នុងបរិមាណច្រើន។)
5. × (ហេតុផល : នៅពេលគោទឹកដោះមានជំងឺរលាកដោះ ការជ្រុះកោសិកាមានការកើនឡើង។)
6. ○
7. × (ហេតុផល : គេចិញ្ចឹមកូនគោនៅក្នុងបរិស្ថានដែលមានការផ្លាស់ប្តូរខ្យល់ល្អប្រសើរនិងមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់។)

សត្វជ្រូក

1. × (ហេតុផល : ពូជជ្រូកឡែនរ៉េស ពូជជ្រូកយ៉កសៀរធំ និង ពូជជ្រូកឌុយរ៉ក។)
2. × (ហេតុផល : គេអនុវត្តការបង្កាត់ដោយធម្មជាតិនិងការបង្កកំណើតសិប្បនិម្មិត(AI)។)
3. ○
4. × (ហេតុផល : កូនជ្រូកនៅពេលកើត មានទម្ងន់ជាមធ្យម1.4គីឡូក្រាម។)
5. ○
6. × (ហេតុផល : ជាគោលការណ៍ សម្រាប់ជ្រូកចិញ្ចឹមបំប៉ន គេផ្តល់ចំណីដោយសេរី។)
7. × (ហេតុផល : ករណីគេចិញ្ចឹមជ្រូកជាហ្វូង គេត្រូវប្រុងប្រយ័ត្ន ព្រោះអាចមានជ្រូកដែលមិនអាចស៊ីចំណីបានគ្រប់គ្រាន់និងមានការលូតលាស់មិនបានល្អ។)

សត្វមាន់

1. × (ហេតុផល : ស៊ុតពូជនឹងភ្ញាស់ក្នុងរយៈពេល21ថ្ងៃ។)
2. ○
3. ○
4. × (ហេតុផល : នៅក្នុងអាជីវកម្មស៊ុតមាន់ គេភាគច្រើនប្រើទំហំMS(52~58ក្រាម) ទំហំM(58~64ក្រាម) និង ទំហំL (64~70ក្រាម)។)
5. × (ហេតុផល : អត្រាផលិតស៊ុតមានការថយចុះយ៉ាងឆាប់រហ័សនៅពេលមាន់មានអាយុ13~14ខែ ហើយបន្ទាប់មក វានឹងចូលដំណាក់កាលផ្លាស់ប្តូរស្លាប។)
6. ○
7. ○

III ការងារគ្រប់គ្រងសត្វចិញ្ចឹមជាប្រចាំថ្ងៃ

1 ការគ្រប់គ្រងអនាម័យនិងការគ្រប់គ្រងសុវត្ថិភាពរបស់កសិដ្ឋាន

1 ស្ថានភាពនៃជំងឺឆ្លងកាចសាហាវ

(1) នៅប្រទេសជប៉ុន នៅឆ្នាំ2010 ជំងឺក្រចកជើងនិងមាត់បានកើតឡើងដែលធ្វើឲ្យសត្វជ្រូកនិងគោជាច្រើនក្បាលត្រូវបានគេសម្លាប់។

(2) នៅប្រទេសជប៉ុន នៅឆ្នាំ2007 ជំងឺផ្តាសាយបក្សីកម្រិតធ្ងន់បានកើតឡើង។

(3) នៅប្រទេសជប៉ុន ចាប់ពីឆ្នាំ2013 ការកើតឡើងនូវជំងឺរាករូសរាតត្បាតកើតនៅលើសត្វជ្រូកបានបង្កបញ្ហានៅគ្រប់តំបន់។

(4) ជំងឺឆ្លងទាំងបីខាងលើនេះសុទ្ធតែជាជំងឺឆ្លងបង្កដោយវីរុស។

(5) នៅប្រទេសជិតខាងរបស់ប្រទេសជប៉ុនក៏មានការកើតឡើងនូវជំងឺក្រចកជើងនិងមាត់ ជំងឺផ្តាសាយបក្សីកម្រិតធ្ងន់ផងដែរ។

(6) ថ្មីៗនេះ លំហូរចេញចូលនៃមនុស្សនិងវត្ថុរវាងប្រទេសបានកើនឡើង ដែលធ្វើឲ្យហានិភ័យនៃការឆ្លងចូលនូវជំងឺឆ្លងកាចសាហាវទៅក្នុងប្រទេសជប៉ុនបានកើនឡើងខ្ពស់។

2 ប្រការត្រូវប្រុងប្រយ័ត្នសម្រាប់អ្នកធ្វើការនៅកសិដ្ឋាន

(1) នៅពេលចេញចូលរោងចិញ្ចឹមសត្វ ត្រូវធ្វើការសម្លាប់មេរោគចំពោះស្បែកជើងកវែងនិងសម្លៀកបំពាក់ការងារឲ្យបានគ្រប់គ្រាន់។

(2) ត្រូវសង្កេតមើលដោយប្រុងប្រយ័ត្នខ្ពស់នូវស្ថានភាពសត្វចិញ្ចឹមហើយត្រូវរាយការណ៍ទៅម្ចាស់កសិដ្ឋាននៅពេលយល់ថាមានភាពមិនប្រក្រតីកើតឡើង។

(3) ត្រូវការពារកុំឲ្យសត្វព្រៃដូចជាបក្សីព្រៃនិងកណ្តុរជាដើមចូលលុកលុយក្នុងរោងចិញ្ចឹមសត្វ។

(4) សត្វរុយមិនត្រឹមតែជាភ្នាក់ងារចម្លងវីរុសឬមេរោគធ្ងន់ធ្ងរប៉ុណ្ណោះទេ ការកើតឡើងនៃដង្កូវរបស់សត្វរុយក៏ទាក់ទាញសត្វបក្សីព្រៃផងដែរ ហេតុនេះការកម្ចាត់សត្វរុយគឺជារឿងសំខាន់។

3 តំបន់កសិដ្ឋាន

តំបន់កសិដ្ឋានចាំបាច់ត្រូវការការគ្រប់គ្រងក្នុងនាមជាតំបន់គ្រប់គ្រងអនាម័យដែលបង្ការការលុកលុយនៃភ្នាក់ងារបង្កជំងឺ។

តំបន់កសិដ្ឋានចែកជាពីរគឺ តំបន់សម្រាប់សត្វចិញ្ចឹម(រោងចិញ្ចឹមសត្វនិងកន្លែងហាត់ប្រាណ) និងតំបន់សម្រាប់គ្រប់គ្រង(ធុងចំណីសត្វ ឃ្លាំងចំណីសត្វ ផ្លូវ និងការិយាល័យជាដើម) ដែលតំបន់ទាំងពីរនេះត្រូវតែដាក់វិន័យនិងគ្រប់គ្រងឲ្យបានតឹងរឹងចំពោះការចេញចូលនៃមនុស្សនិងយានជំនិះ។

(1) មិនឲ្យភ្ញៀវដែលមកកសិដ្ឋានចូលទៅក្នុងរោងចិញ្ចឹមសត្វដោយគ្មានការអនុញ្ញាត ហើយនៅក្នុងករណីបែបនេះ ចាំបាច់ត្រូវផ្តល់ដំណឹងទៅម្ចាស់កសិដ្ឋាន។

(2) ក្នុងករណីជូនភ្ញៀវដែលមកសិដ្ឋានចូលទៅក្នុងរោងចិញ្ចឹមសត្វ ត្រូវឲ្យភ្ញៀវពាក់ស្រោមការពារស្បែកជើង(ធ្វើពីផ្លាស្ទិច)និងពាក់សម្លៀកបំពាក់ការងារដែលមានអនាម័យ រួចធ្វើការសម្លាប់មេរោគដោយអាងជាន់ត្រាំសម្លាប់មេរោគ រួចសឹមឲ្យចូលរោងចិញ្ចឹមសត្វ។

4 អគារសម្លាប់មេរោគនៅច្រកចេញចូលនៃតំបន់គ្រប់គ្រងអនាម័យ

(1) ករណីរថយន្តចេញចូល

តំបន់នេះមានអគារសម្លាប់មេរោគដែលរួមមាន "ច្រកសម្លាប់មេរោគសម្រាប់រថយន្ត" "ឧបករណ៍បាញ់ថ្នាំសម្លាប់មេរោគ" "អាងសម្លាប់មេរោគសម្រាប់រថយន្ត" "តំបន់ម្សៅកំបោរ"។ល។

ចំពោះរថយន្តដែលចេញចូលកសិដ្ឋាន ត្រូវសម្លាប់មេរោគចំពោះកង់រថយន្តដោយឧបករណ៍បាញ់ថ្នាំសម្លាប់មេរោគ អាងសម្លាប់មេរោគសម្រាប់រថយន្តជាដើម។

(2) ករណីមនុស្សចេញចូល

ក្នុងករណីមនុស្សចេញចូលនៅក្នុងតំបន់គ្រប់គ្រងអនាម័យ រួមមានតំបន់សម្រាប់សត្វចិញ្ចឹមនិងតំបន់សម្រាប់ការគ្រប់គ្រងជាដើម គេត្រូវធ្វើការសម្លាប់មេរោគនៅផ្នែកជើង(ស្បែកជើងកវែង)និងសម្លៀកបំពាក់ការងារដោយប្រើ "ឧបករណ៍បាញ់ថ្នាំសម្លាប់មេរោគ" "អាងជាន់ត្រាំសម្លាប់មេរោគ" "តំបន់ម្សៅកំបោរ"។ល។

5 ការគ្រប់គ្រងឧបករណ៍សម្លាប់មេរោគ អាងសម្លាប់មេរោគ និង តំបន់សម្លាប់មេរោគ

(1) ច្រកសម្លាប់មេរោគសម្រាប់រថយន្ត

នៅពេលរថយន្តចូលមក ឧបករណ៍ស្ទង់នឹងបើក ហើយទឹកថ្នាំនឹងត្រូវបាញ់ចេញពីខាងលើ ខាងក្រោម ឆ្វេង និងស្តាំ ដើម្បីសម្លាប់មេរោគពេញតួរថយន្តរួមទាំងផ្នែកខាងក្រោមនៃរថយន្តផងដែរ។ គេចាំបាច់ត្រូវអនុវត្តការចាក់បំពេញថ្នាំសម្លាប់មេរោគនិងការគ្រប់គ្រង់ម៉ាស៊ីនបាញ់ថ្នាំជាប្រចាំថ្ងៃ។

(2) ឧបករណ៍បាញ់ថ្នាំសម្លាប់មេរោគ

ជាឧបករណ៍ដែលបញ្ជាដោយដៃ ដោយសម្រាប់រថយន្ត ឧបករណ៍នេះអាចសម្លាប់មេរោគនៅបរិវេណជុំវិញរថយន្តនិងកង់រថយន្ត ហើយសម្រាប់មនុស្ស ឧបករណ៍នេះអាចសម្លាប់មេរោគនៅផ្នែកជើង។ គេចាំបាច់ត្រូវចាក់បំពេញថ្នាំសម្លាប់មេរោគជានិច្ច។

អាងជាន់ត្រាំសម្លាប់មេរោគ

(3) អាងសម្លាប់មេរោគសម្រាប់រថយន្ត

គេបើកបររថយន្តយឺតៗឆ្លងកាត់ក្នុងទឹកថ្នាំសម្លាប់មេរោគ ធ្វើដូចនេះ គេអាចសម្លាប់មេរោគនៅកង់ឡានបានភាគច្រើន។ ប្រសិទ្ធិភាពនៃទឹកថ្នាំសម្លាប់មេរោគនឹងថយចុះទៅតាមពេលវេលា ដូច្នេះ គេចាំបាច់ត្រូវផ្លាស់ប្តូរទឹកថ្នាំអោយបាន2~3ដងក្នុងមួយសប្តាហ៍។ ម្យ៉ាងទៀត ប្រសិនបើមានការលាយឡំនៃភក់ឬខ្សាច់នៅក្នុងទឹកថ្នាំសម្លាប់មេរោគ ក៏អាចធ្វើអោយប្រសិទ្ធិភាពថ្នាំថយចុះ ដូច្នេះ គេក៏ចាំបាច់ត្រូវធ្វើការសម្អាតផងដែរ។

(4) អាងជាន់ត្រាំសម្លាប់មេរោគ

គេធ្វើការត្រាំស្បែកជើងកវែងរយៈពេល 15~30 វិនាទីនិងក្នុងធើងដែលដាក់ទឹកថ្នាំសម្លាប់មេរោគ។ ប្រសិទ្ធភាពនៃទឹកថ្នាំសម្លាប់មេរោគនឹងថយចុះទៅតាមពេលវេលា ដូច្នេះ គេចាំបាច់ត្រូវផ្លាស់ប្តូរទឹកថ្នាំ។ ការផ្លាស់ប្តូរទឹកថ្នាំត្រូវធ្វើឡើងជារៀងរាល់ថ្ងៃ ហើយនៅពេលឃើញមានការប្រឡាក់ខ្លាំង គេត្រូវផ្លាស់ប្តូរនៅពេលនោះភ្លាមៗ។

(5) តំបន់ម្សៅកំបោរ (តំបន់សម្លាប់មេរោគ)

ត្រូវបាចរោយម្សៅកំបោរនៅច្រកចេញចូលដើម្បីធ្វើការសម្លាប់មេរោគនៅកង់រថយន្តចំពោះរថយន្ត និងនៅបាតស្បែកជើងកវែងចំពោះមនុស្ស។ ការបាចរោយកំបោរគឺចាំបាច់ត្រូវអនុវត្តជាប្រចាំថ្ងៃ។

6 ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ថ្នាំសម្លាប់មេរោគ

នៅពេលប្រើប្រាស់ថ្នាំសម្លាប់មេរោគ ត្រូវគោរពតាមចំណុចមួយចំនួនរួមមាន "ត្រូវគោរពទៅតាមរបៀបនិងកម្រិតប្រើប្រាស់ដែលបានកំណត់រួចស្រេច" "ត្រូវលាយថ្នាំសម្លាប់មេរោគនៅពេលប្រើប្រាស់" "ត្រូវរក្សាទុកថ្នាំសម្លាប់មេរោគ(ទឹកថ្នាំដើម)នៅកន្លែងដែលងងឹតនិងស្ងួត" "មិនត្រូវលាយជាមួយថ្នាំសម្លាប់មេរោគឬថ្នាំសម្លាប់សត្វល្អិតផ្សេងទៀតនោះទេ" "នៅពេលប្រើប្រាស់ ត្រូវពាក់ស្រោមដៃ ហើយនៅពេលបាញ់ឬរោយថ្នាំត្រូវពាក់ម៉ាស"។ នៅពេលធ្វើការសម្លាប់មេរោគ ត្រូវស្លៀកឯកសណ្ឋានសម្រាប់ធ្វើការងារនេះនិងប្រុងប្រយ័ត្នកុំអោយទឹកថ្នាំសម្លាប់មេរោគប៉ះពាល់ត្រូវរាងកាយ ហើយប្រសិនបើទឹកថ្នាំសម្លាប់មេរោគប៉ះត្រូវខ្លួនប្រាណ ត្រូវប្រើទឹកដើម្បីលាងសម្អាតចេញអោយអស់។

ការទុកដាក់ថ្នាំសម្លាប់មេរោគ

សូមស្លៀកពាក់អាវការពារឲ្យបានត្រឹមត្រូវ។
វិធីស្លៀកពាក់អាវការពារដែលត្រឹមត្រូវ

7 ការគ្រប់គ្រងសុវត្ថិភាពរោងចិញ្ចឹមសត្វ

(1) ប្រេងឥន្ធនៈអគ្គិសនី

នៅពេលប្រើប្រាស់ប្រេងឥន្ធនៈ(ប្រេងកាត សាំងជាដើម) ត្រូវពិនិត្យជានិច្ចថាគ្មានភ្លើងនៅក្បែរនិងប្រុងប្រយ័ត្នចំពោះអគ្គិភ័យ។

ត្រូវប្រុងប្រយ័ត្នជាពិសេសចំពោះភ្លើងបារីនិងដែកកេះជាដើម។ មិនត្រូវយកវាមកជិតជាដាច់ខាត។

(2) ប្រព័ន្ធអគ្គិសនី

ព្រីភ្លើងនៅពេលត្រូវសើម អាចមានហានិភ័យឆ្លងចរន្តអគ្គិសនី។

នៅពេលសម្អាត ត្រូវប្រុងប្រយ័ត្នកុំធ្វើឲ្យសើមព្រីភ្លើង។

2 គោចិញ្ចឹមយកទឹកដោះ

1 កាលវិភាគពេញ1ថ្ងៃរបស់កសិករផលិតទឹកដោះ

ពេលព្រឹក	ពេលថ្ងៃ	ពេលយប់
សម្អាតស្នូកដាក់ចំណី សម្អាតស្នូកដាក់ទឹកនិងផ្តិលទឹក ច្របាច់ទឹកដោះ អោយចំណីសត្វ បោសប្រមូលផ្តុំចំណីសត្វ សម្អាតផ្លូវដើរ	បោសប្រមូលផ្តុំចំណីសត្វ ទុកដាក់កាកសំណល់សត្វ (អោយចំណីសត្វ	សម្អាតផ្លូវដើរ ច្របាច់ទឹកដោះ អោយចំណីសត្វ បោសប្រមូលផ្តុំចំណីសត្វ

2 ការគ្រប់គ្រងកសិដ្ឋាន

(1) ផ្លូវដើរ

វាមានសារៈសំខាន់ក្នុងការសម្អាតផ្លូវដើររបស់គោទឹកដោះកុំអោយមានភាពរអិល។

(2) ឃ្លាំងស្តុកចំណីសត្វ

· ប្រុងប្រយ័ត្នកុំអោយសត្វស្លាបព្រៃឬកណ្តុរចូលក្នុងឃ្លាំងស្តុកចំណីសត្វ។

· សម្អាតអោយបានស្អាតមានអនាម័យជានិច្ច។

· ត្រួតពិនិត្យថាតើចំណីសត្វមិនមានដុះផ្សិតទេឬយ៉ាងណា។

(3) ស្នូកដាក់ចំណី

· សម្អាតស្នូកដាក់ចំណីអោយបានស្អាតជានិច្ច មុនពេលអោយចំណីសត្វនៅពេលព្រឹក។

· ផ្ទៃនៃស្នូកដាក់ចំណីគួរមានលក្ខណៈរលោងស្មើ ដោយមិនគួរមានផ្នែកផតឬប្រហោងនោះទេ។

(4) ការបោសប្រមូលផ្តុំចំណីសត្វ

ដើម្បីអោយគោទឹកដោះងាយស្រួលក្នុងការស៊ីចំណី ការបោសប្រមូលផ្តុំចំណីសត្វអោយស្ថិតនៅជិតមាត់របស់គោគឺជាការសំខាន់។

ការងារបោសប្រមូលផ្តុំចំណីសត្វ

(5) ការសម្អាតស្នូកដាក់ទឹកនិងផ្តិលទឹក

· នៅពេលព្រឹក គេធ្វើការសម្អាត ដោយយកចំណីសត្វដែលធ្លាក់នៅក្នុងស្នូកដាក់ទឹកនិងផ្តិលទឹកចេញអោយអស់ ហើយដាក់ទឹកថ្មីៗអោយគោទឹកដោះជាប្រចាំ ។

· នៅរដូវក្តៅដែលមានអាកាសធាតុក្តៅ គេគួរអនុវត្តដោយឧស្សាហ៍ប្តូរទឹកនៅក្នុងស្នូកដាក់ទឹក ដើម្បីអោយគោអាចផឹកទឹកត្រជាក់ៗ ទើបជាការល្អ។

ផ្តិលទឹក

(6) ការផ្លាស់ប្តូរខ្យល់នៅក្នុងរោងចិញ្ចឹមគោ

· នៅរដូវដែលមានអាកាសធាតុរងា គេធ្វើការទប់ខ្យល់ដែលចូលតាមប្រលោះផ្សេងៗ។

· នៅរដូវដែលមានអាកាសធាតុក្តៅ វាមានសារៈសំខាន់ដោយគេត្រូវធ្វើការជម្រុញចរន្តខ្យល់ដោយប្រើកង្ហារ។

· នៅរដូវដែលមានអាកាសធាតុក្តៅ សីតុណ្ហភាពនៅចុងពោះវៀនធំរបស់គោច្រើនតែកើនឡើងលើសពី39អង្សាសេ ល្បឿនដកដង្ហើមរបស់គោក៏កើនឡើង
ហើយការបរិភោគចំណីរបស់វានឹងមានការថយចុះ។

ការផ្លាស់ប្តូរខ្យល់នៅក្នុងរោងចិញ្ចឹមគោ

(7) កន្លែងគោដេក

· គេរក្សាកន្លែងគោដេក (ក្រោលគោ)អោយមានអនាម័យ និង ស្ងួតជានិច្ច។

· ដើម្បីផ្តល់ជាសុកភាពនិងកាត់បន្ថយកុំអោយមានរបួសនៅជើងរបស់គោទឹកដោះ គេប្រើសម្ភារៈក្រាលធ្វើជាកម្រាលដែលមានលក្ខណៈទន់។

កន្លែងគោដេក

(8) ការកម្ចាត់សត្វល្អិតពីខាងក្រៅ

· គេត្រូវចាត់វិធានការទប់ស្កាត់កុំអោយសត្វរុយសាស៊ីបាអិឬសត្វរុយអ៊ីអេបាអិជាដើមអាចបន្តពូជនិងកើនចំនួនបាន។

· ដើម្បីទប់ស្កាត់សត្វល្អិតទាំងនោះ ចាំបាច់ត្រូវធ្វើការសម្អាតនិងកម្ចាត់កាកសំណល់សត្វ ធ្វើការផ្លាស់ប្តូរកម្រាល និងធ្វើការកម្ចាត់ចោលនូវចំណីសត្វដែលស្អុយរលួយ។

(9) ការសង្កេតមើលសត្វគោ

គេសង្កេតមើលសត្វគោដើម្បីដឹងអំពី"ការប្រជែងរវាងគោខ្លាំងនិងគោខ្សោយ""គោដែលមិនមានសុខភាពល្អ""របួសនៅលើខ្លួនគោ""ការរើសចំណី (ការស៊ីចំណីរើស)""ស្ថានភាពលាមកដូចជារាករូសជាដើម"។

3 លំដាប់លំដោយនៃការច្របាច់ទឹកដោះ

(1) ការត្រៀមរៀបចំនិងគោលការណ៍

· នៅមុនពេលច្របាច់ទឹកដោះ គេធ្វើការត្រួតពិនិត្យ លាងសម្អាត និង សម្លាប់មេរោគនៅលើឧបករណ៍និងសម្ភារៈប្រើសម្រាប់ច្របាច់ទឹកដោះ។

· គេធ្វើការច្របាច់ទឹកដោះរបស់គោដែលឃើញមានការជ្រុះកោសិកាច្រើនឬគោដែលមានជំងឺរលាកដោះនៅចុងក្រោយគេ។

(2) ការច្របាច់ទឹកដោះដំបូងចោល

· គេធ្វើការច្របាច់ទឹកដោះដំបូងចោល ដើម្បី"រកនូវសារធាតុកកឬរឹងនៅក្នុងទឹកដោះ" ដើម្បី"ច្របាច់ចោលនូវទឹកដោះដែលអាចមានការជ្រៀតចូលនៃមេរោគនៅក្បាលដោះក្រោយពេលច្របាច់ទឹកដោះលើកមុន"និងដើម្បី"ច្របាច់ចោលនូវទឹកថ្នាំសម្លាប់មេរោគដែលសល់ជាប់នៅក្បាលដោះក្រោយពេលច្របាច់ទឹកដោះលើកមុន"។

· ការសម្លាប់មេរោគនៅដៃនិងការពាក់ស្រោមដៃច្របាច់ទឹកដោះគេត្រៀមរៀបចំធុងទឹកសម្រាប់លាងដៃនិងកន្សែងសម្រាប់ជូតដៃ។

ការច្របាច់ទឹកដោះដំបូងចោល

· ផ្តិលត្រងទឹកដោះ : គេធ្វើការច្របាច់ទឹកដោះដំបូងចោលពីក្បាលដោះនីមួយៗដាក់ចូលក្នុងផ្តិលត្រងទឹកដោះ រួចធ្វើការពិនិត្យរកមើលសារធាតុកកឬរឹងនៅក្នុងទឹកដោះ។ ក្នុងករណីនេះ ប្រសិនបើឃើញក្បាលដោះប្រលាក់ខ្លាំង គេត្រូវធ្វើការលាងសម្អាតក្បាលដោះជាមុនសិន។ ម្យ៉ាងទៀត ប្រសិនបើឃើញក្បាលដោះប្រលាក់ខ្លាំង ត្រូវធ្វើការលាងសម្អាតក្បាលដោះជាមុនសិន។

ផ្តិលត្រងទឹកដោះ

(3) ការជ្រលក់ក្បាលដោះមុនពេលច្របាច់ទឹកដោះ(អនុវត្តនៅកសិដ្ឋានដែលក្បាលដោះមិនស្អាតខ្ចក់)

[1] គេអនុវត្តវាជំនួស "ការជូតសម្អាតក្បាលដោះ" ដែលមានពន្យល់នៅចំណុចបន្ទាប់ ដោយប្រើថ្នាំសម្លាប់មេរោគបន្ទាប់ពីច្របាច់ទឹកដោះដំបូងចោល។

[2] ការជ្រលក់ក្បាលដោះ គឺមានន័យថា "ជ្រលក់ក្នុងទឹកថ្នាំ" ។

[3] គោលបំណងនៃការជ្រលក់ក្បាលដោះគឺសម្លាប់មេរោគនៅក្បាលដោះនិងការពារផ្នែកក្បាលដោះ។

[4] ទឹកថ្នាំជ្រលក់ក្បាលដោះមានរួមបញ្ចូលថ្នាំសម្លាប់មេរោគនិងសារជាតិការពារផ្នែកក្បាលដោះ(ដូចជាជាតិ គ្លីសេរីនជាដើម)។

[5] ក្រោយជ្រលក់ចប់ ដើម្បីការពារមិនឲ្យមានបន្សល់ទឹកថ្នាំទៅក្នុងទឹកដោះ ត្រូវជូតឲ្យស្អាតដោយប្រើក្រដាសកន្សែងដែលប្រើម្តងហើយបោះចោល។

ទឹកថ្នាំជ្រលក់ក្បាលដោះ

(4) ការជូតសម្អាតក្បាលដោះ

· គេធ្វើការជូតសម្អាតក្បាលដោះដោយប្រើកន្សែងដែលជ្រលក់ក្នុងទឹកថ្នាំសម្លាប់មេរោគ។

· គោលបំណងនៃការជូតសម្អាតគឺដើម្បី"ភ្ញោចការបញ្ចេញទឹកដោះ"និង ដើម្បី"សម្លាប់មេរោគនៅលើផ្ទៃនៃក្បាលដោះ"។

· គេត្រៀមកន្សែងលើសពី1សម្រាប់គោមួយក្បាល ហើយនៅពេលគេប្រើរួច គេដាក់វាចូលទៅក្នុងធុងមួយផ្សេងទៀត។

· គេក៏អាចប្រើកន្សែងក្រដាសដែលប្រើម្តងហើយចោល ជំនួសអោយកន្សែងក្រណាត់។

ការជូតសម្អាតក្បាលដោះ

(5) ការសម្ងួតក្បាលដោះ

ក្រោយពីជូតសម្អាតក្បាលដោះរួច ឬក្រោយពីជ្រលក់ក្បាលដោះរួច ត្រូវសម្ងួតក្បាលដោះដោយជូតក្បាលដោះដោយប្រើក្រដាសកន្សែងដែលប្រើម្តងហើយបោះចោល។

(6) ការពាក់បំពង់បឺតទឹកដោះ ការច្របាច់ទឹកដោះ និង ការដកបំពង់បឺតទឹកដោះចេញ

· គេបំពាក់បំពង់បឺតទឹកដោះនៅ 1~2 នាទីក្រោយពេលចាប់ផ្តើមច្របាច់ទឹកដោះដំបូងចោល។

· គេភ្ជាប់បំពង់បឺតនីមួយៗទៅនឹងក្បាលដោះចំនួន4។

· ការច្របាច់ទឹកដោះគួរអនុវត្តក្រោមរយៈពេល5នាទី។

· គេមិនធ្វើការច្របាច់ទឹកដោះច្រើនជ្រុលដោយបង្ខំច្របាច់ទឹកដោះដែលនៅសល់អោយអស់នោះទេ(ការច្របាច់ទឹកដោះលក្ខណៈម៉ាស៊ីន) ព្រោះការធ្វើបែបនេះធ្វើអោយរបួសដល់មាត់និងបំពង់នៅក្នុងក្បាលដោះរបស់គោ។ គឺគេមិនត្រូវច្របាច់ហួសហេតុនោះទេ។

· ក្រោយពេលច្របាច់ទឹកដោះរួចរាល់ហើយ គេនឹងដកបំពង់បឺតទឹកដោះចំនួន4ចេញពីក្បាលដោះព្រមគ្នាតែម្តង។

ការពាក់បំពង់បឺតទឹកដោះ

របៀបច្របាច់ទឹកដោះដែលត្រឹមត្រូវ

មិនត្រូវធ្វើការច្របាច់ទឹកដោះលក្ខណៈម៉ាស៊ីននោះទេ (ឧទាហរណ៍នៃការអនុវត្តមិនបានល្អ)

គេធ្វើការបង្ខាំងសុញ្ញាកាស បន្តិចក្រោយមក ទឹកដោះនឹងធ្លាក់មកដោយឯកឯងហើយនឹងបែងចែកទៅបំពង់ទាំង4ស្របពេលតែមួយ។

របួសនៅជុំវិញមាត់ក្បាលដោះដោយសារការច្របាច់ទឹកដោះច្រើនជ្រុល។

(7) ការសម្លាប់មេរោគក្រោយពេលច្របាច់ទឹកដោះ

· ការសម្លាប់មេរោគក្រោយពេលច្របាច់ទឹកដោះ គឺជាការជ្រលក់ដោះរបស់សត្វគោទៅក្នុងទឹកថ្នាំសម្លាប់មេរោគ នៅក្រោយពេលដកបំពង់បឺតទឹកដោះចេញរួចរាល់។

· គោលបំណងនៃការធ្វើបែបនេះ គឺដើម្បីទប់ស្កាត់ការឆ្លងបាក់តេរីនៅលើក្បាលដោះទុករហូតដល់ពេលច្របាច់ទឹកដោះលើកក្រោយ។

ការជ្រលក់ក្បាលដោះនៅក្នុងទឹកថ្នាំសម្លាប់មេរោគ

ដបជ្រលក់

(8) ការគ្រប់គ្រងសីតុណ្ហភាពនៃធុងរក្សាទឹកដោះអោយត្រជាក់

· នៅពេលបញ្ចូលទឹកដោះក្នុងធុងមុនដំបូង គេត្រូវបញ្ចូលទឹកដោះដែលបានពីការច្របាច់រួចក្នុងអំឡុងពេល1 ម៉ោង ហើយត្រូវរក្សាសីតុណ្ហភាពអោយនៅក្រោម 10 អង្សាសេ បន្ទាប់មក គេត្រូវគ្រប់គ្រងសីតុណ្ហភាពអោយនៅក្រោម4.4អង្សាសេក្នុងអំឡុងពេល1ម៉ោងបន្ទាប់ពីនោះ។

· នៅពេលបញ្ចូលទឹកដោះបន្ថែម គេត្រូវគ្រប់គ្រងសីតុណ្ហភាពកុំអោយឡើងហួសពី 10 អង្សាសេ។

ធុងរក្សាទឹកដោះអោយត្រជាក់

4 ការសង្កេតមើលចំណង់ផ្លូវភេទរបស់សត្វគោ

(1) វដ្តនៃចំណង់ផ្លូវភេទ

វដ្តនៃចំណង់ផ្លូវភេទរបស់គោទឹកដោះគឺមានរយៈពេល21ថ្ងៃ។

(2) ការសង្កេតមើល

· នៅពេលជិតមានចំណង់ផ្លូវភេទ សត្វគោទឹកដោះនឹងទៅជានៅមិនស្ងៀម ទៅត្រដុសគោដទៃឬមនុស្ស ហើយពេ

លយប់ពេលដែលគោដទៃនៅស្ងៀមក៏ដោយ ក៏វានៅតែដើរចុះដើរឡើងដែរ។

· ចិរវេលាជាប់គ្នានៃការមានចំណង់ផ្លូវភេទ កាលពីមុនគេនិយាយថាមានរយៈពេលប្រហែល12ទៅ18ម៉ោង ប៉ុន្តែបានថយចុះជាងមុនទន្ទឹមគ្នានឹងការកើនឡើងនៃបរិមាណទឹកដោះរបស់គោទឹកដោះដោយបច្ចុប្បន្ននេះ គេនិយាយថាចិរវេលាជាប់គ្នានៃការមានចំណង់ផ្លូវភេទជាស្តង់ដារគឺមានរយៈពេល7ទៅ8ម៉ោង។

· គេធ្វើការសង្កេតមើលសកម្មភាពបង្ហាញចំណង់ផ្លូវភេទរបស់គោ (ការបង្ហាញចំណង់ផ្លូវភេទលក្ខណៈជាន់ ជាដើម) នៅពេលព្រឹកព្រលឹមនិងពេលយប់។

· ការបង្ហាញចំណង់ផ្លូវភេទលក្ខណៈជាន់ គឺនៅពេលគោផ្សេងប្រុងឡើងជាន់ពីលើហើយ គោនៅតែសម្ងំស្ងៀមមិនរើបម្រះ។ បែបនេះគេចាត់ទុកថាជាចំណង់ផ្លូវភេទពិតប្រាកដ ។

(3) ការសង្កេតមើលចំណង់ផ្លូវភេទរបស់សត្វគោក្នុងករណីចិញ្ចឹមដោយចង

ក្នុងករណីចិញ្ចឹមដោយចង ឧទាហរណ៍ រោងដែលមានបំពាក់របងគោ ជាដើម គេសង្កេតមើលស្ថានភាពដូចខាងក្រោម។

· គោមិនសូវស៊ីចំណី

· បរិមាណទឹកដោះថយចុះ

· មិនសូវនៅស្ងៀម

· ស្រែករោទ៍

· មានលេចចេញនូវទឹករំអិល

· ប្រដាប់ភេទមានលក្ខណៈហើម



ប្រដាប់ភេទឡើងក្រហមនិងហើមធំ

5 ការមើលថែកូនគោនៅពេលកើត(ត្រៀមលក្ខណៈ)

· មុនកូនគោកើត គេចាំបាច់ត្រូវរៀបចំទុកជាមុននូវទ្រុងចិញ្ចឹមដោយបំបៅដែលមានអនាម័យនិងស្ងួតហើយក្រាលដោយសម្ភារៈក្រាលបានគ្រប់គ្រាន់។

· គេត្រូវត្រៀមកន្សែងស្អាតសម្រាប់ជូតទឹកភ្លោះជាប់នឹងខ្លួនកូនគោ ឧបករណ៍សម្រាប់ដឹកជញ្ជូន ថ្នាំសម្លាប់មេរោគ(ទឹកថ្នាំសម្លាប់មេរោគអ៊ីយ៉ូឌីនជាដើម)។

3 គោចិញ្ចឹមយកសាច់

1 ការត្រួតពិនិត្យកសិដ្ឋាន

ជាមូលដ្ឋាន ផ្នែកនេះគឺមានខ្លឹមសារដូចទៅនឹងផ្នែកទី1ចំណុចទី2នៃ III ដូច្នេះ សូមពិនិត្យមើលខ្លឹមសារត្រង់ចំណុចនោះ។

2 ការត្រួតពិនិត្យសុខភាព

(1) ចំណង់អាហារ

ប្រសិនបើឃើញមានអាការៈដូចខាងក្រោម គេអាចសង្ស័យថាសត្វកំពុងមានជំងឺផ្នែកប្រព័ន្ធរំលាយអាហារ ជំងឺដែលធ្វើអោយក្តៅខ្លួន ឬ ជំងឺធ្មេញ។

- មិនទៅជិតស្នូកដាក់ចំណី
- មានសល់ចំណីតិចឬច្រើន
- ឃ្លាតឆ្ងាយពីហ្វូង

(2) តើកែវភ្នែកស្រទន់ហើយស្អាហាប់ឬទេ

បើមានអាការដូចខាងក្រោម អាចមានការសង្ស័យថាកើតមានជំងឺខ្វះឈាម ជំងឺខាន់លឿង ជំងឺផ្លូវដង្ហើមដំណាក់កាលដំបូង។

- មិនស្អាហាប់
- ភ្នាសស្លេកស្លាំងខ្វះឈាម
- ភ្នាសឡើងក្រហម
- ភ្នាសប្រែជាពណ៌លឿង
- រលាកស្រទាប់ក្រៅនៃកញ្ចក់ភ្នែកដោយមានខ្ទុះ
- ហៀរទឹកភ្នែកច្រើន ពពកភ្នែក

(3) ស្ថានភាពច្រមុះ

បើមានអាការដូចខាងក្រោម អាចមានការសង្ស័យថាកើតមានជំងឺផ្លូវដង្ហើម ជំងឺដែលធ្វើឲ្យក្តៅខ្លួន។

- មានសំបោររាវ
- មានសំបោរពណ៌លឿងស~លឿងបៃតង
- ឧបករណ៍ឆ្លុះច្រមុះស្ងួត

(4) កាយវិការ និងជំងឺឬបញ្ហាដែលត្រូវសង្ស័យ

- អន្ទះអន្ទែង ហៀរទឹកមាត់សង្កៀតធ្មេញ ប្រឹងពោះដើម្បីជុះ កាយដីដោយជើងមុខ ឈឺចាប់ សម្លឹងមើលពោះ → ឈឺសរីរាង្គ ពុល
- មានអាការប្រព័ន្ធប្រសាទឬបញ្ហាស្មារតីដូចជា ស្រងេះស្រងោច រំភើបខុសធម្មតា វិលខ្លួនជារង្វង់ ស្រែកវោទ៍ ញាក់ កន្ត្រាក់ កម្រើកមិនបានជាដើម → ឆ្លងជំងឺ អាការខ្វះជាតិវីតាមីនB1

· ដំណើរខ្វៃចៗ →ជំងឺក្រចកជើង
· ជាំ · គ្រេច · រលាកសន្លាក់ → រចនាសម្ព័ន្ធនៃកម្រាលបាតរៀបចំមិនបានល្អ
· ខ្នងនិងគន្លាក់ជើងក្រោយបត់ខុសធម្មតានៅពេលជុះនោមឬលាមក →ជំងឺពាក់ព័ន្ធមេតាប៉ូលីស
· ត្រដុសខ្លួននឹងជញ្ជាំងឬបង្គោល →ជំងឺស្បែក
· ញ័រស្មាចង្កេះ →រលាកខួរក្បាល ពុល
· រោមមិនស្អាត ហើមជើង លៀនគ្រាប់ភ្នែក សមត្ថភាពភ្នែកធ្លាក់ចុះ → អាការខ្វះជាតិវីតាមីនA

(5) ស្ថានភាពនៃគល់កន្ទុយនិងកន្ទុយ

ប្រសិនបើឃើញមានអាការៈដូចខាងក្រោម គេសង្ស័យថាគោកំពុងមានជំងឺរាករូស។

· រោមនៅគល់កន្ទុយជ្រុះឬត្រដោល
· មានស្នាមប្រលាក់ពណ៌លឿងឬត្នោតខ្មៅនៅជាប់នឹងគល់កន្ទុយ
· មានស្នាមប្រលាក់នៅជាប់ពេញកន្ទុយទាំងមូល

(6) ស្ថានភាពដកដង្ហើម

ប្រសិនបើឃើញមានអាការៈដូចខាងក្រោម គេសង្ស័យថាគោកំពុងមានជំងឺផ្លូវដង្ហើម។

· ដកដង្ហើមដោយហាមាត់ ដកដង្ហើមដោយប្រឹង
· ល្បឿននៃការដកដង្ហើមកើនឡើង
· ដកដង្ហើមពីពោះ

(7) នៅពេលមានអាការៈក្អក

គេសង្ស័យថាគោអាចនឹងកំពុងឈ្លក់ (ច្រឡំលេបវត្ថុចម្លែក) ឬកំពុងមានជំងឺផ្លូវដង្ហើម។

(8) សីតុណ្ហភាពក្នុងខ្លួន (សីតុណ្ហភាពនៅចុងពោះវៀនធំ)

ប្រសិនបើឃើញមានអាការៈក្តៅខ្លួនចាប់ពី40អង្សាសេឡើងទៅឬក៏មានអាការៈញ័រខ្លួន គេសង្ស័យថាគោកំពុងមានជំងឺផ្លូវដង្ហើម។ល។

(9) ស្ថានភាពរោម

· គ្រើមរឹង មិនភ្លឺរលោង →អាចសង្ស័យថាខ្វះជីវជាតិ។

· រែងមិនស្មើគ្នាល្អ រួញខ្លួរ →អាចសង្ស័យថាមានអាការឆ្លងប៉ារ៉ាស៊ីត។

· ជ្រុះរោម →អាចសង្ស័យថាមានជំងឺសើស្បែក។

· នៅចុងរោមប្រដាប់ភេទមានជាប់ដុំគ្រាប់តូចៗពណ៌ាស →អាចសង្ស័យថាជំងឺក្រូសក្នុងតម្រងនោម

4 សត្វជ្រូក

1 ចំណុចត្រូវប្រុងប្រយ័ត្ននៅពេលជ្រូកមេបំបៅដោះកូន

ក្បាលដោះរបស់ជ្រូកមេបែងចែកជា2ជួរ ឆ្វេងនិងស្តាំ ដោយសរុបអាចមានចំនួនលើសពី12។ ក្បាលដោះដែលស្ថិតនៅជិតផ្នែកក្បាលរបស់ជ្រូកមេមានផ្ទុកទឹកដោះច្រើន។ បន្ទាប់ពីកើតកូនបានពីរទៅបីថ្ងៃ កូនជ្រូកនីមួយៗនឹងកំណត់ក្បាលដោះសម្រាប់បៅរៀងៗខ្លួន(លំដាប់លំដោយនៃក្បាលដោះ) ហើយពួកវានឹងបៅពីក្បាលដោះដូចគ្នារាល់ពេល។ ការបំបៅដោះនឹងប្រព្រឹត្តទៅ1ដងក្នុង1ម៉ោង។ រយៈពេលពិតប្រាកដនៃការបញ្ចេញទឹកដោះគឺ10ទៅ20វិនាទី។

នៅពេលបំបៅដោះ អាចមានករណីកូនជ្រូកងាប់ដោយសារជ្រូកមេដេកសង្កត់ពីលើកើតឡើងច្រើន។ គេមិនត្រូវធ្វើអោយជ្រូកមេផ្អើលនោះទេ លើសពីនេះទៀត គេត្រូវធ្វើការគ្រប់គ្រងដោយចងចាំនូវចំណុចទាំង3ខាងក្រោមនេះ។

- ប្រសិនបើការគ្រប់គ្រងសារធាតុចិញ្ចឹមសម្រាប់ជ្រូកមេមិនបានល្អ ធ្វើអោយបរិមាណបញ្ចេញទឹកដោះថយចុះ ហើយកូនជ្រូកមិនងាយនឹងឃ្លាតឆ្ងាយពីជ្រូកមេនោះទេ។
- ប្រសិនបើជ្រូកមេពិបាកក្នុងការធឹកទឹក វានឹងឧស្សាហ៍ក្រោកឈរហើយដេកទៅវិញជាញឹកញាប់។
- ប្រសិនបើការរក្សាកម្តៅអោយកូនជ្រូកមិនបានគ្រប់គ្រាន់ កូនជ្រូកនឹងទៅរកកម្តៅពីមេជ្រូកដោយប៉ះ និងដេកជាមួយជ្រូកមេហើយអាចត្រូវកិនពីលើ។

2 អំពីការរក្សាកម្តៅនៅពេលបំបៅដោះនិងចិញ្ចឹមកូនជ្រូក

សីតុណ្ហភាពសមស្របសម្រាប់កូនជ្រូកគឺខ្ពស់ ហើយសមត្ថភាពរបស់វាក្នុងការសម្រួលសីតុណ្ហភាពរាងកាយគឺនៅទាបនៅឡើយ ហេតុនេះចាំបាច់ត្រូវការការរក្សាកម្តៅឲ្យបានគ្រប់គ្រាន់។ កម្រិតសីតុណ្ហភាពសមស្របគឺប្រែប្រួលទៅតាមការលូតលាស់ ហេតុនេះត្រូវវិនិច្ឆ័យថាវាសមស្របឬអត់ទៅតាមពេលនិមួយៗ។ សីតុណ្ហភាពសមស្របនៅពេលកើតគឺ36អង្សា 1សប្តាហ៍ក្រោយគឺ30អង្សា 2សប្តាហ៍ក្រោយគឺ28អង្សា 3សប្តាហ៍ក្រោយគឺ26អង្សា គឺវាធ្លាក់ចុះបន្តិចម្តងៗ។ ករណីដែលកូនជ្រូកនៅចំពីក្រោមឧបករណ៍កម្តៅ គេវិនិច្ឆ័យថាវាត្រជាក់។ ផ្ទុយទៅវិញ បើកូនជ្រូកដេកនៅឃ្លាតឆ្ងាយពីឧបករណ៍កម្តៅ គេវិនិច្ឆ័យថាវាក្តៅ។ គេធ្វើយ៉ាងណារក្សាស្ថានភាពដែលកូនជ្រូកស្ថិតនៅបែងខ្ញែកសមស្រប។

ក្នុងការប្រើប្រាស់ឧបករណ៍កម្តៅ ត្រូវមានការប្រុងប្រយ័ត្ន។ ភាគច្រើននៃគ្រោះអគ្គិភ័យនៅរោងចិញ្ចឹមជ្រូកគឺបណ្តាលមកពីការធ្លាក់ឧបករណ៍កម្តៅ ភ្លើងដែលចេញពីឧបករណ៍កម្តៅ។

	អាយុក្រោយកើត · ទម្ងន់	សីតុណ្ហភាពសមស្រប
កូនជ្រូក	ក្រោយកើត 1-3ថ្ងៃ 4– 7 8–30 31–45	30–32°C 28–30 22–25 20–22
ជ្រូកសាច់	15– 50kg 50–100	20–25 18–20
ជ្រូកពេញវ័យ	ចាប់ពី100kgឡើង	15–18

សីតុណ្ហភាពសមស្របសម្រាប់ជ្រូក

3 ចំណុចត្រូវប្រុងប្រយ័ត្ននៅក្នុងការគ្រប់គ្រងកូនជ្រូក

កូនជ្រូកងាយកើតជំងឺណាស់ ហើយវាច្រើនកើតជំងឺទាក់ទងនឹងប្រព័ន្ធរំលាយអាហារ (រាករូស)និងប្រព័ន្ធផ្លូវដង្ហើម (រលាកសួត)។ ម្យ៉ាងទៀត អាចមានករណីដែលកូនជ្រូកធំធាត់មិនបានល្អដោយសារឆ្លងប៉ារ៉ាស៊ីតពីជ្រូកមេ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការកម្ចាត់ប៉ារ៉ាស៊ីតនៅលើជ្រូកបង្កាត់ពូជដែលនឹងក្លាយជាជ្រូកមេ ដោយគេត្រូវចាក់វ៉ាក់សាំងទាំងកូនជ្រូកនិងមេជ្រូក។

ការបំបៅដោះកូនជ្រូក

4 ចំណុចត្រូវប្រុងប្រយ័ត្នពេលក្រៀវកូនជ្រូក

កូនជ្រូកឈ្មោលត្រូវក្រៀវសិនសឹមចិញ្ចឹមបំប៉ន។ នេះគឺដើម្បីបង្ការមិនឲ្យក្លិនមិនល្អរបស់ជ្រូកឈ្មោលជ្រាតចូលទៅក្នុងសាច់ជ្រូក។ គេក្រៀវនៅកំឡុងពេលប៉ុន្មានថ្ងៃក្រោយកើតរហូតដល់មុនផ្តាច់ទឹកដោះ ហើយភាគច្រើនគឺក្រៀវក្នុងកំឡុងពេលមិនលើស1សប្តាហ៍។

5 ចំណុចត្រូវប្រុងប្រយ័ត្ននៅពេលជ្រូកបង្កាត់ពូជកើតមានចំណង់ផ្លូវភេទ បង្កាត់ពូជ និងពេលកើត

កូនជ្រូកក្រោយផ្តាច់ទឹកដោះបានមួយរយៈ វានឹងកើតមានចំណង់ផ្លូវភេទ។ វដ្តនៃការមានចំណង់ផ្លូវភេទគឺមានរយៈពេល21ថ្ងៃ ហើយមានភាពខុសគ្នាទៅតាមជ្រូកនិមួយៗ ប៉ុន្តែវាបន្តក្នុងពេល2-3ថ្ងៃ។ អាការមានចំណង់ផ្លូវភេទគឺអាចមើលឃើញដូចជា ការឡើងឈរទ្រោបពីលើ ថយចុះចំណង់អាហារ បំបះកន្ទុយ ប្រដាប់ភេទហើម មានទឹក រំអិល។ ត្រូវឆាប់រកឲ្យឃើញក្នុងដំណាក់កាលដំបូងនៃការមានចំណង់ផ្លូវភេទដែលប្រដាប់ភេទឡើងក្រហមហើយប៉ោង ហើយពេលចូលដល់ដំណាក់កាលមានចំណង់ផ្លូវភេទ ត្រូវធ្វើការបង្កាត់ពូជនៅពេលសមស្របសម្រាប់ការបង្កាត់ពូជនោះ។ ពេលសមស្របសម្រាប់បង្កាត់ពូជដែលអត្រាជើមខ្ពស់បំផុតគឺ10-25ម៉ោងក្រោយពេលចូលដល់ដំណាក់កាលមានចំណង់ផ្លូវភេទ។ ជ្រូកបង្កាត់ពូជនៅពេលដែលចូលដល់ដំណាក់កាលមានចំណង់ផ្លូវភេទ វានឹងនៅស្ងៀមពេលដែលមនុស្សធ្វើការត្រួតពិនិត្យប្រតិកម្មតបពេលសង្កត់ខ្នងដោយយកដៃទាំងពីរសង្កត់ផ្នែកខ្នងនិង ចង្កេះ។ ម្យ៉ាងទៀត ពេលដាក់ជ្រូកឈ្មោលឲ្យទៅជិតជ្រូកញីដែលព្រម វានឹងនៅស្ងៀមមិនកម្រើកទោះបីជ្រូកឈ្មោលឡើងជិះ ហើយវានឹងបះត្រចៀកឡើង។ ជ្រូកដែលមិនធ្លាប់បង្កើតកូនជួនកាលអាចនឹងមិនបញ្ចេញអាការមានចំណង់ផ្លូវភេទឲ្យឃើញច្បាស់។

ការបញ្ជាក់ការមានចំណង់ផ្លូវភេទ



ប្រដាប់ភេទឡើងក្រហមនិងហើម

(រូបភាពផ្តល់ដោយ៖ នីតិបុគ្គលរដ្ឋបាលឯករាជ្យ មជ្ឈមណ្ឌលកែលម្អសត្វចិញ្ចឹម)

(1) ដំណាក់កាលដំបូងនៃការមានចំណង់ផ្លូវភេទ : 2.7 ថ្ងៃ លេចចេញអាការប្រដាប់ភេទឡើងក្រហមនិងហើម
(2) ដំណាក់កាលមានចំណង់ផ្លូវភេទ : 2.4 ថ្ងៃ ពីពេលចាប់ផ្តើមទទួលសត្វឈ្មោលដល់បញ្ចប់
(3) ដំណាក់កាលចុងក្រោយនៃការមានចំណង់ផ្លូវភេទ : 1.8 ថ្ងៃ ថយចុះនូវអាការប្រដាប់ភេទឡើងក្រហមនិងហើម
(4) ដំណាក់កាលផ្អាកមានចំណង់ផ្លូវភេទ : 14.1 ថ្ងៃ

សត្វជ្រូកដោយសារកំឡុងពេលមានចំណង់ផ្លូវភេទមានរយៈពេលយូរ ដើម្បីឲ្យអត្រាផើមខ្ពស់ហើយទទួលបានកូនច្រើនតាមតែអាចក្នុងពេលផើមមួយលើក គេធ្វើការបង្កកំណើត2ដងក្នុងកំឡុងមានចំណង់ផ្លូវភេទម្តង ទោះបីតាមរយៈការបង្កាត់ពូជធម្មជាតិដោយសត្វឈ្មោលឬការបង្កកំណើតសប្បនិម្មិតក៏ដោយ។ ការផើមគឺគេបញ្ជាក់តាមរយៈការដែលមិនមានចំណង់ផ្លូវភេទម្តងទៀតនៅ21ថ្ងៃក្រោយ និងដោយប្រើឧបករណ៍ពិនិត្យការផើម។ នៅពេលផើម សត្វជ្រូកភាគច្រើននឹងនៅស្ងៀមស្ងាត់ ហើយចំណង់អាហារក៏កើនឡើងដែរ។

មុនដាក់ជ្រូកចូលកន្លែងរក្សាកម្តៅសម្រាប់ការបង្កើតកូន ត្រូវសម្អាត សម្លាប់មេរោគ និងសម្ងួតទុកជាមុន។ សត្វជ្រូកងាយបង្កើតកូន ហើយកម្រនឹងពិបាកកើតណាស់។ ម្យ៉ាងទៀត បើកូនជ្រូកមិនដកដង្ហើម ត្រូវធ្វើចលនាដង្ហើមសប្បនិម្មិត។



ទំនាក់ទំនងរវាងអាការនៃប្រដាប់ភេទបង្ហាញដោយការមានចំណង់ផ្លូវភេទនិងពេលសមស្របសម្រាប់បង្កាត់ពូជ (បង្កកំណើត) (ករណីបង្កាត់ពូជដោយធម្មជាតិនិងបង្កកំណើតសប្បនិម្មិតដោយទឹកកាមរាវ)

6 ចំណុចត្រូវប្រុងប្រយ័ត្ននៅពេលមានអាកាសធាតុក្តៅ

កូនជ្រូកមិនសូវធន់នឹងអាកាសធាតុត្រជាក់នោះទេ ចំណែកឯជ្រូកដែលលូតលាស់ក្លាយជាជ្រូកចិញ្ចឹមបំប៉ននិងជ្រូកបង្កាត់ពូជមិនសូវធន់នឹងអាកាសធាតុក្តៅនោះឡើយ។

បរិស្ថានសម្រាប់ចិញ្ចឹមជ្រូកចិញ្ចឹមបំប៉ននិងជ្រូកបង្កាត់ពូជ គឺគួរមានសីតុណ្ហភាពប្រមាណ20អង្សាសេជាការសមស្រប។ ជ្រូកបង្កាត់ពូជនិងកូនជ្រូកដែលស្ថិតក្នុងកន្លែងដែលខុសពីសីតុណ្ហភាពសមស្រប ឧទាហរណ៍នៅពេលដែលជ្រូកបង្កាត់ញី(ជ្រូកមេ)ទទួលឥទ្ធិពលពីសីតុណ្ហភាពខ្ពស់នៅមុននិងក្រោយពេលកើតកូន អាចធ្វើអោយកូនជ្រូកក៏ទទួលឥទ្ធិពលមិនល្អនោះផងដែរ។

នៅពេលមានអាកាសធាតុក្តៅ ត្រូវធ្វើការផ្លាស់ប្តូរខ្យល់ដោយប្រើប្រាស់កង្ហារ ជាពិសេសគេត្រូវបន្តផ្លាស់ប្តូរខ្យល់ជានិច្ចនៅក្បែរផ្នែកម្រាល គឺដើម្បីអោយខ្យល់បាញ់ត្រូវខ្លួនជ្រូកផងនិងដើម្បីកម្ចាត់សំណើមចេញផង។ ខ្យល់បាញ់របស់កង្ហារគួរតែមានល្បឿនលើសពី 10ម៉ែត្រ/វិនាទី។ គេត្រូវប្រុងប្រយ័ត្នចំពោះគន្លងនៃការផ្លាស់ប្តូរខ្យល់គឺត្រូវធ្វើយ៉ាងណាអោយទិសខ្យល់នៅក្នុងរោងចិញ្ចឹមជ្រូកមានទិសដៅថេរ។ ក្នុងករណីខ្យល់ដែលបញ្ចេញមកមានលក្ខណៈក្តៅ ហើយការបញ្ជូនខ្យល់មានប្រសិទ្ធិភាពទាប គេអាចបំពាក់បំពង់បញ្ជូនខ្យល់ដែលប្រើឧបករណ៍ធ្វើអោយខ្យល់ត្រជាក់ជាដើម។ រដូវក្តៅនៅប្រទេសជប៉ុនមានបរិយាកាសដែលមានសីតុណ្ហភាពនិងជាតិសំណើមខ្ពស់ គឺមានល័ក្ខខ័ណ្ឌលំបាកជាងបរិយាកាសនៃរដូវក្តៅនៅទ្វីបអឺរ៉ុបនិងសហរដ្ឋអាមេរិច ដូច្នេះ បច្ចេកវិទ្យាគ្រប់គ្រងអាកាសធាតុក្តៅដែលប្រើប្រាស់នៅប្រទេសក្រៅភាគច្រើនមិនអាចប្រើប្រាស់នៅប្រទេសជប៉ុនបានឡើយ។

7 ការគ្រប់គ្រងស្នូកដាក់ចំណីនិងការផឹកទឹករបស់សត្វ

ជាទូទៅ ការអោយចំណីដល់ជ្រូកចិញ្ចឹមបំប៉នគឺគេអនុវត្តវិធីដាក់ចំណីមិនអោយដាច់។ គឺត្រូវរក្សាស្ថានភាពអោយមានចំណីនៅក្នុងស្នូកជានិច្ច។ ក្នុងករណីប្រើឧបករណ៍បន្សើមចំណីដែលបន្ថែមទឹកនៅពេលជ្រូកស៊ីចំណី ត្រូវប្រយ័ត្នចំពោះចំណីសល់ដែលអាចនឹងរលួយ។ ត្រូវទប់ស្កាត់កុំអោយសត្វស្លាបដែលចង់ស៊ីចំណីចូលបាន ហើយត្រូវអនុវត្តវិធានការកម្ចាត់សត្វកណ្តុរជាប្រចាំ។ ត្រូវដាក់ទឹកអោយជ្រូកអាចផឹកបានដោយសេរី។ ក្នុងករណីប្រើឧបករណ៍បញ្ចេញទឹកទម្រង់ខាំឬទម្រង់ជាក្បាលដោះ ត្រូវប្រយ័ត្នចំពោះសម្ពាធទឹក ព្រោះអាចធ្វើអោយជ្រូកមិនអាចផឹកទឹកក្នុងបរិមាណចាំបាច់បានគ្រប់គ្រាន់។

8 ចំណុចត្រូវប្រុងប្រយ័ត្ននៅក្នុងការរក្សាទុកនិងប្រើប្រាស់ចំណីសត្វ

ចំណីសត្វគួររក្សាទុកនៅក្នុងទីកន្លែងដែលត្រជាក់ល្មមនិងងងឹតតាមដែលធ្វើទៅបាន ដោយចៀសវាងការរក្សាទុកនៅក្នុងបរិស្ថានដែលមានសីតុណ្ហភាពនិងជាតិសំណើមខ្ពស់។ ជាពិសេស ទឹកដោះសិប្បនិម្មិតគឺងាយខូចណាស់ដូច្នេះត្រូវប្រើប្រាស់អស់អោយបានឆាប់រហ័ស។ មិនត្រូវផ្តល់ចំណីដែលដុះផ្សិតហើយទៅអោយសត្វនោះទេ។ ត្រូវចាត់វិធានការទប់ស្កាត់ការបំផ្លាញចំណីដែលរក្សាទុកក្នុងឃ្លាំងពីសត្វកណ្តុរ សត្វស្លាប និងសត្វល្អិតផ្សេងៗ។

9 ការគ្រប់គ្រងបរិស្ថាននិងអនាម័យនៅរោងចិញ្ចឹមជ្រូក

ការរៀបចំបរិស្ថានអោយមានអនាម័យនៅរោងចិញ្ចឹមជ្រូក គឺមិនត្រឹមតែដើម្បីទប់ស្កាត់ជំងឺនិងថែរក្សាសុខភាពសត្វជ្រូកប៉ុណ្ណោះទេ ប៉ុន្តែ វាក៏មានសារៈសំខាន់សម្រាប់ការថែរក្សាសុខភាពរបស់កសិករផងដែរ។ ការថែរក្សាបរិស្ថានអោយមានអនាម័យនៅរោងចិញ្ចឹមជ្រូកគឺស្មើនឹងការថែរក្សាបរិស្ថាននៅកន្លែងធ្វើការរបស់កសិករ ។ ដើម្បីរក្សាអនាម័យចំណីអាហារ ក៏ដូចជាដើម្បីទប់ស្កាត់កង្វក់បរិស្ថាននៅជុំវិញ ការគ្រប់គ្រងអនាម័យនៅរោងចិញ្ចឹមជ្រូកគឺជាការងារដ៏សំខាន់មួយ។

គេធ្វើការបែងចែកជា តំបន់សម្រាប់បង្កាត់ពូជ និង តំបន់សម្រាប់ចិញ្ចឹមបំប៉ន នៅក្នុងរោងចិញ្ចឹមជ្រូក ដើម្បីអោយការផ្លាស់ទីនៅពេលធ្វើការងារក្នុងរោងមានទិសដៅតែមួយ។ គេសាងសង់រោងសម្រាប់ត្រួតពិនិត្យជំងឺឆ្លងចំពោះជ្រូកបង្កាត់ដែលនាំចូលពីខាងក្រៅ។ ម្យ៉ាងទៀត គេរៀបចំទីតាំងទាំងមូល ដោយដាក់រោងសម្រាប់ជ្រូកចិញ្ចឹមបំប៉ននៅទីតាំងទល់មុខនឹងបរិវេណខាងក្រៅជាងគេ ព្រោះប្រសិនបើមានការជ្រៀតចូលនៃមេរោគបង្កជំងឺ ក៏អាចទប់ស្កាត់ការរាតត្បាតត្រឹមជ្រូកចិញ្ចឹមបំប៉នបាន។

ជំងឺដែលកើតលើសត្វជ្រូក នឹងបង្ហាញជាអាការៈផ្សេងៗ។ នៅពេលឃើញមានអាការៈខុសប្រក្រតី ត្រូវរាយការណ៍ដល់ពេទ្យសត្វដែលប្រចាំនៅកសិដ្ឋានចិញ្ចឹមជ្រូកអោយបានឆាប់រហ័ស និងអនុវត្តតាមការណែនាំរបស់ពេទ្យសត្វ។

5 ការចិញ្ចឹមមាន់ (មានចិញ្ចឹមយកស៊ុតនិងមាន់ចិញ្ចឹមយកសាច់)

1 ការគ្រប់គ្រងឧបករណ៍ចិញ្ចឹមកូនមាន់

(1) ការគ្រប់គ្រងសីតុណ្ហភាព

កូនមាន់ដែលទើបនឹងកើតមានរូបរាងតូច សីតុណ្ហភាពក្នុងខ្លួនក៏ទាប ហើយមិនសូវមានកម្លាំងសម្របទៅតាមសីតុណ្ហភាពនៅក្នុងបរិស្ថាននោះទេ ដូច្នេះ ប្រសិនបើគ្មានការផ្តល់កម្តៅទេនោះ កូនមាន់នឹងមិនលូតលាស់ឡើយ។ ទោះជាក្នុងករណីប្រើប្រាស់រោងចិញ្ចឹមមាន់(ទម្រង់បើកចំហឬទម្រង់គ្មានបង្អួច)ឬករណីប្រើប្រាស់បច្ចេកទេសចិញ្ចឹមកូនមាន់(ឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាធ្នើរ ឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ឆ័ត្រនិងលើផ្ទៃរាបផ្ទាល់ដី និងឧបរណ៍ផ្តល់កម្តៅតាមផ្នែកម្រាល)ក៏ដោយ ក៏ត្រូវធ្វើការសង្កេតស្ថានភាពរបស់កូនមាន់តូច ហើយត្រូវធ្វើការបញ្ចុះសីតុណ្ហភាពបន្តិចម្តងៗពីសីតុណ្ហភាព32~35អង្សាសេនៅពេលបញ្ចូលកូនមាន់ដំបូង រហូតដល់កូនមាន់អាចសំាននឹងការរស់នៅក្រោមសីតុណ្ហភាពក្នុងបន្ទប់ដូចធម្មតាក្រោយរយៈពេល3~4សប្តាហ៍ បន្ទាប់ពីនោះ អាចបញ្ឈប់ការផ្តល់កម្តៅបាន។

(2) ការគ្រប់គ្រងជាតិសំណើម

គេធ្វើអោយកូនមាន់ដែលទើបនឹងកើតអាចសំាទៅនឹងជាតិសំណើមក្នុងបន្ទប់ធម្មតាបន្តិចម្តងៗផ្តើមពីបរិស្ថានដែលមានជាតិសំណើម65%។ នៅពេលចាប់ផ្តើមបញ្ចូលកូនមាន់ ដើម្បីរក្សាជាតិសំណើមអោយបាន65%នៅក្រោមសីតុណ្ហភាព35អង្សាសេ ចាំបាច់ត្រូវប្រើថាសទឹកជាដើមដើម្បីបន្ថែមជាតិសំណើម ទោះជាគេប្រើឧបករណ៍ចិញ្ចឹមកូនមាន់ប្រភេទណាក៏ដោយ។ ប៉ុន្តែ បន្ទាប់ពីរយៈពេល1សប្តាហ៍ លាមកបស់កូនមាន់នឹងកើនឡើង ហើយចំហាយទឹកដែលហើរចេញពីលាមកក៏កើនឡើងដែរ ស្របពេលនោះគេត្រូវកាត់បន្ថយការបញ្ចូលទឹក។ ចាប់ពីប្រហែលថ្ងៃទី10តទៅ គេត្រូវរក្សាអោយមានភាពស្ងួតវិញ។

(3) ការគ្រប់គ្រងការផ្លាស់ប្តូរខ្យល់

នៅក្នុងឧបករណ៍ចិញ្ចឹមកូនមាន់ប្រភេទណាក៏ដោយ ប្រសិនបើមានសីតុណ្ហភាពខ្ពស់ នោះនឹងធ្វើអោយមានគម្លាតរវាងសីតុណ្ហភាពក្នុងបន្ទប់ ហើយការផ្លាស់ប្តូរខ្យល់នឹងកើតឡើងដោយធម្មជាតិ ប៉ុន្តែ ការផ្លាស់ប្តូរខ្យល់ហួសហេតុពេកនឹងធ្វើអោយសីតុណ្ហភាពនៅក្នុងឧបករណ៍ចិញ្ចឹមកូនមាន់ធ្លាក់ចុះ។ ត្រូវប្រុងប្រយ័ត្នដោយធ្វើការសង្កេតមើលស្ថានភាពរបស់កូនមាន់ ហើយគ្រប់គ្រងសីតុណ្ហភាពអោយបានសមស្រប។

2 ការគ្រប់គ្រងឧបករណ៍ផ្តល់ចំណីនិងឧបករណ៍ផ្តល់ទឹក

(1) ដំណាក់កាលកូនមាន់តូច

ឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាធ្នើរឬក៏ឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់រាបផ្ទាល់ដី(នៅក្នុងរបងព័ទ្ធ) មួយណាក៏ដោយ នៅពេលបញ្ចូលកូនមាន់ ដើម្បីអោយកូនមាន់ងាយទទួលយកចំណី គេត្រូវដាក់ចំណីជ្រាយនៅក្នុងប្រអប់ចំណី(ប្រអប់ដែលរាបស្មើនិងមានគែមទាប)ដោយធ្វើការរោយចំណីនោះក្នុងបរិមាណតិចប៉ុន្តែច្រើនដង។ ដើម្បីបង្កការងាយស្រួលដល់ការផឹកទឹកពីឧបករណ៍ផ្តល់ទឹក គេប្រើប្រាស់បន្ទះផ្តល់ទឹកឬឧបករណ៍ជំនួយការផ្តល់ទឹក។ កូនមាន់តូចតែងតែស៊ីចំណីនិងផឹកទឹកជាញឹកញាប់ ដូច្នេះ ត្រូវដាក់ឧបករណ៍ផ្តល់ចំណីនិងឧបករណ៍ផ្តល់ទឹកអោយនៅជិតគ្នា។

ការគ្រប់គ្រងសីតុណ្ហភាពអោយបានសមស្រប(ដោយបញ្ចុះសីតុណ្ហភាពនៅផ្នែកផ្តល់កម្តៅពីសីតុណ្ហភាព32~35អង្សាសេនៅពេលបញ្ចូលកូនមាន់ដំបូងបន្តិចម្តងៗជារៀងរាល់ថ្ងៃ) កូនមាន់នឹងចាប់ផ្តើមចេញពីផ្នែកផ្តល់កម្តៅទៅផ្នែកដែលមានសីតុណ្ហភាពក្នុងបន្ទប់បន្តិចម្តងៗទៅតាមពេលវេលា ដើម្បីស៊ីចំណីនិងផឹកទឹក។ ក្រោយពេលចាប់ផ្តើមអោយចំណីចាប់ពី2ថ្ងៃទៅ គេនឹងរៀបចំដាក់ចំណីនិងទឹកផឹកនៅផ្នែកដែលមានសីតុណ្ហភាពក្នុងបន្ទប់(សំដៅលើកន្លែងហាត់ប្រាណករណីឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាធ្នើរ និង បរិវេណដែលឃ្លាតឆ្ងាយពីប្រភពកម្តៅនៅក្នុងរបងព័ទ្ធករណីឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់រាបផ្ទាល់ដី)។ នៅពេលកូនមាន់ភាគច្រើនចាប់ផ្តើមចេញមករកចំណីនៅផ្នែកសីតុណ្ហភាពក្នុងបន្ទប់ហើយ គេនឹងបញ្ឈប់ការអោយចំណីនិងទឹកនៅផ្នែកផ្តល់កម្តៅ។

នៅក្នុងដំណាក់កាលកូនមាន់តូច គេត្រូវរៀបចំអោយមានចំណីនិងទឹកផឹកជាប្រចាំ ហើយអោយកូនមាន់ស៊ីចំណីនិងផឹកទឹកដោយសេរី។ គេដាក់ចំណីក្នុងឧបករណ៍ផ្តល់ចំណីក្នុងបរិមាណប្រហែលពាក់កណ្តាល ដើម្បីកុំអោយកូនមាន់ធ្វើអោយកំពប់នៅពេលស៊ីចំណី ។ ម្យ៉ាងទៀត គេប្រើឆ័ត្រឬរបាំងបែងចែកជាដើម ដើម្បីកុំអោយកូនមាន់ចូលទៅក្នុងឧបករណ៍ផ្តល់ចំណី។ គេនឹងបំពេញទឹកសម្រាប់អោយវាផឹកជានិច្ច ប៉ុន្តែ សម្រាប់ឧបករណ៍ផ្តល់ទឹកទម្រង់ជាជួងដែលផ្គុកទឹកនៅលើចានផ្តល់ទឹក ងាយនឹងធ្វើអោយចំណីឬលាមកធ្លាក់ចូលលាយឡំ ដូច្នេះ គេត្រូវធ្វើការសម្អាតនិងប្តូរចេញ1ថ្ងៃម្តង។ សម្រាប់ឧបករណ៍បញ្ចេញទឹកទម្រង់ជាក្បាលដោះវិញ កូនមាន់នឹងឃើញតំណក់ទឹកនៅខាងចុង ហើយវានឹងផឹកទឹកនោះដោយផ្ទាល់ ដូច្នេះគេត្រូវរក្សាអនាម័យអោយបានស្អាតល្អ។ គេត្រូវប្រែប្រួលកម្ពស់និងកម្រិតទឹកនៅក្នុងឧបករណ៍បញ្ចេញទឹកទម្រង់ជាក្បាលដោះឬឧបករណ៍ផ្តល់ទឹកទម្រង់ជាជួងស្របទៅតាមការលូតលាស់របស់កូនមាន់។



ទីតាំងនៃឧបករណ៍ផ្តល់ចំណីនិងឧបករណ៍ផ្តល់ទឹកនៅក្នុងរបងព័ទ្ធ

(2) ដំណាក់កាលកូនមាន់មធ្យម~កូនមាន់ធំ

[1] ការគ្រប់គ្រងឧបករណ៍ផ្តល់ចំណី

នៅដំណាក់កាលនេះ កន្លែងសម្រាប់ស៊ីចំណីនឹងមានទំហំមិនគ្រប់គ្រាន់សម្រាប់កូនមាន់ ដូច្នេះ គេត្រូវធ្វើការពង្រីកកន្លែងទៅផ្នែកកន្លែងហាត់ប្រាណក្នុងករណីឧបករណ៍ចិញ្ចឹមកូនមានទម្រង់ជាធ្នើរឬពង្រីករបងព័ទ្ធក្នុងករណីឧបករណ៍ចិញ្ចឹមកូនមានទម្រង់រាបផ្ទាល់ដី ព្រមទាំងប្រើចាននៅក្នុងឧបករណ៍ផ្តល់ចំណីដើម្បីបន្ថែមចំណីអោយបានគ្រប់គ្រាន់។ បន្ទាប់ពីនោះ គេបំពាក់ឧបករណ៍ផ្តល់ចំណីរាងជាទនៅកៀនទ្រុងសម្រាប់ឧបករណ៍ចិញ្ចឹមកូនមានទម្រង់ជាធ្នើរ ដើម្បីដឹកនាំអោយកូនមាន់អើតក្បាលចេញពីទ្រុងស៊ីចំណី។ សម្រាប់ឧបករណ៍ចិញ្ចឹមកូនមានទម្រង់រាបផ្ទាល់ដីវិញ មុននឹងដករបងព័ទ្ធចេញ គេត្រូវផ្លាស់ប្តូរឧបករណ៍ទៅជាឧបករណ៍ផ្តល់ចំណីដែលមានរាងជាឡាវ ហើយនៅរោងចិញ្ចឹមមាន់ដែលមានឧបករណ៍ផ្តល់ចំណីជាជួរ គេត្រូវផ្លាស់ប្តូរពីការអោយចំណីដោយដៃទៅជាការអោយចំណីដោយស្វ័យប្រវត្តិបន្តិចម្តងៗ។ ការអោយចំណីដោយស្វ័យប្រវត្តិគឺប្រើប្រាស់ឧបករណ៍ផ្តល់ចំណីដែលមានបំពាក់បំពង់ផ្តល់ចំណី ដោយគេនឹងដាក់ចំណីទៅក្នុងឧបករណ៍ផ្តល់ចំណីរាងជាទក្នុងករណីប្រើឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាធ្នើរ ហើយទៅក្នុងឧបករណ៍ផ្តល់ចំណីរាងជាចានក្នុងករណីគេប្រើឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់រាបផ្ទាល់ដី។

គេសង្កេតមើលស្ថានភាពលូតលាស់និងការស៊ីចំណីរបស់កូនមាន់ ហើយគេនឹងសម្រួលកម្ពស់នៃឧបករណ៍ផ្តល់ចំណីនិងបរិមាណចំណីនៅក្នុងទឬឡាវ។ ការដាក់ចំណីអោយមានលក្ខណៈស្មើសាច់ក្នុងបរិមាណស្មើគ្នានៅក្នុងចាននៃឧបករណ៍ផ្តល់ចំណីដោយស្វ័យប្រវត្តិគឺសំខាន់ណាស់ ដើម្បីអាចអោយកូនមាន់ស៊ីចំណីបានងាយស្រួល។ សម្រាប់ឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាធ្នើរ កូនមាន់នឹងមិនចូលទៅខាងក្នុងឧបករណ៍ផ្តល់ចំណី(ទ)នោះទេ ប៉ុន្តែសម្រាប់ឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់រាបផ្ទាល់ដីវិញ គេត្រូវប្រើឆ័ត្រឬរបាំងបែងចែកឬខ្សែខ្វៀនជាដើម ដើម្បីការពារកុំអោយកូនមាន់ចូលទៅក្នុងឧបករណ៍ផ្តល់ចំណី។

[2] ការគ្រប់គ្រងឧបករណ៍ផ្តល់ទឹក

នៅពេលគេពង្រីកកន្លែងហាត់ប្រាណឬដករបងព័ទ្ធសម្រាប់កូនមាន់ចេញ គេត្រូវបង្កើនចំនួនឧបករណ៍ផ្តល់ទឹកទៅតាមនោះដែរ ហើយរៀបចំទីតាំងនៃឧបករណ៍ទាំងនោះអោយមានតុល្យភាពគ្នាល្អ។ ទាំងឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់ជាធ្នើរទាំងទម្រង់រាបផ្ទាល់ដី គេត្រូវពិចារណាបង្កើនចំនួនឧបករណ៍ផ្តល់ទឹកទម្រង់ក្បាលដោះ ហើយដាក់ក្បាលដោះអោយនៅកម្ពស់ខ្ពស់ជាងភ្នែករបស់កូនមាន់បន្តិច ព្រមទាំងសម្រួលសម្ពាធទឹកដើម្បីអោយកូនមាន់ងាយស្រួលផឹកទឹក។ សម្រាប់ឧបករណ៍ចិញ្ចឹមកូនមាន់ទម្រង់រាបផ្ទាល់ដី គេត្រូវដាក់ទីតាំងនៃចានរបស់ឧបករណ៍ផ្តល់ទឹករាងជាជួងអោយស្ថិតនៅកម្ពស់ស្មើនឹងទ្រូងរបស់កូនមាន់។ សម្រាប់ពូជមាន់ប្រយុទ្ធ គេត្រូវកំណត់កម្ពស់នោះស្របទៅតាមកូនមាន់ញីជាពិសេស។ ការផឹកទឹករបស់កូនមាន់នឹងកើនឡើង ដូច្នេះ ការគ្រប់គ្រងបរិក្ខារផ្តល់ទឹក(ឧបករណ៍ផ្តល់ទឹក បំពង់ផ្តល់ទឹក ធុងបម្រុង។ល។)គឺមានសារៈសំខាន់ណាស់ ដោយត្រូវអនុវត្តការលាងសម្អាតអោយបានទៀងទាត់។

3 វិធីសាស្ត្រកាត់ចំពុះ(កាត់ចុងចំពុះ)

ក្នុងកំឡុងពេលចិញ្ចឹម ការចឹកគូទគ្នាក្នុងចំណោមកូនមាន់ត្រូវបានមើលឃើញជារឿយៗ។ កូនមាន់នៅកំឡុងពេលវានៅតូច ត្រឹមរបួសត្រង់បរិវេណក្បែរកន្ទុយគឺមិនបញ្ហានោះទេ ប៉ុន្តែពេលដល់ពេលមុនផលិតស៊ុតលើកដំបូងភាគច្រើនគឺចឹកធ្លាយដល់ពោះវៀនហើយលើសពីនេះគឺធ្វើឲ្យទទួលរងគ្រោះថ្នាក់ដែលស្មានមិនដល់ក្នុងពេលខ្លី។ ជាទូទៅគេបង្ការគ្រោះថ្នាក់បែបនេះដោយធ្វើការកាត់ចំពុះ(កាត់ចុងចំពុះ)។

គេកាត់ចំពុះដោយប្រើឧបករណ៍កាត់ចំពុះដោយដុតកាត់ផ្នែកខាងលើនិងក្រោមនៃចំពុះ ដោយចំពោះមាន់ចិញ្ចឹម

យកស៊ុត ភាគច្រើនគេកាត់នៅអាយុ3-10ថ្ងៃ។ ចំពោះពូជមាន់ប្រយុទ្ធ គេកាត់នៅអាយុ1ថ្ងៃឬកាន់តែឆាប់កាន់តែល្អ ប៉ុន្តែក៏មានករណីដែលគេអនុវត្តនៅកន្លែងភ្ញាស់ផងដែរ។

ការកាត់ចំពុះនឹងបង្ការទុកជាមុនមិនឲ្យកើតមានទម្លាប់អាក្រក់ ហើយទន្ទឹមគ្នានេះ ក៏ធ្វើឲ្យថយចុះនូវការកំពប់ជ្រុះចំណីពេលស៊ីផងដែរ។ បន្ទាប់ពីក្លាយជាមាន់ពេញវ័យ ការបាត់បង់ស៊ុតដោយសារការចឹកស៊ុតនឹងថយចុះ។

រូបភាពកាត់ចំពុះ(កាត់ចុងចំពុះ)

4 ការថ្លឹងទម្ងន់

ទម្ងន់គឺជាសន្ទស្សន៍វាយតម្លៃដ៏មានប្រសិទ្ធិភាពមួយសម្រាប់ការធ្វើអោយការលូតលាស់របស់កូនមាន់ចិញ្ចឹម យកស៊ុតនិងលទ្ធភាពផលិតស៊ុតរបស់វានៅពេលក្រោយអាចទទួលបានលទ្ធផលល្អប្រសើរគ្រប់គ្រាន់ ដោយគេអនុវត្តការពិនិត្យទម្ងន់រៀងរាល់1~2សប្តាហ៍ម្តងចំពោះកូនមាន់ដែលគេជ្រើសរើសដោយសេរីមិនមានការចំណាំទុក។ ម្យ៉ាងទៀត ការពិនិត្យទម្ងន់បែបនេះក៏មានសារៈសំខាន់សម្រាប់ការគ្រប់គ្រងការកើនទម្ងន់របស់កូនមាន់យកសាច់នៅក្នុងគម្រោងបញ្ចេញលក់សម្រាប់ពូជមាន់ប្រយុទ្ធផងដែរ។

ក្រោយពេលមាន់ចាប់ផ្តើមផលិតស៊ុត ក៏គេនៅតែធ្វើការថ្លឹងទម្ងន់រៀងរាល់4សប្តាហ៍ម្តងដែរ ហើយវាជាការចាំបាច់ក្នុងការពិនិត្យអោយដឹងអំពីការប្រែប្រួលទម្ងន់របស់មាន់ដើម្បីអោយដឹងថាសារធាតុចិញ្ចឹមដែលផ្តល់អោយមាន់មានបរិមាណគ្រប់គ្រាន់ និងមិនមានលក្ខណៈច្រើនជ្រុល។ សម្រាប់ការថ្លឹងទម្ងន់របស់មាន់ពេញវ័យ គេគួរធ្វើការថ្លឹងមាន់នីមួយៗសម្រាប់មាន់ប្រភេទដូចគ្នា។

5 ចំណុចត្រូវប្រុងប្រយ័ត្ននៅក្នុងការនាំចូល រក្សាទុក និង ប្រើប្រាស់ចំណីសត្វ

(1) ការនាំចូលចំណីសត្វ

គេត្រូវធ្វើការសម្អាតធុងដាក់ចំណីឬឃ្លាំងស្តុកចំណីមុនពេលបញ្ជូនចំណីសត្វចូល ហើយរថយន្តដឹកជញ្ជូនចំណីសត្វចូលក៏ត្រូវទទួលការសម្លាប់មេរោគនៅច្រកទ្វារចូលកសិដ្ឋានអោយបានត្រឹមត្រូវផងដែរ។ ចំណុចដែលចាំបាច់ត្រូវពិនិត្យលើចំណីសត្វនោះគឺ រូបរាងខាងក្រៅ ពណ៌ ក្លិននិងគុណភាពរបស់ចំណីសត្វមិនត្រូវមានលក្ខណៈខុសប្រក្រតីនោះទេ ហើយមិនត្រូវមានវត្ថុប្លែកផ្សេងទៀតលាយឡំនោះឡើយ ម្យ៉ាងទៀត ត្រូវមានការភ្ជាប់មកជាមួយនូវឯកសារស្តីអំពីលទ្ធផលពិនិត្យបាក់តេរីសាល់ម៉ូនេឡាពីក្រុមហ៊ុនផលិតចំណីសត្វដែលបានអនុវត្តការពិនិត្យនោះជាទៀងទាត់។ ក្រៅពីនោះ ការគ្រប់គ្រងនូវព័ត៌មានស្តីអំពីសារធាតុបន្ថែមឬថ្នាំបន្ថែមនៅក្នុងចំណីសត្វនិងរយៈពេលផុតកំណត់នៃការបញ្ចេញទំនិញអោយបានច្បាស់លាស់ក៏ជាការសំខាន់ផងដែរ។

(2) ការរក្សាទុកចំណីសត្វ

គេត្រូវកំណត់គម្រោងនៃការទិញចំណីសត្វចូលអោយបានច្បាស់លាស់ទុកជាមុន ដោយប្រុងប្រយ័ត្នមិនត្រូវអោយការស្តុកទុកចំណីនៅក្នុងឃ្លាំងមានរយៈពេលយូរនោះទេ។

ចំណុចចាំបាច់មួយចំនួនទាក់ទងនឹងចំណីរួមមាន មិនត្រូវធ្វើអោយចំណីសត្វខូចខាតដោយសារការដុះផ្សិតជាដើមនោះទេ ហើយត្រូវរក្សាកុំអោយសារធាតុនៅក្នុងចំណីសត្វ(ប្រូតេអ៊ីនិងខ្លាញ់ជាដើម)មានការប្រែប្រួលគុណភាព (ខូចគុណភាព) និង ត្រូវរក្សាសារធាតុ(ថ្នាំ)បន្ថែមដូចជាសារធាតុវីតាមីនជាដើមនៅក្នុងទឹកន្លែងដែលត្រជាក់ល្មមនិងងងឹត។ ម្យ៉ាងទៀត គេមិនត្រូវអោយឃើញមានសត្វកណ្តុរឬអាចម ៍កណ្តុរជាដើមនៅក្នុងឃ្លាំងស្តុកចំណីសត្វនោះទេ។

(3) ការប្រើប្រាស់ចំណីសត្វ

គេត្រូវរៀបចំគម្រោងសម្រាប់ការផ្តល់ចំណីដល់សត្វអោយបានសមស្រប ហើយក្នុងករណីធ្វើការលាយសារធាតុបន្ថែមក្នុងចំណីសត្វនៅកសិដ្ឋាន គេត្រូវអនុវត្តការលាយនោះអោយមានលក្ខណៈសព្វសាច់ល្អនៅក្នុងចំណីសត្វ និង ត្រូវផ្តល់ចំណីទៅតាមកម្រិតប្រើប្រាស់និងរបៀបប្រើប្រាស់ដែលបានកំណត់រួចស្រេច។ ជាពិសេស នៅក្រោយពេលបញ្ចូលកូនមាន់ក្នុងឧបករណ៍ចិញ្ចឹម គេត្រូវអនុវត្តការថ្លឹងទម្ងន់របស់កូនមាន់រៀងរាល់1សប្តាហ៍ម្តង ដើម្បីអាចផ្តល់ចំណីគ្រប់ប្រភេទគ្រប់គ្រាន់ទៅតាមគម្រោងនៃការផ្តល់ចំណី(ប្រព័ន្ធចំណី)ស្របទៅនឹងការលូតលាស់និងដំណាក់កាលផលិតស៊ុតរបស់មាន់។ ម្យ៉ាងទៀត គេត្រូវគោរពទៅតាមរយៈពេលផុតកំណត់បញ្ចេញទំនិញនៃសារធាតុបន្ថែមក្នុងចំណីសត្វអោយបានម៉ត់ចត់ ព្រោះវានឹងមានឥទ្ធិពលដោយផ្ទាល់លើគុណភាពផលិតផលរបស់មាន់(ស៊ុតនិងសាច់) ព្រមទាំងត្រូវប្រុងប្រយ័ត្នចំពោះគុណភាពរបស់ចំណីសត្វ (រូបរាងខាងក្រៅ ពណ៌ ក្លិន ការដុះផ្សិត ការប្រែប្រួលគុណភាព ជាដើម) ដែលសុទ្ធសឹងជាកត្តាចាំបាច់នៅក្នុងការរៀបចំផ្តល់ចំណីដល់សត្វមាន់។

គេចាំបាច់ត្រូវរក្សាទុកបញ្ជីកត់ត្រាការគ្រប់គ្រងការផ្តល់ចំណីសត្វ យ៉ាងហោចណាស់រយៈពេល2ឆ្នាំ។

6 ការគ្រប់គ្រងនៅពេលមានអាកាសធាតុក្តៅ

នៅរដូវក្តៅ នៅក្នុងរោងចិញ្ចឹមមាន់យកស៊ុតលក្ខណៈបើកចំហដែលមានសីតុណ្ហភាពបរិយាកាសខាងក្រៅ32~33អង្សាសេ ក៏អាចមានមាន់ងាប់ដោយសារកម្តៅផងដែរ។ ដំបូលឬជញ្ជាំងនៃរោងចិញ្ចឹមមាន់នឹងឡើងកម្តៅដោយសារប៉ះត្រូវពន្លឺព្រះអាទិត្យ ហើយវាក៏ទទួលពន្លឺផ្លាតពីដីដែលត្រូវថ្ងៃក្តៅផងដែរ ធ្វើអោយនៅក្នុងរោងចិញ្ចឹមមាន់មានកម្តៅលើសពីសីតុណ្ហភាពបរិយាកាសខាងក្រៅចាប់ពី5អង្សាសេឡើងទៅ ហើយនៅជុំវិញខ្លួនមាន់ក៏មានសីតុណ្ហភាពកាន់តែខ្ពស់។ ដូច្នេះ គេចាំបាច់ត្រូវចាត់វិធានការទប់ទល់នឹងកម្តៅ។ នៅរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ គេត្រូវធ្វើអោយការផ្លាស់ប្តូរខ្យល់នៅក្នុងរោងប្រព្រឹត្តទៅបានល្អប្រសើរ ហើយប្រសិនបើមានការហាប់ខ្យល់ គេត្រូវបញ្ចេញខ្យល់ដោយប្រើម៉ាស៊ីនបញ្ចូនខ្យល់ក្នុងល្បឿនប្រមាណ0.5~0.8ម៉ែត្រ/វិនាទី។ ម្យ៉ាងទៀត គេក៏អាចធ្វើការដាំដើមឈើដើម្បីអោយមានម្លប់ កុំអោយរោងចិញ្ចឹមមាន់ប៉ះត្រូវពន្លឺព្រះអាទិត្យដោយផ្ទាល់។ ការបាញ់ទឹកនៅក្នុងរោងចិញ្ចឹមមាន់ក៏មានប្រសិទ្ធិភាពធ្វើអោយសីតុណ្ហភាពនៅក្នុងរោងថយចុះបានផងដែរ។ ប្រសិនបើសីតុណ្ហភាពបរិយាកាសនៅក្នុងរោងចិញ្ចឹមមាន់កើនឡើង នោះទឹកផឹករបស់មាន់ក៏មានសីតុណ្ហភាពកើនឡើងផងដែរ ធ្វើអោយមាន់ចៀសវាងការផឹកទឹក ដូច្នេះ គេត្រូវផ្តល់ទឹកដែលត្រជាក់ជានិច្ចតាមដែលអាចធ្វើទៅបាន។

នៅរោងចិញ្ចឹមមាន់ដែលគ្មានបង្អួច គេប្រើវិធីផ្លាស់ប្តូរខ្យល់ ធ្វើយ៉ាងណាអោយសីតុណ្ហភាពនៅក្នុងរោងចិញ្ចឹមមាន់មានកម្រិតទាបជាងសីតុណ្ហភាពបរិយាកាសខាងក្រៅ និង មានលក្ខណៈស្មើគ្នាគ្រប់កន្លែងនៅក្នុងរោងតាមដែលអាចធ្វើទៅបាន។ ជាទូទៅ គេបង្កើនបរិមាណផ្លាស់ប្តូរខ្យល់ដើម្បីធ្វើអោយសីតុណ្ហភាពដែលមាន់ទទួលដឹងមាន

កម្រិតទាប។ ទាំងនេះក៏ទទួលឥទ្ធិពលពីគុណភាពទប់កម្តៅរបស់ដំបូលឬជញ្ជាំងនៃរោងចិញ្ចឹមមាន់ផងដែរ ដូច្នេះប្រសិនបើដំបូលឬជញ្ជាំងមានគុណភាពអាចទប់កម្តៅបានល្អ នោះរោងចិញ្ចឹមមាន់ក៏មិនងាយនឹងទទួលឥទ្ធិពលពីសីតុណ្ហភាពបរិយាកាសខាងក្រៅនោះដែរ។

ចំពោះពូជមាន់ប្រយឡឺ វិធានការទប់ទល់កម្តៅនៅរដូវក្តៅគឺជាការគ្រប់គ្រងដ៏សំខាន់បំផុត។ នៅក្នុងនោះ ការផ្លាស់ប្តូរចរន្តខ្យល់គឺប្រៀបដូចជាខ្សែសុវត្ថិភាពការពារអាយុជីវិតរបស់កូនមាន់។ ហេតុនេះហើយ ក្នុងកំឡុងពេលក្តៅខ្លាំង គេប្រើវិធីបាញ់ខ្យល់ទៅក្នុងរោងចិញ្ចឹមមាន់ផ្ទាល់ដោយតភ្ជាប់បំពង់បញ្ជូនខ្យល់ពីកង្ហារបាញ់ខ្យល់។ ម្យ៉ាងទៀតនៅពេលថ្ងៃដែលកម្តៅឡើងខ្ពស់បំផុត គេបាញ់ទឹកបញ្ចុះកម្តៅក្នុងរោងដោយកម្តៅដែលរំហួតទឹកនោះ។ ការក្តៅស្លាប់ដោយសារកម្តៅខ្លាំង គឺងាយនឹងកើតឡើងចំពោះមាន់ដែលធំធាត់ជិតដល់ពេលបញ្ចេញលក់បាន។ នៅពេលនោះ ជុំវិញខ្លួនសត្វមាន់គឺក្តៅជាងសីតុណ្ហភាពបរិយាកាសខាងក្នុងដល់ទៅជិត5អង្សាសេ។ ការក្តៅស្លាប់គឺកើតឡើងភ្លាមៗ ហេតុនេះនៅថ្ងៃដែលសីតុណ្ហភាពខ្ពស់ ចាំបាច់ត្រូវចាត់វិធានការទប់ទល់។

7 ការគ្រប់គ្រងនៅពេលមានអាកាសធាតុត្រជាក់

នៅរោងចិញ្ចឹមមាន់លក្ខណៈបើកចំហ គេចាំបាច់ត្រូវចាត់វិធានការទប់ទល់នឹងភាពត្រជាក់ដោយប្រើវាំងននជាដើមដើម្បីកុំអោយខ្យល់ត្រជាក់បក់ចូលមក។ ប៉ុន្តែ មិនត្រូវបិទជិតឈឹងធ្វើអោយការផ្លាស់ប្តូរខ្យល់ប្រព្រឹត្តទៅមិនបានល្អនោះទេ។ ចំណែកឯនៅរោងចិញ្ចឹមមាន់ដែលគ្មានបង្ហួចវិញ គេត្រូវបន្ថយបរិមាណផ្លាស់ប្តូរខ្យល់ ប៉ុន្តែក៏ត្រូវប្រុងប្រយ័ត្នកុំអោយដល់កម្រិតធ្វើអោយការផ្លាស់ប្តូរខ្យល់ប្រព្រឹត្តទៅមិនបានល្អនោះដែរ។

8 ការគ្រប់គ្រងសុខភាពរបស់សត្វមាន់

វាមានសារៈសំខាន់ណាស់ដែលគេត្រូវសង្កេតមើលថាតើមាន់ដែលគេកំពុងចិញ្ចឹមមានអាការៈដូចជា មានស្នាមប្រលាក់នៅគូទ ជើងខ្សោយ សម្លេងដកដង្ហើមមានភាពខុសប្រក្រតី ដំណើរដើរខុសធម្មតា និង អាការៈរោគផ្សេងៗទៀតដែរឬទេ។ គេចាំបាច់ត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចជា ការគ្រប់គ្រងសីតុណ្ហភាព ជាតិសំណើម និងការផ្លាស់ប្តូរខ្យល់អោយបានត្រឹមត្រូវស្របទៅតាមអាយុចិញ្ចឹមរបស់ប្រភេទមាន់នីមួយៗ ការគ្រប់គ្រងការផ្លាស់ប្តូរខ្យល់អោយបានត្រឹមត្រូវស្របទៅតាមអាយុចិញ្ចឹមនិងសីតុណ្ហភាពបរិយាកាស(សីតុណ្ហភាពក្នុងបន្ទប់) និង ការគ្រប់គ្រងផ្ទៃដីសម្រាប់ចិញ្ចឹមមាន់អោយបានត្រឹមត្រូវស្របទៅតាមអាយុចិញ្ចឹម។

អ្នកគ្រប់គ្រងត្រូវសង្កេតមើលក្នុងបន្ទប់ចិញ្ចឹមជារៀងរាល់ថ្ងៃ ដើម្បីពិនិត្យមើលក្រែងមានមាន់ដែលមានអាការៈខុសប្រក្រតីឬមាន់ងាប់ និងធ្វើការវាស់សីតុណ្ហភាព ជាតិសំណើម ការផ្លាស់ប្តូរខ្យល់នៃបរិយាកាស ព្រមទាំងពិនិត្យថាតើការផ្តល់ចំណីនិងទឹកផឹកមានលក្ខណៈសមស្របដែរឬទេ។

9 ចាប់ពីការប្រមូលស៊ុតរហូតដល់ការបញ្ចេញទំនិញ

មាន់ស្ទើរតែទាំងអស់នឹងធ្វើការផលិតស៊ុតនៅពេលព្រឹក។ កសិដ្ឋានចិញ្ចឹមមាន់និងផលិតស៊ុត ទោះជាមានទំហំឬប្រភេទណាក៏ដោយ ក៏ត្រូវធ្វើការងារតាមលំដាប់លំដោយដូចគ្នាដែរគឺ ប្រមូលស៊ុត→បែងចែកស៊ុត→ត្រួតពិនិត្យស៊ុត→លាងសម្អាតស៊ុត→បញ្ចេញទំនិញ ប៉ុន្តែគេបែងចែងជាការងារធ្វើដោយដៃ និង ការងារធ្វើដោយម៉ាស៊ីន ប្រសិនបើកសិដ្ឋាននោះមានបំពាក់ម៉ាស៊ីនផ្សេងៗដូចជាម៉ាស៊ីនប្រមូលស៊ុតស្វ័យប្រវត្តិ ម៉ាស៊ីនបែងចែកស៊ុតស្វ័យប្រវត្តិ និង ម៉ាស៊ីនលាងសម្អាតស៊ុត ។ល។

ការប្រមូលស៊ុតអោយបានឆាប់រហ័សគឺជាការសំខាន់ ដើម្បីកុំអោយស៊ុតប៉ះគ្នា ឬមាន់ធ្វើអោយខូចស៊ុត(ដោយសារទម្លាប់ស៊ីស៊ុតរបស់មាន់មួយចំនួន)ឬធ្វើអោយប្រលាក់ស៊ុត(ដោយសារការប្រលាក់នៅគូទមាន់មួយចំនួន) ។ ជាទូទៅ គេរើសយកស៊ុតដែលមិនល្អដោយសារមានរបួសឬខុសទម្រង់ធម្មតាជាដើមចេញ រួចប្រមូលស៊ុតទុកដាក់

នៅលើថាសរៀបស៊ុត ហើយបញ្ចេញទៅតាមរថយន្តដឹកទំនិញ។ ក៏មានករណីដែលកសិករធ្វើការលាងសម្អាតស៊ុត បែងចែងស៊ុត(បែងចែកទៅតាមទម្ងន់កំណត់) ខ្ចប់ឬច្រកស៊ុតចូលក្នុងប្រអប់ ដើម្បីបញ្ជូនទៅតាមគេហដ្ឋានឬធ្វើការលក់ដោយផ្ទាល់ ជាដើម។ ការភ្ជាប់ការងារប្រមូលស៊ុតពីកសិដ្ឋានចិញ្ចឹមមាន់និងផលិតស៊ុត ទៅនឹងមជ្ឈមណ្ឌលGP (អគារដែលធ្វើការងារប្រមូលស៊ុត បែងចែកស៊ុត លាងសម្អាតស៊ុត និង ខ្ចប់ស៊ុត) ហៅថា ប្រព័ន្ធក្នុងខ្សែ (In-line system)។

នៅមុនពេលបញ្ចេញទំនិញ ត្រូវរក្សាទុកស៊ុតនៅក្នុងកន្លែងដែលនៅឃ្លាតឆ្ងាយពីរោងចិញ្ចឹមមាន់ ហើយធ្វើការគ្រប់គ្រងសីតុណ្ហភាពនៅក្នុងកន្លែងរក្សាទុកស៊ុតនោះ ដោយប្រៀបធៀបជាមួយសីតុណ្ហភាពនៃបរិយាកាសខាងក្រៅ ដើម្បីសម្របសម្រួលសីតុណ្ហភាពនៅខាងក្នុងកុំអោយស៊ុតបែកញើស។ រយៈពេលរក្សាទុកត្រូវធ្វើអោយមានរយៈពេលខ្លីតាមដែលអាចធ្វើទៅបាន។

កសិករត្រូវលាងសម្អាតនិងសម្លាប់មេរោគនៅម្រាមដៃជាដើមមុននឹងចាប់ផ្តើមធ្វើការងារ។ គេត្រូវប្រើកញ្រ្ចែងប្រមូលស៊ុត ឬ ថាសរៀបស៊ុត ឬ ប្រអប់ដាក់ស៊ុតដែលត្រូវបានលាងសម្អាតនិងសម្លាប់មេរោគរួចរាល់។ គេចាំបាច់ត្រូវអនុវត្តការត្រៀមជាមុនអោយបានត្រឹមត្រូវ ដោយត្រូវពិនិត្យមើលថាតើឧបករណ៍ឬម៉ាស៊ីនប្រមូលស៊ុតមានដំណើរការប្រក្រតីដែរឬទ។ ម្យ៉ាងទៀត គេត្រូវធ្វើការត្រួតពិនិត្យ លាងសម្អាតនិងសម្លាប់មេរោគចំពោះឧបករណ៍ឬម៉ាស៊ីនប្រមូលស៊ុត។ ក្នុងករណីប្រមូលស៊ុតដោយប្រើដៃ ដើម្បីរក្សាភាពនៅស្រស់របស់ស៊ុត គេត្រូវបែងចែកការប្រមូលស៊ុតអោយបានច្រើនដងក្នុង1ថ្ងៃតាមដែលអាចធ្វើទៅបាន។

10 ការបញ្ចេញលក់មាន់ខ្ចីចិញ្ចឹមយកសាច់(ពូជប្រយុទ្ធ)

រយៈពេលមុនបញ្ចេញលក់7ថ្ងៃ គេឲ្យចំណីដែលគ្មានជាតិថ្នាំ(ចំណីដែលគ្មានសារជាតិប្រឆាំងបាក់តេរី)។ បើផ្តល់សារជាតិប្រឆាំងបាក់តេរីក្នុងពេលចិញ្ចឹម ត្រូវធ្វើឲ្យប្រាកដថាវាហួសរយៈពេលកំហិតការបញ្ចេញលក់។ ចំពោះពន្លឺត្រូវបំភ្លឺភ្លើងមុនបញ្ចេញលក់ពី7ថ្ងៃទៅ24ម៉ោង។ បញ្ឈប់ការផ្តល់ចំណី(ផ្អាកចំណី)ចាប់ពី12ម៉ោងមុនពេលដែលកំណត់ធ្វើចំណាត់សម្លាប់យកសាច់។ គេចាប់ផ្តើមចាប់សត្វមាន់ឲ្យស្របនឹងពេលវេលាបញ្ចេញលក់ ហើយស្របពេលនឹងការពិនិត្យមើលថាមានសល់ចំណីឬអត់ គេសម្រាំងដកចេញនូវមាន់ដែលធំធាត់មិនល្អនិងមាន់ដែលរូបរាងប្រឡាក់មិនស្អាត ដោយបញ្ចេញលក់មាន់ដែលមានសុខភាពល្អនិងមានរូបរាងស្អាត។

11 ការថែរក្សាការពារនិងការគ្រប់គ្រងអនាម័យនៅកសិដ្ឋាននិងសម្ភារៈបរិក្ខារផ្សេងៗ

កសិដ្ឋានរួមមាន រោងចិញ្ចឹមមាន់ អគាររក្សាទុកចំណីសត្វ អគាររក្សាទុកជីកំប៉ុស្ត៍ អគាររក្សាទុកកាកសំណល់និងអគារពាក់ព័ន្ធផ្សេងៗ គឺត្រូវសាងសង់ឡើងអោយស្ថិតនៅទីតាំងដែលអាចធ្វើអោយគេអនុវត្តការចិញ្ចឹមមាន់ប្រកបដោយភាពមានអនាម័យត្រឹមត្រូវ។ វាមានសារៈសំខាន់ណាស់ដែលគេត្រូវធ្វើការគ្រប់គ្រងជាប្រចាំថ្ងៃ ដើម្បីកុំអោយអគារមានការខូចខាតឬមិនអាចដំណើរការបាន ឬក៏បាត់បង់អនាម័យដោយសារធូលីឬស្មាមប្រលាក់ផ្សេងៗ។

6 ការគ្រប់គ្រងអនាម័យនៅកសិដ្ឋាន

① សេះទម្ងន់ស្រាល

1 ការគ្រប់គ្រងសុខភាព

(1) សីតុណ្ហភាពក្នុងខ្លួន (សីតុណ្ហភាពនៅចុងពោះវៀនធំ)

កម្តៅជាមធ្យមគឺ 37.5-38.4 អង្សាសេ។ ចាប់ពី 38.5អង្សាសេឡើងទៅគឺត្រូវចាត់ទុកថាក្តៅខ្លួន។

(2) ពិនិត្យមើលជើង

ជើងគឺងាយនឹងហើមដោយសារឆ្លងមេរោគពីរបួស ហើយក៏អាចបង្កឲ្យប៉ះពាល់ទៅដល់ការហ្វឹកហាត់ផងដែរ។ មុននិងក្រោយព្រលែងឬហ្វឹកហាត់ ត្រូវពិនិត្យមើលឲ្យបានល្អ ហើយបើមានរបួស ចាំបាច់ត្រូវព្យាបាលឲ្យបានឆាប់រហ័ស។

2 ការបំពាក់ក្រចកជើងសេះ

· នៅពេលការហ្វឹកហាត់វិវឌ្ឍន៍ទៅមុខ ការកកិតក្រចកជើងនឹងកាន់តែខ្លាំងទៅៗ ហេតុនេះគេបំពាក់ដែកក្រចកជើងសេះដើម្បីការពារក្រចកជើង។

· ·ជាទូទៅគេផ្លាស់ប្តូរដែកក្រចកជើងសេះជារៀងរាល់ 3សប្តាហ៍ទៅ1ខែម្តង។

3 ការគ្រប់គ្រងវាលស្មៅព្រលែងសេះ

(1) ការជម្រះសម្អាត

វាលស្មៅព្រលែងសេះត្រូវធ្វើការជម្រះសម្អាតឲ្យស្មៅខ្លីៗជាទៀងទាត់។

សត្វសេះចូលចិត្តស្មៅខ្លីៗ ធ្វើឲ្យវាស៊ីបានច្រើន ហើយក៏ជួយដល់ការកម្ចាត់ស្មៅផងដែរ។

(2) ការគ្រប់គ្រងអនាម័យ

ត្រូវប្រមូលលាមកសេះក្នុងវាលស្មៅព្រលែងសេះ ដើម្បីបង្ការការរាលដាលឆ្លងប៉ារ៉ាស៊ីត។

4 ចំណុចសំខាន់ក្នុងការគ្រប់គ្រងការចិញ្ចឹម

(1) ការគ្រប់គ្រងវាលស្មៅសម្រាប់ផលិត

· ជាទូទៅគេធ្វើការគ្រប់គ្រងការព្រលែងចំពោះទាំងមេសេះនិងកូនសេះ។ ហុកកៃដូដែលជាតំបន់ផលិតចម្បង នៅរដូវរងាសីតុណ្ហភាពធ្លាក់ទាបហើយមានព្រិលគរច្រើន ហេតុនេះ ភាគច្រើននៅរដូវរងាគេអនុវត្តការព្រលែងពេលថ្ងៃដែលព្រលែងតែពេលថ្ងៃហើយពេលម៉ោងផ្សេងគឺចិញ្ចឹមក្នុងអោង ហើយចំពោះរដូវក្រៅពីរដូវរងា គេអនុវត្តការព្រលែងពេលថ្ងៃនិងយប់ឬព្រលែងពេលយប់ ដែលចិញ្ចឹមក្នុងអោងតែក្នុងចន្លោះពេលកំណត់មួយហើយពេលវេលាក្រៅពីនេះគឺព្រលែង។

· នៅពេលចិញ្ចឹមក្នុងរោង គេផ្តល់ចំណីជីវជាតិ ហើយសម្រាប់មេសេះដែលកំពុងបំបៅកូនឬផើមរួច គេបង្កើនបរិមាណចំណី។
· ចំពោះការព្រលែងគឺគេព្រលែងជាក្រុម តែចំពោះកូនសេះដែលទើបផ្តាច់ដោះ គេព្រលែងដោយបែងចែកញី ឈ្មោលដាច់ពីគ្នា។

ការព្រលែងពេលថ្ងៃ

ការព្រលែងពេលយប់

(2) ការគ្រប់គ្រងវាលស្មៅសម្រាប់ចិញ្ចឹម
· គេបង្កើនបរិមាណចំណីដែលផ្តល់ឲ្យទៅតាមកម្រិតនៃការហ្វឹកហាត់បន្សាំការជិះ។
· សេះដែលការហ្វឹកហាត់បន្សាំការជិះរីវឌ្ឍន៍ទៅមុខ គេបំពាក់ដែកក្រចកជើងនៅជើងវា ហេតុនេះដើម្បីកុំឲ្យវាប្រលែងគ្នានាំឲ្យមានរបួស ជាទូទៅគេមិនព្រលែងជាក្រុមនោះទេគឺព្រលែងមួយក្បាលៗតែឯងក្នុងទីលានតូចមួយ (កូនលានព្រលែងសេះ)។

② ការចិញ្ចឹមឃ្មុំ

1 លំដាប់លំដោយការងារក្នុង1ឆ្នាំ(ឧទាហរណ៍)

រដូវ	ខែ	ខ្លឹមសារការងារ
រដូវរងា	1	ពិនិត្យទឹកឃ្មុំក្នុងរន្ធសម្បុកឃ្មុំ គ្រប់គ្រងសីតុណ្ហភាពក្នុងប្រអប់សម្បុកឃ្មុំ
	2	ពិនិត្យទឹកឃ្មុំក្នុងរន្ធសម្បុកឃ្មុំ សម្លាប់មេរោគនិងជួសជុលឧបករណ៍ចិញ្ចឹមឃ្មុំ ពិនិត្យមើលសត្វឃ្មុំក្នុងប្រអប់សម្បុក ផ្តល់ចំណីនិងថ្នាំ
រដូវផ្ការីក	3	បន្ថែមបន្ទះក្តារសម្បុកក្នុងប្រអប់សម្បុក ពិនិត្យសត្វឃ្មុំក្នុងប្រអប់សម្បុក
	4	បន្ថែមបន្ទះក្តារសម្បុកក្នុងប្រអប់សម្បុក ពិនិត្យសត្វឃ្មុំក្នុងប្រអប់សម្បុក
	5	ប្រមូលផលទឹកឃ្មុំ
រដូវក្តៅ	6	ប្រមូលផលទឹកឃ្មុំ
	7	គ្រប់គ្រងសីតុណ្ហភាពក្នុងប្រអប់សម្បុក ផ្តល់ចំណីនិងថ្នាំ
	8	គ្រប់គ្រងសីតុណ្ហភាពក្នុងប្រអប់សម្បុក ផ្តល់ចំណីនិងថ្នាំ បន្តយបន្ទះក្តារសម្បុកក្នុងប្រអប់សម្បុក កម្ចាត់សត្វឪម៉ាល់
រដូវស្លឹកឈើជ្រុះ	9	ផ្តល់ចំណី បន្តយបន្ទះក្តារសម្បុកក្នុងប្រអប់សម្បុក កម្ចាត់សត្វឪម៉ាល់
	10	ផ្តល់ចំណីនិងថ្នាំ រក្សាទុកបន្ទះក្តារសម្បុក កម្ចាត់សត្វឪម៉ាល់
	11	ផ្តល់ចំណី
រដូវរងា	12	គ្រប់គ្រងសីតុណ្ហភាពក្នុងប្រអប់សម្បុក

* សត្វឪម៉ាល់ = សត្រូវរបស់សត្វឃ្មុំ

2 សម្លៀកបំពាក់

នៅពេលពិនិត្យសត្វឃ្មុំក្នុងប្រអប់សម្បុក ឬពេលធ្វើការប្រមូលផលទឹកឃ្មុំជាដើម ត្រូវអនុវត្តការងារដោយពាក់ក្រណាត់បាំងមុខ(ការពារមុខ) ស្រោមដៃ និងសម្លៀកបំពាក់ភ្លឺដែលមិនអាចមើលឃើញស្បែក។

3 ឧបករណ៍ចិញ្ចឹមឃ្មុំ

(1) ឧបករណ៍ដុតផ្សែង

គេប្រើវាដើម្បីបង្កើយផ្សែងដាក់សត្វឃ្មុំដើម្បីការបន្តយការវាយប្រហាររបស់វា។ គេប្រើដោយដុតក្រណាត់ក្រដាស ស្លឹកឈើជ្រុះជាដើម។

(2) ឧបករណ៍ឈូសកៀរ

វាជាប្រដាប់ឈូសចូកធ្វើពីលោហៈ គេប្រើដើម្បីឈូសផ្តាច់នៅពេលបន្ទះក្តារសម្បុកស្អិតជាប់នឹងប្រអប់សម្បុក។

(3) ច្រាសបោសឃ្មុំ

គេប្រើវានៅពេលបោសទម្លាក់សត្វឃ្មុំពីបន្ទះក្តារសម្បុកឬប្រអប់សម្បុក។



ទិដ្ឋភាពនៃការងារចិញ្ចឹមឃ្មុំ

4 ឧបករណ៍សម្រាប់ផលិតទឹកឃ្មុំ

(1) កាំបិតចៀរឃ្មុំ

វាជាកាំបិតប្រើនៅពេលប្រមូលផលទឹកឃ្មុំសម្រាប់ចៀរស្តើងៗផ្នាំងសម្បុកឃ្មុំ(ក្រមួនឃ្មុំ)ដែលជាផ្នែកដែលទឹកឃ្មុំផ្ទុំគ្នាច្រើននៅក្នុងបន្ទះក្តារសម្បុក។ គេប្រើវាដោយត្រាំទឹកក្តៅឲ្យក្តៅបណ្តើរ ហើយក៏មានប្រភេទអគ្គិសនីផងដែរ។

(2) ម៉ាស៊ីនបង្វិល

ជាម៉ាស៊ីនទាញយកទឹកឃ្មុំដោយកម្លាំងចាកថ្មិតដោយដាក់ចូលហើយបង្វិលបន្ទះក្តារសម្បុកដែលទឹកឃ្មុំផ្ទុំគ្នាដោយបានកាត់ចៀរផ្នាំងសម្បុកឃ្មុំរួច។

(3) ឧបករណ៍ច្រោះទឹកឃ្មុំ

ប្រើដើម្បីច្រោះកាកសំណល់ពីសម្បុកចម្រាញ់យកទឹកឃ្មុំនៅពេលផ្ទេរទឹកឃ្មុំពីម៉ាស៊ីនបង្វិលទៅឧបករណ៍ផ្ទុកទឹកឃ្មុំ។

(4) ឧបករណ៍វាស់កម្រិតជាតិស្ករ

ប្រើសម្រាប់វាស់កម្រិតកំហាប់ជាតិស្ករក្នុងទឹកឃ្មុំ។

ម៉ាស៊ីនបង្វិល



ឧបករណ៍ច្រោះទឹកឃ្មុំ

កាំបិតចៀរឃ្មុំ

ឧបករណ៍វាស់កម្រិតជាតិស្ករ

5 ការងារប្រមូលផលទឹកឃ្មុំ

ជំហានដើម្បីបានទឹកឃ្មុំ

6 ការប្រើប្រាស់សត្វឃ្មុំសម្រាប់កសិកម្ម

សត្វឃ្មុំក្របផ្កាដើម្បីទទួលបានចំណី ហើយទន្ទឹមគ្នានេះ វាក៏បំពេញតួនាទីជញ្ជូនលម្អងផ្កាពីផ្កាមួយទៅផ្កាមួយទៀតផងដែរ។ ហេតុនេះហើយ សត្វឃ្មុំត្រូវបានគេប្រើប្រាស់នៅទីតាំងផលិតកម្មកសិកម្មដែលផ្តល់ផ្លែដូចជាស្ត្របេរី ត្រសក់ស្រូវ ឪឡឹក ផ្លែឆឺរីជាដើម។

សត្វឃ្មុំដែលបញ្ជូនលម្អងផ្កាស្ត្របេរី

ប្រអប់សម្បុកដែលគេដាក់នៅក្នុងចម្ការស្ត្របេរី

7 ចំណុចសំខាន់ៗនៅក្នុងការងារគ្រប់គ្រងនិងការសង្កេតមើលសត្វចិញ្ចឹម (សម្រាប់ការប្រឡងជំនាញអនុវត្តន៍)

នៅក្នុងការធ្វើការងារនៅកសិដ្ឋានរៀងរាល់ថ្ងៃ អ្វីដែលសំខាន់នោះគឺការធ្វើការងារបណ្តើរ និង រៀនពីអ្នកគ្រប់គ្រងទាក់ទងនឹងចំណុចខាងក្រោមបណ្តើរ ដោយអ្នកនឹងរៀនចេះនូវរបៀបធ្វើការងារអោយបានត្រឹមត្រូវនិងរបៀបសង្កេតមើលសត្វចិញ្ចឹមបានទៀតផង។

1 សត្វគោ

- របៀបនៃការចូលទៅជិត ការទាញ ការចងភ្ជាប់សត្វគោ
- របៀបសង្កេតដើម្បីបែងចែកគោដែលមានសុខភាពល្អនិងគោដែលមិនមានសុខភាពល្អ
- ការសង្កេតមើលស្ថានភាពនៃក្រចកជើងគោនិងរបៀបកាត់ក្រចកជើងគោ
- ការស្វែងយល់អំពីឈ្មោះនិងមុខងារនៃអគារនីមួយៗ (កន្លែងផ្ទុកជីកំប៉ុស្ត៍ កន្លែងផ្អាប់ចំណី រោងចិញ្ចឹមគោគ្មានរបាំងខណ្ឌ រោងចិញ្ចឹមគោមានរបាំងខណ្ឌ អគារច្របាច់ទឹកដោះ ។ល។)
- ការស្វែងយល់អំពីឈ្មោះនិងមុខងារនៃសម្ភារៈនិងឧបករណ៍ដែលប្រើប្រាស់ចំពោះគោទឹកដោះ
- ការគ្រប់គ្រងអនាម័យនៅពេលច្របាច់ទឹកដោះ និង របៀបបំពាក់និងដោះឧបករណ៍ច្របាច់ទឹកដោះចេញ
- ការសង្កេតមើលសភាពនៃលាមកសត្វ (របៀបសង្កេតដើម្បីបែងចែកលាមកធម្មតានិងលាមកទន់ឬរាក)
- ការស្វែងយល់អំពីប្រភេទនិងឈ្មោះនៃចំណីសត្វ (ភាពខុសគ្នារវាងចំណីមិនកែច្នៃនិងចំណីជីវជាតិ)
- ភាពខុសគ្នានៃ ការផ្តល់ចំណីមិនកែច្នៃនិងចំណីជីវជាតិដាច់ដោយឡែកពីគ្នា និង ការផ្តល់ចំណីលាយគ្នា(TMR)
- លំដាប់លំដោយនៃការអោយចំណីមិនកែច្នៃនិងចំណីជីវជាតិករណីផ្តល់ចំណីទាំងពីរនេះដាច់ដោយឡែកពីគ្នាចំពោះគោទឹកដោះ
- ចំណុចសំខាន់ៗនៅក្នុងការគ្រប់គ្រងស្នូកដាក់ចំណីនិងស្នូកដាក់ទឹកជាប្រចាំថ្ងៃ
- ការសង្កេតមើលអាការៈនៃការបង្ហាញចំណង់ផ្លូវភេទ
- របៀបក្រៀវសត្វ
- របៀបកាត់ស្នែង
- របៀបផ្តល់ទឹកដោះដល់កូនគោ
- ការសង្កេតដើម្បីបែងចែកទឹកដោះដំបូងនិងទឹកដោះធម្មតា
- ការស្វែងយល់អំពីរបៀបធ្វើអាងជាន់ត្រាំសម្លាប់មេរោគនិងរបៀបឆ្លងកាត់

2 ការចិញ្ចឹមជ្រូក

- របៀបដឹកនាំជ្រូក
- របៀបសង្កេតដើម្បីបែងចែកជ្រូកដែលមានសុខភាពល្អនិងជ្រូកដែលមិនមានសុខភាពល្អ
- ការស្វែងយល់អំពីប្រភេទនិងឈ្មោះនៃចំណីសត្វ
- របៀបចិញ្ចឹមកូនជ្រូកដែលទើបនឹងកើត
- ការសង្កេតមើលសភាពនៃលាមកសត្វ (របៀបសង្កេតដើម្បីបែងចែកលាមកធម្មតានិងលាមកទន់ឬរាក)
- របៀបក្រៀវសត្វ
- ការសង្កេតដើម្បីបែងចែកជ្រូកបង្កាត់ពូជនិងជ្រូកចិញ្ចឹមបំប៉ន

· ការសង្កេតមើលនិងស្វែងយល់អំពីការរៀបជួរនៃក្បាលដោះដែលមានលក្ខណៈប្រក្រតី
· ការស្វែងយល់អំពីដំណាក់កាលបញ្ចេញលក់និងទំហំរបស់សត្វជ្រូក
· ពូជជ្រូក
· ការសង្កេតមើលសាច់ជាប់ឆ្អឹងរបស់សត្វជ្រូក
· ការស្វែងយល់អំពីរបៀបធ្វើអាងជាន់ត្រាំសម្លាប់មេរោគនិងរបៀបឆ្លងកាត់

3 ការចិញ្ចឹមមាន់ (មាន់ចិញ្ចឹមយកស៊ុត)

· ការសង្កេតមើលសភាពនៃលាមកសត្វ
· ការបែងចែកស៊ុតកង្កក់
· ការតម្រៀបស៊ុតពូជនៅលើទម្រស៊ុតនៅក្នុងឧបករណ៍ភ្ញាស់ស៊ុត
· ការសង្កេតដើម្បីសម្គាល់ស៊ុតដែលមានការបង្កកំណើត
· របៀបសង្កេតដើម្បីបែងចែកកូនមាន់ដែលមានសុខភាពល្អនិងកូនមាន់ដែលមិនមានសុខភាពល្អ
· ដំណាក់កាលលូតលាស់របស់កូនមាន់
· ការសង្កេតមើលសីតុណ្ហភាពនៅក្នុងបន្ទប់គ្រប់គ្រងកូនមាន់ និង ស្ថានភាពប្រមូលផ្តុំនិងបែកហ្វូងរបស់កូនមាន់
· ការសង្កេតដើម្បីបែងចែកឧបករណ៍ផ្តល់ទឹកនិងឧបករណ៍ផ្តល់ចំណី និង ការសម្អាតឧបករណ៍ទាំងនោះ
· របៀបចាក់វ៉ាក់សាំង
· របៀបកាត់ចុងចំពុះ
· ការពិនិត្យមើលស្ថានភាពនៃសារធាតុចិញ្ចឹមនិងស្ថានភាពសុខភាពនៃមាន់ចិញ្ចឹមយកស៊ុត(វិធីពិនិត្យដោយសង្កេតមើលសាច់ដុំទ្រូង)
· ការសង្កេតមើលស្ថានភាពផលិតស៊ុតរបស់មាន់ចិញ្ចឹមយកស៊ុត
· របៀបប្រើប្រាស់ថាសរៀបស៊ុត
· ការស្វែងយល់អំពីប្រភេទនៃមាន់ចិញ្ចឹមយកស៊ុតនិងពណ៌របស់ស៊ុត
· ការវិនិច្ឆ័យលើគុណភាពស៊ុតតាមរយៈឧបករណ៍បំបែកស៊ុត
· ការស្វែងយល់អំពីចំណីសម្រាប់កូនមាន់តូច កូនមាន់មធ្យម និង មាន់ពេញវ័យ
· ការស្វែងយល់អំពីរបៀបធ្វើអាងជាន់ត្រាំសម្លាប់មេរោគនិងរបៀបឆ្លងកាត់

4 ការគ្រប់គ្រងអនាម័យ

1. ការស្វែងយល់អំពីសម្លៀកបំពាក់នៅពេលចូលអោងចិញ្ចឹមសត្វ (មួក ស្រោមដៃ សម្លៀកបំពាក់ធ្វើការងារ កន្សែងស្បែកជើងកវែង)
2. សម្រាប់អ្នកដែលមកពីខាងក្រៅកសិដ្ឋាន ត្រូវអោយគេពាក់ស្បែកជើងកវែងធ្វើអំពីផ្លាស្ទិច។
3. ចំណុចដែលត្រូវពិនិត្យ (ការជ្រៀតចូលនៃសត្វតូចៗដូចជាសត្វស្លាបព្រៃឬកណ្តុរជាដើម តើចំណីផ្តាប់មានដុះផ្សិតដែរឬទេ តើមានអ្នកដែលមិនស្គាល់មុខដើរចូលក្នុងកសិដ្ឋានដែរឬទេ)
4. របៀបស្លៀកពាក់អាវការពារអោយបានត្រឹមត្រូវ
5. របៀបពង្រាវទឹកថ្នាំសម្លាប់មេរោគ។

8 សំណួរសាកល្បង

ចូរឆ្លើយសំណួរខាងក្រោម ដោយគូសសញ្ញារង្វង់ ○ ប្រសិនបើជាប្រយោគត្រឹមត្រូវ ហើយគូសសញ្ញាខ្វែង×ប្រសិនបើជាប្រយោគខុស។

<សត្វគោ>

1. គេចាំបាច់ត្រូវសម្អាតស្នូកដាក់ទឹកនិងផ្តិលទឹកអោយបានស្អាតជានិច្ច។ ( )
2. គោទឹកដោះអាចអើតក្បាលចេញដើម្បីស៊ីចំណី ដូច្នេះមិនចាំបាច់បោសប្រមូលផ្តុំចំណីនៅក្នុងស្នូកដាក់ចំណីនោះទេ។ ( )
3. ទោះជានៅក្រោមអាកាសធាតុក្តៅនៃរដូវក្តៅក៏ដោយ ក៏គោទឹកដោះមិនដែលមានសីតុណ្ហភាពក្នុងខ្លួនលើសពី39អង្សាសេនោះទេ។ ( )
4. នៅពេលគោមានជំងឺរាករូស គូទរបស់វានឹងជាប់ស្មាមប្រឡាក់ពេញកន្ទុយ។ ( )
5. គេមិនត្រូវធ្វើការច្របាច់ទឹកដោះច្រើនជ្រុល (ការច្របាច់ទឹកដោះលក្ខណៈម៉ាស៊ីន)នោះទេ។ ( )
6. នៅពេលច្របាច់ទឹកដោះចប់រួចរាល់ហើយ គេធ្វើការដោះបំពង់បឺតទឹកដោះម្តងមួយ។ ( )
7. នៅពេលគោទឹកដោះមានចំណង់ផ្លូវភេទ វាមានសភាពនៅមិនស្ងៀម។ ( )

<សត្វជ្រូក>

1. នៅពេលបំបៅដោះកូនជ្រូក ប្រសិនបើគេរក្សាកម្តៅអោយកូនជ្រូកមិនបានគ្រប់គ្រាន់ទេនោះ អាចធ្វើអោយមានឧបទ្វរហេតុកិនកូនជ្រូកងាប់ងាយនឹងកើតឡើង។ ( )
2. កូនជ្រូកមិនសូវធន់នឹងអាកាសធាតុត្រជាក់ទេ ប៉ុន្តែ ជ្រូកដែលធំធាត់ហើយបែរជាមិនសូវធន់នឹងអាកាសធាតុក្តៅទៅវិញ។ ( )
3. ប្រសិនបើមានអាងជាន់ត្រាំសម្លាប់មេរោគហើយ គេមិនចាំបាច់ធ្វើការលាងសម្អាតស្បែកជើងកវែងនោះទេ។ ( )
4. ទឹកដោះសិប្បនិម្មិតសម្រាប់កូនជ្រូកមានតែ1ប្រភេទប៉ុណ្ណោះ។ ( )
5. ដើម្បីទប់ស្កាត់ក្លិនស្អុយពីរោងចិញ្ចឹមជ្រូក គេមិនត្រូវសន្សំទុកកាកសំណល់សត្វនៅក្នុងរោងចិញ្ចឹមជ្រូកនោះទេ។ ( )

<សត្វមាន់>

1. ប្រសិនបើប្រទះឃើញសាកសពសត្វស្លាបងាប់នៅក្បែររោងចិញ្ចឹមមាន់ គេត្រូវប្រញាប់យកទៅបោះចោលក្នុងធុងសម្រាមភ្លាម។ ( )
2. ការចិញ្ចឹមមាន់ច្រើនក្បាល អាចធ្វើអោយការផ្លាស់ប្តូរខ្យល់ប្រព្រឹត្តទៅមិនបានល្អ ដូច្នេះ គេត្រូវប្រុងប្រយ័ត្នចំពោះជំងឺផ្លូវដង្ហើម។ ( )
3. នៅអាកាសធាតុក្តៅក្នុងរដូវក្តៅ គេត្រូវអោយមាន់ផឹកទឹកក្តៅ។ ( )
4. នៅដំណាក់កាលកូនមាន់មធ្យម អាចមានការចឹកគ្នារវាងកូនមាន់ធ្វើអោយមានរបួស។ ( )
5. គេអាចអោយមាន់ចិញ្ចឹមយកសាច់ (ពូជប្រយ៉ឺ)ស៊ីចំណីលាយដែលមានផ្ទុកសារធាតុប្រឆាំងមេរោគបានរហូតដល់មួយថ្ងៃមុនពេលបញ្ចេញលក់។ ( )

ចម្លើយ

<សត្វគោ>

1. ○
2. ×(ហេតុផល : គេធ្វើការបោសប្រមូលផ្តុំចំណីអោយមកនៅកន្លែងដែលគោងាយស្រួលស៊ី។)
3. ×(ហេតុផល : នៅពេលបរិយាកាសមានសីតុណ្ហភាពប្រហែល30អង្សាសេ នៅចុងពោះវៀនធំរបស់គោអាចមានសីតុណ្ហភាព40អង្សាសេ។)
4. ○
5. ○
6. ×(ហេតុផល : បំពង់បឺតទឹកដោះមានចំនួន4 ដូច្នេះគេត្រូវដកចេញពីក្បាលដោះព្រមគ្នា។)
7. ○

<សត្វជ្រូក>

1. ○
2. ○
3. ×(ហេតុផល : បន្ទាប់ពីលាងជម្រុះចោលនូវស្មៅមប្រឡាក់ដូចជាភក់ជាដើមដែលនៅជាប់នឹងស្បែកជើងកវែងហើយ ទើបគេធ្វើការសម្លាប់មេរោគដោយត្រាំស្បែកជើង។)
4. ×(ហេតុផល : គេជ្រើសរើសប្រើនិងផ្តល់ទឹកដោះសិប្បនិម្មិតស្របទៅតាមការលូតលាស់របស់កូនជ្រូក។)
5. ○

<សត្វមាន់>

1. ×(ហេតុផល : ដើម្បីសុំអោយមានការប្រុងប្រយ័ត្នចំពោះវីរុសផ្តាសាយបក្សីដែលមានលទ្ធភាពបង្កជំងឺខ្ពស់ គេចាំបាច់ត្រូវធ្វើការជូនដំណឹងដល់ម្ចាស់កសិដ្ឋាន និងទាក់ទងទៅមជ្ឈមណ្ឌលថែរក្សាសុខុមាលភាពសត្វចិញ្ចឹម។)
2. ○
3. ×(ហេតុផល : នៅអាកាសធាតុក្តៅក្នុងរដូវក្តៅ គេត្រូវអោយមាន់ផឹកទឹកត្រជាក់។)
4. ○
5. ×(ហេតុផល : គេមិនត្រូវផ្តល់ចំណីដែលមានផ្សំកសារធាតុប្រឆាំងមេរោគចំពោះមាន់ក្នុងរយៈពេល7ថ្ងៃមុនការសម្លាប់នោះទេ ។)

<ឯកសារយោង>វាក្យសព្ទទាក់ទងនឹងការចិញ្ចឹមសត្វដែលអ្នកនឹងជួបប្រទះញឹកញាប់នៅក្នុងការងារប្រចាំថ្ងៃ

<សត្វគោ>

ចំណី ..... សំដៅលើចំណីសត្វ។

ការអោយចំណី ..... ការផ្តល់ចំណីដល់សត្វចិញ្ចឹម។

ការរើសចំណី ..... ការដែលសត្វចិញ្ចឹមស៊ីតែចំណីដែលវាចូលចិត្ត ហើយបន្សល់ទុកចំណីដែលវាមិនចូលចិត្តនៅក្នុងស្នូកដាក់ចំណី ក៏អាចហៅបានថា ការស៊ីចំណីរើស។

បាក់តេរីStaphylococcus aureus ... បាក់តេរីដែលនៅពេលកើនចំនួនច្រើននៅក្នុងក្បាលដោះ អាចបណ្តាលអោយកើតជំងឺរលាកដោះដែលពិបាកជាសះស្បើយ។

បរិមាណនៃការបរិភោគចំណីស្ងួត ... ចំណីស្ងួតគឺជាចំណីដែលមិនមានផ្ទុកជាតិទឹក ហើយបរិមាណនៃការបរិភោគចំណីស្ងួតសំដៅលើបរិមាណនៃចំណីស្ងួត(គិតជាគីឡូក្រាម)ដែលសត្វចិញ្ចឹមស៊ីក្នុង1ថ្ងៃ។

ការត្រួតពិនិត្យហ្វូងគោ ..... ប្រព័ន្ធនៃការត្រួតពិនិត្យស្តានភាពនៃបរិមាណទឹកដោះ គុណភាពទឹកដោះ ការបង្កាត់ពូជជាដើម នៃគោទឹកដោះរបស់កសិករ ដែលធ្វើឡើងម្តងក្នុងមួយខែ។

ការមិនព្រមស៊ីចំណី ..... ស្តានភាពដែលការស៊ីចំណីរបស់គោមានបរិមាណធ្លាក់ចុះខ្លាំង។

ចំនួនថ្ងៃទំនេរពោះ ..... ចំនួនថ្ងៃគិតចាប់ពីក្រោយពេលសត្វកើតកូនរួចរហូតដល់ពេលមានផ្ទៃពោះបន្ទាប់។

ដំណាក់កាលជិតកើត ..... សំដៅលើរយៈពេលចុងក្រោយនៃការផ្អាកការច្របាច់ទឹកដោះរបស់គោទឹកដោះ។ គឺជារយៈពេល3សប្តាហ៍មុនពេលកើតកូន។ គេអាចហៅថា ដំណាក់កាលមុនកើត។

ជំងឺក្រចកជើងនិងមាត់ ..... ជំងឺឆ្លងដែលមានលទ្ធភាពឆ្លងខ្លាំងនិងលឿន ដោយមានរោគសញ្ញាដូចជាកើតពងទឹកនៅលើស្បែកនៅច្រមុះ មាត់ និង ក្រចកជើង ជាដើម ដែលកើតឡើងដោយសារវីរុសPicornaviridae Aphthovirus។
វាត្រូវបានចាត់ចូលជាជំងឺឆ្លងដែលចែងក្នុងច្បាប់។

សម្ភារៈក្រាល ..... វត្ថុធាតុដែលប្រើដើម្បីផ្តល់ជាសុកភាពដល់សត្វចិញ្ចឹម និង ដើម្បីជម្រុញការផលិតជីកំប៉ុស្តិ៍ពីកាកសំណល់សត្វ ដោយគេច្រើនប្រើកម្ទេចរណារ អង្កាម ឬចំបើងស្រូវសាលី។ ការបញ្ចេញសម្ភារៈក្រាលទៅក្រៅរោងចិញ្ចឹមសត្វ ហៅថា ការបញ្ចេញកាកសំណល់ក្រាល។

ទឹកដោះដំបូង ..... ទឹកដោះដែលបញ្ចេញក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីសត្វកើតកូនរួច។

ការបង្កកំណើតសិប្បនិម្មិត ..... ការចាក់ទឹកកាមទៅក្នុងប្រដាប់បន្តពូជរបស់សត្វញីធ្វើឡើងដោយមនុស្ស ដើម្បីអោយសត្វញីមានផ្ទៃពោះ។

ស្ត្រេស ..... ស្តានភាពដែលសត្វចិញ្ចឹមទទួលរងសម្ពាធផ្នែកស្មារតី។

ជំងឺក្រពះទីបួនប្តូរទីតាំង ..... ជំងឺដែលក្រពះទីបួនផ្លាស់ប្តូរកន្លែងពីទីតាំងធម្មតាទៅខាងឆ្វេងឬខាងស្តាំ ធ្វើអោយការស៊ីចំណីរបស់សត្វមានការធ្លាក់ចុះ ហើយបរិមាណទឹកដោះក៏ថយចុះផងដែរ។

ជំងឺរលាកក្រចកជើងសត្វ ..... ជំងឺដែលក្រចកជើងគោឡើងក្រហមនិងមានអាការៈឈឺចាប់ខ្លាំង នាំអោយពិបាកធ្វើចលនា។

ការផ្ទេរអំប្រីយ៉ុង ..... ការចាក់អំប្រីយ៉ុង(ស៊ុតបង្កកំណើត)ទៅក្នុងប្រដាប់បន្តពូជរបស់សត្វញីធ្វើឡើងដោយមនុស្ស ដើម្បីអោយសត្វញីមានផ្ទៃពោះ។

ចំណង់ផ្លូវភេទ ..... ស្តានភាពដែលសត្វញីព្រមអោយសត្វឈ្មោលពាក់។ គេអនុវត្តការបង្កកំណើតសិប្បនិម្មិតនៅពេលសត្វញីបង្ហាញចំណង់ផ្លូវភេទនេះ។

ការខ្ជាក់ចំណីមកទំពា ..... សកម្មភាពដែលសត្វគោខ្ជាក់អាហារចេញពីក្រពះទីមួយ (Rumen) ដើម្បីទំពារួចលេបទៅវិញម្តងទៀត។

កករក្នុងទឹកដោះ ..... កករដែលមានទំហំផ្សេងៗអាចធំអាចតូច ឃើញមាននៅក្នុងទឹកដោះរបស់គោដែលមានជំងឺរលាកដោះ។

ការបង្កើតកូន ..... ការកើតនៃកូនគោ។

គម្លាតនៃការបង្កើតកូន ..... រយៈពេលគិតចាប់ពីថ្ងៃកើតកូនម្តងរហូតដល់ថ្ងៃកើតកូនម្តងទៀតចំពោះគោដែលកើតកូនចាប់ពី2ដងឡើងទៅ។

ការចិញ្ចឹមដោយបំបៅ ..... រយៈពេលពេលនៃការផ្តល់ចំណីរាវដល់កូនសត្វចាប់ពីពេលកើតក្លាមរហូតដល់ពេលផ្តាច់ដោះ។

ស្ថានភាពរាងកាយ ..... តួលេខបង្ហាញអំពីជាតិខ្លាញ់ដែលមាននៅក្រោមស្បែក ដែលគេប្រើធ្វើជាមូលដ្ឋានគ្រឹះសម្រាប់វិនិច្ឆ័យថាសត្វចិញ្ចឹមកំពុងធាត់ជ្រុលឬស្គមជ្រុល។ តួលេខនេះកាន់តែខ្ពស់ មានន័យថា សត្វផ្ទុកជាតិខ្លាញ់កាន់តែច្រើន។

កសិដ្ឋានខ្នាតធំ ..... កសិដ្ឋានលក្ខណៈជាសហគ្រាសដែលមានខ្នាតធំសម្បើម។

TDN ..... បរិមាណសរុបនៃសារធាតុចិញ្ចឹមនៅក្នុងចំណីដែលនឹងត្រូវរំលាយនៅក្នុងក្រពះ ដោយបើតួលេខនេះកាន់តែខ្ពស់ មានន័យថា ចំណីនោះមានផ្ទុកថាមពលកាន់តែច្រើន។

<សត្វជ្រូក>

ការផ្តល់ចំណីសើម ..... វិធីផ្តល់ចំណីដោយលាយចំណីជាមួយទឹកដើម្បីបានជាចំណីជ្រាយ។

ចំណី ..... សំដៅលើចំណីសត្វ។

ការអោយចំណី ..... ការផ្តល់ចំណីដល់សត្វចិញ្ចឹម។

ការចាប់ផ្តើមអោយចំណី..... ការអោយចំណីលើកដំបូងបន្ទាប់ពីកូនសត្វកើត ដោយប្រើទឹកដោះសិប្បនិម្មិត ។

រោងចិញ្ចឹមជ្រូកក្រាលកម្ទេចរណារ... រោងចិញ្ចឹមជ្រូកដែលមិនបែងចែកលាមកនិងទឹកនោមសត្វ ហើយនិងសម្ភារៈក្រាលនោះទេ។

ការមិនព្រមស៊ីចំណី ..... ស្ថានភាពដែលការស៊ីចំណីរបស់ជ្រូកមានបរិមាណធ្លាក់ចុះខ្លាំង។

ជ្រូកបង្កាត់បីសាសន៍ ..... វិធីផលិតជ្រូកដែលកើតពីការបង្កាត់ពូជជ្រូកចំនួន3 ឬ ការបង្កាត់3ជំនាន់។ គឺជាជ្រូកដែលគេយកកូនជ្រូក(ជ្រូកញី)បានពីការបង្កាត់ជ្រូក2ពូជទៅបង្កាត់បន្តជាមួយជ្រូកឈ្មោលពូជទី3ផ្សេងទៀត។

សម្ភារៈក្រាល ..... វត្ថុធាតុដែលប្រើដើម្បីផ្តល់ជាសុកភាពដល់សត្វចិញ្ចឹម និង ដើម្បីជម្រុញការផលិតជីកំប៉ុស្តិ៍ពីកាកសំណល់សត្វ ដោយគេច្រើនប្រើកម្ទេចរណារ អង្កាម ឬចំបើងស្រូវសាលី។ ការបញ្ចេញសម្ភារៈក្រាលទៅក្រៅរោងចិញ្ចឹមសត្វ ហៅថាការបញ្ចេញកាកសំណល់ក្រាល។

ទឹកដោះដំបូង ..... ទឹកដោះដែលបញ្ចេញក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីសត្វកើតកូនរួច។

ទឹកដោះសិប្បនិម្មិត ..... ចំណីដែលគេផ្តល់អោយកូនជ្រូកក្នុងដំណាក់កាលចិញ្ចឹមដោយបំបៅ រួមមានទឹកដោះសិប្បនិម្មិតAដែលគេផ្តល់អោយរហូតដល់កូនជ្រូកមានទម្ងន់10គីឡូក្រាម និង ទឹកដោះសិប្បនិម្មិតBដែលគេផ្តល់អោយបន្ទាប់ពីនោះរហូតដល់កូនជ្រូកមានទម្ងន់30គីឡូក្រាម។

PRRS ..... បណ្តុំរោគសញ្ញានៃជំងឺទាក់ទងនឹងប្រព័ន្ធបន្តពូជនិងប្រព័ន្ធផ្លូវដង្ហើមរបស់សត្វជ្រូក

PED ..... ជំងឺរាករូសរាតត្បាតកើតនៅលើសត្វជ្រូក

ជ្រូកSPF ..... ជ្រូកដែលមិនមានផ្ទុកមេរោគបង្កជំងឺមួយចំនួន។ ជ្រូកបង្កាត់ពូជដែលនឹងក្លាយជាជ្រូកSPF គឺជាជ្រូកដែលត្រូវបានរះកាត់ចេញពីស្បូនរបស់ជ្រូកមេដោយផ្ទាល់ និងត្រូវបានចិញ្ចឹមដោយវិធីសិប្បនិម្មិត។

(សម្ភាល់) ការហៅជ្រូកចិញ្ចឹមបំប៉ន... ជ្រូកបង្កាត់ពូជ ជ្រូកមេ ជ្រូកពូជ ក្នុងភាសាជប៉ុនមានពីររបៀបសម្រាប់ពាក្យនីមួយៗ។

<សត្វមាន់>

ការចិញ្ចឹមកូនមាន់..... ការចិញ្ចឹមកូនមាន់ដែលទើបតែញាស់។

ចំណី ..... សំដៅលើចំណីសត្វ។

ការអោយចំណី ..... ការផ្តល់ចំណីដល់សត្វចិញ្ចឹម។

ការស៊ីចំណី..... ស្ថានភាពនៃការស៊ីចំណីច្រើនឬតិច។

ការរាយចំណីអោយស្មើ ..... ការកែតម្រូវភាពលម្អៀងនៃចំណីនៅក្នុងស្នូកដាក់ចំណី។

ការចាប់ផ្តើមអោយចំណី..... ការអោយចំណីលើកដំបូងបន្ទាប់ពីកូនសត្វកើត ដោយប្រើទឹកដោះសិប្បនិម្មិត ។

ការផ្លាស់ប្តូរស្លាប ..... ការជ្រុះស្លាបចាស់និងជំនួសដោយការដុះស្លាបថ្មី។ គេឃើញកើតមានចាប់ពីចុងរដូវក្តៅដល់រដូវស្លឹកឈើជ្រុះ។ សម្រាប់មាន់ផលិតស៊ុតគឺច្រើនតែផ្អាកការផលិតស៊ុត។

ការវាយប្រហារគ្នាឯង ..... មាន់ដែលគេចិញ្ចឹមជាហ្វូង ដោយសារឥទ្ធិពលពីបរិស្ថានមិនល្អឬសារធាតុចិញ្ចឹមមិនគ្រប់គ្រាន់ ធ្វើអោយមាន់ក្នុងហ្វូងចឹកគ្នាទៅវិញទៅមក។ ពេលខ្លះអាចធ្វើអោយមានមាន់ងាប់ដោយសារការចឹកគ្នានេះ។

ការផ្តល់កម្តៅ ..... ការរក្សាកម្តៅក្នុងបន្ទប់ដែលគេចិញ្ចឹមកូនមាន់។

ក្រួស ..... ថ្មតូចៗដែលមាន់ប្រើក្នុងការជួយកិនបំបែកធញ្ញជាតិដែលមាននៅក្នុងក្រពះ(ក្រពះសាច់ដុំ)របស់មាន់។

មាន់ក្នុងបម្រើបម្រាស់ ..... អាចហៅបានថាមាន់សម្រាប់ធ្វើអាជីវកម្ម។ ជាពូជមាន់ដែលមានលទ្ធភាពផលិតស៊ុតឬផលិតសាច់ខ្ពស់ ដែលត្រូវបានគេប្រើប្រាស់ជាទូទៅច្រើន។

មាន់តំបន់..... ពូជមាន់ដែលស្ថិតនៅក្នុងតំបន់ណាមួយ ខុសពីពូជមាន់ប្រយុទ្ធដែលជាប្រភេទមាន់ក្នុងបម្រើបម្រាស់ ដោយមាន់តំបន់ជាមាន់ដែលគេប្រើដើម្បីផលិតសាច់មាន់ដែលមានគុណភាពខ្ពស់។

ការកាត់ចំពុះ ..... ការដុតនិងកាត់ចំពុះលើនិងក្រោមរបស់មាន់អស់ពាក់កណ្តាល។ គេធ្វើការងារនេះចំពោះកូនមាន់មធ្យមឡើងទៅ ដើម្បីទប់ស្កាត់ការចឹកគូទឬស្លាបជាដើមនៅក្នុងហ្វូងមាន់។ ក៏អាចហៅថាការកាត់ចុងចំពុះផងដែរ។

លំដាប់នៅក្នុងហ្វូង ..... សកម្មភាពនៃមាន់ដែលរស់នៅជាហ្វូងដោយមាន់ធ្វើការវាយប្រហារគ្នាដូចជាប្រើចំពុះចឹកឬក៏ហាក់ឡើងខ្ពស់ដើម្បីធាក់មាន់ផ្សេងទៀត។ នេះគឺជាសកម្មភាពបែបធម្មជាតិក្នុងចំណោមសត្វមាន់ដើម្បីកំណត់លំដាប់លំដោយនៃភាពខ្លាំងរបស់មាន់នីមួយៗ ដោយធ្វើបែបនេះគឺអាចរក្សាភាពរៀបរយនៅក្នុងការរស់នៅជាហ្វូងរបស់មាន់។

ការចិញ្ចឹមលក្ខណៈណែន ..... ការរក្សាមាន់ច្រើនហួសពីចំនួនដែលទីកន្លែងដែលមានផ្ទៃក្រឡាកំណត់មួយគួរផ្ទុក ធ្វើអោយមានឥទ្ធិពលមិនល្អដល់ស្ថានភាពសុខភាពរបស់សត្វមាន់។

Support project to properly accept foreigners for agricultural support

Agricultural Skill Assessment Test
Text: General livestock farming
Cambodian(Khmer) Edition

Published by National Chamber of Agriculture, October 2019
Chuorodokijunkyokai Bldg. 9-8 Nibancho,Chiyoda-ku,Tokyo,Japan 102-0084
Dedicated Website http://asat-nca.jp/

◎ **All rights reserved**